វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

# ផលប្រយោជន៍ និងចំណាយនៃ
# ទេសន្តរប្រវេសន៍កំលាំងពលកម្មក្នុងមហាអនុតំបន់មេគង្គ

## ករណីសិក្សានៅប្រទេសកម្ពុជា

ឯកសារពិភាក្សាលេខ ៤៤

ច័ន្ទ សុផល

ខែធ្នូ ឆ្នាំ២០០៩

បណ្តាញវិភាគអភិវឌ្ឍន៍ (DAN) បានទទួលជំនួយឧបត្ថម្ភផ្នែកហិរញ្ញវត្ថុពីមូលនិធិ Rockefeller

# ផលប្រយោជន៍ និងចំណាយ នៃ ទេសន្តរប្រវេសន៍កំលាំងពលកម្មក្នុងមហាអនុតំបន់មេគង្គ

## ករណីសិក្សានៅប្រទេសកម្ពុជា

ឯកសារពិភាក្សាលេខ ៤៤

ច័ន្ទ សុផល

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
ភ្នំពេញ, ខែធ្នូ ឆ្នាំ២០០៩

© រក្សាសិទ្ធិឆ្នាំ២០០៩ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

រក្សាសិទ្ធិគ្រប់យ៉ាង - គ្មានផ្នែកណាមួយនៃឯកសារនេះ ត្រូវបានចម្លងទុក ឬផ្សព្វផ្សាយតាមទម្រង់ និងតាមមធ្យោបាយផ្សេងៗ ដូចជា អេឡិចត្រូនិក យន្តកម្ម ថតចម្លង... ។ល។ ដោយគ្មានការអនុញ្ញាតជាលាយល័ក្ខណ៍អក្សរវិទ្យាស្ថានបណ្តុះ-បណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជាឡើយ ។

ទស្សនៈទាំងឡាយនៅក្នុងឯកសារនេះ គឺជាគំនិតផ្ទាល់របស់អ្នកនិពន្ធ ។ ទស្សនៈទាំងនោះ មិនមែនជាទស្សនៈរបស់វិទ្យាស្ថាន CDRI ទេ ។

**ISBN 978-99950-52-31-7**

**ផលប្រយោជន៍ និងចំណាយ នៃទេសន្តរប្រវេសន៍កំលាំងពលកម្មក្នុងមហាអនុតំបន់មេគង្គៈ ករណីសិក្សានៅប្រទេសកម្ពុជា**

*ខែធ្នូ ឆ្នាំ២០០៩*

**ចន្ទ សុផល**

វិទ្យាស្ថាន CDRI
អាគារលេខ ៥៦ ផ្លូវលេខ ៣១៥ ខ័ណ្ឌទួលគោក ភ្នំពេញ កម្ពុជា
ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា
ទូរស័ព្ទៈ (៨៥៥-២៣) ៨៨១-៣៨៤, ៨៨១-៧០១, ៨៨១-៩១៦, ៨៨៣-៦០៣
ទូរសារៈ (៨៥៥-២៣) ៨៨០-៧៣៤
អ៊ីមែលៈ cdri@wicam.com.kh
គេហទំព័រ: http://www.cdri.org.kh

បកប្រែដោយៈ លោក វ៉ា វណ្ណៈ និងលោក ខេង សេង
កែសម្រួល និងរចនាដោយៈ កញ្ញា អ៊ឹង សុជាតិ លោក អ៊ុំ ចាន់ថា និង លោក យូ សិទ្ធីរិទ្ធ
បោះពុម្ពនៅប្រទេសកម្ពុជា ដោយរោងពុម្ពជប៉ុន រាជធានីភ្នំពេញ

# មាតិកា


បញ្ជីតារាង ក្រាហ្វិក និងប្រអប់ ......... ៧
បញ្ជីអក្សរកាត់ និងពាក្យបំព្រួញ ......... ៩
សេចក្តីថ្លែងអំណរគុណ ......... ១១

**ជំពូក ១. សេចក្តីផ្តើម** ......... ១៣

**ជំពូក ២. ការវិវត្តនៃទេសន្តរប្រវេសន៍កំលាំងពលកម្មនៅកម្ពុជា** ......... ១៥

២.១. ប្រវត្តិនៃអន្តោប្រវេសន៍ និងទេសន្តរប្រវេសន៍កំលាំងពលកម្ម ......... ១៥
២.២. លក្ខណៈផ្លូវការនៃការធ្វើចំណាកស្រុក និងការផ្ញើប្រាក់ទៅផ្ទះ ......... ១៨

**ជំពូក ៣. ករណីសិក្សា** ......... ២១

៣.១. វិធីសាស្ត្រស្រាវជ្រាវ ......... ២១
៣.១.១. ការជ្រើសរើសសហគមន៍សំរាប់ការសិក្សា ......... ២១
៣.១.២. ការធ្វើអង្កេតគ្រួសារ ......... ២៣
៣.១.៣. វិធីសាស្ត្រស្រាវជ្រាវបែបគុណភាព ......... ២៣

៣.២. របកគំហើញបានពីករណីសិក្សានៅសហគមន៍ ......... ២៤
៣.២.១. អត្រាចំណាកស្រុកឆ្លងកាត់ព្រំដែននៅក្នុងភូមិសិក្សា ......... ២៤
៣.២.២. កត្តាពាក់ព័ន្ធបង្កចំណាកស្រុក ......... ២៦
៣.២.៣. ប្រទេសគោលដៅនៃពលករចំណាកស្រុកនៅក្នុងភូមិសិក្សា ......... ២៩
៣.២.៤. ប្រភេទការងាររបស់ពលករចំណាកស្រុក ......... ២៩
៣.២.៥. ចំណាយ និងមធ្យោបាយសំរាប់ឱ្យពលករធ្វើចំណាកស្រុកទៅដល់ប្រទេសគោលដៅ ......... ៣១
៣.២.៦. ប្រាក់ផ្ញើទៅផ្ទះ ......... ៣៤
៣.២.៧. មធ្យោបាយផ្ញើប្រាក់ទៅផ្ទះរបស់ពលករចំណាកស្រុក ......... ៣៩
៣.២.៨. ការប្រើប្រាស់ប្រាក់ផ្ញើទៅផ្ទះនៅក្នុងសហគមន៍បញ្ជូនពលករ ......... ៤១
៣.២.៩. ការប្រៀបធៀបទ្រព្យសម្បត្តិរបស់គ្រួសារដែលមាន និងគ្មានសមាជិកធ្វើចំណាកស្រុក ......... ៤៣
៣.២.១០. ការប្រៀបធៀបគ្រួសារដែលមាន និងគ្មានសមាជិកធ្វើចំណាកស្រុកក្នុងចន្លោះ ឆ្នាំ២០០២-២០០៧ ......... ៤៦
៣.២.១១. ចំណាយ និងផលចំណេញខាងហិរញ្ញវត្ថុរបស់បុគ្គលពលករចំណាកស្រុកទៅថៃ ......... ៤៩
៣.២.១២. អត្ថប្រយោជន៍ និងចំណាយផ្សេងទៀត ......... ៥០
៣.២.១៣. ការយល់ឃើញផ្ទាល់ខ្លួននៃក្រុមគ្រួសារដែលមានសមាជិកធ្វើចំណាកស្រុក ......... ៥០

**ជំពូក ៤. បញ្ហាសំខាន់ៗពាក់ព័ន្ធនឹងការធ្វើចំណាកស្រុកឆ្លងកាត់ព្រំដែន** ....................................... ៥៣

៤.១. ការវាយតម្លៃលើអនុស្សរណៈនៃការយោគយល់គ្នារវាងរដ្ឋាភិបាលកម្ពុជា និងថៃ ................................ ៥៤
៤.២. ទីភ្នាក់ងារជ្រើសរើសពលករ ........................................................................................................ ៥៦
៤.៣. ចំណាយនៃការបញ្ជូនពលករចំណាកស្រុក ..................................................................................... ៥៨
៤.៤. លិខិតឆ្លងដែន .......................................................................................................................... ៦១
៤.៥. របៀបសម្រួលការចេញលិខិតឆ្លងដែនក្នុងរយៈពេលលឿន ................................................................ ៦២
៤.៦. ដំណើរជ្រើសរើសបុគ្គលិក ......................................................................................................... ៦៣
៤.៧. សំណុំបែបបទទិដ្ឋាការ ............................................................................................................. ៦៣
៤.៨. កង្វះកិច្ចសន្យាដែលមានលក្ខណៈស្តង់ដារ ....................................................................................... ៦៤
៤.៩. កង្វះកញ្ចប់បណ្តុះបណ្តាលពលករមុនពេលចាកចេញតាមលក្ខណៈស្តង់ដារ ........................................... ៦៥
៤.១០. កង្វះធនធានក្នុងការគ្រប់គ្រងទេសន្តរប្រវេសន៍កំលាំងពលកម្ម និងត្រួតពិនិត្យទីភ្នាក់ងារ
ជ្រើសរើសពលករ ......................................................................................................................... ៦៦
៤.១១. បញ្ហានៃការបោះបង់ និងរត់ចោលការងារៈ ...
អ្នកជ្រើសរើសពលករ......................................................................................................................... ៦៦
៤.១២. ជម្រើសផ្សេងៗក្រៅពីការចំណាយប្រាក់ជាមុនដោយទីភ្នាក់ងារជ្រើសរើសពលករ ......................... ៦៨
៤.១៣. សុខុមាលភាព និងលក្ខខណ្ឌការងារ នៅក្នុងប្រទេសទទួលពលករ ................................................ ៦៨

**ជំពូក ៥. សន្និដ្ឋាន និងអនុសាសន៍** .......................................................................................... ៧១

ឯកសារយោង .................................................................................................................................. ៧៣

ឧបសម្ព័ន្ធ ....................................................................................................................................... ៧៥

បញ្ជីឯកសារពិភាក្សារបស់ វបសអ ....................................................................................................... ៨៧

# បញ្ជីតារាង ក្រាហ្វិក និងប្រអប់

## បញ្ជីតារាង


តារាង ២.១: កំណើនប្រជាជន និងទិន្នន័យ ផសស នៃប្រទេសជ្រើសរើសមួយចំនួនក្នុងឆ្នាំ២០០៥ .......... ១៦
តារាង ២.២: ការបែងចែកកូតា និងការផ្ដល់លិខិតអនុញ្ញាតការងារ នៅតាមតំបន់នានាក្នុងប្រទេសថៃ .......... ១៧
តារាង ២.៣: ចំនួនពលករចំណាកស្រុកកម្ពុជាបញ្ជូនចេញជាផ្លូវការទៅក្រៅប្រទេស .......... ១៩
តារាង ២.៤: ប្រាក់ផ្ញើទៅផ្ទះរបស់ពលករ .......... ២០

តារាង ៣.១: ភូមិ និងលក្ខណៈពាក់ព័ន្ធសំខាន់ៗដែលបានជ្រើសរើសសំរាប់តំបន់សិក្សា .......... ២១
តារាង ៣.២: ចំនួនគ្រួសារនៅក្នុងភូមិសិក្សា និងនៅក្នុងគំរូតាង .......... ២៥
តារាង ៣.៣: ចំនួនពលករចំណាកស្រុកបែងចែកតាមភេទ នៅក្នុងគំរូតាងអង្កេត .......... ២៦
តារាង ៣.៤: ប្រាក់ចំណូលប្រចាំថ្ងៃ និងប្រចាំខែ នៅពេលធ្វើចំណាកស្រុកចុងក្រោយ ក្នុងអំឡុង ៥ឆ្នាំមុន .......... ២៨
តារាង ៣.៥: ប្រទេសគោលដៅធំៗរបស់ពលករចំណាកស្រុក .......... ២៩
តារាង ៣.៦: ប្រភេទការងារក្នុងចំណាកស្រុកចុងក្រោយរបស់ពលករបុរស និងនារី .......... ៣០
តារាង ៣.៧: ចំណាយរបស់ពលករចំណាកស្រុកដើម្បីទៅដល់ប្រទេសគោលដៅ .......... ៣២
តារាង ៣.៨: វិធីរកប្រាក់របស់ពលករចំណាកស្រុក ដើម្បីបង់កម្រៃធ្វើដំណើរទៅថៃ ឬ ម៉ាឡេស៊ី .......... ៣៣
តារាង ៣.៩: ភាគរយពលករចំណាកស្រុកបានផ្ញើប្រាក់ទៅផ្ទះក្នុងអំឡុងពេល ១ឆ្នាំមុន .......... ៣៥
តារាង ៣.១០: ប្រាក់ផ្ញើទៅផ្ទះសំរាប់គ្រួសារមានសមាជិកធ្វើចំណាកស្រុកទៅថៃ .......... ៣៦
តារាង ៣.១១: ប្រាក់ផ្ញើទៅផ្ទះ សំរាប់ការផ្ញើមួយលើកៗ និងសំរាប់ការធ្វើចំណាកស្រុកលើកចុងក្រោយ .......... ៣៧
តារាង ៣.១២: ប្រាក់ផ្ញើទៅផ្ទះ នៅអំឡុងពេល ១ឆ្នាំមុន និង ៥ឆ្នាំមុន .......... ៣៧
តារាង ៣.១៣: ប្រាក់ផ្ញើទៅផ្ទះរបស់ពលករចំណាកស្រុក បែងចែកតាមប្រភេទការងារ និងទីកន្លែង .......... ៣៨
តារាង ៣.១៤: ប្រាក់ផ្ញើទៅផ្ទះរបស់ពលករចំណាកស្រុក បែងចែកតាមទីកន្លែងការងារ និងភេទពលករ .......... ៣៩
តារាង ៣.១៥: មធ្យោបាយសំរាប់ផ្ញើប្រាក់ទៅផ្ទះ .......... ៤០
តារាង ៣.១៦: ការប្រើប្រាស់ប្រាក់ផ្ញើទៅផ្ទះ តាមការរាយការណ៍របស់ក្រុមគ្រួសារ .......... ៤២
តារាង ៣.១៧: ភាគរយនៃផលចំណេញបានពីការយកប្រាក់ផ្ញើទៅផ្ទះ ទៅទិញទ្រព្យផលិតកម្ម .......... ៤៣
តារាង ៣.១៨: ប្រាក់ចំណូលប្រចាំឆ្នាំរបស់គ្រួសារ .......... ៤៤
តារាង ៣.១៩: ចំណាយគ្រួសារក្នុងអំឡុងពេល ១ឆ្នាំមុន ទៅលើទំនិញមិនមែនអាហារ .......... ៤៥
តារាង ៣.២០: ចំណាយជាមធ្យមរបស់គ្រួសារក្នុងរយៈពេល ១ខែ ទៅលើទំនិញមិនមែនអាហារ .......... ៤៥
តារាង ៣.២១: ចំណាយរបស់គ្រួសារលើម្ហូបអាហារក្នុងអំឡុង ១សប្ដាហ៍មុន .......... ៤៦
តារាង ៣.២២: ប្រភេទផ្ទះនៅឆ្នាំ២០០២ និង ២០០៧ .......... ៤៧
តារាង ៣.២៣: តម្លៃផ្ទះនៅឆ្នាំ២០០២ និង ២០០៧ .......... ៤៨
តារាង ៣.២៤: តម្លៃទ្រព្យសម្បត្តិរបស់គ្រួសារនៅឆ្នាំ២០០២ និង ២០០៧ .......... ៤៩

តារាង ៣.២៥: ចំណាយ និងផលចំណេញខាងហិរញ្ញវត្ថុរបស់បុគ្គលពលករចំណាកស្រុកទៅថៃ ..... ៤៩
តារាង ៣.២៦: មូលហេតុនាំឱ្យក្រុមគ្រួសារយល់ឃើញថា ស្ថានភាពគ្រួសារបានប្រសើរជាងមុន ..... ៥២
តារាង ៤.១: បញ្ជីថ្លៃចំណាយក្នុងការបញ្ជូនពលករទៅកូរ៉េខាងត្បូង ..... ៥៩
តារាង ៤.២: បញ្ជីចំណាយក្នុងការបញ្ជូនពលករទៅថៃ ..... ៦០

## បញ្ជីក្រាហ្វិក

ក្រាហ្វិក ២.១: ចំនួនពលករចំណាកស្រុកបញ្ជូនទៅម៉ាឡេស៊ី កូរ៉េខាងត្បូង និងថៃ ..... ១៨

ក្រាហ្វិក ៣.១: ទីតាំងនៃភូមិទាំង ៦ ដែលបានជ្រើសរើសជាតំបន់សិក្សា ..... ២២
ក្រាហ្វិក ៣.២: ភាគរយគ្រួសារមានផលស្រូវផលិតខ្លួនឯងគ្រប់គ្រាន់សំរាប់បរិភោគ ..... ២៧
ក្រាហ្វិក ៣.៣: ការយល់ឃើញផ្ទាល់ខ្លួននៃក្រុមគ្រួសារដែលមានសមាជិកធ្វើចំណាកស្រុក ..... ៥០
ក្រាហ្វិក ៣.៤: ការយល់ឃើញពីស្ថានភាពរបស់ខ្លួនផ្ទាល់នៃក្រុមគ្រួសារមានសមាជិកធ្វើចំណាកស្រុក នៅចន្លោះឆ្នាំ២០០៧ និង ២០០២ ..... ៥១

ក្រាហ្វិក ៤.១: ស្ថាប័នពាក់ព័ន្ធនឹងចំណាកពលកម្មអន្តរជាតិ ..... ៥៣
ក្រាហ្វិក ៤.២: តារាងដំណើរការជ្រើសរើសពលករ ..... ៥៧

## បញ្ជីប្រអប់

ប្រអប់ ៣.១: ករណីបុគ្គលពលករចំណាកស្រុកម្នាក់ទៅម៉ាឡេស៊ី ..... ២៥
ប្រអប់ ៣.២: ករណីបុគ្គលពលករជាយុវនារីម្នាក់ធ្វើចំណាកស្រុកទៅថៃ ..... ២៧
ប្រអប់ ៣.៣: ករណីបុគ្គលពលករបុរសចាស់ចិត្តគំនិតម្នាក់ធ្វើចំណាកស្រុកទៅថៃ ..... ៣០
ប្រអប់ ៣.៤: ករណីបុគ្គលពលករចំណាកស្រុកតាមរដូវទៅធ្វើការនៅតាមព្រំដែនថៃ ..... ៣៣
ប្រអប់ ៣.៥: ករណីមួយចំនួននៃឈ្មួញប្រកបរបរផ្ញើរប្រាក់ផ្ញើទៅផ្ទះ នៅក្នុងសហគមន៍មូលដ្ឋាន ..... ៤០

ប្រអប់ ៤.១: មាត្រាដកស្រង់ពីអនុក្រឹត្យលេខ ៥៧ ..... ៦៥

# បញ្ជីអក្សរកាត់ និងពាក្យបំព្រួញ

| | |
|---|---|
| ផសស | ផលិតផលក្នុងស្រុកសរុប (Gross Domestic Product) |
| វបសអ - CDRI | វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (Cambodia Development Research Institute) |
| 3D | កខ្វល់ លំបាក និងគ្រោះថ្នាក់ (Dirty, Difficult and Dangerous) (ប្រភេទការងារដែលមានលក្ខខណ្ឌមិនល្អ) |
| AMC | មជ្ឈមណ្ឌលចំណាកស្រុកអាស៊ី (Asian Migrant Center) |
| CARAM Cambodia | អង្គការស្រាវជ្រាវសកម្មភាពសំរបសំរួលស្តីពីជំងឺអេដស៍ និងចំណាកស្រុកនៅកម្ពុជា (Coordinated Action Research on AIDS and Migration Cambodia) |
| CCVI | វិញ្ញាបនប័ត្របញ្ជាក់ការចេញទិដ្ឋាការ (Certificate of Confirmation for Visa Issuance) |
| CLS | ការផ្គត់ផ្គង់ពលកម្មកម្ពុជា (Cambodian Labour Supply) |
| DAN | បណ្តាញវិភាគអភិវឌ្ឍន៍ (Development Analysis Network) |
| FGD | ការពិភាក្សាតាមក្រុមស្នូល (Focus Group Discussion) |
| GDP | ផលិតផលក្នុងស្រុកសរុប (Gross Domestic Product) |
| IFAD | មូលនិធិអន្តរជាតិសំរាប់ការអភិវឌ្ឍកសិកម្ម (International Fund for Agricultural Development) |
| ILO | អង្គការពលកម្មពិភពលោក (International Labour Organization) |
| IMF | មូលនិធិរូបិយវត្ថុអន្តរជាតិ (International Monetary Fund) |
| IOM | អង្គការអន្តរជាតិសំរាប់ចំណាកស្រុក (International Organization for Migration) |
| MFIs | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ (Micro-Finance Institutes) |
| MG | គ្រួសារមានសមាជិកធ្វើចំណាកស្រុកក្នុងរយៈពេល ៥ឆ្នាំចុងក្រោយ (Migrant) |
| MLVT | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (Ministry of Labour and Vocational Training) |
| MOPS | ការសិក្សាពីការចាកចេញពីភាពក្រីក្រ (Moving Out of Poverty Study) |
| MoU | អនុស្សរណៈនៃការយោគយល់គ្នា (Memorandum of Understanding) |
| MTOSB | ក្រុមប្រឹក្សាបណ្តុះបណ្តាលហត្ថពលករ និងការបញ្ជូនពលករទៅក្រៅប្រទេស (the Manpower Training and Overseas Sending Board) |
| NPIC | វិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា (National Polytechnic Institute of Cambodia) |
| TDRI | វិទ្យាស្ថានស្រាវជ្រាវដើម្បីអភិវឌ្ឍន៍ប្រទេសថៃ (Thailand Development Research Institute) |
| UNIFEM | មូលនិធិសហប្រជាជាតិសំរាប់ស្ត្រី (United Nations Development Funds for Women) |

# សេចក្តីថ្លែងអំណរគុណ

អ្នកនិពន្ធសូមថ្លែងអំណរគុណដល់ការចូលរួមចំណែកពីសំណាក់លោកស្រី ទូត សុខផល្លី និងលោកស្រី ឆាយ ពិដោរ ដែលជាសមាជិកក្រុមសិក្សាស្រាវជ្រាវតាំងពីដំណាក់កាលដំបូង និងបណ្ឌិត Srawooth Paitoonpong អ្នកឯកទេសស្រាវជ្រាវជាន់ខ្ពស់ នៃវិទ្យាស្ថានស្រាវជ្រាវដើម្បីអភិវឌ្ឍន៍ប្រទេសថៃ ដែលបានជួយរៀបចំការចុះស្រាវជ្រាវដល់មូលដ្ឋានឱ្យក្រុមសិក្សាកម្ពុជា ដើម្បីធ្វើសម្ភាសន៍ជាមួយពលរដ្ឋចំណាកស្រុកកម្ពុជា និងអាជ្ញាធរពាក់ព័ន្ធនានានៅក្នុងប្រទេសថៃ និងសូមអរគុណដល់អាជ្ញាធរកម្ពុជាគ្រប់កំរិត ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ចំពោះកិច្ចសហការជួយដល់ក្រុមសិក្សាក្នុងនេះ មានទាំងអ្នកចុះធ្វើសម្ភាសន៍ចំនួនប្រាំនាក់ដែលបានទៅស្នាក់នៅក្នុងភូមិចំនួនប្រាំមួយ អស់រយៈពេលប្រាំមួយសប្តាហ៍ ។ ឯកសារស្រាវជ្រាវនេះ បានទទួលយោបល់មួយចំនួនពីសមាជិកនៃបណ្តាញវិភាគអភិវឌ្ឍន៍ (DAN) ដែលបានធ្វើការសិក្សាដូចគ្នានៅក្នុងប្រទេសថៃ ឡាវ និងវៀតណាម ។

អ្នកនិពន្ធសូមថ្លែងអំណរគុណដល់កញ្ញា អ៊ូច ច័ន្ទតារ៉ានី អ្នកសម្របសម្រួល នៃបណ្តាញវិភាគអភិវឌ្ឍន៍ (DAN) និងបណ្ឌិត Rebecca (Pem) F. CATALLA ទីប្រឹក្សាស្រាវជ្រាវ នៃវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា លើដំណើរការពិនិត្យកែសម្រួលសំរាប់ការបោះពុម្ពផ្សាយ ។ អ្នកនិពន្ធសូមថ្លែងអំណរគុណដល់ការលើកទឹកចិត្ត មតិណែនាំ និងការដឹកនាំតម្រង់ទិសដោយបណ្ឌិត Hossein Jalilian នាយកផ្នែកស្រាវជ្រាវ លោក Larry Strange នាយកប្រតិបត្តិ និងលោក អ៊ឹង ស៊ានលី នាយកផ្នែកប្រតិបត្តិការ នៃវិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា ។ អ្នកនិពន្ធសូមថ្លែងអំណរគុណជាពិសេសដល់មូលនិធិ Rockefeller ដែលបានផ្តល់ថវិកាសំរាប់ការស្រាវជ្រាវទាំងនៅក្នុងប្រទេសកម្ពុជា និងនៅក្នុងមហាអនុតំបន់មេគង្គ ។

# ជំពូក ១ សេចក្ដីផ្ដើម

ប្រទេសកម្ពុជា ទើបមានទេសន្តប្រវេសន៍កំលាំងពលកម្មឆ្លងកាត់ព្រំដែននាពេលថ្មីៗ ។ ជនចំណាកស្រុកភាគច្រើនធ្វើដំណើរដោយមធ្យោបាយខុសច្បាប់ ឬក្រៅផ្លូវការ និងច្រើនតែទៅកាន់ប្រទេសថៃ ឯការធ្វើចំណាកស្រុកដោយស្របច្បាប់ គឺជាជម្រើសមួយថ្មីដែលត្រូវចំណាយប្រាក់ច្រើន និងជាទូទៅ មិនងាយស្រួលឡើយ ។ ទីភ្នាក់ងាររដ្ឋាភិបាលជាប់ពាក់ព័ន្ធ ត្រូវជួបនឹងបញ្ហាប្រឈមកាន់តែច្រើនក្នុងការគ្រប់គ្រងចរន្តទេសន្តរប្រវេសន៍កំលាំងពលកម្មដែលគេរំពឹងថានឹងកើនឡើងដោយសារកត្តាខាងក្នុង និងខាងក្រៅ ។ ដោយសារការបង្កើតការងារមានផលិតភាព មិនអាចដើរទាន់កំណើនកំលាំងពលកម្មប្រមាណ ២៥០.០០០នាក់ក្នុងមួយឆ្នាំ ជាពិសេសក្នុងស្ថានភាពវិបត្តិសេដ្ឋកិច្ចក្នុងឆ្នាំ២០០៩ សំពាធនៃការធ្វើអន្តោប្រវេសន៍ ទំនងជានឹងកើនឡើង ។ ប្រាក់កម្រៃខ្ពស់នៅក្នុងប្រទេសគោលដៅ ដូចជា ថៃ ម៉ាឡេស៊ី កូរ៉េ ជប៉ុន និងសិង្ហបុរី ក៏ជាកត្តាអូសទាញមួយដែរ ។ ចាប់ពីឆ្នាំ១៩៩៨ រហូតដល់ចុងឆ្នាំ២០០៨ មានពលករប្រហែល ២៥.០០០នាក់ ត្រូវបានបញ្ជូនឱ្យទៅធ្វើការនៅក្រៅប្រទេសជាផ្លូវការ យោងតាមទិន្នន័យផ្លូវការរបស់ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ។ ប៉ុន្តែទោះជាយ៉ាងនេះក្ដី ក៏នៅមានពលករកម្ពុជាប្រមាណ ១៨០.០០០នាក់ កំពុងធ្វើការនៅក្នុងប្រទេសថៃ ដែលភាគច្រើនមិនបានបំពេញសំណុំបែបបទទេ (IOM, 2006) ។ ដូច្នេះ ទេសន្តរប្រវេសន៍កំលាំងពលកម្មទៅកាន់ប្រទេសថៃ គួរតែមានការយកចិត្តទុកដាក់ខ្លាំងជាងនេះ ។

ជាទូទៅ ការបង្កើតការងារ និងការអភិវឌ្ឍនៅក្នុងប្រទេស វាប្រសើរជាងក៏ពិតមែន ប៉ុន្តែក៏គួរមានការគ្រប់គ្រងគ្រប់ជ្រុងជ្រោយលើអន្តោប្រវេសន៍កំលាំងពលកម្ម ដើម្បីកាត់បន្ថយហានិភ័យនិងចំណាយ និងបង្កើនអត្ថប្រយោជន៍ដល់អ្នកធ្វើចំណាកស្រុកផងដែរ ។ ប្រសិនបើគ្រប់គ្រងបានល្អ ទេសន្តរប្រវេសន៍កំលាំងពលកម្មជួយផ្ដល់ការងារ និងប្រាក់ចំណូល បានច្រើនសន្ធឹកសន្ធាប់ក្នុងរយៈពេលខ្លី រយៈពេលមធ្យម និងអាចដល់រយៈពេលវែងទៀតផង សំរាប់ប្រទេសជាច្រើននៅក្នុងតំបន់ ។ ទេសន្តរប្រវេសន៍កំលាំងពលកម្មទៅក្រៅប្រទេស អាចចូលរួមចំណែកកាត់បន្ថយភាពក្រីក្រ ។ ប្រាក់ផ្ញើទៅផ្ទះដែលហូរចូលប្រទេសកម្ពុជា ដែលទំនងជាមានទាំងប្រាក់ផ្ញើរបស់បុគ្គលមិនមែនជាជនចំណាកស្រុកផង មានដល់ប្រមាណ ២០០លានដុល្លារអាមេរិក ឬ ៣,២៣% នៃ GDP នៅឆ្នាំ២០០៥ ។ ក្នុងអំឡុងពេលដូចគ្នា ប្រទេសថៃបានទទួលប្រាក់ផ្ញើទៅផ្ទះ ១,២ពាន់លានដុល្លារអាមេរិក រីឯប្រទេសវៀតណាម បានទទួល ៤ពាន់លានដុល្លារអាមេរិក យោងតាមធនាគារពិភពលោក (២០០៧) ។ ម្យ៉ាងទៀត ប្រទេសហ្វីលីពីន បានទទួល ១៣,៥ពាន់លានដុល្លារអាមេរិក និងប្រទេសបង់ក្លាដែស បានទទួល ៤,២ពាន់លានដុល្លារអាមេរិក ។ ការសិក្សាក្នុងពេលថ្មីៗនេះរបស់មូលនិធិអន្តរជាតិសំរាប់ការអភិវឌ្ឍកសិកម្ម (IFAD, 2007) និងធនាគារអភិវឌ្ឍន៍អន្តរអាមេរិក (Inter-American Development Bank) បានរកឃើញថា ពលករចំណាកស្រុក មានប្រមាណ ១៥០លាននាក់ ហើយពួកគេបានផ្ញើប្រាក់ទៅផ្ទះចំនួន ៣០០ពាន់លានដុល្លារអាមេរិកក្នុងឆ្នាំ២០០៦ ដែលច្រើនជាងជំនួយអភិវឌ្ឍន៍ និងវិនិយោគផ្ទាល់ពីបរទេសទៅទៀត ។

ផ្អែកលើការពិនិត្យទិន្នន័យទី ២ ដែលមានស្រាប់ និងរបាយការណ៍ និងបទសម្ភាសន៍ជាមួយមន្ត្រីរាជការ ទាំងនៅក្នុងប្រទេសកម្ពុជា និងនៅប្រទេសថៃ ការសិក្សាបង្ហាញត្រួសៗពីនិន្នាការ និងបញ្ហាចំបងនៃទេសន្តរប្រវេសន៍កំលាំងពលកម្មនៅក្នុងប្រទេសកម្ពុជា ។ ទោះជាយ៉ាងនេះក្ដី ការស្រាវជ្រាវនេះដែលជាផ្នែកមួយនៃការសិក្សាក្នុងតំបន់ បានផ្ដោតជាសំខាន់លើការវាយតម្លៃពីផលប្រយោជន៍ និងចំណាយហិរញ្ញវត្ថុនៃសហគមន៍ និងគ្រួសារបញ្ជូនពលករចេញ ។ តាមនេះ ការស្រាវជ្រាវបានធ្វើអង្កេតលើ ៥២៦គ្រួសារក្នុង ៦សហគមន៍ ដែលបានជ្រើសរើសដោយមានគោលដៅ

បានពិភាក្សាតាមក្រុមស្នូល ធ្វើសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់ៗ និងធ្វើសម្ភាសន៍ស៊ីជម្រៅជាមួយជនចំណាកស្រុកដែលមកលេងផ្ទះជាបណ្តោះអាសន្ននៅក្នុងអំឡុងខែកញ្ញា និងតុលា ២០០៧ ។ ក្នុងជំពូកទី ២ មានអធិប្បាយជាសង្ខេបពីការវិវត្តនៃអន្តោប្រវេសន៍កំលាំងពលកម្មនៅប្រទេសកម្ពុជា ។ ជំពូកទី ៣ បង្ហាញពីករណីសិក្សានៅក្នុងសហគមន៍ស្តីពីផលប្រយោជន៍ និងចំណាយនៃទេសន្តរប្រវេសន៍កំលាំងពលកម្មឆ្លងកាត់ព្រំដែននៅក្នុងប្រទេសកម្ពុជា ។ ជំពូកទី ៤ ពិភាក្សាពីបញ្ហាសំខាន់ៗពាក់ព័ន្ធនឹងអន្តោប្រវេសន៍កំលាំងពលកម្មនៅកម្ពុជា និងជំពូកទី ៥ បូកសរុប និងផ្តល់ជាអនុសាសន៍ខាងគោលនយោបាយ ។

## ជំពូក ២ ការវិវត្តនៃទេសន្តរប្រវេសន៍កំលាំងពលកម្មនៅកម្ពុជា

### ២.១. ប្រវត្តិនៃអន្តោប្រវេសន៍ និងទេសន្តរប្រវេសន៍កំលាំងពលកម្ម

ក្នុងពីរទសវត្សរ៍ចុងក្រោយនេះ មានការផ្លាស់ប្តូរពីការធ្វើអន្តោប្រវេសន៍ដោយបង្ខំរបស់ជនភៀសខ្លួន ឬប្រជាជននៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃ ដោយសារសង្គ្រាមស៊ីវិល និងអស្ថិរភាពនយោបាយទៅជាការធ្វើទេសន្តរប្រវេសន៍ដោយស្ម័គ្រចិត្ត ដើម្បីរកការងារធ្វើ ។ រលកថ្មីមួយនៃការធ្វើចំណាកស្រុកទៅធ្វើការនៅប្រទេសថៃ បានកើតឡើងនៅក្នុងទសវត្សរ៍ចុងក្រោយនេះ ព្រោះមានទាំងកត្តាជំរុញ និងកត្តាអូសទាញ រួមមានកង្វះការងារធ្វើនៅក្នុងប្រទេសកម្ពុជា និងអត្រាប្រាក់កម្រៃខ្ពស់នៅក្នុងប្រទេសថៃ ។ ការធ្វើទេសន្តរប្រវេសន៍ មាន ២ប្រភេទចំបង គឺអ្នកទៅធ្វើការនិងស្នាក់នៅជាច្រើនខែ/ឆ្នាំនៅក្នុងប្រទេសថៃ និងអ្នកទៅធ្វើការក្នុងតំបន់នៅក្បែរៗព្រំដែន ដែលភាគច្រើនធ្វើការងារកសិកម្ម ។ ជនចំណាកស្រុកកម្ពុជារយៈពេលវែង ច្រើនទៅធ្វើការខាងសំណង់ កម្មន្តសាល ចំការដំណាំ ការងារផ្ទះ និងនេសាទ ដែលភាគច្រើនជាការងារប្រភេទ 3D (កង្វក់ លំបាក គ្រោះថ្នាក់) (IOM, 2006) ។ នៅក្នុងសិក្ខាសាលាពិភាក្សាពីសំណើបង្កើតគោលនយោបាយទេសន្តរប្រវេសន៍កំលាំងពលកម្មនៅកម្ពុជាកាលពីថ្ងៃទី ៥ ឧសភា ២០០៩ ឯកឧត្តម សេង សក្តា អគ្គនាយក នៃអគ្គនាយកដ្ឋានការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានលើកឡើងថា ទោះជាមានជនចំណាកស្រុកថៃ ១លាននាក់ បានវិលត្រឡប់ពីប្រទេសផ្សេងៗ ដោយសារវិបត្តិសេដ្ឋកិច្ចសាកលក្តី ក៏និយោជកថៃមិនអាចរកពលករបានគ្រប់គ្រាន់សំរាប់ការងារប្រភេទ 3D ដែរ ។

ដោយសម្រេចបានកំណើនសេដ្ឋកិច្ចខ្ពស់ក្នុងប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ ប្រទេសទទួលពលករត្រូវតែរកកំលាំងពលកម្មមានជំនាញទាប មកបំពេញតម្រូវការដែលផុសចេញពីការរីកលូតលាស់នៃសេដ្ឋកិច្ច និងការថយចុះកំលាំងទាក់ទាញនៃការងារប្រភេទនេះ ក្នុងចំណោមកំលាំងពលកម្មដែលទទួលបានការបណ្តុះបណ្តាលល្អ ។ កង្វះខាតការងារនៅក្នុងប្រទេសបញ្ជូនពលករ និងការមានការងារច្រើន ព្រមទាំងកំរិតប្រាក់ចំណូលខ្ពស់នៅក្នុងប្រទេសទទួលពលករ វាជាកត្តាបង្កចលនាកំលាំងពលកម្មចេញពីប្រទេសក្រីក្រ ។ ពលករក្រីក្រគ្មានជំនាញ ចេញពីមហាអនុតំបន់មេគង្គមកធ្វើការនៅក្នុងប្រទេសថៃ រីឯពលករមានជំនាញមធ្យមចេញពីប្រទេសថៃទៅធ្វើការនៅតំបន់អាស៊ីខាងកើត (World Bank, 2007) ។ ប៉ុន្តែ កំណើនខ្ពស់គ្រាន់តែជាលក្ខខណ្ឌមួយក្នុងចំណោមលក្ខខណ្ឌជាច្រើនដែលបង្កើតតម្រូវការនូវពលករបរទេស ។ គេក៏ឃើញមានជនចំណាកស្រុកកាន់តែច្រើន នៅក្នុងបណ្តាប្រទេសមានអត្រាកំណើនទាបដែរ ។ ភាពខុសគ្នានៃអត្រាប្រាក់កម្រៃ និងចលនាពលករពីការងារថ្នាក់ទាបទៅកាន់ការងារថ្នាក់ខ្ពស់ វាបង្កើតបានជាកង្វះកំលាំងពលកម្ម និងភាពមិនស៊ីគ្នានៅក្នុងទីផ្សារពលកម្ម ។ ដូច្នេះ ការប្រែប្រួលខុសលំនាំដើម និងអប្រសិទ្ធភាពនៃទីផ្សារការងារ ជាទូទៅ វាជួយរួមចំណែកបង្កើតតម្រូវការខ្ពស់នូវពលករបរទេសនៅក្នុងប្រទេសទទួលពលករ ។

ការធ្វើអន្តោប្រវេសន៍កំលាំងពលកម្មរបស់កម្ពុជា មានសន្ទុះកើនឡើងតាំងពីពាក់កណ្តាលទសវត្សរ៍ ១៩៩០ នៅពេលដែលប្រទេសកម្ពុជាទទួលបានសន្តិភាពទាំងស្រុង និងបានជួបកត្តាជំរុញចំណាកស្រុក គឺគ្រោះមហន្តរាយជាបន្តបន្ទាប់ ដូចជា ការរាំងស្ងួត និងទឹកជំនន់ ជាដើម (CDRI, 2007b, Chan and So, 1999) ។ ខេត្តដែលបញ្ជូនពលករទៅធ្វើការច្រើនជាងគេនៅក្រៅប្រទេស គឺខេត្តបន្ទាយមានជ័យ និងបាត់ដំបង ។ បច្ចុប្បន្ន ពលករចំណាកស្រុកមិនត្រឹមតែមកពីខេត្តទាំងពីរ ដែលធ្លាប់ទទួលជនភៀសខ្លួនធ្វើមាតុភូមិនិវត្តន៍មកពីជំរំនៅតាមព្រំដែនថៃនោះទេ ប៉ុន្តែក៏មានមកពីខេត្តផ្សេងៗទៀតនៅកម្ពុជាដែរ ។ ម្យ៉ាងទៀត គេឃើញមានជនចំណាកស្រុកតិចតួចប៉ុណ្ណោះ ដែលមកពី

តំបន់ជនបទដាច់ស្រយាលមិនសូវមានប្រព័ន្ធគមនាគមន៍ និងហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រាន់ ។ ថ្វីបើប្រទេសថៃ នៅតែជាទិសដៅធំបំផុតសំរាប់ជនចំណាកស្រុកកម្ពុជាក្តី ប៉ុន្តែក៏មានទិសដៅផ្សេងៗទៀត ដូចជា ប្រទេសម៉ាឡេស៊ី កូរ៉េខាងត្បូង អារ៉ាប់ប៊ីសាអូឌីត តៃវ៉ាន់ សិង្ហបុរី និងជប៉ុនដែរ ។

តារាង ២. ១ បង្ហាញនូវទំនាក់ទំនងច្បាស់លាស់រវាងប្រាក់ចំណូលជាតិ និងការធ្វើចំណាកស្រុក ប៉ុន្តែគ្មានទំនាក់ទំនងអ្វីទៅនឹងចំនួនប្រជាជនទេ ។ ប្រទេសមានប្រាក់ចំណូលទាប ដូចជា កម្ពុជា ឡាវ និងវៀតណាម គឺជាប្រទេសបញ្ជូនពលករចេញ រីឯប្រទេសមានប្រាក់ចំណូលខ្ពស់ ដូចជា កូរ៉េខាងត្បូង សិង្ហបុរី និងជប៉ុន គឺជាប្រទេសទទួលពលករ ដើម្បីបំពេញតម្រូវការកំលាំងពលកម្មគ្មានជំនាញ និងមានជំនាញទាប ដោយសារកំលាំងពលកម្មនៅក្នុងប្រទេសទាំងនោះបានឡើងថ្នាក់មួយកំរិតទៀត ។ គួរឱ្យចម្លែកដែរ ប្រទេសក្រីក្របញ្ជូនពលករចេញ ដូចជា ឡាវ កម្ពុជា និងនេប៉ាល់ ជាដើម ទទួលពលករចំណាកស្រុកយ៉ាងច្រើនពីប្រទេសជិតខាង ដូចជា វៀតណាម ចិន ថៃ ទាំងស្របច្បាប់ និងខុសច្បាប់ ដែលមកប្រកួតប្រជែងឈ្នះពលករក្នុងស្រុក ហើយទទួលបានប្រាក់កម្រៃយ៉ាងខ្ពស់ ដោយសារកំរិតជំនាញខ្ពស់ជាង ។

ចំណុចគួរកត់សម្គាល់ គឺថៃ និងម៉ាឡេស៊ី ដែលជាប្រទេសមានប្រាក់ចំណូលកំរិតកណ្តាល-ខ្ពស់ មានបញ្ជូនផង និងទទួលផងនូវពលករទេសន្តរប្រវេសន៍ រីឯហ្វីលីពីនដែលជាប្រទេសមានប្រាក់ចំណូលកំរិតកណ្តាល-ទាប មានបញ្ជូនពលករចេញទៅក្រៅប្រទេសច្រើនជាងគេនៅអាស៊ី ។ ជាទូទៅ ប្រទេសបញ្ជូនពលករចេញ ច្រើនមានកំណើនប្រជាជនខ្ពស់ជាងប្រទេសទទួលពលករ ។

**តារាង ២.១: កំណើនប្រជាជន និងទិន្នន័យ ផសស នៃប្រទេសជ្រើសរើសមួយចំនួនក្នុងឆ្នាំ២០០៥**

| | ស្ថានភាពពាក់ព័ន្ធនឹងទេសន្តរប្រវេសន៍កំលាំងពលកម្ម | ចំនួនប្រជាជន (លាននាក់) | កំណើនប្រជាជន (%) | ផសស ក្នុងមនុស្សម្នាក់ (ជាដុល្លារអាមេរិក ថេរឆ្នាំ២០០០) |
|---|---|---|---|---|
| កម្ពុជា | បញ្ជូនពលករចេញ | 14.1 | 1.96 | 402 |
| ឡាវ | បញ្ជូនពលករចេញ | 5.9 | 2.26 | 396 |
| វៀតណាម | បញ្ជូនពលករចេញ | 83.1 | 1.16 | 538 |
| ហ្វីលីពីន | បញ្ជូនពលករចេញ | 83.1 | 1.75 | 1,129 |
| ថៃ | បញ្ជូនពលករចេញទៅប្រទេសមានប្រាក់ចំណូលខ្ពស់ជាង ប៉ុន្តែទទួលពលករពីប្រទេសមានប្រាក់ចំណូលទាបជាង | 64.2 | 0.84 | 2,441 |
| ម៉ាឡេស៊ី | បញ្ជូនពលករចេញទៅប្រទេសមានប្រាក់ចំណូលខ្ពស់ជាង ប៉ុន្តែទទួលពលករពីប្រទេសមានប្រាក់ចំណូលទាបជាង | 25.3 | 1.80 | 4,437 |
| កូរ៉េខាងត្បូង | ទទួលពលករ | 48.3 | 0.44 | 13,210 |
| សិង្ហបុរី | ទទួលពលករ | 4.3 | 2.39 | 25,845 |
| ជប៉ុន | ទទួលពលករ | 127.8 | 0.01 | 39,075 |

*ប្រភពៈ សូចនាករអភិវឌ្ឍន៍សាកលលោកឆ្នាំ2007, ធនាគារពិភពលោក*

Godfrey et al. (2001), Maltoni (2006) និង CDRI (2007) បានបកស្រាយពីកត្តាជំរុញមួយចំនួន ដែលបណ្តាលឱ្យមានកំណើនចលនាអន្តោប្រវេសន៍ រួមមាន ភាពក្រីក្រ ភាពគ្មានដីធ្លី កង្វះការងារធ្វើ កង្វះលទ្ធភាពទៅកាន់ទីផ្សារ សម្ភារៈនិយម ការជំពាក់បំណុល និងគ្រោះធម្មជាតិ ។ ចលនានេះ ក៏មានកត្តា ជួយសម្រួល ដូចជា ប្រព័ន្ធគមនាគមន៍ និងហេដ្ឋារចនាសម្ព័ន្ធល្អប្រសើរ និងកំណើនតម្រូវការទីផ្សារនូវពលករគ្មានជំនាញនៅប្រទេសថៃ និងនៅបណ្តាប្រទេស នៅអាស៊ីអាគ្នេយ៍ ដូចជា ម៉ាឡេស៊ី កូរ៉េខាងត្បូង ជប៉ុន និងតៃវ៉ាន់ (AMC 2002) ។

ប្រទេសជាច្រើន បានរកឃើញថា ការធ្លាក់ចុះបរិស្ថាន ជាកត្តាបង្កកំណើនចំនួនជនចំណាកស្រុកនៅក្នុងប្រទេស និងបន្ទាប់មក ទៅក្រៅប្រទេស ។ នៅប្រទេសកម្ពុជា ដែលធ្លាប់មានព្រៃឈើគ្របដណ្តប់ដល់ទៅ ៧០% នៃផ្ទៃដីសរុប នៅទសវត្សរ៍ ១៩៨០ ការរានយកដីពីព្រៃខូចគុណភាព បានបង្កើតការងារជាច្រើនក្នុងការរានដី និងធ្វើស្រែចំការ ហើយជាលទ្ធផល វាបានកាត់បន្ថយសំពាធនៃការធ្វើចំណាកស្រុក ។ ប៉ុន្តែនៅពេលគេរានយកដីព្រៃ និងបង្កើតស្រែចំការបានហើយ ពលករនឹងត្រូវទៅរកការងារធ្វើនៅកន្លែងផ្សេងទៀត ។

នៅប្រទេសថៃ ពលករទេសន្តរប្រវេសន៍ភាគច្រើនមកពីមីយ៉ាន់ម៉ា ឡាវ និងកម្ពុជា ។ ក្រសួងការងារប្រទេសថៃ បានផ្តល់កូតាដល់ពលករទេសន្តរប្រវេសន៍ពីប្រទេសទាំងបីនេះ ។ ប៉ុន្តែកូតានេះ មិនបានក្លាយទាំងអស់ជាលិខិតអនុញ្ញាតការងារនោះទេ ។ ឧទាហរណ៍ គេអាចផ្តល់ ២២៧.២៧៥ការងារឱ្យពលករកម្ពុជា ប៉ុន្តែមានពលករតែ ១១០.០៤២នាក់ប៉ុណ្ណោះ ដែលត្រូវបានចុះបញ្ជី និងផ្តល់លិខិតអនុញ្ញាតការងារនៅក្រោមកម្មវិធីនិយតកម្ម ដែលបានផ្តួចផ្តើមធ្វើនៅឆ្នាំ ២០០៤ (តារាង ២.២) ។

**តារាង ២.២: ការបែងចែកកូតា និងការផ្តល់លិខិតអនុញ្ញាតការងារ នៅតាមតំបន់នានាក្នុងប្រទេសថៃ នៅឆ្នាំ២០០៥**

| តំបន់ | កូតា | | | | លិខិតអនុញ្ញាតការងារ | | | |
|---|---|---|---|---|---|---|---|---|
| | មីយ៉ាន់ម៉ា | ឡាវ | កម្ពុជា | សរុប | មីយ៉ាន់ម៉ា | ឡាវ | កម្ពុជា | សរុប |
| បាងកក | 166,138 | 63,365 | 33,037 | 262,540 | 105,771 | 40,177 | 17,709 | 163,657 |
| កណ្តាល | 265,509 | 46,647 | 49,859 | 362,015 | 156,874 | 24,815 | 23,840 | 205,529 |
| ខាងកើត | 71,758 | 25,885 | 110,315 | 207,958 | 34,965 | 15,272 | 53,781 | 104,018 |
| ខាងលិច | 101,652 | 11,629 | 5,547 | 118,828 | 46,685 | 3,850 | 2,105 | 52,640 |
| ខាងជើង | 226,189 | 7,532 | 1,099 | 234,820 | 129,904 | 3,110 | 944 | 133,958 |
| ឦសាន | 6,159 | 30,145 | 5,440 | 41,744 | 2,832 | 11,595 | 1,464 | 15,891 |
| ខាងត្បូង | 249,248 | 13,456 | 21,978 | 284,682 | 155,423 | 6,315 | 10,199 | 171,937 |
| សរុប | 1,086,653 | 198,659 | 227,275 | 1,512,587 | 632,454 | 105,134 | 110,042 | 847,630 |

*ប្រភព: ក្រសួងការងារប្រទេសថៃ ទិន្នន័យដល់ថ្ងៃទី ៣១ ខែឧសភា ឆ្នាំ2005 (Paitoonpong and Chalamwong 2007) ។*

ពីមួយឆ្នាំទៅមួយឆ្នាំ មានការចរចាជាបន្តបន្ទាប់ រវាងរដ្ឋាភិបាល ទីភ្នាក់ងារការងារ និងពាណិជ្ជកម្ម ដើម្បីព្យាយាមរកឱ្យបាននូវវិធីសមស្របមួយសំរាប់គ្រប់គ្រងលំហូរពលករ ដោយមិនប៉ះពាល់ខ្លាំងដល់អនាគតសេដ្ឋកិច្ចរបស់ប្រជាជនថៃ (Paitoonpong and Chalamwong, 2007) ។ នៅឆ្នាំ២០០៥ ការផ្តល់លិខិតអនុញ្ញាតការងារ ធៀបនឹងកូតា ដែលកំណត់ឱ្យពលករមកពីមីយ៉ាន់ម៉ា ឡាវ និងកម្ពុជា មានតែ ៥៨% ៥៣% និង ៤៨% ប៉ុណ្ណោះ (តារាង ២.២) ។ តួលេខនេះ បង្ហាញច្បាស់ថា ការអនុវត្តប្រព័ន្ធផ្តល់លិខិតអនុញ្ញាតការងារ មានចោទបញ្ហា ហើយគួរតែកែលំអឡើង ។

តារាង ២.២ ក៏បានបង្ហាញថា ពលករទេសន្តរប្រវេសន៍កម្ពុជា មាននៅរាយប៉ាយជាខ្លាំងក្នុងប្រទេសថៃ ប៉ុន្តែនៅតំបន់ខាងកើត តំបន់កណ្ដាល និងទីក្រុងបាងកក ឃើញមានច្រើនជាងគេ ។ កូតាដែលផ្ដល់ដល់តំបន់ខាងកើត មានចំនួនច្រើនជាខ្លាំងជាងចំនួនលិខិតអនុញ្ញាតការងារដែលបានផ្ដល់ឱ្យជាក់ស្ដែង ។ រឿងនេះ មានន័យថា មានតម្រូវការខ្ពស់នូវពលករកម្ពុជា ។ ក្នុងអំឡុងពេលចុះស្រាវជ្រាវដល់កន្លែងនៅឯប្រទេសថៃ ដែលអ្នកនិពន្ធបានធ្វើឡើង ដោយសហការជាមួយវិទ្យាស្ថានស្រាវជ្រាវដើម្បីអភិវឌ្ឍន៍ប្រទេសថៃ (TDRI) ពលករកម្ពុជាបានបញ្ជាក់ពីចំណាប់អារម្មណ៍ចង់បានលិខិតអនុញ្ញាតការងារទៅតាមតម្លៃកំណត់ ។ ប៉ុន្តែគេមិនឃើញមានការផ្ដល់សេវាទេ នៅអំឡុងពេលដែលពលករអាចធ្វើបាននោះទេ ។ ពេលវេលាកំណត់ផ្ដល់សេវា មានមិនសូវញឹកញាប់ និងគោលបំណងម្យ៉ាងទៀត គឺគេមិនចង់លើកទឹកចិត្តឱ្យពលករថ្មីចូលប្រទេសថៃដោយខុសច្បាប់ ហើយបន្ទាប់មកក៏ត្រូវបានផ្ដល់លិខិតអនុញ្ញាតការងារ ។

## ២.២. លក្ខណៈផ្លូវការនៃការធ្វើចំណាកស្រុក និងការផ្ញើប្រាក់ទៅផ្ទះ

ជារួម មានការធ្វើចំណាកស្រុកចេញពីកម្ពុជាពីរបែប គឺស្របច្បាប់ និងខុសច្បាប់ ។ តារាង ២.៣ ផ្ដល់ស្ថិតិថ្មីៗបំផុតស្ដីពីពលករចំណាកស្រុកកម្ពុជា ដែលបញ្ជូនចេញជាផ្លូវការទៅធ្វើការនៅបីប្រទេស ចាប់តាំងពីឆ្នាំ១៩៩៨ ។ ពីឆ្នាំ១៩៩៨ ដល់ចុងឆ្នាំ២០០៧ មានពលករស្របច្បាប់ ២០.៦៣០នាក់ ចេញទៅធ្វើការនៅម៉ាឡេស៊ី កូរ៉េខាងត្បូង និងថៃ ។ ពលករភាគច្រើនដែលបញ្ជូនទៅម៉ាឡេស៊ី ជាស្ត្រីអ្នកជួយធ្វើកិច្ចការផ្ទះ ឬអ្នកបម្រើ ចំណែកឯពលករទៅកូរ៉េខាងត្បូង ភាគច្រើនជាបុរសទៅធ្វើការតាមរោងចក្រ ។ ទោះបីថៃបានទទួលពលករចំណាកស្រុកកម្ពុជាចាប់តាំងពីឆ្នាំ១៩៩៤ មកក្ដី ក៏ពលករភាគច្រើនពុំមានឯកសារបញ្ជាក់ត្រឹមត្រូវ ។ ការបញ្ជូនពលករជាផ្លូវការទើបចាប់ផ្ដើមក្នុងឆ្នាំ២០០៦ ដោយយោងតាមអនុស្សរណៈនៃការយោគយល់គ្នា (MoU) រវាងប្រទេសថៃ និងប្រទេសកម្ពុជា ដែលចុះហត្ថលេខាក្នុងខែឧសភា ២០០៣ ។

**ក្រាហ្វិក ២.១: ចំនួនពលករចំណាកស្រុកបញ្ជូនទៅម៉ាឡេស៊ី កូរ៉េខាងត្បូង និងថៃ ត្រឹមខែមករា ២០០៨**




*ប្រភព: ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ (ស្ថិតិផ្លូវការ) UNIFEM (2006), IOM (2006)*

ពលករកម្ពុជាជាង ៦១១៤នាក់ ដែលនៅក្នុងប្រទេសថៃនាបច្ចុប្បន្ននេះ គឺស្ថិតនៅក្រោមរបៀបរបបច្បាប់ថ្មី ។ ម្យ៉ាងទៀត មានពលករ ប្រមាណ ១០០.០០០នាក់ បានទទួលលិខិតអនុញ្ញាតការងារក្នុងឆ្នាំ២០០៤ ក្នុងនោះមាន ៥០.០០០នាក់ បានទទួលវិញ្ញាបនប័ត្របញ្ជាក់អត្តសញ្ញាណ (CI) ។ សរុបមក ជាលក្ខណៈបច្ចេកទេស ពលករ

កម្ពុជាភាគច្រើននៅក្នុងប្រទេសថៃ មានស្ថានភាពស្របច្បាប់មកទល់ពេលថ្មីៗនេះ គឺពេលដែលលិខិតអនុញ្ញាតការងារ និងវិញ្ញាបនប័ត្របញ្ជាក់អត្តសញ្ញាណ ដែលចេញឱ្យពួកគេកាលពីឆ្នាំ២០០៤ បានផុតកំណត់ ។ យោងតាមក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានពលករតែ ៥០០០នាក់ប៉ុណ្ណោះ ដែលទទួលបានវិញ្ញាបនប័ត្របញ្ជាក់អត្តសញ្ញាណ ក្នុងឆ្នាំ២០០៧ ។ ដូច្នេះ ពលករភាគច្រើនដែលកាន់លិខិតអនុញ្ញាតការងារ និងវិញ្ញាបនប័ត្របញ្ជាក់អត្តសញ្ញាណចាស់ ត្រូវស្ថិតក្នុងស្ថានភាពមិនច្បាស់លាស់ទេ ។ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈកម្ពុជា បានស្នើថា រដ្ឋាភិបាលថៃ គួរបញ្ជូនពលករទាំងនេះទៅប្រទេសដើមវិញ ដើម្បីឱ្យគេអាចបញ្ជូនពលករទៅកាន់ប្រទេសថៃវិញដោយវិធីស្របច្បាប់ ។ ប៉ុន្តែមធ្យោបាយស្របច្បាប់នេះ ដែលត្រូវចំណាយអស់ ៦០០ដុល្លារអាមេរិកក្នុងម្នាក់ វាថ្លៃខ្លាំងណាស់សំរាប់ពលករភាគច្រើន ។

**តារាង ២.៣: ចំនួនពលករចំណាកស្រុកកម្ពុជាបញ្ជូនចេញជាផ្លូវការទៅក្រៅប្រទេស តាំងពីឆ្នាំ១៩៩៨**

| | ម៉ាឡេស៊ី | | | កូរ៉េខាងត្បូង | | | ថៃ | | | សរុប | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | សរុប | ប្រុស | ស្រី | សរុប | ប្រុស | ស្រី | សរុប | ប្រុស | ស្រី | សរុប | ប្រុស | ស្រី |
| ១៩៩៨ | 120 | 0 | 120 | .. | .. | .. | .. | .. | .. | 120 | 0 | 120 |
| ១៩៩៩ | 86 | 0 | 86 | .. | .. | .. | .. | .. | .. | 86 | 0 | 86 |
| ២០០០ | 502 | 307 | 195 | .. | .. | .. | .. | .. | .. | 502 | 307 | 195 |
| ២០០១ | 846 | 342 | 504 | .. | .. | .. | .. | .. | .. | 846 | 342 | 504 |
| ២០០២ | 1,049 | 246 | 803 | .. | .. | .. | .. | .. | .. | 1,049 | 246 | 803 |
| ២០០៣ | 573 | 73 | 500 | 756 | 638 | 118 | .. | .. | .. | 1,329 | 711 | 618 |
| ២០០៤ | 809 | 105 | 704 | 675 | 519 | 155 | .. | .. | .. | 1,483 | 624 | 859 |
| ២០០៥ | 1,776 | 467 | 1,309 | 468 | 432 | 36 | .. | .. | .. | 2,244 | 899 | 1,345 |
| ២០០៦ | 1,690 | 231 | 1,459 | 1,501 | 1,341 | 160 | 445 | 219 | 226 | 3,636 | 1,791 | 1,845 |
| ២០០៧ | 3,081 | 174 | 2,907 | 584 | 499 | 85 | 5,669 | 3,913 | 1,756 | 9,334 | 4,586 | 4,748 |
| សរុប | 10,532 | 1,945 | 8,587 | 3,984 | 3,429 | 554 | 6,114 | 4,132 | 1,982 | 20,630 | 9,506 | 11,123 |

*ប្រភព: ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (ស្ថិតិផ្លូវការ)*

កន្លែងផ្សេងៗទៀតនៅក្នុងតំបន់ ទេសន្តរប្រវេសន៍កំលាំងពលកម្ម មានច្រើនគួរកត់សម្គាល់ ហើយប្រាក់ផ្ញើទៅផ្ទះ និងប្រាក់ប៉ះប៉ូវផ្សេងៗ ក៏ច្រើនគួរសមដែរ ។ យោងតាម Dang (2007) សព្វថ្ងៃ មានពលករវៀតណាមប្រហែល ៤០០.០០០នាក់ កំពុងធ្វើការក្នុង ៤០ប្រទេស និងផ្ញើប្រាក់ទៅផ្ទះប្រហែល ២ពាន់លានដុល្លារអាមេរិកក្នុងមួយឆ្នាំ ។ ប៉ុន្តែ របាយការណ៍ធនាគារពិភពលោក (២០០៧) បានឱ្យដឹងថា ប្រាក់ផ្ញើទៅផ្ទះមានចំនួនច្រើនជាងនេះជាខ្លាំង ដូចមានបង្ហាញក្នុងតារាង ២.៤ ។

ថៃមានពលករចំណាកស្រុក ១៦០.០០០នាក់កំពុងធ្វើការនៅក្រៅប្រទេស និងទទួលបានប្រាក់ផ្ញើទៅផ្ទះ ចំនួន ១,៦ពាន់លានដុល្លារអាមេរិកក្នុងមួយឆ្នាំ មុនពេលវាធ្លាក់ចុះមកត្រឹម ១,២ពាន់លានដុល្លារអាមេរិកក្នុងឆ្នាំ២០០៥ ។ តួលេខនេះ ក៏មានចុះក្នុងបទបង្ហាញរបស់ Paitoonpong and Chamlamwong (2007) ដែរ ។ ទេសន្តរប្រវេសន៍កំលាំងពលកម្ម គឺជាប្រភពប្រាក់ចំណូលចំបងសំរាប់ប្រទេសហ្វីលីពីន (ប្រមាណ ៧% នៃ ផសស) និងបង់ក្លាដែស (ប្រហែល ១៣,៧% នៃ ផសស) ។ យោងតាមរបាយការណ៍ធនាគារពិភពលោក (២០០៧) ប្រទេសកម្ពុជាក៏ទទួលបានផ្ញើប្រាក់ទៅផ្ទះ និងប្រាក់ប៉ះប៉ូវផ្សេងៗរបស់ពលករ ចំនួន ២០០លានដុល្លារក្នុងមួយឆ្នាំ ។

សេចក្តីដូចខាងលើ មិនមែនជាការជំរុញឱ្យកម្ពុជាបង្កើតជំនាញឯកទេស ឬពឹងផ្អែកលើការបញ្ជូនពលករទៅក្រៅប្រទេសសំរាប់ធ្វើការអភិវឌ្ឍរយៈពេលវែងនោះទេ ប៉ុន្តែគ្រាន់តែចង់បញ្ជាក់ថា ប្រសិនបើគ្រប់គ្រងបានល្អ ពលករទៅធ្វើការនៅក្រៅប្រទេស អាចជួយកាត់បន្ថយសំពាធប្រជាសាស្ត្រក្នុងរយៈពេលមធ្យម ខណៈដែលការបង្កើតការងារនៅក្នុងប្រទេស ដើរមិនទាន់កំណើនយ៉ាងលឿននៃកំលាំងពលកម្មដល់ ២៥០.០០០នាក់ក្នុងមួយឆ្នាំ ធៀបនឹងចំនួនការងារ ៣៥០.០០០កន្លែងនៅពេលបច្ចុប្បន្នក្នុងឧស្សាហកម្មកាត់ដេរ ដែលជាវិស័យផ្តល់ការងារបានច្រើនជាងគេនៅកម្ពុជា ។ ឧស្សាហកម្មនេះ ទំនងមិនអាចផ្តល់ការងារបានច្រើនខ្លាំងទៀតទេ ពីព្រោះវាកំពុងធ្លាក់ចុះវិញដោយសារវិបត្តិហិរញ្ញវត្ថុសាកល និងការប្រកួតប្រជែងខ្លាំងពីប្រទេសចិន និងប្រទេសដទៃទៀត ដោយសារលក្ខខណ្ឌសម្បទានជាកូតាទីផ្សារដែលផ្តល់ដោយសហរដ្ឋអាមេរិក និងសហគមន៍អឺរ៉ុប ត្រូវរស់សុពលភាពនៅឆ្នាំ២០០៨ ។

**តារាង ២.៤: ប្រាក់ផ្ញើទៅផ្ទះរបស់ពលករ**

| ប្រទេស | 1996 | 1998 | 2000 | 2002 | 2003 | 2004 | 2005 |
|---|---|---|---|---|---|---|---|
| | លានដុល្លារអាមេរិក | | | | | | |
| ហ្វីលីពីន | 4,875 | 5,130 | 6,212 | 9,735 | 10,243 | 11,471 | 13,566 |
| បង់ក្លាដែស | 1,345 | 1,606 | 1,968 | 2,858 | 3,192 | 3,584 | 4,251 |
| វៀតណាម | .. | .. | .. | 2,714 | 2,700 | 3,200 | 4,000 |
| ថៃ | 1,806 | 1,424 | 1,697 | 1,380 | 1,607 | 1,622 | 1,187 |
| កម្ពុជា | 12 | 120 | 121 | 140 | 138 | 177 | 200 |
| ឡាវ | 45 | 50 | 1 | 1 | 1 | 1 | 1 |
| | គិតជា % នៃ ផសស | | | | | | |
| ហ្វីលីពីន | 5.88 | 7.87 | 8.24 | 12.75 | 12.66 | 12.65 | 13.70 |
| បង់ក្លាដែស | 3.31 | 3.64 | 4.18 | 6.02 | 6.16 | 6.32 | 7.08 |
| វៀតណាម | .. | .. | .. | 7.74 | 6.81 | 7.08 | 7.63 |
| ថៃ | 0.99 | 1.27 | 1.38 | 1.09 | 1.12 | 1.00 | 0.67 |
| កម្ពុជា | 0.34 | 3.85 | 3.31 | 3.27 | 3.01 | 3.37 | 3.23 |
| ឡាវ | 2.40 | 3.91 | 0.06 | 0.05 | 0.05 | 0.04 | 0.03 |

*ប្រភព: សូចនាករអភិវឌ្ឍន៍សាកលលោកឆ្នាំ2007, ធនាគារពិភពលោក*

# ជំពូក ៣ ករណីសិក្សា

## ៣.១. វិធីសាស្ត្រស្រាវជ្រាវ

### ៣.១.១. ការជ្រើសរើសសហគមន៍សំរាប់ការសិក្សា

ការចុះសិក្សាដល់កន្លែងបានធ្វើឡើងពីថ្ងៃទី ១១ ដល់ ១៣ សីហា ២០០៧ ដោយបានចុះទៅដល់សហគមន៍ជាច្រើនក្នុង ៤ខេត្ត ដែលគេរាយការណ៍ថា មានប្រជាជនធ្វើចំណាកស្រុកចេញទៅក្រៅប្រទេសច្រើន គឺមានខេត្តបាត់ដំបង បន្ទាយមានជ័យ សៀមរាប និងកំពង់ធំ ។ នៅលើកដំបូងនេះ បានចុះសិក្សានៅ ១៥ភូមិ និងបានធ្វើសម្ភាសន៍ជាមួយអាជ្ញាធរឃុំ មេភូមិ និងអ្នកភូមិ ដើម្បីទទួលបានព័ត៌មានមូលដ្ឋានស្តីពីការធ្វើចំណាកស្រុកទៅក្រៅប្រទេស ។ បន្ទាប់ពីដំណើរការចុះអង្កេតត្រៀមនេះ យើងបានជ្រើសយក ៦ឃុំដែលមានបញ្ជូនពលករចេញទៅធ្វើការក្រៅប្រទេស ដើម្បីធ្វើការសិក្សា ។ លក្ខណៈពាក់ព័ន្ធសំខាន់ៗទាំងឡាយ មានចុះនៅក្នុងតារាង ៣.១ ហើយទីតាំងឃុំទាំង ៦ មានបង្ហាញនៅក្នុងក្រាហ្វិក ៣.១ ។

**តារាង ៣.១: ភូមិ និងលក្ខណៈពាក់ព័ន្ធសំខាន់ៗដែលបានជ្រើសរើសសំរាប់តំបន់សិក្សា**

| ភូមិ | ចំនួនគ្រួសារសរុប | %ប៉ាន់ស្មាននៃគ្រួសារមានសមាជិកធ្វើចំណាកស្រុក | គោលដៅរបស់ពលករចំណាកស្រុក | អត្តសញ្ញាណផ្សេងៗ |
|---|---|---|---|---|
| ១. ស្រម៉មាស ឃុំព្រៃស្វាយ ស្រុកមោងឫស្សី ខេត្តបាត់ដំបង | 330 | >30% | ម៉ាឡេស៊ី | ក្រុមជនជាតិភាគតិច អ៊ិស្លាម |
| ២. ក្រសាំង ឃុំតាម៉ឺន ស្រុកថ្មគោល ខេត្តបាត់ដំបង | 250 | >30% | ថៃ | បូកចូលក្នុង MOPS ធ្វើចំណាកស្រុកទៅថៃ |
| ៣. គោកធ្នង់ ឃុំអូរប្រាសាទ ស្រុកមង្គលបុរី ខេត្តបន្ទាយមានជ័យ | 105 | >70% | ថៃ | ជនជាតិភាគតិចឡាវ បានលទ្ធផលល្អដោយធ្វើចំណាកស្រុកទៅធ្វើការនៅថៃ |
| ៤. រំដួល ឃុំភ្នំលៀប ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ | 280 | >50% | ថៃ | ជីវភាពក្រីក្រ ទោះជាធ្វើចំណាកស្រុកទៅធ្វើការនៅថៃ |
| ៥. សៀមពាយ ឃុំព្រះដំរី ស្រុកស្ទោង ខេត្តកំពង់ធំ | 185 | >40% | ថៃ | នៅឆ្ងាយពីប្រទេសថៃ និងឆ្ងាយពីផ្លូវជាតិ |
| ៦. ខ្ទយ ឃុំតាកោ ស្រុកកំពង់លាវ ខេត្តព្រៃវែង | 110 | >50% | ថៃ | ខេត្តនៅឆ្ងាយពីថៃ ក្បែររាជធានីភ្នំពេញ និងវៀតណាម |

*ប្រភព: ការចុះសិក្សាដល់កន្លែងរបស់ CDRI ពីថ្ងៃទី ១១-១៣ សីហា ២០០៧*

ក្រាហ្វិក ៣.១: ទីតាំងនៃភូមិទាំង ៦ ដែលបានជ្រើសរើសជាតំបន់សិក្សា



ដោយសារប្រទេសថៃ ជាគោលដៅធំជាងគេឆ្ងាយណាស់សំរាប់ពលករចំណាកស្រុកពីកម្ពុជា ដូច្នេះ យើងបានជ្រើសរើសភូមិចំនួន ៥ ដើម្បីសិក្សាពីចំណាកស្រុកទៅប្រទេសថៃ ។ ភូមិមួយ គឺភូមិស្រម៉មាសដែលមានជនចំណាកស្រុកយ៉ាងច្រើនទៅធ្វើការនៅប្រទេសម៉ាឡេស៊ី ត្រូវបានជ្រើសរើសសំរាប់គោលដៅនៃការសិក្សា ។

### ៣.១.២. ការធ្វើអង្កេតគ្រួសារ

នៅខែកញ្ញា និងតុលា ២០០៧ មានការចុះធ្វើអង្កេតមួយលើប្រជាជនចំនួន ៥២៦គ្រួសារ ដែលរស់នៅក្នុងភូមិទាំង ៦ ដែលបានជ្រើសរើស ។ គ្រួសារជាគំរូតាង ត្រូវបានជ្រើសរើសដោយចៃដន្យសំរាប់តំណាងឱ្យក្រុមទាំង ២ គឺគ្រួសារមានសមាជិកធ្វើចំណាកស្រុក និងគ្រួសារគ្មានសមាជិកធ្វើចំណាកស្រុក ។ សមាសភាពនៃក្រុមទាំងពីរនៅក្នុងគំរូតាង គឺដូចគ្នានឹងសមាសភាពនៃក្រុមទាំងពីរនៅក្នុងប្រជាជនសរុប ដូច្នេះ គំរូតាងសរុប អាចតំណាងឱ្យប្រជាជនសរុបបាន ។ នៅថ្ងៃទីមួយនៅក្នុងភូមិ ក្រុមអង្កេតបានសហការជាមួយអាជ្ញាធរមូលដ្ឋាន ដើរស្រង់ឈ្មោះគ្រួសារពីផ្ទះមួយទៅផ្ទះមួយ ដើម្បីបង្កើតបញ្ជីពីរនៃគ្រួសារទាំងពីរប្រភេទ ដូចបានពិព៌ណនាខាងលើ ។ ហេតុនេះនៅមុនពេលចាប់ធ្វើអង្កេត គេបានធ្វើបញ្ជីគ្រួសារទាំងពីរក្រុមនៅភូមិនីមួយៗរួចរាល់ហើយ ។ គេជ្រើសរើសដោយចៃដន្យ មកធ្វើសម្ភាសន៍ ប្រហែល ៥០% នៃគ្រួសារដែលមានសមាជិកធ្វើចំណាកស្រុក និងប្រហែល ៣០% ទៅ ៥០%នៃគ្រួសារដែលគ្មានសមាជិកធ្វើចំណាកស្រុក ។

ក្រុមអង្កេតដែលមានសមាជិក ៤នាក់ បានដំណើរការអង្កេតគ្រួសារ ។ សមាជិកម្នាក់ៗ បានសម្ភាស ៦គ្រួសារក្នុងមួយថ្ងៃ ។ សំរាប់ភូមិនីមួយៗ ការសម្ភាសនេះ ត្រូវប្រើពេល ៤ថ្ងៃ ដើម្បីបញ្ចប់អង្កេតគ្រួសារ ដូច្នេះ យើងសម្ភាសបានប្រហែល ១០០គ្រួសារក្នុងមួយភូមិ ។ សំរាប់ភូមិតូចៗ ដូចជា ភូមិគោកធ្នង់ និងភូមិខ្ទយ ដែលមានប្រជាជនតែប្រហែល ១០០គ្រួសារ គឺយើងបានធ្វើជំរឿនវិញ ។

អង្កេតគ្រួសារ ពិនិត្យជាសំខាន់លើៈ

- ទ្រព្យសម្បត្តិគ្រួសារ ប្រាក់ចំណូល និងចំណាយក្នុងគ្រួសារ
- លក្ខណៈសេដ្ឋកិច្ច-សង្គមកិច្ចនៃពលករចំណាកស្រុក
- ផលប្រយោជន៍ និងចំណាយសេដ្ឋកិច្ចនៃពលករចំណាកស្រុក
- ផលប៉ះពាល់លើសង្គមនៃការធ្វើចំណាកស្រុក
- ប្រាក់ផ្ញើទៅផ្ទះៈ ទំហំ យន្តការ និងផលប៉ះពាល់

ការរំលឹកមកវិញ ជាវិធីចំបងសំរាប់ប្រមូលព័ត៌មានក្នុងរយៈពេល ៥ឆ្នាំកន្លងមកនេះ ដោយគេសួរគ្រួសារប្រជាជនឱ្យប្រៀបធៀបស្ថានភាពរស់នៅរបស់ខ្លួននាពេលបច្ចុប្បន្នទៅនឹងមុនពេល និងក្រោយពេល ដែលសមាជិកគ្រួសារបានធ្វើចំណាកស្រុក ។

### ៣.១.៣. វិធីសាស្ត្រស្រាវជ្រាវបែបគុណភាព

*ការពិភាក្សាតាមក្រុមស្នូល (FGD)*

ក្នុងភូមិនីមួយៗ មានការពិភាក្សាតាមក្រុមស្នូលចំនួន ៣ ដែលចូលរួមដោយៈ

១. សមាជិក ៨រូបក្នុងចំណោមអ្នកភូមិមានចំណេះដឹង និងអាជ្ញាធរ ដើម្បីរំលឹកមកវិញនូវនិន្នាការក្នុងរយៈពេល ១០ឆ្នាំកន្លងទៅ និងដើម្បីប្រមូលព័ត៌មានពាក់ព័ន្ធនឹងភូមិទាំងមូល
២. សមាជិក ៨រូប តំណាងឱ្យគ្រួសារធូរធារដែលមានសមាជិកធ្វើចំណាកស្រុកបានជោគជ័យ
៣. សមាជិក ៨រូប តំណាងឱ្យគ្រួសារដែលមានសមាជិកធ្វើចំណាកស្រុក ប៉ុន្តែនៅតែមានជីវភាពក្រីក្រ

សមាជិកក្នុង FGD ត្រូវបានជ្រើសរើសដោយចៃដន្យពីក្នុងចំណោមអ្នកតំណាងគ្រួសារនានា ។ FGD និងការសម្ភាសអ្នកផ្តល់ព័ត៌មានសំខាន់ៗ ត្រូវចំណាយពេលពីរថ្ងៃ បន្ទាប់ពីការធ្វើអង្កេតគ្រួសារ ។

*ការសម្ភាសអ្នកផ្តល់ព័ត៌មានគន្លឹះ*

ការសម្ភាសស៊ីជម្រៅ បានធ្វើឡើងជាមួយអ្នកផ្តល់ព័ត៌មានគន្លឹះពាក់ព័ន្ធនឹងភូមិបានសិក្សា ក៏ដូចជាមន្ត្រីរាជការ ដៃគូអភិវឌ្ឍន៍ក្រៅប្រទេស និងបុគ្គលិក NGO ។ នៅកំរិតសហគមន៍ អ្នកផ្តល់ព័ត៌មានគន្លឹះ មានដូចតទៅៈ

- អ្នកចងការប្រាក់ និងឈ្មួញកណ្តាលផ្តល់សេវាផ្ទេរប្រាក់ផ្ញើទៅផ្ទះ
- NGOs ដែលសកម្មលើបញ្ហាពលករចំណាកស្រុកក្នុងមូលដ្ឋាន
- ក្រុមប្រឹក្សាឃុំ និងអាជ្ញាធរស្រុក

*ការសម្ភាសស៊ីជម្រៅជាមួយពលករចំណាកស្រុកដែលមកលេង/ត្រឡប់មកផ្ទះ*

គេរំពឹងថា ពលករចំណាកស្រុកមួយចំនួននឹងត្រឡប់មកផ្ទះនៅពេលបុណ្យភ្ជុំបិណ្ឌ ដែលជាពិធីបុណ្យសំខាន់ក្នុងពុទ្ធសាសនា និងត្រូវប្រារព្ធឡើងចាប់ពីថ្ងៃទី ១ ដល់ទី១៥ តុលាក្នុងឆ្នាំ២០០៧ ។ អ្នកសួរសម្ភាសន៍បានចុះទៅដល់ភូមិផ្ទាល់ និងរកបានពលករចំណាកស្រុកចំនួន ២០នាក់មកធ្វើសម្ភាសន៍ ។ បទសម្ភាសន៍ មានសួរពីបញ្ហាមួយចំនួន ដូចជា ការងារ និងស្ថានភាពរស់នៅ បទពិសោធន៍ការងារ ប្រាក់ចំណូល ជម្រើសគោលដៅត្រូវទៅ ហានិភ័យ ប្រាក់ផ្ញើទៅផ្ទះ និងគម្រោងទៅថ្ងៃអនាគត ។

## ៣.២. *របកគំហើញបានពីករណីសិក្សានៅសហគមន៍*

### ៣.២.១. អត្រាចំណាកស្រុកឆ្លងកាត់ព្រំដែននៅក្នុងភូមិសិក្សា

មានរបកគំហើញជាច្រើន ដែលគួរលើកមកបង្ហាញ ប៉ុន្តែយើងជឿជាក់ថា វិធីល្អបំផុតគឺត្រូវសង្ខេបជាតួលេខ ហើយទុកឱ្យតួលេខនោះវាបកស្រាយបញ្ជាក់តែម្តង ។ ទោះយ៉ាងនេះក្តី ក៏របាយការណ៍នេះ បានពិភាក្សាលើបញ្ហាច្រើនណាស់តាមតែអាចធ្វើបាន ។ ដោយសារភូមិសិក្សានីមួយៗ បានជ្រើសរើសឡើងយ៉ាងប្រយ័ត្នប្រយែង និងដោយមានគោលដៅ ដូច្នេះ គំរូតាងក្នុងអង្កេត គឺមានលក្ខណៈគ្រប់គ្រាន់សំរាប់តំណាងឱ្យភូមិទាំងមូល និងអនុក្រុមនានានៃប្រជាជនក្នុងភូមិ ។ គំរូតាងក្នុងភូមិនីមួយៗ មានទំហំធំរហូតដល់ ៣៣%-៨៤% (តារាង ៣.២) ។ ជារួម មាន ៥២៦គ្រួសារក្នុងចំណោមប្រជាជនសរុប ១១២៩គ្រួសារ ត្រូវបានធ្វើអង្កេត ហើយក្នុងនោះ មានគ្រួសារ ៥៥% មានសមាជិកធ្វើចំណាកស្រុកទៅថៃក្នុងអំឡុងពេល ៥ឆ្នាំចុងក្រោយ ។ ភូមិស្រម៉មាសដែលមានភាគរយគំរូតាងតិចជាងគេ (២៩%) ត្រូវបានជ្រើសរើស ដោយសារមានប្រជាជនធ្វើចំណាកស្រុកទៅម៉ាឡេស៊ី ។ ភូមិនេះជាភូមិចាម ឬភូមិអ្នកកាន់អ៊ិស្លាម ដែលមានលក្ខណៈប្រហាក់ប្រហែល និងងាយចុះសម្រុងជាមួយអ្នកកាន់អ៊ិស្លាមនៅប្រទេសម៉ាឡេស៊ី (សូមអានប្រអប់ ៣.១ សំរាប់ព័ត៌មានបន្ថែម) ។

សំរាប់ភូមិសៀមពាយវិញ គឺមានគ្រួសាររហូតដល់ ៨៣% ដែលមានបទពិសោធន៍ដូចគ្នា ។ ជាទូទៅ នៅភូមិនីមួយៗ អង្កេតបានរកឃើញពី ៣៩ ទៅ ៦៧គ្រួសារ ដែលមានសមាជិកធ្វើចំណាកស្រុកទៅថៃក្នុងអំឡុងពេល ៥ឆ្នាំចុងក្រោយ និងដែលតំណាងឱ្យប្រហែល ៥០% នៃប្រជាជនមានលក្ខណៈបែបនេះនៅក្នុងភូមិ ។

អង្កេតបានរកឃើញថា ពលករចំណាកស្រុកជាបុរស មាន ៦៥% ក្នុងចំណោមពលករ ចំណាកស្រុកសរុប ៥៣៨នាក់ក្នុង ៣១០គ្រួសារនៅភូមិសិក្សាទាំង ៦ ។ ភូមិភាគច្រើនមានលក្ខណៈស្រដៀងគ្នា បើគិតពីរបាយនៃពលករចំណាកស្រុកជាបុរស និងជានារី លើកលែងតែភូមិខ្នាយដែលមានពលករនារីតែ ៩នាក់ប៉ុណ្ណោះដែលធ្វើចំណាកស្រុក ។ ភូមិខ្នាយ ស្ថិតនៅឆ្ងាយពីប្រទេសថៃ ហើយពលករភាគច្រើនដែលចេញពីភូមិនេះ បានទៅធ្វើការក្នុងឧស្សាហកម្ម

នេសាទនៅតាមឆ្នេរសមុទ្រថៃ ។ ការចុះអង្កេតដល់កន្លែងនៅឯប្រទេសថៃ បង្ហាញថា ពលករទាំងអស់ដែលធ្វើការលើទូកនេសាទ សុទ្ធតែជាបុរស ។

**តារាង ៣.២: ចំនួនគ្រួសារនៅក្នុងភូមិសិក្សា និងនៅក្នុងគំរូតាង**

| ភូមិ | ចំនួនគ្រួសារនៅក្នុងភូមិ | ចំនួនគ្រួសារនៅក្នុងគំរូតាង | %គ្រួសារនៅក្នុងគំរូតាង | ចំនួនគ្រួសារមានសមាជិកធ្វើចំណាកស្រុកទៅក្រៅប្រទេសក្នុងអំឡុងពេល ៥ឆ្នាំមុន | %គ្រួសារមានសមាជិកធ្វើចំណាកស្រុកទៅក្រៅប្រទេសក្នុងអំឡុងពេល ៥ឆ្នាំមុន | ចំនួនគ្រួសារដែលមានសមាជិកចំណាកស្រុកនៅក្នុងប៉ាន់គំរូ |
|---|---|---|---|---|---|---|
| ស្រម៉មាស | 263 | 88 | 33% | 75 | 29% | 48 |
| ក្រសាំង | 209 | 90 | 43% | 150 | 72% | 49 |
| គោកធ្នង់ | 105 | 74 | 70% | 53 | 50% | 39 |
| រំដួល | 280 | 91 | 33% | 140 | 50% | 45 |
| សៀមពាយ | 162 | 91 | 56% | 135 | 83% | 67 |
| ខ្នាយ | 110 | 92 | 84% | 63 | 57% | 62 |
| សរុប | 1129 | 526 | 47% | 616 | 55% | 310 |

*ប្រភព: អង្កេតធ្វើឡើងដោយ CDRI ក្នុងអំឡុងខែកញ្ញា និងតុលា ២០០៧*

**ប្រអប់ ៣.១: ករណីបុគ្គលពលករចំណាកស្រុកម្នាក់ទៅម៉ាឡេស៊ី**

លោក យូ វីម៉ាស់ អាយុ ៤២ឆ្នាំ កាន់សាសនាអ៊ីស្លាម រស់នៅជាមួយក្រុមគ្រួសារមានសមាជិក ៦នាក់ នៅភូមិស្រម៉មាស ឃុំព្រៃស្វាយ ស្រុកមោងឫស្សី ខេត្តបាត់ដំបង ។ គាត់បានធ្វើចំណាកស្រុកទៅធ្វើការនៅម៉ាឡេស៊ី ។ គាត់សម្រេចចិត្តទៅធ្វើការនៅទីនោះ ដើម្បីបានប្រាក់បន្ថែមមកផ្គត់ផ្គង់គ្រួសារ ។

លោក វីម៉ាស់ មានគេណែនាំឱ្យស្គាល់បុរសម្នាក់ដែលគេថា អាចជួយគាត់ស្នើសុំលិខិតឆ្លងដែន ។ នៅពេលទទួលបានលិខិតឆ្លងដែនហើយ គាត់បានជិះយន្តហោះទៅម៉ាឡេស៊ីជាមួយនឹងអ្នកកាន់អ៊ីស្លាមខ្លះទៀតដែលមានសាច់ញាតិនៅម៉ាឡេស៊ី ហើយគាត់ស្នាក់នៅម៉ាឡេស៊ីដោយប្រើទិដ្ឋាការទេសចរណ៍មានរយៈពេល ១ខែ ។ ដើម្បីបានទៅដល់ទីនោះ លោក វីម៉ាស់ ចំណាយអស់ ៥០០ដុល្លារលើលិខិតឆ្លងដែន និងសំបុត្រយន្តហោះ ។

លោក វីម៉ាស់ រកបានការងារមួយមានប្រាក់កម្រៃ ១៥០ដុល្លារ/ខែ ។ ប៉ុន្តែគាត់ត្រូវរស់នៅក្នុងការភ័យខ្លាចត្រូវប៉ូលីសចាប់ខ្លួន ពីព្រោះគាត់មិនមានទិដ្ឋាការសំរាប់ធ្វើការទេ ។ គាត់ត្រូវប្រឈមនឹងការលំបាកយ៉ាងច្រើនដោយសារត្រូវពួនគេចពីប៉ូលីស និងត្រូវស្វែងរកការងារថ្មីនៅពេលការងារចាស់បានផុតកំណត់ ។ ទោះបីលំបាកដូច្នេះក្តី ក៏គាត់បានព្យាយាមស្នាក់នៅ និងធ្វើការនៅទីនោះបាន ១៣ខែ ។

លោក វីម៉ាស់ ប្រាប់ថា ប្រាក់កម្រៃសំរាប់ការងារដូចគ្នានៅកម្ពុជា ក៏មិនតិចជាងម៉ាឡេស៊ីប៉ុន្មានទេ ។ ប៉ុន្តែអ្វីដែលគាត់បានលើសពីការងារនៅកម្ពុជា គឺបទពិសោធន៍ក្នុងជីវិត និងជំនាញខាងភាសា ។ លោក វីម៉ាស់ រកចំណូលបានគ្រប់គ្រាន់ និងសន្សំប្រាក់បានសំរាប់ទិញគោបន្ថែមមកចិញ្ចឹម ដោយគាត់គិតថា គោទាំងនោះ នឹងជួយឱ្យគ្រួសារគាត់មានជីវភាពកាន់តែប្រសើរ ។ គាត់គ្មានបំណងទៅធ្វើការនៅម៉ាឡេស៊ីទៀតទេ ពីព្រោះចង់នៅជិត និងមើលថែទាំគ្រួសារ ។

លោក រីម៉ាស់ បានលើកមតិថា រដ្ឋាភិបាលគួរបង្កើតឱកាសការងារនៅកម្ពុជាបន្ថែមទៀត ដើម្បីកុំឱ្យមានលំហូរពលករទៅក្រៅប្រទេស ពីព្រោះលក្ខខណ្ឌការងារនៅកម្ពុជា វាល្អជាងនៅបរទេស ។ ប៉ុន្តែ រដ្ឋាភិបាលក៏គួរផ្តល់លក្ខខណ្ឌអំណោយផលដល់ពលករដែលចង់ធ្វើការនៅក្រៅប្រទេសដែរ ព្រមទាំងមានផ្តល់ការគាំទ្រ និងការណែនាំផ្នែកច្បាប់ដល់ពលករនៅអំឡុងពេលដែលពួកគេស្នាក់នៅឯក្រៅប្រទេស ។

*ប្រភព: បទសម្ភាសន៍នៅខែកញ្ញា ២០០៧*

**តារាង ៣.៣: ចំនួនពលករចំណាកស្រុកបែងចែកតាមភេទ នៅក្នុងគំរូតាងអង្កេត**

| ភូមិ | ចំនួនពលករចំណាកស្រុកនៅក្នុងគ្រួសារគំរូតាង | | | ភាគរយ | | |
|---|---|---|---|---|---|---|
| | ប្រុស | ស្រី | សរុប | ប្រុស | ស្រី | សរុប |
| ស្រម៉មាស | 34 | 33 | 67 | 51% | 49% | 100% |
| ក្រសាំង | 62 | 43 | 105 | 59% | 41% | 100% |
| គោកធ្នង់ | 33 | 38 | 71 | 46% | 54% | 100% |
| រំដួល | 53 | 26 | 79 | 67% | 33% | 100% |
| សៀមពាយ | 87 | 40 | 127 | 69% | 31% | 100% |
| ខ្នុយ | 80 | 9 | 89 | 90% | 10% | 100% |
| សរុប | 349 | 189 | 538 | 65% | 35% | 100% |

*ប្រភព: អង្កេតធ្វើឡើងដោយ CDRI ក្នុងអំឡុងខែកញ្ញា និងតុលា ២០០៧*

### ៣.២.២. កត្តាពាក់ព័ន្ធបង្កចំណាកស្រុក

ការពិភាក្សាតាមក្រុមស្នូលនៅភូមិទាំងអស់ បានបង្ហាញពីហេតុផលដែលជំរុញឱ្យប្រជាជនធ្វើចំណាកស្រុក ឬហ៊ានប្រថុយជីវិតលួចចូលទៅក្នុងប្រទេសជិតខាងដោយខុសច្បាប់ ។ ជាទូទៅ ពួកគេបានលើកពីភាពក្រីក្រ និងកង្វះសកម្មភាពបង្កើតប្រាក់ចំណូលនៅក្នុងភូមិ នៅតំបន់ជិតៗភូមិ ឬនៅតំបន់ឯទៀតក្នុងប្រទេសកម្ពុជា ថាជាហេតុផលចំបងនៃការធ្វើចំណាកស្រុកទៅធ្វើការនៅថៃ ។ ពួកគេបានបញ្ជាក់ពីចំណូលចិត្តធ្វើការនៅកម្ពុជាជាង ដោយអះអាងថាសុខចិត្តទទួលយកកម្រៃទាបជាងប្រហែល ២០%-៣០%(កម្រៃប្រចាំថ្ងៃ) ប្រសិនបើអាចមានការងារធ្វើនៅជិតៗផ្ទះ ។ ប៉ុន្តែនៅភូមិសៀមពាយ ហាក់ដូចមានហេតុផលខុសប្លែងពីគេ ។ អ្នកភូមិជាច្រើនបានបាត់បង់ប្រាក់យ៉ាងច្រើននៅក្នុងក្រុមសន្សំប្រាក់បោកប្រាស់មួយ ។ ការប្រថុយទៅរកប្រាក់នៅថៃ គឺជាច្រកចុងក្រោយរបស់ពួកគេ ហើយនៅពេលមានមនុស្សមួយចំនួនទទួលបានជោគជ័យ ប្រជាជនជាច្រើននៅក្នុងភូមិក៏ធ្វើចំណាកស្រុកទៅដែរ ។

ជាទូទៅ គ្រួសារដែលមានសមាជិកធ្វើចំណាកស្រុក តែងធ្វើស្រែចំការតិចជាងគេ ។ អង្កេតរកឃើញថា នៅ ៥ភូមិក្នុងចំណោមភូមិទាំង ៦ ចំនួនភាគរយនៃគ្រួសារគ្មានសមាជិកចំណាកស្រុក ដែលធ្វើស្រែបានគ្រប់គ្រាន់សំរាប់ការប្រើប្រាស់ក្នុងគ្រួសារ គឺមានកំរិតខ្ពស់ជាងគ្រួសារដែលមានសមាជិកធ្វើចំណាកស្រុក ។ ភាពខុសគ្នាខ្លាំងបំផុតបានពិនិត្យឃើញនៅភូមិរំដួល ដែលជាភូមិក្រីក្រជាងគេក្នុងចំណោមភូមិបានសិក្សា (ក្រាហ្វិក ៣.២) ។ អ្នកចូលរួមនៅក្នុងក្រុមពិភាក្សាស្នូល និងការសម្ភាសពាក់កណ្តាលរៀបរយជាមួយអ្នកផ្តល់ព័ត៌មានគន្លឹះ បានបង្ហាញជាទូទៅថាផលិតភាពនៃការធ្វើស្រែនៅក្នុងភូមិ មានកំរិតទាបណាស់ (0,៥ ទៅ ២តោនក្នុងមួយហិកតា) ដោយសារកង្វះប្រព័ន្ធធារាសាស្ត្រ និងជី ព្រមទាំងការពឹងផ្អែកខ្លាំងទៅលើទឹកភ្លៀង ហើយប្រជាជនក៏មិនអាចរកការងារធ្វើបានក្នុងរយៈពេលជាច្រើនខែក្នុងមួយឆ្នាំៗ ។

**ក្រាហ្វិក ៣.២: ភាគរយគ្រួសារមានផលស្រូវផលិតខ្លួនឯងគ្រប់គ្រាន់សំរាប់បរិភោគ**




*ប្រភព: អង្កេតធ្វើឡើងដោយ CDRI ក្នុងអំឡុងខែកញ្ញា និងតុលា ឆ្នាំ២០០៧*

កត្តាទាក់ទាញ ក៏មានមួយដែរ ។ នៅអំឡុងពេលសិក្សា ប្រាក់កម្រៃជាមធ្យមសំរាប់ការលក់កំលាំងពលកម្មរបស់អ្នកភូមិ គឺ ១,៥-២ដុល្លារ ប៉ុន្តែការងារស្រដៀងគ្នានេះ នៅថៃ ផ្តល់កម្រៃ ៣-៦ដុល្លារ និងនៅម៉ាឡេស៊ី ៤-៩ដុល្លារ (តារាង ៣.៤) ។ ការងារនៅថៃ ប៉ុន្តែនៅជិតព្រំដែនថៃ-ខ្មែរ បានចំណូលទាបជាងគេ គឺតិចជាង ៣ដុល្លារក្នុងមួយថ្ងៃ និងមានការប្រែប្រួលតិចបំផុត (គំលាតស្តង់ដារតិចជាង ១ដុល្លារ) ។ ករណីជាក់ស្តែងមានបង្ហាញនៅក្នុងប្រអប់ ៣.២ ។ ប្រាក់ខែបានមកពីការងារកសិកម្មនៅទីនោះ មានជាមធ្យមត្រឹមតែ ៧០ដុល្លារ គឺស្មើគ្នានឹងប្រាក់ខែជាមធ្យមរបស់ពលកររោងចក្រកាត់ដេរនៅរាជធានីភ្នំពេញ ។ បញ្ហាចោទ គឺឧស្សាហកម្មកាត់ដេរទាំងមូលនៅកម្ពុជា អាចផ្តល់ការងារដល់ពលករតែ ៣៥០.០០០នាក់ប៉ុណ្ណោះ ខណៈដែលមានយុវជន ២៥០.០០០នាក់បន្ថែមទៀតចូលទៅរកការងារក្នុងទីផ្សារពលកម្ម ជារៀងរាល់ឆ្នាំ ។

**ប្រអប់ ៣.២: ករណីបុគ្គលពលករជាយុវនារីម្នាក់ធ្វើចំណាកស្រុកទៅថៃ**

យុវនារី ចន្ថា អាយុ ១៩ឆ្នាំ មកពីភូមិរំដួល ឃុំភ្នំលាភ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ បានធំពេញវ័យក្នុងគ្រួសារក្រីក្រមួយមានសមាជិក ៤នាក់ ។ នាងគ្មានការងារធ្វើទេ ហើយក៏សម្រេចចិត្តទៅប្រទេសថៃរកការងារធ្វើ បន្ទាប់ពីបានឮតគ្នាពីអ្នកភូមិដទៃទៀតថា មានការងារប្រាក់ខែច្រើននៅថៃ ។ នាងទាក់ទងមេខ្យល់ម្នាក់ដែលធ្លាប់នាំអ្នកភូមិពីរបីនាក់ទៅថៃរួចហើយដោយឆ្លងកាត់តាមច្រកទ្វារបឹងត្រកួន ។ ដើម្បីនាំទៅដល់កន្លែងធ្វើការនៅខេត្តច័ន្ទបុរី មេខ្យល់ទារឱ្យនាងបង់ប្រាក់ ២៥០.០០០រៀល (ប្រហែល ៦០ដុល្លារ) ។ គ្រួសារចន្ថា មិនមានលទ្ធភាពសន្សំប្រាក់បានច្រើនបែបនេះទេ ដូច្នេះត្រូវបង្ខំចិត្តខ្ចីប្រាក់ពីអ្នកចងការប្រាក់ ។ ប្រាក់ ២៥០.០០០រៀល ដែលបង់ឱ្យមេខ្យល់ដើម្បីបានទៅធ្វើការនៅខេត្តច័ន្ទបុរី មិនទាន់បូកចំណាយអស់ទេ ។ ចន្ថា ត្រូវចំណាយ ៣០.០០០រៀលថែមទៀតលើការធ្វើដំណើរពីផ្ទះនាងទៅច្រកទ្វារបឹងត្រកួន ដែលត្រូវចំណាយពេលអស់ ៤ម៉ោង ។ ពេលទៅដល់បឹងត្រកួន មេខ្យល់បានទូរស័ព្ទទៅមេខ្យល់ម្នាក់ទៀតនៅថៃ ឱ្យមកទទួលចន្ថា និងអ្នកភូមិដទៃទៀត ដើម្បីនាំពួកគេទៅច័ន្ទបុរី ។

ចន្ថា រកប្រាក់បាន ១៤.០០០រៀលក្នុងមួយថ្ងៃ ហើយនាងចំណាយតែ ២៥០០រៀលប៉ុណ្ណោះក្នុងមួយថ្ងៃ ។ ចន្ថាធ្វើការហត់នឿយណាស់ ប៉ុន្តែក៏រកបានប្រាក់ច្រើនដែរ ។ នាងរំពឹងថា អាចសន្សំបាន ១៧២.៥០០រៀលក្នុងមួយខែ ។

ជាមួយនឹងប្រាក់សន្សំនេះ នាងនឹងអាចសងបំណុល និងផ្ញើប្រាក់ខ្លះទៅផ្ទះ ដើម្បីជួយសំរាលជីវភាពគ្រួសារ ។ នៅថ្ងៃទី១៥ ដែលនាងបានធ្វើការនៅថៃ ការរំពឹងទុក និងសេចក្ដីសង្ឃឹមបានរលាយអស់នៅពេលដែលរូបនាង និងពលករកម្ពុជាផងគ្នាងទៀត ត្រូវតម្រួតថៃចាប់ខ្លួន និងបញ្ជូនទៅដាក់ពន្ធនាគារ ។ ផ្ទុយពីការរំពឹងទុក ចន្ថាពុំអាចទាំងរកប្រាក់បានគ្រប់ថ្លៃធ្វើដំណើរ និងប្រាក់កម្រៃបង់ទៅឱ្យមេខ្យល់នោះផងទេ ។ នាងជាប់ឃុំនៅក្នុងបន្ទប់មួយមានដាក់អ្នកជាប់ឃុំជាច្រើននាក់ប្រជ្រៀតគ្នា និងទទួលអាហារមានគុណភាព ដូចបាយជ្រូក ។ បន្ទប់ឃុំដាក់ពលករចំណាកស្រុកខុសច្បាប់ពេញណែនពេក មិនអាចដើរចុះឡើងបានទេ ។ នៅថ្ងៃទីបីនៃការជាប់ឃុំ តម្រួតថៃបានបញ្ជូននាង និងពលករខុសច្បាប់ដទៃទៀតមកកម្ពុជាវិញតាមច្រកព្រំដែនប៉ោយប៉ែត ។

ពលករមួយចំនួនមកពីភូមិរបស់នាង ត្រូវម្ចាស់ចំការនៅថៃបោកប្រាស់ ហើយម្ចាស់ចំការទាំងនេះ បានឆ្លៀតយកចំណេញពីការស្នាក់នៅខុសច្បាប់របស់ពលករ ដោយមិនបង់ប្រាក់កម្រៃពលកម្មឱ្យ និងគំរាមថា បើពលករហ៊ានតវ៉ា គេនឹងប្ដឹងទៅតម្រួតថៃ ។ ចន្ថា បានប្រាប់ថា ប្រសិនបើមានការងារទៀងទាត់នៅក្នុងសហគមន៍របស់នាង ឬនៅជិតភូមិនាង បើទោះជាទទួលបានកម្រៃតែ ៥០០០រៀលក្នុងមួយថ្ងៃក៏ដោយ ក៏នាងសុខចិត្តធ្វើដែរ ពីព្រោះនាងអាចស្នាក់នៅជាមួយក្រុមគ្រួសារដោយគ្មានការភ័យខ្លាច ឬការគំរាមកំហែងអ្វីឡើយ ។ ក្រៅពីនេះ ចន្ថាចង់រៀនពីបច្ចេកទេសធ្វើស្រែផ្ដល់ផលច្រើន ដើម្បីជួយគ្រួសារឱ្យដាំដុះបានទិន្នផលខ្ពស់ ។

បើទោះជាធ្លាប់ជួបប្រទះនឹងព្រឹត្តិការណ៍គួរឱ្យភ័យខ្លាច ក៏ ចន្ថា យល់ថា ការធ្វើការងារនៅថៃ អាចឱ្យពលករខ្មែររកប្រាក់បានច្រើនសំរាប់ជួយលើកស្ទួយគ្រួសារឱ្យរួចផុតពីភាពក្រីក្រខ្លាំង ហើយអាចរៀនជំនាញថ្មីៗ និងបានស្គាល់ទីកន្លែងផ្សេងៗនៅក្រៅប្រទេស ។ ប៉ុន្តែការរំពឹងទុកទាំងនេះ ត្រូវចងភ្ជាប់នឹងលក្ខខណ្ឌនៃពលករមានច្បាប់ការពារយ៉ាងពេញលេញ ពីព្រោះពលករខុសច្បាប់តែងត្រូវនិយោជកបរទេសកេញប្រវ័ញ្ចជានិច្ច ។

*ប្រភព: បទសម្ភាសន៍នៅខែកញ្ញា ២០០៧*

**តារាង ៣.៤: ប្រាក់ចំណូលប្រចាំថ្ងៃ និងប្រចាំខែ នៅពេលធ្វើចំណាកស្រុកចុងក្រោយ ក្នុងអំឡុង ៥ឆ្នាំមុន**

| ប្រទេសគោលដៅ | ប្រភេទការងារ | ចំនួន | ប្រាក់កម្រៃប្រចាំថ្ងៃ(ដុល្លារ) | | ប្រាក់កម្រៃប្រចាំខែ (ដុល្លារ) | |
|---|---|---|---|---|---|---|
| | | | មធ្យម | គំលាតស្តង់ដារ | មធ្យម | គំលាតស្តង់ដារ |
| នៅក្នុងប្រទេសថៃ | សំណង់ | 115 | 4.59 | 1.12 | 116 | 38 |
| | កសិកម្ម | 27 | 3.88 | 1.47 | 101 | 42 |
| | នេសាទ | 24 | 3.80 | 1.69 | 114 | 51 |
| | ការងារផ្ទះ | 22 | 3.73 | 1.51 | 109 | 44 |
| | រោងចក្រ | 14 | 4.25 | 1.47 | 120 | 38 |
| | ផ្សេងៗ | 21 | 4.90 | 3.73 | 131 | 110 |
| នៅតាមព្រំដែនថៃ-ខ្មែរ | កសិកម្ម | 183 | 2.79 | 0.83 | 70 | 43 |
| | នេសាទ | 8 | 2.89 | 0.67 | 169 | 89 |
| នៅប្រទេសម៉ាឡេស៊ី | សំណង់ | 15 | 8.88 | 2.28 | 197 | 75 |
| | កសិកម្ម | 7 | 6.22 | 1.61 | 121 | 62 |
| | ការងារផ្ទះ | 6 | 3.47 | 1.55 | 96 | 59 |
| | រោងចក្រ | 22 | 5.79 | 1.42 | 135 | 50 |
| | ផ្សេងៗ | 6 | 6.38 | 2.60 | 137 | 40 |

*ប្រភព: អង្កេតធ្វើឡើងដោយ CDRI នាខែកញ្ញា និងតុលា ២០០៧*

### ៣.២.៣. ប្រទេសគោលដៅនៃពលករចំណាកស្រុកនៅក្នុងភូមិសិក្សា

គេបានជ្រើសយក ៥ភូមិក្នុងចំណោម ៦ភូមិ ដើម្បីសំដៅឆ្លុះបញ្ចាំងពីក្រុមដែលធ្វើដំណើរចូលជ្រៅទៅក្នុងប្រទេសថៃ និងក្រុមចូលទៅថៃដែរ ប៉ុន្តែនៅជិតៗព្រំដែនដែលភាគច្រើនធ្វើការងារកសិកម្ម ។ ភូមិចំនួន ៣ (គោកធ្លង់ រំដួល និងខ្នុយ) ត្រូវបានជ្រើសរើសសំរាប់ករណីចូលជ្រៅ ហើយភូមិក្រសាំង និងភូមិសៀមពាយសំរាប់ករណីចូលជិតៗ ។ ប៉ុន្តែសូម្បីភូមិដែលមានជនចំណាកស្រុកភាគច្រើនទៅធ្វើការជិតៗព្រំដែន ក៏នៅតែមានពលករច្រើននាក់ដែរ ដែលធ្វើដំណើរចូលជ្រៅទៅក្នុងប្រទេសថៃ ។

ភូមិគោកធ្លង់នៅខេត្តបន្ទាយមានជ័យ មានប្រវត្តិគួរឱ្យចាប់អារម្មណ៍ ។ អ្នកភូមិភាគច្រើនជាជនជាតិឡាវ ដែលបានមករស់នៅទីនោះជាច្រើនជំនាន់ហើយ ។ អ្នកភូមិអាចនិយាយភាសាថៃបានល្អ គឺដូចពួកឡាវភាគច្រើនដែរ ។ ដោយមានចំណុចអំណោយផលនេះ ពួកគេមានបទពិសោធន៍ធ្វើការរយៈពេលវែងនៅថៃ ដូចជា ការងារផ្ទះជាដើម ។ ជាក់ស្តែង ភូមិនេះមានប្រជាជនច្រើនជាងគេដែលធ្វើចំណាកស្រុកទៅធ្វើជាអ្នកបម្រើតាមផ្ទះ ។ ដោយសារពួកគេអាចនិយាយថៃបានស្ទាត់ ពួកគេមិនងាយរងគ្រោះទេ ហើយបានជោគជ័យច្រើនក្នុងការធ្វើចំណាកស្រុក ។ ភូមិនេះ ប្រហែលធូរធារជាងគេក្នុងចំណោមភូមិទាំង ៦ ដែលបានសិក្សា ។

**តារាង ៣.៥: ប្រទេសគោលដៅធំៗរបស់ពលករចំណាកស្រុក (ការធ្វើចំណាកស្រុកចុងក្រោយ ក្នុងអំឡុងពេល ៥ឆ្នាំមុន)**

| ភូមិ | ចំនួន | | | | ភាគរយ | | | |
|---|---|---|---|---|---|---|---|---|
| | នៅក្នុងប្រទេសថៃ | នៅព្រំដែនថៃ | នៅម៉ាឡេស៊ី | សរុប | នៅក្នុងប្រទេសថៃ | នៅព្រំដែនថៃ | នៅម៉ាឡេស៊ី | សរុប |
| ស្រម៉មាស | 3 | 0 | 57 | 60 | 5 | 0 | 95 | 100 |
| ក្រសាំង | 24 | 75 | 3 | 102 | 24 | 74 | 3 | 100 |
| គោកធ្លង់ | 66 | 1 | 0 | 67 | 99 | 1 | 0 | 100 |
| រំដួល | 71 | 2 | 0 | 73 | 97 | 3 | 0 | 100 |
| សៀមពាយ | 18 | 108 | 0 | 126 | 14 | 86 | 0 | 100 |
| ខ្នុយ | 81 | 4 | 0 | 85 | 95 | 5 | 0 | 100 |
| សរុប | 263 | 190 | 60 | 513 | 51 | 37 | 12 | 100 |

*ប្រភព: អង្កេតធ្វើឡើងដោយ CDRI នៅខែកញ្ញា និងតុលា ២០០៧*

### ៣.២.៤. ប្រភេទការងាររបស់ពលករចំណាកស្រុក

ពលករចំណាកស្រុកភាគច្រើន ស៊ីឈ្នួលធ្វើចំការ ឬការងារសំណង់ ។ ការនេសាទ គឺជាការងារចំបងទីបីសំរាប់ពលករចំណាកស្រុក ហើយរោងចក្រនៅថៃ ក៏ផ្តល់ការងារយ៉ាងច្រើនដែរ ។ បុរស និងនារី មានច្រើនប្រហែលគ្នាក្នុងប្រភេទការងារ ដូចជា សំណង់ កសិកម្ម កម្មន្តសាល និងការងារផ្សេងៗទៀត ប៉ុន្តែគេឃើញមានបុរសភាគច្រើនធ្វើការងារនេសាទ និងនារីភាគច្រើនធ្វើការងារផ្ទះ (តារាង ៣.៦) ។ យោងតាម FGD និងការសម្ភាសអ្នកផ្តល់ព័ត៌មានគន្លឹះ ពលករចំណាកស្រុកទទួលធ្វើការងារគ្រប់ប្រភេទ រួមទាំងការភ្ជួរស្រែ ការដាំអំពៅនិងប្រមូលផលការដាំដើមឈើ ការធ្វើការតាមភោជនីយដ្ឋាន ការដាំកៅស៊ូ និងការចិញ្ចឹមជ្រូក ។ គេទទួលស្គាល់ថា ការងារទាំងនោះភាគច្រើនជាការងារ 3D (មានលក្ខខណ្ឌមិនល្អ គឺ កខ្វក់ លំបាក និងគ្រោះថ្នាក់) ។

ប្រភេទការងារ ប្រែប្រួលខុសគ្នាយ៉ាងខ្លាំងទៅតាមភូមិផ្សេងៗ ។ ប្រជាជននៅភូមិស្រម៉មាស ភាគច្រើនធ្វើចំណាកស្រុកទៅធ្វើការងារសំណង់ (ភាគច្រើនជាបុរស) និងការងាររោងចក្រ (ភាគច្រើនជានារី) នៅម៉ាឡេស៊ី ។ ពលករភាគច្រើនលើសលប់ពីភូមិក្រសាំង និងសៀមពាយ ទៅធ្វើការងារកសិកម្មនៅថៃ ហើយភាគច្រើននៅជិតៗព្រំដែន ។ ពលករភាគច្រើនមកពីភូមិខ្ទយ (ភាគច្រើនជាបុរស) ទៅធ្វើការក្នុងឧស្សាហកម្មនេសាទ ហើយពលករភាគច្រើនមកពីភូមិគោកធ្នង់ទៅធ្វើការខាងសំណង់ ។

**តារាង ៣.៦: ប្រភេទការងារក្នុងចំណាកស្រុកចុងក្រោយរបស់ពលករបុរស និងនារី**

| ភូមិ | | សំណង់ | កសិកម្ម | នេសាទ | ការងារផ្ទះ | រោងចក្រ | ផ្សេងៗ | សរុប |
|---|---|---|---|---|---|---|---|---|
| ស្រម៉មាស | ប្រុស | 16 | 4 | 0 | 1 | 6 | 5 | 32 |
| | ស្រី | 1 | 5 | 0 | 2 | 19 | 1 | 28 |
| | ទាំងពីរភេទ | 17 | 9 | 0 | 3 | 25 | 6 | 60 |
| ក្រសាំង | ប្រុស | 4 | 51 | 0 | 2 | 2 | 3 | 62 |
| | ស្រី | 0 | 34 | 0 | 4 | 0 | 2 | 40 |
| | ទាំងពីរភេទ | 4 | 85 | 0 | 6 | 2 | 5 | 102 |
| គោកធ្នង់ | ប្រុស | 24 | 1 | 0 | 1 | 1 | 3 | 30 |
| | ស្រី | 21 | 1 | 0 | 11 | 1 | 3 | 37 |
| | ទាំងពីរភេទ | 45 | 2 | 0 | 12 | 2 | 6 | 67 |
| រំដួល | ប្រុស | 26 | 11 | 0 | 0 | 6 | 7 | 50 |
| | ស្រី | 10 | 3 | 0 | 5 | 2 | 3 | 23 |
| | ទាំងពីរភេទ | 36 | 14 | 0 | 5 | 8 | 10 | 73 |
| សៀមពាយ | ប្រុស | 11 | 71 | 4 | 0 | 0 | 0 | 86 |
| | ស្រី | 1 | 37 | 2 | 0 | 0 | 0 | 40 |
| | ទាំងពីរភេទ | 12 | 108 | 6 | 0 | 0 | 0 | 126 |
| ខ្ទយ | ប្រុស | 18 | 0 | 58 | 0 | 0 | 0 | 76 |
| | ស្រី | 1 | 0 | 3 | 2 | 2 | 1 | 9 |
| | ទាំងពីរភេទ | 19 | 0 | 61 | 2 | 2 | 1 | 85 |
| ភូមិទាំងអស់ | ប្រុស | 99 | 138 | 62 | 4 | 15 | 18 | 336 |
| | ស្រី | 34 | 80 | 5 | 24 | 24 | 10 | 177 |
| | ទាំងពីរភេទ | 133 | 218 | 67 | 28 | 39 | 28 | 513 |

*ប្រភព: អង្កេតធ្វើឡើងដោយ CDRI នាខែកញ្ញា និងតុលា ២០០៧*

**ប្រអប់ ៣.៣: ករណីបុគ្គលពលករបុរសចាស់ចិត្តគំនិតម្នាក់ធ្វើចំណាកស្រុកទៅថៃ**

លោក ចឹម ចាន់ អាយុ ៤១ឆ្នាំ បានរៀបការ មានកូន ៤នាក់ រស់នៅភូមិក្រសាំង ឃុំជ្រោយស្តៅ ស្រុកថ្មគោល ខេត្តបាត់ដំបង ជាពលករធ្វើចំណាកស្រុកតាមរដូវទៅថៃ ។ ក្នុងអំឡុងពេល ៥ឆ្នាំមុន គាត់បានចំណាយពេលទៅធ្វើការនៅថៃយ៉ាងតិច ៤ខែក្នុងមួយឆ្នាំ ដោយសារគ្រួសារគាត់គ្មានដីកសិកម្ម និងក្នុងភូមិគ្មានការងារផ្តល់កម្រៃច្រើន ។

លោក ចាន់ ធ្វើដំណើរជាមួយអ្នកភូមិ ១៩នាក់ទៀតទៅច្រកទ្វារព្រំដែន និងបង់ប្រាក់ ៧០.០០០រៀលសំរាប់ធ្វើប័ណ្ណឆ្លងព្រំដែនដំបូង ដែលមានសុពលភាព ៧ថ្ងៃ ។ ប័ណ្ណនេះត្រូវធ្វើសាថ្មីរៀងរាល់សប្តាហ៍ ដោយត្រូវបង់ប្រាក់

២០០០រៀលក្នុងមួយលើក។ ។ ការបង់ប្រាក់ ២០០០រៀលនេះ មិនចោទបញ្ហាខាងហិរញ្ញវត្ថុដល់លោក ចាន់ទេ ប៉ុន្តែគាត់ត្រូវធ្វើដំណើរទៅច្រកទ្វារព្រំដែន ដើម្បីធ្វើប័ណ្ណថ្មី ហើយគាត់ត្រូវចំណាយ ៧០០០រៀល សំរាប់ការធ្វើដំណើរទៅព្រំដែន និងចំណាយពេលមួយថ្ងៃពេញ គឺបានន័យថា គាត់ត្រូវខាតបង់មិនបានធ្វើការអស់មួយថ្ងៃ ។

លោក ចាន់ រកប្រាក់បាន ១០.០០០រៀលក្នុងមួយថ្ងៃ និងចំណាយជាមធ្យមអស់ ២៥០០រៀលលើចំណីអាហារ ។ គាត់សន្សំបាន ១៥០.០០០រៀលក្នុងមួយខែ ។ គាត់មិនដែលផ្ញើប្រាក់មកផ្ទះទេ នៅពេលគាត់កំពុងធ្វើការក្នុងប្រទេសថៃ គឺគាត់យកប្រាក់សន្សំបានមកផ្ទះ នៅពេលគាត់មកមើលក្រុមគ្រួសារម្តង។ ។ ជាមួយនឹងប្រាក់សន្សំទាំងនេះ គាត់អាចបែងចែកប្រាក់ខ្លះទៅឱ្យកូន។ អាចបើកតូបលក់អីវ៉ាន់ចំរុះ (ចាប់ហួយ) នៅផ្ទះ ទិញឧបករណ៍នេសាទ និងសងបំណុលគេ ។ សព្វថ្ងៃ របរទាំងនេះ គឺជាប្រភពប្រាក់ចំណូលដែលជួយផ្គត់ផ្គង់ជីវភាពគ្រួសាររបស់គាត់ ។ លោក ចាន់មានគម្រោងជួលដីធ្វើស្រែបន្ថែម ដើម្បីកុំឱ្យក្រុមគ្រួសារជួបកង្វះខាតស្បៀង ។ បើទោះលោក ចាន់ រកបានច្រើនក្តី ក៏ការធ្វើការឆ្ងាយពីផ្ទះ បានដាក់សំពាធផ្លូវចិត្តដល់គាត់ ។ គាត់ត្រូវទុកឱ្យប្រពន្ធមើលថែកូនតែម្នាក់ឯង ។ ការមកមើលក្រុមគ្រួសារ ត្រូវចំណាយប្រាក់ច្រើនដែលគាត់មិនចង់ខ្ជះខ្ជាយទេ ហេតុនេះ គាត់ខំទប់ចិត្ត ហើយមកមើលក្រុមគ្រួសារ តែកាលណាមានការចាំបាច់តែប៉ុណ្ណោះ ។

លោក ចាន់ ប្រាប់ថា គាត់មិនទៅធ្វើការនៅប្រទេសថៃទេ ប្រសិនបើមានការងារទៀងទាត់ដែលអាចផ្តល់កម្រៃ ៨០០០រៀលក្នុងមួយថ្ងៃ ។ ការងារនៅក្នុងភូមិសព្វថ្ងៃនេះ ផ្តល់កម្រៃតែ ៥០០០រៀលក្នុងមួយថ្ងៃ ដែលតិចតួចពេក មិនអាចទ្រទ្រង់ជីវភាពគ្រួសារបានសមរម្យទេ ។ លោក ចាន់ សំណូមពរឱ្យរដ្ឋាភិបាលពិចារណាបន្ទាបតម្លៃប័ណ្ណឆ្លងព្រំដែនដំបូងពី ៧០.០០០រៀល មកត្រឹម ៣០.០០០រៀល ។

*ប្រភព: បទសម្ភាសន៍នៅខែកញ្ញា ២០០៧*

### ៣.២.៥. ចំណាយ និងមធ្យោបាយសំរាប់ឱ្យពលករធ្វើចំណាកស្រុកទៅដល់ប្រទេសគោលដៅ

អាស្រ័យទៅលើកន្លែងគោលដៅ និងចម្ងាយផ្លូវពីទីលំនៅរបស់ពលករទៅដល់កន្លែងនោះ ពលករត្រូវចាយវាយ (សំរាប់ការឆ្លងដែនខុសច្បាប់) អស់ពី ៤ដុល្លារ (គ្រាន់តែឆ្លងផុតព្រំដែនចូលក្នុងប្រទេសថៃ) រហូតដល់ ១៣៧០ដុល្លារ (ទៅម៉ាឡេស៊ី)។ ការធ្វើដំណើរទៅម៉ាឡេស៊ី អាចចំណាយអស់តែ ៣៨ដុល្លារប៉ុណ្ណោះ ប្រសិនបើពលករស្គាល់ផ្លូវទៅខ្លួនឯង ដោយធ្វើដំណើរតាមផ្លូវគោកឆ្លងកាត់ប្រទេសថៃ ។ ជាទូទៅ ចំណាយសំរាប់ការធ្វើដំណើររបស់ពលករពីកម្ពុជាទៅបាងកក ឬកន្លែងជ្រៅ។ក្នុងប្រទេសថៃ គឺពី ៧០ដុល្លារ ដល់ ១០០ដុល្លារ ។ នេះគឺជាកម្រៃផ្តល់ឱ្យមេខ្យល់សំរាប់រត់ពន្ធពលករពីកម្ពុជារហូតដល់កន្លែងធ្វើការនៅថៃ ។ ក្នុងកម្រៃនេះ មានបូកទាំងថ្លៃដឹកជញ្ជូនផង ប៉ុន្តែពលករក៏ត្រូវមានលុយជាប់ខ្លួនមួយចំនួនធំដែរ ។ ពេលពួកយើងចុះទៅធ្វើសម្ភាសន៍ អ្នកផ្តល់ព័ត៌មានគន្លឹះនៅថៃបានប្រាប់ថា មេខ្យល់ខាងថៃ (ជាជនជាតិថៃ) បានទទួលកម្រៃបន្ថែមពីនិយោជកក្នុងការបញ្ជូនពលករចំណាកស្រុកទៅឱ្យគេ ដោយអាចច្រើនរហូតដល់ ២៥០០បាត ឬប្រហែល ៧០ដុល្លារ ។ វាដូចជាការជួញដូរដូច្នោះដែរ ។ ការធ្វើដំណើរឆ្លងកាត់ព្រំដែន ត្រូវធ្វើដោយលួចលាក់ ។ ពលករចំណាកស្រុកទៅធ្វើការនៅថៃ ដែលមកលេងផ្ទះបានប្រាប់ក្រុមស្រាវជ្រាវថា មានគេនាំផ្លូវពួកគាត់ឆ្លងកាត់ព្រំដែននៅពេលយប់ ។ ពួកគាត់ត្រូវដើរឆ្លងកាត់វាលស្រែជាច្រើនម៉ោង មុនពេលឡើងជិះឡានទ្រុង (pick-up truck) ដែលនៅរង់ចាំជាស្រេច ។ ពួកគាត់ត្រូវគេផ្ទុកលើឡានដូចគល់អុស និងគ្របក្រណាត់ប្លាស្ទិកជិត ហើយត្រូវធ្វើដំណើរជាច្រើនម៉ោងទៀត ទើបទៅដល់កន្លែងធ្វើការ ។ ច្រកទ្វារដែលពួកគាត់ឆ្លងចូលទៅថៃញឹកញាប់ជាងគេ គឺម៉ាឡៃ និងបឹងត្រកួន ។ ពលករដែលធ្វើចំណាកស្រុកទៅធ្វើការនៅម៉ាឡេស៊ី តាមរយៈទីភ្នាក់ងារនៅរាជធានីភ្នំពេញ ត្រូវធ្វើដំណើរតាមផ្លូវគោកឆ្លងកាត់ប្រទេសថៃ ដោយត្រូវចំណាយពេលអស់ ២យប់ ៣ថ្ងៃ យោងតាមសំដីអ្នកចូលរួមក្នុង FGD និងពលករចំណាកស្រុកផ្ទាល់ ។

**តារាង ៣.៧: ចំណាយរបស់ពលករចំណាកស្រុកដើម្បីទៅដល់ប្រទេសគោលដៅ**

| ភូមិ | ប្រទេសគោលដៅ | ចំនួន | មធ្យម | គំលាតស្តង់ដារ | អប្បបរមា | អតិបរមា |
|---|---|---|---|---|---|---|
| ស្រម៉មាស | ក្នុងប្រទេសថៃ | 2 | 94 | 44 | 63 | 125 |
| | ប្រទេសម៉ាឡេស៊ី | 55 | 429 | 275 | 38 | 1,370 |
| ក្រសាំង | ក្នុងប្រទេសថៃ | 21 | 71 | 43 | 3 | 177 |
| | ប្រទេសម៉ាឡេស៊ី | 3 | 649 | 54 | 618 | 711 |
| | នៅព្រំដែនថៃ | 78 | 14 | 11 | 3 | 75 |
| គោកធ្លង់ | ក្នុងប្រទេសថៃ | 66 | 52 | 28 | 5 | 88 |
| | នៅព្រំដែនថៃ | 1 | 4 | - | 4 | 4 |
| រំដួល | ក្នុងប្រទេសថៃ | 70 | 87 | 39 | 6 | 238 |
| | នៅព្រំដែនថៃ | 3 | 52 | 47 | 5 | 100 |
| សៀមពាយ | ក្នុងប្រទេសថៃ | 18 | 69 | 26 | 10 | 113 |
| | នៅព្រំដែនថៃ | 108 | 9 | 8 | 4 | 63 |
| ខ្នាយ | ក្នុងប្រទេសថៃ | 81 | 102 | 40 | 18 | 236 |
| | នៅព្រំដែនថៃ | 4 | 28 | 6 | 25 | 38 |

*ប្រភពៈ អង្កេតធ្វើឡើងដោយ CDRI នាខែកញ្ញា និងតុលា ២០០៧*

ដោយសារពលករចំណាកស្រុក ជាទូទៅ មិនមែនចេញពីគ្រួសារធូរធារ ដូច្នេះ ពួកគេមិនទំនងជាមានប្រាក់នៅក្នុងដៃសំរាប់បង់ថ្លៃធ្វើដំណើរទៅថៃឡើយ ជាពិសេសដំណើរឆ្ងាយៗចូលជ្រៅទៅក្នុងប្រទេសថៃ ។ ពួកគេទំនងជាត្រូវខ្ចីប្រាក់គេ ដែលមានការប្រាក់ ៤%-៥% ក្នុងមួយខែ បើយោងតាម FGD ។ អង្កេតរកឃើញថា មានពលករប្រហែល ៥០% បានចងការប្រាក់ និងមានតែ ៨% ប៉ុណ្ណោះដែលប្រើប្រាស់ប្រាក់សន្សំផ្ទាល់ខ្លួន ហើយ ៤២% ទៀត ប្រើប្រាក់សន្សំរបស់គ្រួសារ (តារាង ៣.៨) ។ អ្នកផ្តល់ព័ត៌មានគន្លឹះដែលបានចូលរួមក្នុង FGD នៅក្នុងភូមិរំដួល ជឿថា ពលករធ្វើចំណាកស្រុកទាំងអស់ សុទ្ធតែត្រូវចងការប្រាក់សំរាប់ចំណាយលើការធ្វើដំណើរទៅថៃ ។ ប៉ុន្តែអង្កេតគ្រួសារបានរកឃើញថា មាន ៧៤% ចងការប្រាក់គេ និង ២៣% ប្រើប្រាស់ប្រាក់សន្សំរបស់គ្រួសារ ។ នៅភូមិរំដួល មានអ្នកចូលរួមម្នាក់ក្នុង FGDដែលមានសុទ្ធតែពលករចំណាកស្រុកវិលត្រលប់មកផ្ទះវិញ បានរាយការណ៍ថា ក្នុងរយៈពេល ៤ខែមុននេះ នាងបានចងការប្រាក់ចំនួន ២ដង ដើម្បីបង់ថ្លៃធ្វើដំណើរទៅរកការងារធ្វើនៅថៃ ។ នាងបរាជ័យទាំងពីរលើក ដោយត្រូវតម្រួតចាប់ខ្លួន នៅពេលធ្វើការជាកម្មករសំណង់នៅបាងកក និងត្រូវបញ្ជូនមកផ្ទះវិញ ។ នាងបានជាប់បំណុលប្រមាណ ៦០០០បាត (ឬ ១៧០ដុល្លារ) ដែលមិនទាន់បានសងគេនៅឡើយទេ ។ បន្ទាប់មក នាងសម្រេចចិត្តធ្វើការជាអ្នកបម្រើតាមផ្ទះ នៅទីរួមខេត្តបន្ទាយមានជ័យ ។

ដើម្បីបានទៅធ្វើការនៅថៃជាផ្លូវការតាមរយៈទីភ្នាក់ងារជ្រើសរើសពលករ បេក្ខជនម្នាក់ៗ ត្រូវចំណាយអស់ប្រហែល ៧០០ដុល្លារ និងត្រូវរង់ចាំជាច្រើនខែទំរាំរួចរាល់សព្វគ្រប់ ។ ទឹកប្រាក់នេះច្រើនហួសពេកសំរាប់ពលករដែលមិនអាចចំណាយសូម្បីតែ ៧០-១០០ដុល្លារ ដោយមិនចងការប្រាក់នោះ ។ ដោយសារមូលហេតុនេះ ទីភ្នាក់ងារ និងនិយោជកនៅថៃ បានរកឃើញវិធីឱ្យខ្ចីប្រាក់ជាមុនសំរាប់ដោះស្រាយចំណាយចំនួន ៦០០ដុល្លារ (ទីភ្នាក់ងារខ្លះតម្រូវឱ្យពលករមានប្រាក់ ១០០ដុល្លារសំរាប់ការធ្វើលិខិតឆ្លងដែន និងការត្រួតពិនិត្យសុខភាព) ។ ប្រាក់ភាគច្រើនបានមកពីនិយោជកនៅថៃ ។ ប៉ុន្តែពលករមួយចំនួនមិនទ្រាំធ្វើការគ្រប់មួយឆ្នាំ ដើម្បីកាត់សងប្រាក់ដែលនិយោជកបានចំណាយឱ្យមុន ដូចបានព្រមព្រៀងគ្នាជាមួយក្រុមហ៊ុនឡើយ ។ បន្ទាប់ពីបានទៅដល់ថៃ និងធ្វើការប្រហែល

៤-៥ខែ ពួកគេក៏ឈប់ធ្វើការងារនោះ ហើយទៅធ្វើការជាមួយពួកពលករចំណាកស្រុកខុសច្បាប់ ឬគ្មានចុះបញ្ជីដ៏ច្រើនសំបើមនោះ ។

**តារាង ៣.៨: វិធីរកប្រាក់របស់ពលករចំណាកស្រុក ដើម្បីបង់កម្រៃធ្វើដំណើរទៅថៃ ឬ ម៉ាឡេស៊ី**

| ភូមិ | ប្រាក់សន្សំផ្ទាល់ខ្លួន | ប្រាក់សន្សំរបស់គ្រួសារ | ចងការប្រាក់ | ផ្សេងៗ | សរុប |
|---|---|---|---|---|---|
| ស្រម៉មាស | 17% | 9% | 64% | 10% | 100% |
| ក្រសាំង | 3% | 59% | 38% | 0% | 100% |
| គោកផ្ទង់ | 6% | 33% | 61% | 0% | 100% |
| រំដួល | 0% | 23% | 74% | 3% | 100% |
| សៀមពាយ | 3% | 50% | 47% | 0% | 100% |
| ខ្ទយ | 20% | 55% | 25% | 0% | 100% |
| ភូមិទាំងអស់ | 8% | 42% | 49% | 2% | 100% |

*ប្រភព: អង្កេតធ្វើឡើងដោយ CDRI នាខែកញ្ញា និងតុលា ២០០៧*

**ប្រអប់ ៣.៤: ករណីបុគ្គលពលករចំណាកស្រុកតាមរដូវទៅធ្វើការនៅតាមព្រំដែនថៃ**

រដ្ឋា អាយុ ២៥ឆ្នាំ មានប្រពន្ធ និងកូនមួយ រស់នៅក្នុងភូមិសៀមពាយ ឃុំព្រះដំរី ស្រុកស្ទោង ខេត្តកំពង់ធំ ។ ក្នុងអំឡុងពេល ៥ឆ្នាំកន្លងមកនេះ គាត់ និងប្រពន្ធ បានចំណាយពេលយ៉ាងហោចណាស់ ៤ខែក្នុងមួយឆ្នាំ ទៅធ្វើការក្នុងប្រទេសថៃ នៅតាមព្រំដែនថៃ ដោយទុកកូនឱ្យឪពុកម្តាយគាត់ជួយមើលថែ ។ ពួកគាត់ទៅធ្វើការនៅខេត្តរ៉ាក់យ៉ង ប្រទេសថៃ ដើម្បីបានប្រាក់មកសងបំណុលគេ និងសន្សំខ្លះទុកសាងសង់ផ្ទះ ។

រដ្ឋា និងប្រពន្ធ ធ្វើដំណើរទៅច្រកទ្វារបឹងត្រកួន និងរង់ចាំអស់ ៥ថ្ងៃ ទើបអាចចូលទៅក្នុងប្រទេសថៃតាមការនាំផ្លូវរបស់មេខ្យល់ថៃ ។ ពួកគេត្រូវបង់កម្រៃសំរាប់ការនាំផ្លូវចំនួន ២៥០០បាតក្នុងម្នាក់ ។ ប្រាក់ ៥០០បាតដំបូង ត្រូវបង់ឱ្យមេខ្យល់មុនពេលឡើងជិះឡានទ្រុង (pick-up) ដែលដឹកពួកគេទៅចំការ និងប្រាក់ ២០០០បាតនៅសល់ ត្រូវបានកាត់ចេញពីប្រាក់ខែរបស់សាមីពលករនៅក្នុងរយៈពេល ៤ខែ ។ រដ្ឋា លួចធ្វើការនៅថៃដោយខុសច្បាប់ ។ គាត់អាចសុំលិខិតអនុញ្ញាតឱ្យធ្វើការស្របច្បាប់សំរាប់រយៈពេល ៦ខែ ប៉ុន្តែគាត់មិនអាចរកប្រាក់បានគ្រប់គ្រាន់សំរាប់បង់តម្លៃលិខិតអនុញ្ញាតការងារចំនួន ៣៨០០បាតនោះទេ ។ លិខិតអនុញ្ញាតការងារ ត្រូវធ្វើសាជាថ្មីក្នុងតម្លៃ ៣២០០បាត ។

រដ្ឋា អាចសន្សំបាន ២៥០.០០០រៀលក្នុងមួយខែៗនៅពេលគាត់ធ្វើការនៅថៃ ។ គាត់ក៏រៀនភាសាថៃបានខ្លះៗ និងចេះជំនាញសិប្បកម្ម ដូចជា ការធ្វើសីម៉ង្ការីម និងវត្ថុអនុស្សាវរីយ៍ ព្រមទាំងចេះបច្ចេកទេសកសិកម្ម ដូចជាការដាំត្រសក់ និងការកំចាត់សត្វចង្រៃ ជាដើម ។

រដ្ឋា មិនមានបំណងធ្វើការដោយខុសច្បាប់នៅថៃទេ ប្រសិនបើមានការងារទៀងទាត់ធ្វើនៅក្នុងភូមិ ឬនៅឃុំជិតៗនោះ ទោះវាផ្តល់កម្រៃត្រឹម ៨០០០រៀលក្នុងមួយថ្ងៃ ។ ប៉ុន្តែសព្វថ្ងៃនេះ ការងារនៅក្នុងភូមិ ឬនៅក្នុងឃុំមានមិនសូវទៀងទាត់ទេ ហើយផ្តល់កម្រៃបានតែ ៥០០០រៀល ។ គាត់និយាយថា នឹងសន្សំប្រាក់ទិញម៉ាស៊ីនបូមទឹកមួយមកដាំត្រសក់ ពីព្រោះគាត់បានរៀនចេះបច្ចេកទេសដាំពីថៃ ។ គាត់ស្នើសុំឱ្យរដ្ឋាភិបាលកម្ពុជា ចរចាជាមួយរដ្ឋាភិបាលថៃ ដើម្បីឱ្យពលករកម្ពុជាចូលទៅធ្វើការនៅប្រទេសថៃដោយស្របច្បាប់ ដោយបង់កម្រៃទាបជាងមុន ។

គាត់គិតថា បើលិខិតអនុញ្ញាតការងាររយៈពេល ៦ខែ មានតម្លៃតែ ១៥០.០០០រៀល និងការធ្វើសាជាថ្មីសំរាប់ ៦ខែបន្ទាប់ មានតម្លៃតែ ១០០.០០០រៀល នោះពលករកម្ពុជាពេញចិត្តនឹងទៅធ្វើការនៅថៃដោយស្របច្បាប់ ហើយពេលនោះ ពួកគេនឹងមានច្បាប់ជួយការពារ ព្រមទាំងអាចគេចផុតពីការកេងប្រវ័ញ្ចទៀតផង ។

*ប្រភព: បទសម្ភាសន៍នៅខែកញ្ញា ២០០៧*

### ៣.២.៦. ប្រាក់ផ្ញើទៅផ្ទះ

ប្រាក់ផ្ញើទៅផ្ទះ ជាអថេរមួយសំខាន់បំផុតក្នុងការសិក្សានេះ ។ ជាទូទៅ វាជាអ្វីដែលពលករចង់បានក្នុងការធ្វើចំណាកស្រុក ។ គេពិបាកបន្តិចក្នុងការប៉ាន់ស្មានឱ្យសុក្រិតពីចំនួនទឹកប្រាក់ដែលពលករផ្ញើទៅផ្ទះ ។ ទីមួយ ពួកគេប្រហែលមិនប្រាប់ពីចំនួនពិតទេ ព្រោះចង់លាក់បាំងពីកំរិតប្រាក់ចំណូលរបស់ខ្លួន ។ ទីពីរ គឺការភ្លេចភ្លាំង ជាពិសេសប្រសិនបើការផ្ញើប្រាក់ទៅផ្ទះលើកក្រោយបង្អស់ បានធ្វើឡើងតាំងពីច្រើនខែ ឬច្រើនឆ្នាំមុន ។ ទីបី គឺការបញ្ជាក់ថា តើការផ្ញើប្រាក់នោះ បានធ្វើឡើងសំរាប់អំឡុងពេលណា? ពលករខ្លះត្រឡប់ទៅធ្វើការនៅតាមព្រំដែនចុះឡើងច្រើនដង អ្នកខ្លះមួយឆ្នាំក្រោយត្រឡប់មកផ្ទះវិញ និងមិនបានធ្វើចំណាកស្រុកទៀតទេ ក្នុងរយៈពេល ២ឆ្នាំកន្លងទៅនេះ ។ ទីបួន ពលករមួយចំនួន អាចនឹងត្រឡប់មកផ្ទះវិញឆាប់ៗជាមួយនឹងប្រាក់សន្សំ ប៉ុន្តែអ្នកឆ្លើយសម្ភាសន៍នៅផ្ទះមិនបានដឹងប្រាកដទេ ។ ក្រុមចុះអង្កេតព្យាយាមដោះស្រាយបញ្ហាទាំងនេះ ដោយសម្ភាសអ្នកនៅផ្ទះ ដើម្បីទទួលបានតួលេខប៉ាន់ស្មានដែលត្រឹមត្រូវតាមតែអាចធ្វើទៅបានសំរាប់អំឡុងពេល ៥ឆ្នាំមុន សំរាប់អំឡុងពេល ១ឆ្នាំមុន និងសំរាប់ការធ្វើចំណាកស្រុកចុងក្រោយបង្អស់ ។

អង្កេតបានរកឃើញថា ១០០% នៃពលករចំណាកស្រុកដែលធ្វើការងារកសិកម្មនៅតាមតំបន់ជិតព្រំដែន បានផ្ញើប្រាក់ទៅផ្ទះ ។ ពលករទាំងនេះទៅធ្វើការពី ២-៣សប្តាហ៍ ដល់ ២-៣ខែ បន្ទាប់មក ត្រឡប់មកផ្ទះជាមួយនឹងប្រាក់សន្សំបាន ហើយយើងចាត់ទុកប្រាក់នោះថា ជាប្រាក់ផ្ញើទៅផ្ទះ ។ ប្រាក់ដែលពួកគេរកបាន វាមិនច្រើនដូចពលករទៅធ្វើការនៅតំបន់ជ្រៅៗក្នុងប្រទេសថៃ ឬទៅម៉ាឡេស៊ីឡើយ ។ ប៉ុន្តែពួកពលករដែលទៅឆ្ងាយៗ ត្រូវរកឈ្មួញកណ្តាលផ្ញើប្រាក់ទៅផ្ទះ ។ សំរាប់ពលករដែលធ្វើការនៅតំបន់ជិតព្រំដែន វាជាករណី "ប្រថុយតិច រកប្រាក់បានតិច" ។

ទោះជាយ៉ាងនេះក្តី ពលករដែលទៅធ្វើការនៅតំបន់ជ្រៅៗក្នុងប្រទេសថៃ មិនមែនសុទ្ធតែបានផ្ញើប្រាក់ទៅផ្ទះទាំងអស់គ្នានោះទេ គឺជាក់ស្តែងមានតែ ៧៣%ប៉ុណ្ណោះ ដែលបានផ្ញើប្រាក់ទៅផ្ទះនៅឆ្នាំមុន ។ ប្រភេទពលករមានភាគរយខ្ពស់បំផុតនៃអ្នកផ្ញើប្រាក់ទៅផ្ទះ គឺអ្នកធ្វើការនៅតាមផ្ទះ (៩១%) ។ មានភាគរយតិចបំផុត គឺពួកពលករធ្វើការងារកសិកម្មនៅឆ្ងាយពីព្រំដែន ដោយមាន ១១នាក់ក្នុងចំណោម ២៧នាក់ មិនបានផ្ញើប្រាក់ទៅផ្ទះទេ ។ រឿងនេះអាចមកពីពលករទាំងនេះ នឹងយកប្រាក់សន្សំមកផ្ទះ នៅពេលត្រឡប់មកផ្ទះវិញនាពេលអនាគត ។ ករណីនេះប្រហាក់ប្រហែលគ្នានឹងពលករដែលធ្វើចំណាកស្រុកទៅម៉ាឡេស៊ី ។ គិតជារួម ២០% នៃពលករដែលទៅធ្វើការនៅម៉ាឡេស៊ី (៥០% ធ្វើការនៅតាមផ្ទះ) មិនទាន់បានផ្ញើប្រាក់ទៅផ្ទះទេ ។

**តារាង ៣.៩: ភាគរយពលករចំណាកស្រុកបានផ្ញើប្រាក់ទៅផ្ទះក្នុងអំឡុងពេល ១ឆ្នាំមុន**

| ប្រទេសគោលដៅ | ប្រភេទការងារ | ចំនួនពលករចំណាកស្រុកផ្ញើប្រាក់ទៅផ្ទះ | | | ភាគរយពលករបានផ្ញើប្រាក់ទៅផ្ទះ | | |
|---|---|---|---|---|---|---|---|
| | | ផ្ញើ | អត់ផ្ញើ | សរុប | ផ្ញើ | អត់ផ្ញើ | សរុប |
| ជ្រៅក្នុងប្រទេសថៃ | សំណង់ | 79 | 36 | 115 | 69 | 31 | 100 |
| | កសិកម្ម | 16 | 11 | 27 | 59 | 41 | 100 |
| | នេសាទ | 48 | 11 | 59 | 81 | 19 | 100 |
| | ការងារផ្ទះ | 20 | 2 | 22 | 91 | 9 | 100 |
| | រោងចក្រ | 10 | 4 | 14 | 71 | 29 | 100 |
| | ផ្សេងៗ | 16 | 5 | 21 | 76 | 24 | 100 |
| | សរុបរង | 189 | 69 | 258 | 73 | 27 | 100 |
| នៅជិតព្រំដែនថៃ* | កសិកម្ម | 184 | 0 | 184 | 100 | 0 | 100 |
| | នេសាទ | 8 | 0 | 8 | 100 | 0 | 100 |
| | សរុបរង | 192 | 0 | 192 | 100 | 0 | 100 |
| ប្រទេសម៉ាឡេស៊ី | សំណង់ | 14 | 2 | 16 | 88 | 13 | 100 |
| | កសិកម្ម | 5 | 2 | 7 | 71 | 29 | 100 |
| | ការងារផ្ទះ | 3 | 3 | 6 | 50 | 50 | 100 |
| | រោងចក្រ | 20 | 5 | 25 | 80 | 20 | 100 |
| | ផ្សេងៗ | 6 | 0 | 6 | 100 | 0 | 100 |
| | សរុបរង | 48 | 12 | 60 | 80 | 20 | 100 |
| សរុប | | 429 | 81 | 510 | 84 | 16 | 100 |

** ពលករចំណាកស្រុករយៈពេលខ្លី និងយកប្រាក់ទៅផ្ទះដោយខ្លួនឯង*

*ប្រភព: អង្កេតធ្វើឡើងដោយ CDRI នាខែកញ្ញា និងតុលា ២០០៧*

ពិតណាស់ ចំនួនប្រាក់ផ្ញើទៅផ្ទះ វាអាស្រ័យលើប្រភេទការងារដែលពលករចំណាកស្រុកធ្វើ និងគំលាតរយៈពេលផ្ញើប្រាក់ទៅផ្ទះ ។ ពលករពីភូមិក្រសាំង និងភូមិសៀមពាយ ដែលធ្វើចំណាកស្រុកទៅធ្វើការនៅជិតៗព្រំដែន និងទៅមួយលើកៗមិនយូរទេ ពួកគេបានផ្ញើប្រាក់ទៅផ្ទះ ឬយកប្រាក់ទៅផ្ទះដោយខ្លួនឯងពី ៣០ដុល្លារ ដល់ ៨៤ដុល្លារ សំរាប់ចំណាកស្រុកចុងក្រោយ ដែលមានរយៈពេលពី ២-៣សប្តាហ៍ទៅ ២-៣ខែ ។ ចំពោះពលករដែលចូលជ្រៅទៅក្នុងប្រទេសថៃ និងនៅធ្វើការយូរពេលក្នុងមួយលើកៗ ពួកគេបានប្រាក់ផ្ញើទៅផ្ទះពី ១៥០ដុល្លារ-១៨០ដុល្លារសំរាប់ចំណាកស្រុកចុងក្រោយ ។ គួរចងចាំជាសំខាន់ថា ប្រាក់ផ្ញើទៅផ្ទះមិនមែនជាចំណូលសរុបដែលពលកររកបាននោះទេ ។ វាជាប្រាក់សន្សំសុទ្ធ ដែលទទួលបានក្រោយពីកាត់កងចំណាយលើការស្នាក់នៅហូបចុករបស់ពលករ ។

ប្រាក់ផ្ញើទៅផ្ទះនៅអំឡុងពេល ១ឆ្នាំមុន មានចំនួនច្រើនជាងប្រាក់ផ្ញើទៅផ្ទះក្នុងចំណាកស្រុកលើកចុងក្រោយ ប៉ុន្តែមិនលើសច្រើនណាស់ណាទេ ។ រឿងនេះបញ្ជាក់ថា ពលករមិនបានធ្វើចំណាកស្រុកច្រើនលើកទេក្នុងរយៈពេលមួយឆ្នាំនេះ ដោយសារពួកគេភាគច្រើននៅផ្ទះក្នុងរដូវធ្វើស្រែ ។ នៅអំឡុងពេល ៥ឆ្នាំមុន តាមដែលអ្នកឆ្លើយសម្ភាសន៍អាចរកនឹកឃើញ ប្រាក់ផ្ញើទៅផ្ទះ មានពី ៦០០ដុល្លារ-២១០០ដុល្លារ ហើយក៏រិតខ្ពស់បំផុត គឺនៅភូមិគោកធ្លង់ដែលមានជនជាតិដើមឡាវរស់នៅ ។ គួរកត់សម្គាល់ថា ពលករទៅធ្វើការនៅម៉ាឡេស៊ី មិនបានផ្ញើប្រាក់

ទៅផ្ទះបានច្រើនជាងពលករទៅធ្វើការនៅថៃទេ ទោះបីជាប្រាក់កម្រៃនៅម៉ាឡេស៊ី មានកំរិតខ្ពស់ជាងនៅថៃក្តី (តារាង ៣.១០) ។

អង្កេតរកឃើញថា ប្រាក់ផ្ញើទៅផ្ទះមួយចំណែកធំ ត្រូវក្រុមគ្រួសារនៅឯផ្ទះចាយវាយ និងប្រើប្រាស់ ហើយនៅសល់តិចតួចណាស់ដែលអាចចាត់ទុកជាប្រាក់សន្សំបាន ។ ចំណែកដែលអាចសន្សំបាន មិនសូវខុសគ្នាច្រើនទេ លើកលែងតែពលករចំណាកស្រុកមកពីភូមិខ្នាយដែលដូចជាអាចរកបាន និងសន្សំប្រាក់បានច្រើនជាងពលករមកពីភូមិដទៃទៀត ។ រឿងនេះបង្ហាញពីលក្ខខណ្ឌ "ប្រថុយខ្ពស់ រកប្រាក់បានច្រើន" នៃការងារក្នុងឧស្សាហកម្មនេសាទ ។

**តារាង ៣.១០: ប្រាក់ផ្ញើទៅផ្ទះសំរាប់គ្រួសារមានសមាជិកធ្វើចំណាកស្រុកទៅថៃ (ដុល្លារ)**

| ឈ្មោះភូមិ | ក្នុងដំណើរចំណាកស្រុកចុងក្រោយ | | | នៅអំឡុងពេល ១ឆ្នាំមុន | | | នៅអំឡុងពេល ៥ឆ្នាំមុន | | |
|---|---|---|---|---|---|---|---|---|---|
| | ប្រាក់ផ្ញើទៅផ្ទះ | ប្រាក់ផ្ញើទៅផ្ទះបានចំណាយ | ប្រាក់សន្សំក្រោយពេលចំណាយ | ប្រាក់ផ្ញើទៅផ្ទះ | ប្រាក់ផ្ញើទៅផ្ទះបានចំណាយ | ប្រាក់សន្សំក្រោយពេលចំណាយ | ប្រាក់ផ្ញើទៅផ្ទះ | ប្រាក់ផ្ញើទៅផ្ទះបានចំណាយ | ប្រាក់សន្សំក្រោយពេលចំណាយ |
| ស្រម៉មាស | 182 | 155 | 13 | 138 | 119 | 21 | 766 | 730 | 21 |
| ក្រសាំង | 84 | 75 | 10 | 111 | 96 | 9 | 1,043 | 923 | 63 |
| គោកធ្លង់ | 152 | 138 | 13 | 300 | 277 | 24 | 2,105 | 2,048 | 23 |
| រំដួល | 149 | 134 | 4 | 226 | 207 | 19 | 605 | 555 | 45 |
| សៀមពាយ | 29 | 27 | 2 | 46 | 43 | 3 | 856 | 840 | 15 |
| ខ្នាយ | 168 | 121 | 40 | 270 | 225 | 43 | 979 | 914 | 55 |
| សរុប | 122 | 14 | 103 | 173 | 20 | 153 | 1,018 | 37 | 963 |

*ប្រភពៈ អង្កេតធ្វើឡើងដោយ CDRI នាខែកញ្ញា និងតុលា ២០០៧*

តារាង ៣.១១ បង្ហាញពីទឹកប្រាក់ដ៏ច្រើនដែលពលករចំណាកស្រុកផ្ញើទៅផ្ទះ ។ ពលករចំណាកស្រុកមកពីភូមិសៀមពាយ ផ្ញើប្រាក់តិចជាងគេ ដែលបង្ហាញពីកំរិតប្រាក់ចំណូលទាបជាងនៃការងារកសិកម្មនៅជិតព្រំដែន ។ ផ្ទុយទៅវិញ ការធ្វើចំណាកស្រុកចុងក្រោយ ដែលអាចមានរយៈពេលលើសពី ១ឆ្នាំ ធ្វើឱ្យពលករមកពីភូមិស្រម៉មាស និងភូមិគោកធ្លង់ មានប្រាក់ផ្ញើទៅផ្ទះ លើសពី ៣០០០ដុល្លារ ។ តារាង ៣.១២ បង្ហាញពីប្រាក់ផ្ញើទៅផ្ទះរបស់ពលករចំណាកស្រុកមកពីភូមិនីមួយៗនៅអំឡុងពេល ១ឆ្នាំមុន និង ៥ឆ្នាំមុន ។ លើកលែងតែនៅភូមិសៀមពាយមួយចេញ កំរិតនៃប្រាក់ផ្ញើទៅផ្ទះ មិនសូវខុសគ្នាប៉ុន្មានទេ ។

**តារាង ៣.១១: ប្រាក់ផ្ញើទៅផ្ទះ សំរាប់ការផ្ញើមួយលើកៗ និងសំរាប់ការផ្ញើចំណាកស្រុកលើកចុងក្រោយ**

| ភូមិ | ប្រាក់ផ្ញើទៅផ្ទះក្នុងមួយលើកៗ (ដុល្លារ) | | | | ប្រាក់ផ្ញើទៅផ្ទះនៅអំឡុងពេលផ្ញើចំណាកស្រុកចុងក្រោយ (ដុល្លារ) | | | |
|---|---|---|---|---|---|---|---|---|
| | ចំនួន | មធ្យម | គំលាតស្តង់ដារ | អតិបរមា | ចំនួន | មធ្យម | គំលាតស្តង់ដារ | អតិបរមា |
| ស្រម៉មាស | 50 | 114 | 163 | 750 | 50 | 440 | 546 | 3,125 |
| ក្រសាំង | 25 | 145 | 174 | 875 | 25 | 233 | 248 | 900 |
| គោកធ្លង់ | 53 | 101 | 95 | 500 | 53 | 412 | 626 | 3,250 |
| រំដួល | 46 | 95 | 71 | 409 | 46 | 207 | 172 | 818 |
| សៀមពាយ | 38 | 52 | 57 | 250 | 38 | 70 | 86 | 300 |
| ខ្នុយ | 69 | 118 | 108 | 750 | 68 | 319 | 327 | 1,500 |

*ប្រភព: អង្កេតលើ ៥២៦គ្រួសារ នៅ ៦ភូមិ ធ្វើឡើងដោយ CDRI នាខែកញ្ញា និងតុលា ២០០៧*

**តារាង ៣.១២: ប្រាក់ផ្ញើទៅផ្ទះ នៅអំឡុងពេល ១ឆ្នាំមុន និង ៥ឆ្នាំមុន (ដុល្លារ)**

| ភូមិ | ប្រាក់ផ្ញើទៅផ្ទះនៅអំឡុងពេល ១ឆ្នាំមុន | | | | ប្រាក់ផ្ញើទៅផ្ទះនៅអំឡុងពេល ៥ឆ្នាំមុន | | | |
|---|---|---|---|---|---|---|---|---|
| | ចំនួន | មធ្យម | គំលាតស្តង់ដារ | អតិបរមា | ចំនួន | មធ្យម | គំលាតស្តង់ដារ | អតិបរមា |
| ស្រម៉មាស | 30 | 192 | 209 | 750 | 52 | 616 | 948 | 6,000 |
| ក្រសាំង | 24 | 208 | 198 | 900 | 27 | 480 | 876 | 4,500 |
| គោកធ្លង់ | 43 | 267 | 197 | 750 | 59 | 899 | 795 | 3,525 |
| រំដួល | 42 | 201 | 160 | 818 | 50 | 384 | 455 | 2,500 |
| សៀមពាយ | 41 | 74 | 88 | 300 | 50 | 128 | 174 | 938 |
| ខ្នុយ | 54 | 292 | 274 | 1,100 | 78 | 650 | 688 | 3,713 |
| ភូមិទាំងអស់ | 234 | 211 | 211 | 1,100 | 316 | 552 | 733 | 6,000 |

*ប្រភព: អង្កេតធ្វើឡើងដោយ CDRI នាខែកញ្ញា និងតុលា ២០០៧*

នៅក្នុងតារាង ៣.១៣ បង្ហាញថា ការធ្វើការងារកសិកម្ម និងការនេសាទនៅជិតៗព្រំដែន ផ្តល់ប្រាក់សំរាប់ផ្ញើទៅផ្ទះបានតិចជាងគេ រីឯការធ្វើការងារតាមផ្ទះ ហាក់ដូចជួយឱ្យសន្សំប្រាក់បានច្រើនសំរាប់ផ្ញើទៅផ្ទះ ។ ការធ្វើការងារតាមផ្ទះ ជាទូទៅ មិនតម្រូវឱ្យពលករចំណាយលើការស្នាក់នៅ និងហូបចុកទេ ។ ពួកគេអាចសន្សំបានជាមធ្យម ៣៣៤ដុល្លារនៅអំឡុងពេល ១ឆ្នាំចុងក្រោយនេះ និង ១៤៦០ដុល្លារនៅអំឡុងពេល ៥ឆ្នាំមុន ។ ករណីនេះឃើញមានភាគច្រើននៅភូមិគោកធ្លង់ដែលមានពលករចំណាកស្រុកជាជនជាតិដើមឡាវ និងចេះនិយាយភាសាថៃបានស្ទាត់ ។

គួរកត់សម្គាល់ជាសំខាន់ថា ប្រាក់ផ្ញើទៅផ្ទះប្រែប្រួលខុសគ្នាជាខ្លាំងក្នុងប្រភេទការងារជាច្រើន (បង្ហាញដោយគំលាតស្តង់ដារខ្ពស់) ។ ខណៈដែលប្រាក់ផ្ញើទៅផ្ទះជាមធ្យមក្នុងមួយឆ្នាំរបស់ពលករចំណាកស្រុកដែលធ្វើការងារសំណង់ គឺ ២១៨ដុល្លារ ក៏ឃើញមានពលករយ៉ាងហោចណាស់ម្នាក់ដែរដែលរាយការណ៍ថា បានផ្ញើប្រាក់ទៅផ្ទះ ១១០០ដុល្លារ ។

នៅអំឡុងពេល ៥ឆ្នាំមុន មានពលករយ៉ាងហោចណាស់ម្នាក់បានរាយការណ៍ថា បានផ្ញើប្រាក់មកផ្ទះ ៤៥០០ដុល្លារ នៅពេលចំណាកស្រុកទៅធ្វើការជាអ្នកបម្រើនៅតាមផ្ទះក្នុងប្រទេសថៃ ។

**តារាង ៣.១៣: ប្រាក់ផ្ញើទៅផ្ទះរបស់ពលករចំណាកស្រុក បែងចែកតាមប្រភេទការងារ និងទីកន្លែង**

| | ប្រាក់ផ្ញើទៅមកផ្ទះក្នុងអំឡុង ១ឆ្នាំមុន (ដុល្លារ) | | | | ប្រាក់ផ្ញើទៅផ្ទះក្នុងអំឡុង ៥ឆ្នាំមុន (ដុល្លារ) | | | |
|---|---|---|---|---|---|---|---|---|
| | ចំនួន | មធ្យម | គំលាតស្តង់ដារ | អតិបរមា | ចំនួន | មធ្យម | គំលាតស្តង់ដារ | អតិបរមា |
| នៅក្នុងប្រទេសថៃ | | | | | | | | |
| សំណង់ | 70 | 265 | 218 | 1,100 | 87 | 619 | 595 | 2,500 |
| កសិកម្ម | 12 | 156 | 164 | 600 | 19 | 201 | 203 | 900 |
| នេសាទ | 32 | 183 | 157 | 750 | 55 | 539 | 660 | 3,713 |
| ការងារផ្ទះ | 19 | 334 | 268 | 900 | 21 | 1,460 | 1,196 | 4,500 |
| រោងចក្រ | 10 | 322 | 209 | 750 | 10 | 650 | 571 | 1,713 |
| ផ្សេងៗ | 16 | 275 | 277 | 1,100 | 18 | 505 | 587 | 2,500 |
| នៅតាមព្រំដែនថៃ | | | | | | | | |
| កសិកម្ម | 43 | 61 | 65 | 270 | 51 | 143 | 207 | 900 |
| នេសាទ | 1 | 250 | - | 250 | 4 | 231 | 107 | 375 |
| នៅប្រទេសម៉ាឡេស៊ី | | | | | | | | |
| សំណង់ | 5 | 302 | 298 | 625 | 15 | 731 | 839 | 3,125 |
| កសិកម្ម | 4 | 384 | 308 | 750 | 5 | 768 | 703 | 1,500 |
| ការងារផ្ទះ | 3 | 65 | 91 | 171 | 3 | 151 | 165 | 342 |
| រោងចក្រ | 13 | 138 | 103 | 300 | 20 | 708 | 1,287 | 6,000 |
| ផ្សេងៗ | 4 | 176 | 229 | 515 | 6 | 386 | 191 | 700 |

*ប្រភព: អង្កេតធ្វើឡើងដោយ CDRI នាខែកញ្ញា និងតុលា ២០០៧*

នៅអំឡុងពេល ១ឆ្នាំមុន និង ៥ឆ្នាំមុននេះ ពលករចំណាកស្រុកជានារី ទំនងជាផ្ញើប្រាក់ទៅផ្ទះបានច្រើនជាង ពលករបុរស តាមរយៈការធ្វើការងារនៅតំបន់ឆ្ងាយៗនៅថៃ (តារាង ៣.១៤) ។ ប៉ុន្តែតួលេខនេះ វាផ្ទុយគ្នាស្រឡះ សំរាប់ពលករចំណាកស្រុកដែលធ្វើការនៅជិតព្រំដែន ។ ពលករបុរសផ្ញើប្រាក់ទៅផ្ទះ បានច្រើនជាងពលករនារី ។ រឿងនេះគឺដោយសារការងារកសិកម្ម នៅទីនោះត្រូវប្រើកំលាំងកាយច្រើន និងផ្តល់កម្រៃទៅតាមលទ្ធផលធ្វើបានក្នុងមួយថ្ងៃៗ ។ សំរាប់ការងារនៅម៉ាឡេស៊ី វាផ្តល់ជាប្រាក់ផ្ញើទៅផ្ទះខុសគ្នាតិចតួចទេ ក្នុងអំឡុងពេល ១ឆ្នាំមុននេះ ។ ពលករចំណាកស្រុកបុរស មានប្រាក់ផ្ញើទៅផ្ទះច្រើនជាងក្នុងអំឡុងពេល ៥ឆ្នាំចុងក្រោយនេះ ដោយសារពួកគេធ្វើការនៅម៉ាឡេស៊ីក្នុងរយៈពេលយូរជាង ។

**តារាង ៣.១៤: ប្រាក់ផ្ញើទៅផ្ទះរបស់ពលករចំណាកស្រុក បែងចែកតាមទីកន្លែងការងារ និងភេទពលករ**

| | ប្រាក់ផ្ញើទៅផ្ទះក្នុងអំឡុង ១ឆ្នាំមុន (ដុល្លារ) | | | | ប្រាក់ផ្ញើទៅផ្ទះក្នុងអំឡុង ៥ឆ្នាំមុន (ដុល្លារ) | | | |
|---|---|---|---|---|---|---|---|---|
| | ចំនួន | មធ្យម | គំលាតស្តង់ដារ | អតិបរមា | ចំនួន | មធ្យម | គំលាតស្តង់ដារ | អតិបរមា |
| នៅក្នុងប្រទេសថៃ | | | | | | | | |
| ប្រុស | 109 | 241 | 210 | 1,100 | 145 | 560 | 614 | 3,713 |
| ស្រី | 50 | 279 | 239 | 1,100 | 65 | 806 | 917 | 4,500 |
| នៅតាមព្រំដែនថៃ | | | | | | | | |
| ប្រុស | 35 | 79 | 103 | 500 | 44 | 171 | 238 | 900 |
| ស្រី | 11 | 62 | 59 | 150 | 13 | 120 | 125 | 438 |
| នៅប្រទេសម៉ាឡេស៊ី | | | | | | | | |
| ប្រុស | 12 | 201 | 245 | 625 | 26 | 777 | 1,262 | 6,000 |
| ស្រី | 17 | 196 | 190 | 750 | 23 | 501 | 436 | 1,500 |

*ប្រភព: អង្កេតធ្វើឡើងដោយ CDRI នាខែកញ្ញា និងតុលា ២០០៧*

## ៣.២.៧. មធ្យោបាយផ្ញើប្រាក់ទៅផ្ទះរបស់ពលករចំណាកស្រុក

ពលករតិចតួចណាស់ ដែលបានរាយការណ៍ពីការប្រើប្រាស់ប្រព័ន្ធធនាគារ ដើម្បីផ្ញើប្រាក់សន្សំទៅផ្ទះ ហើយចំណុចនេះបង្ហាញពីកំរិតទាបនៃការប្រើប្រាស់ប្រព័ន្ធធនាគារនៅកម្ពុជា ។ មធ្យោបាយដែលពួកគេចូលចិត្តប្រើ គឺអាស្រ័យលើទីកន្លែងដែលពលករធ្វើការ ។ សំរាប់អ្នកចូលជ្រៅទៅក្នុងប្រទេសថៃ មាន ៨៥% បានផ្ញើប្រាក់តាមឈ្មួញកណ្តាលដែលជាអ្នកភ្ជាប់ទំនាក់ទំនងរវាងពលករ និងក្រុមគ្រួសារពលករ តាមរយៈទូរស័ព្ទ ។ ចំពោះកម្រៃជើងសារ ពលករត្រូវបង់ប្រហែល ៤%-៥% ។ សំរាប់ពលករធ្វើការនៅជិតព្រំដែន មានតែ ១៤% ប៉ុណ្ណោះ ដែលអនុវត្តវិធីមុននេះ រីឯ ៨៤% ទៀត ផ្ញើប្រាក់តាមពលករចំណាកស្រុកដទៃទៀតដែលពួកគេទុកចិត្ត ។ ចំពោះពលករចំណាកស្រុកទៅម៉ាឡេស៊ី មាន ៧៥% បានផ្ញើប្រាក់តាមឈ្មួញកណ្តាលដែលជាអ្នកធ្វើដំណើរផ្ទាល់ទៅមកម៉ាឡេស៊ី-កម្ពុជា ចំណែកឯ ២៣% ទៀតពឹងផ្អែកលើពលករចំណាកស្រុកដទៃទៀត ។

**តារាង ៣.១៥: មធ្យោបាយសំរាប់ផ្ញើប្រាក់ទៅផ្ទះ**

| ប្រទេសគោលដៅ | ឈ្មួញកណ្តាលប្រើប្រាស់ទូរស័ព្ទ | ឈ្មួញកណ្តាលធ្វើដំណើរដោយផ្ទាល់ | ពលករចំណាកស្រុកដទៃទៀត | ធនាគារ | ផ្សេងៗ | សរុប |
|---|---|---|---|---|---|---|
| | ចំនួនពលករចំណាកស្រុក | | | | | |
| នៅក្នុងប្រទេសថៃ | 154 | 7 | 6 | 13 | 1 | 181 |
| នៅព្រំដែនថៃ | 6 | 0 | 37 | 1 | 0 | 44 |
| នៅប្រទេសម៉ាឡេស៊ី | 0 | 33 | 10 | 0 | 1 | 44 |
| | ភាគរយពលករចំណាកស្រុក | | | | | |
| នៅក្នុងប្រទេសថៃ | 85 | 4 | 3 | 7 | 1 | 100 |
| នៅព្រំដែនថៃ | 14 | 0 | 84 | 2 | 0 | 100 |
| នៅប្រទេសម៉ាឡេស៊ី | 0 | 75 | 23 | 0 | 2 | 100 |

*ប្រភព: អង្កេតធ្វើឡើងដោយ CDRI នាខែកញ្ញា និងតុលា ឆ្នាំ២០០៧*

**ប្រអប់ ៣.៥: ករណីមួយចំនួននៃឈ្មួញប្រកបរបរផ្ទេរប្រាក់ផ្ញើទៅផ្ទះ នៅក្នុងសហគមន៍មូលដ្ឋាន**

*ករណីទី ១: ឈ្មួញផ្តល់សេវាផ្ទេរប្រាក់តាមទូរស័ព្ទនៅស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ*

តាំងពីគាត់ដឹងថា មានប្រជាជនជាច្រើនធ្វើចំណាកស្រុកទៅថៃ និងបានផ្ញើប្រាក់ទៅផ្ទះនៅស្រុកក្រឡាញ់ គាត់បានចាប់ផ្តើមមុខរបរផ្ទេរប្រាក់តាមទូរស័ព្ទនៅឆ្នាំ២០០៥ ដោយមានជំនួយពីមនុស្ស ២នាក់នៅថៃ ដែលទទួលខុសត្រូវខាងការប្រមូល និងផ្ទេរប្រាក់ ។ គាត់ចាប់ដំណើរការមុខរបរនេះដំបូងដោយមានទុន ៥០.០០០បាត (មុខរបរនេះប្រើប្រាស់ប្រាក់បាតថៃ) ។ ជាទូទៅ គាត់ទទួលផ្ទេរប្រាក់ពី ១២.០០០បាត-៥០.០០០បាតក្នុងមួយខែ ប៉ុន្តែបរិមាណផ្ទេរអាចកើនឡើងដល់ ៣០.០០០បាតនៅអំឡុងរយៈពេល ២-៣ថ្ងៃ នៃបុណ្យភ្ជុំបិណ្ឌ ។ ជាមធ្យម ប្រាក់ដែលពលករចំណាកស្រុកផ្ញើទៅផ្ទះ មានចំនួនពី ២០០០បាត ដល់ ៥០០០បាតក្នុងមួយខែ ។ ឈ្មួញកណ្តាលនៅថៃយក ១% ហើយគាត់យក ៣% បន្ថែមទៀត សំរាប់សេវាប្រគល់ប្រាក់នៅកម្ពុជា ។

ឈ្មួញកណ្តាលនៅថៃ ផ្ទេរប្រាក់ចូលក្នុងគណនីរបស់ឈ្មួញខ្មែរ ។ បីម៉ោងក្រោយមក គាត់នឹងទាក់ទងទៅធនាគារនៅសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ដើម្បីផ្ទៀងផ្ទាត់មើលទឹកប្រាក់ក្នុងគណនី ។ ក្រោយពេលបានទទួលប្រាក់ក្នុងគណនីហើយ គាត់ក៏ប្រគល់ប្រាក់ទៅឱ្យក្រុមគ្រួសាររបស់ពលករ ។ គាត់ក៏ត្រូវបង់ប្រាក់កម្រៃ ៣០បាតទៅឱ្យធនាគារដែរ សំរាប់ការផ្ទេរ ១០.០០០បាត ។ ពលករចំណាកស្រុកមិនទទួលរ៉ាប់រងមុខចំណាយនេះទេ ។

*ករណីទី ២: ឈ្មួញផ្តល់សេវាផ្ទេរប្រាក់តាមទូរស័ព្ទនៅស្រុកស្ទោង ខេត្តកំពង់ធំ*

គាត់ចាប់ផ្តើមមុខរបរនេះចំនួនមួយឆ្នាំមកហើយ ជំនួសឱ្យបងប្រុសគាត់ដែលជួបគ្រោះថ្នាក់ចរាចរណ៍ ត្រូវពិការជើងទាំងពីរ ហើយគ្មាននរណាផ្សេងអាចជំនួសបងប្រុសគាត់បាន ។ គាត់មិនព្រមប្រាប់ពីចំនួនទុនសំរាប់ចាប់ផ្តើមអាជីវកម្មនេះទេ ។ គាត់យក ៤០០០រៀលសំរាប់ការផ្ទេរ ១០០.០០០រៀល (ឬ ៤%) ជាថ្លៃសេវាផ្ទេរប្រាក់មកពីខេត្តដទៃក្នុងប្រទេសកម្ពុជា ។ ចំពោះការផ្ទេរប្រាក់មកពីថៃ ពលករភាគច្រើនដែលធ្វើការនៅក្នុង ឬនៅជិតក្រុងបាងកក ជាមធ្យម គេផ្ញើប្រាក់ទៅផ្ទះពី ១៥០០បាតទៅ ២០០០បាតក្នុងមួយលើកៗ រីឯពលករធ្វើការបានដល់ ១ឆ្នាំ ឬយូរជាងនេះ គេផ្ញើប្រាក់មកប្រហែល ១០.០០០បាតក្នុងមួយលើកៗ ។ ក្នុងមួយខែ គាត់មានអតិថិជនពី ៥ ទៅ ១០នាក់ប៉ុណ្ណោះ ដែលប្រើប្រាស់សេវានេះ ។ ដូច្នេះ គាត់ទទួលធ្វើការផ្ទេរប្រាក់សរុបពី ២០.០០០បាត-៣០.០០០បាតក្នុងមួយខែ និងប្រហែល ៥០.០០០បាតនៅអំឡុងថ្ងៃបុណ្យភ្ជុំបិណ្ឌ ។

គាត់ពុំមានគណនីធនាគារសំរាប់អាជីវកម្មនេះទេ ។ គាត់គ្រាន់តែទទួលបន្តពីបងប្រុសគាត់នៅប៉ោយប៉ែតប៉ុណ្ណោះ ។ នៅពេលពលករចំណាកស្រុកបានផ្ញើប្រាក់ចូលក្នុងគណនីបងប្រុសគាត់ បងគាត់នឹងទូរស័ព្ទប្រាប់គាត់ឱ្យប្រគល់ប្រាក់ដល់គ្រួសារពលករ ។ គាត់មិនបានដឹងថា បងគាត់យកកម្រៃប៉ុន្មានទេ ឯរូបគាត់គឺយក ១,៥% ។ រៀងរាល់ ១០ថ្ងៃម្តង គាត់ត្រូវទៅប៉ោយប៉ែតបើកយកប្រាក់ពីបងគាត់វិញទៅតាមចំនួនទឹកប្រាក់ដែលបានផ្ញើ ។

*ករណីទី ៣: ឈ្មួញផ្តល់សេវាផ្ញើប្រាក់តាមទូរស័ព្ទនៅស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ*

គាត់ចាប់ផ្តើមអាជីវកម្មនៅឆ្នាំ២០០៧ ក្រោយពេលឈប់ធ្វើការពីឡូតិ៍នេសាទ ហើយបានកត់សម្គាល់ថាប្រជាជនភូមិរំដួល មានការលំបាកក្នុងការផ្ញើប្រាក់ពីថៃមកឱ្យក្រុមគ្រួសារ ។ ទុនដំបូងសំរាប់ចាប់ផ្តើមអាជីវកម្មរបស់គាត់ គឺ ១០០.០០០បាត ។ គាត់យក ២,៥% ហើយឈ្មួញកណ្តាលនៅសិរីសោភ័ណ កាត់យក ០,៥% សំរាប់សេវានេះ ។ មានឈ្មួញកណ្តាលម្នាក់ទៀតនៅថៃ យក ៥០បាតពីពលករ នៅពេលពួកគេផ្ញើប្រាក់ទៅផ្ទះក្នុងមួយលើក១ ។ ឈ្មួញខ្មែរត្រូវបង់ ៥០.០០០រៀលក្នុងមួយខែទៅឱ្យប្រៃសណីយ៍ និង ២០០០បាតសំរាប់សេវាទូរស័ព្ទនៅថៃ ដែលអាចកើនឡើងដល់ ៣០០០បាតនៅអំឡុងពេលបុណ្យចូលឆ្នាំខ្មែរ បុណ្យភ្ជុំបិណ្ឌ និងបុណ្យសំខាន់១ផ្សេងទៀត ។

នៅភូមិនេះ មានតែតូបមួយប៉ុណ្ណោះដែលធ្វើអាជីវកម្មនេះ ។ តាមធម្មតា គាត់ផ្ញើប្រាក់បាន ២០.០០០បាត-៣០.០០០បាតក្នុងមួយខែ ប៉ុន្តែនៅអំឡុងពេលបុណ្យជាតិ បរិមាណផ្ញើរអាចឡើងដល់ ២០០.០០០បាត ។ គាត់អាចបើកប្រាក់ឱ្យគ្រួសារពលករជាមុនបានក្នុងករណីបន្ទាន់ ហើយគាត់ធ្វើការទាក់ទងទៅពលករនៅថៃ ឱ្យទូទាត់បង់ប្រាក់ជាក្រោយ ។ ជាមធ្យម ពលករម្នាក់អាចផ្ញើប្រាក់ទៅផ្ទះពី ៣០០បាត-១០០០បាត ។ សំរាប់អាជីវកម្មផ្ញើប្រាក់ដើមទុន ១០០.០០០បាត មិនគ្រប់គ្រាន់ទេ ដោយសារពេលខ្លះ ពួកពលករចំណាកស្រុកបានផ្ញើប្រាក់ទៅផ្ទះសរុបទាំងអស់ដល់ទៅប្រហែល ២០០.០០០បាតក្នុងមួយខែ ។ ដូច្នេះ គាត់ត្រូវខ្ចីប្រាក់ពីមិត្តភក្តិដោយបង់ការប្រាក់ ៣%-៤%ក្នុងមួយខែ ។ ចាប់តាំងពីដំណើរការអាជីវកម្មនេះមកគាត់មិនដែលជួបបញ្ហាអ្វីទេ ដោយសារឈ្មួញកណ្តាលដែលគាត់រកស៊ីជាមួយសុទ្ធតែជាអ្នកភូមិជាមួយគ្នា ។ នៅឃុំភ្នំលាភ មានទីភ្នាក់ងារ/តូប ចំនួន ៧ ដែលផ្តល់សេវានេះ ។ គាត់ប្រាប់ថា អាជីវកម្មគាត់អាចផ្តល់ប្រាក់ចំណេញសុទ្ធបាន ១៥០០បាតក្នុងមួយខែ ។

*ប្រភព: បទសម្ភាសន៍នៅខែកញ្ញា ២០០៧*

### ៣.២.៨. ការប្រើប្រាស់ប្រាក់ផ្ញើទៅផ្ទះនៅក្នុងសហគមន៍បញ្ជូនពលករ

មានការជជែកវែកញែកជាយូរមកហើយថា តើប្រាក់ផ្ញើទៅផ្ទះបានចូលរួមចំណែកទៅដល់ការអភិវឌ្ឍសហគមន៍បញ្ជូនពលករ ឬក៏គ្រាន់តែធ្វើឱ្យសហគមន៍ពឹងផ្អែកលើប្រាក់ចំណូលបានពីប្រទេសគោលដៅ ។ មានការអះអាងមួយថា ក្រុមគ្រួសាររបស់ពលករចំណាកស្រុក ចំណាយប្រាក់ផ្ញើទៅផ្ទះសំរាប់ចំណាយលើការប្រើប្រាស់ហូបចុក មិនមែនចំណាយទៅលើការបង្កើនសមត្ថភាពរបស់គ្រួសារ ឬជួយអភិវឌ្ឍន៍សហគមន៍នោះឡើយ ។ ហេតុនេះការសិក្សាព្យាយាមស្វែងយល់ពីរបៀបរបបដែលប្រជាជនចាយវាយប្រាក់ផ្ញើទៅផ្ទះ ។ ដើម្បីធ្វើការងារនេះ មានការបែងចែកចំណាយជា ២ប្រភេទ គឺ ១-ចំណាយប្រើប្រាស់ដែលមិនផ្តល់ផលត្រឡប់មកវិញ និង ២-ការធ្វើវិនិយោគ ឬការងារបង្កើនប្រាក់ចំណូល ។ ដូចដែលមានបង្ហាញក្នុងតារាង ៣.១៦ នៅអំឡុងពេល ១ឆ្នាំមុន គ្រួសារដែលទទួលបានប្រាក់ផ្ញើទៅផ្ទះ បានចំណាយ ៨១% ទៅលើការប្រើប្រាស់ក្នុងគ្រួសារ និង ១៩% ទៅលើការងារបង្កើនចំណូល ហើយតួលេខសំរាប់អំឡុងពេល ៥ឆ្នាំមុន គឺ ៧៧% និង ២៣% ។ ក្នុងចំណាយប្រភេទទីមួយ ចំណាយលើម្ហូបអាហារ និងការប្រើប្រាស់ទូទៅ មានច្រើនជាងគេ បន្ទាប់មក គឺចំណាយសងបំណុល និងការព្យាបាលជម្ងឺ ។ ចំណាយ

លើទ្រព្យប្រើបានយូរ និងផ្ទះសំបែងក៏ប្រើប្រាក់ផ្ញើទៅផ្ទះអស់ច្រើនណាស់ដែរ ។ ប៉ុន្តែជាអកុសល មានការចំណាយតិចតួចតែប៉ុណ្ណោះទៅលើការអភិវឌ្ឍធនធានមនុស្ស ។ ក្នុងអំឡុងពេល ១ឆ្នាំមុន មានប្រាក់ផ្ញើទៅផ្ទះតែ ៤% ប៉ុណ្ណោះ ដែលគេរាយការណ៍ថា បានចំណាយទៅលើការអប់រំ និងបណ្តុះបណ្តាល ។

**តារាង ៣.១៦: ការប្រើប្រាស់ប្រាក់ផ្ញើទៅផ្ទះ តាមការរាយការណ៍របស់ក្រុមគ្រួសារ**

| | ក្នុងអំឡុងពេល ១ឆ្នាំមុន | ក្នុងអំឡុងពេល ៥ឆ្នាំមុន |
|---|---|---|
| ចំណាយប្រើប្រាស់ | **81%** | **77%** |
| ចំណាយប្រើប្រាស់/ចំណាយទូទៅ (ភាគច្រើនលើអាហារ) | 23% | 20% |
| សងបំណុល | 14% | 12% |
| ព្យាបាលជម្ងឺ | 12% | 8% |
| ទិញទ្រព្យមិនមែនផលិតកម្ម (ដីទំនេរ ទូរទស្សន៍) | 7% | 5% |
| អប់រំ និងបណ្តុះបណ្តាល | 4% | 2% |
| កែលម្អផ្ទះសំបែង | 3% | 3% |
| ថែទាំ/ជួលជុលផ្ទះ | 3% | 3% |
| សាងសង់ផ្ទះ | 4% | 15% |
| របស់ប្រើប្រាស់បានយូរក្នុងផ្ទះ (បរិក្ខារប្រើប្រាស់បានយូរ) | 8% | 7% |
| ឱ្យប្រាក់គេខ្ចីដោយមិនយកការប្រាក់ | 4% | 2% |
| ចំណាយផលិតកម្ម | **19%** | **23%** |
| ទិញដីកសិកម្ម | 7% | 3% |
| ទិញដីសំរាប់ផលិតកម្ម | 3% | 5% |
| ទិញម៉ាស៊ីនសំរាប់ផលិតកម្មកសិកម្ម | 2% | 4% |
| ទិញម៉ូតូ ឬយានយន្តសំរាប់បម្រើអាជីវកម្ម | 0% | 2% |
| វិនិយោគក្នុងអាជីវកម្មថ្មី | 1% | 1% |
| ពង្រីកអាជីវកម្មកំពុងដំណើរការ | 1% | 0% |
| ឱ្យប្រាក់គេខ្ចីដើម្បីបានការប្រាក់ | 0% | 1% |
| ចំណាយផ្សេងទៀតទៅលើទ្រព្យផលិតកម្ម ឬអាជីវកម្ម | 5% | 6% |
| ចំណាយសរុបនៃប្រាក់ផ្ញើទៅផ្ទះ | **100%** | **100%** |

*ប្រភព: អង្កេតធ្វើឡើងដោយ CDRI នាខែកញ្ញា និងតុលា ២០០៧*

គួរកត់សម្គាល់ថា នៅអំឡុងពេល ១ឆ្នាំមុន គ្រួសារពលករចំណាយប្រាក់ផ្ញើទៅផ្ទះមួយចំនួនធំទៅលើការទិញដី ទិញដីដាំដុះ និងទិញម៉ាស៊ីនសំរាប់ការងារកសិកម្ម ។ គេរាយការណ៍ថា ចំណាយទិញរបស់ទាំងនេះបានហុចផលចំណេញច្រើនគួរសម ដូចមានចុះសង្ខេបក្នុងតារាង ៣.១៧ ។ ច្បាស់ណាស់ ប្រាក់ដែលពលករចំណាកស្រុកផ្ញើទៅផ្ទះ មិនមែនប្រើប្រាស់តែទៅលើចំណាយមិនមែនគោលដៅផលិតកម្មប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងទៅលើចំណាយវិនិយោគដែលហុចផលចំណេញខ្ពស់ផងដែរ ។ នៅភូមិសិក្សាមួយចំនួន អ្នកចូលរួមក្នុង FGD បានរាយការណ៍ពីការសាងសង់ផ្ទះថ្មីជាច្រើន ដោយប្រើប្រាស់ប្រាក់ផ្ញើទៅផ្ទះនេះ ។ ពលករវ័យក្មេងទំនងជាប្រើប្រាស់ប្រាក់ផ្ញើទៅផ្ទះ

សំរាប់ទិញទូរស័ព្ទដៃ និងម៉ូតូ ។ គេសង្ឃឹមថា នៅពេលតម្រូវការចាំបាច់នានាបានបំពេញរួចរាល់ហើយ នឹងមានប្រាក់ផ្ញើទៅផ្ទះកាន់តែច្រើនដែលប្រើប្រាស់សំរាប់គោលដៅផលិតកម្ម ។

**តារាង ៣.១៧: ភាគរយនៃផលចំណេញបានពីការយកប្រាក់ផ្ញើទៅផ្ទះ ទៅទិញទ្រព្យផលិតកម្ម**

| | ក្នុងអំឡុងពេល ១ឆ្នាំមុន | ក្នុងអំឡុងពេល ៥ឆ្នាំមុន |
|---|---|---|
| ទិញម៉ូតូ ឬយានយន្តសំរាប់បម្រើអាជីវកម្ម | - | 8% |
| ទិញដីសំរាប់ផលិតកម្ម | 34% | 18% |
| ទិញដីកសិកម្ម | 34% | 62% |
| វិនិយោគក្នុងអាជីវកម្មថ្មី | 0% | 21% |
| ពង្រីកអាជីវកម្មកំពុងដំណើរការ | 66% | 133% |
| ឱ្យប្រាក់គេខ្ចីដើម្បីបានការប្រាក់ | 71% | 38% |
| ចំណាយផ្សេងទៀតលើទ្រព្យផលិតកម្ម ឬអាជីវកម្ម | 23% | 28% |
| សរុប | 27% | 26% |

*ប្រភព: អង្កេតធ្វើឡើងដោយ CDRI នាខែកញ្ញា និងតុលា ២០០៧*

### ៣.២.៩. ការប្រៀបធៀបទ្រព្យសម្បត្តិរបស់គ្រួសារដែលមាន និងគ្មានសមាជិកធ្វើចំណាកស្រុក

ជាទូទៅ មានសំនួរមួយថា តើគ្រួសារមានសមាជិកធ្វើចំណាកស្រុក តែងមានជីវភាពប្រសើរជាង ឬយ៉ាប់យ៉ឺនជាងគ្រួសារគ្មានសមាជិកធ្វើចំណាកស្រុក? អាចមានសម្មតិកម្មពីរខុសគ្នា គឺ ១-គ្រួសារមានប្រាក់ចំណូលច្រើនជាងមុនបន្ទាប់ពីមានសមាជិកធ្វើចំណាកស្រុក និង ២-ដំបូងឡើយ គ្រួសារនោះមានជីវភាពក្រីក្រ ដូច្នេះហើយ ទើបបញ្ជូនសមាជិកឱ្យទៅធ្វើការនៅក្រៅប្រទេស ។ ការសិក្សារកឃើញថា រឿងនេះអាស្រ័យលើកត្តាមួយចំនួន ដូចជា លំនាំនៃការកាន់កាប់ដីនៅក្នុងភូមិចំណាយធ្វើចំណាកស្រុកទៅថៃ ឬម៉ាឡេស៊ី និងប្រាក់ចំណូល ។ តារាង ៣.១៨ បង្ហាញពីប្រាក់ចំណូលគ្រួសារលំអិតតាមប្រភពនីមួយៗ ដើម្បីងាយប្រៀបធៀប ។ ភូមិគោកធ្លង់ មានជីវភាពធូរធារជាងគេក្នុងចំណោមភូមិទាំង ៦ ដោយគ្រួសារមួយជាមធ្យម រកបាន ៣០០០ដុល្លារក្នុងមួយឆ្នាំ ចំណែកឯនៅភូមិរំដួលដែលក្រីក្រជាងគេវិញ គ្រួសារមួយ អាចរកបានពី ១០០០ដុល្លារ-១៥០០ដុល្លារប៉ុណ្ណោះ ។

គ្រួសារដែលគ្មានសមាជិកធ្វើចំណាកស្រុក ច្រើនតែរកចំណូលបានច្រើនពីកសិកម្ម និងប្រភពដទៃទៀត ដែលនាំឱ្យចំណូលសរុបកើនឡើងដែរ ។ រឿងនេះពិតណាស់នៅក្នុងភូមិដែលភាពគ្មានដីមានកំរិតខ្ពស់ (ក្រសាំង គោកធ្លង់ និងសៀមពាយ) ។ នៅភូមិក្រសាំង ប្រជាជនជិត ៥០% គ្មានដីកសិកម្មទេ ហើយពឹងផ្អែកយ៉ាងខ្លាំងលើចំណាកស្រុកទៅធ្វើការនៅថៃ ប៉ុន្តែភូមិខ្ទយខុសប្លែកពីគេ ដោយគ្រួសារមានសមាជិកធ្វើចំណាកស្រុក អាចរកចំណូលបានច្រើនជាងគ្រួសារគ្មានសមាជិកធ្វើចំណាកស្រុក ។ ភូមិនេះនៅឆ្ងាយពីប្រទេសថៃ ហើយពលករម្នាក់ៗត្រូវចំណាយអស់ប្រហែល ១០០ដុល្លារ ដើម្បីឆ្លងដែនចូលទៅធ្វើការក្នុងឧស្សាហកម្មនេសាទនៅតំបន់ឆ្នេរសមុទ្រថៃ ។ ជាទូទៅ គ្រួសារក្រីក្រពុំមានលទ្ធភាពដោះស្រាយចំណាយឆ្លងដែននេះបានទេ ។

**តារាង ៣.១៨: ប្រាក់ចំណូលប្រចាំឆ្នាំរបស់ក្រុមគ្រួសារ (ដុល្លារ)**

| ភូមិ | ស្រម៉ាស | | ក្រសាំង | | គោកធ្លង់ | | រំដួល | | សៀមពាយ | | ខ្ទយ | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | MG | No MG | MG | No MG | MG | No MG | MG | No MG | MG | No MG | MG | No MG |
| លក់ផលដំណាំ | 382 | 355 | 196 | 428 | 433 | 599 | 59 | 153 | 55 | 47 | 1,062 | 586 |
| លក់ជ្រូក | - | - | 4 | 5 | 57 | 159 | 97 | 83 | 13 | 31 | 48 | 24 |
| លក់គោក្របី | 79 | 127 | 17 | 8 | 16 | - | 43 | 14 | 8 | 6 | 142 | 35 |
| លក់មាន់ទា | 7 | 7 | 3 | 1 | 1 | 15 | 15 | 10 | 7 | 8 | 3 | 5 |
| **លក់កសិផល** | **468** | **489** | **220** | **442** | **508** | **774** | **214** | **260** | **82** | **92** | **1,255** | **649** |
| ធ្វើការនៅជ្រៅក្នុងប្រទេសថៃ | - | - | 137 | - | 445 | - | 245 | - | 36 | - | 307 | - |
| ធ្វើការនៅថៃជិតព្រំដែន | 0 | - | 346 | - | 22 | - | 3 | - | 222 | - | - | - |
| ធ្វើការនៅកម្ពុជាជិតព្រំដែន | - | - | 6 | 20 | - | - | - | 7 | 1 | - | - | - |
| ធ្វើការនៅម៉ាឡេស៊ី | 123 | - | 3 | - | - | - | - | - | - | - | - | - |
| ធ្វើការនៅតំបន់ផ្សេងនៅកម្ពុជា | 26 | 3 | 6 | 66 | 87 | 236 | 16 | 79 | 35 | 206 | 119 | 136 |
| បានពីសាច់ញាតិនៅបរទេស | 13 | 14 | - | 224 | 24 | 102 | 2 | 5 | 4 | 54 | 5 | 80 |
| **ប្រាក់ផ្ញើទៅផ្ទះសរុប** | **163** | **16** | **497** | **309** | **579** | **337** | **266** | **92** | **299** | **260** | **430** | **216** |
| ការនេសាទ | 8 | 25 | 95 | 85 | 0 | 2 | 37 | 20 | 7 | 9 | - | 2 |
| ការដើរបេះបោចរកអាហារ | - | 0 | 2 | - | - | 8 | - | 2 | 3 | - | - | - |
| ធនធានទ្រព្យរួមដទៃទៀត | 0 | 10 | - | 9 | - | - | 2 | 12 | 1 | - | - | - |
| **ចំណូលសរុបបានពីធនធានទ្រព្យរួម** | **8** | **35** | **96** | **94** | **0** | **10** | **40** | **34** | **11** | **9** | **-** | **2** |
| អាជីវកម្ម/ពាណិជ្ជកម្មខ្នាតតូច | 67 | 55 | 84 | 382 | 109 | 380 | 50 | 270 | 94 | 310 | 91 | 56 |
| ការជួល និងការប្រាក់ | 13 | 5 | - | 20 | 22 | 16 | 45 | 1 | 5 | 8 | 9 | 5 |
| ផ្សេងៗ | 79 | 65 | 85 | 70 | 18 | 198 | 119 | 102 | 17 | 176 | 64 | 121 |
| **ចំណូលផ្សេងៗសរុប** | **893** | **812** | **1,117** | **1,790** | **1,386** | **2,313** | **941** | **1,132** | **630** | **1,356** | **1,977** | **1,235** |
| **ចំណូលសរុប** | **1,533** | **1,353** | **1,930** | **2,635** | **2,474** | **3,433** | **1,460** | **1,518** | **1,022** | **1,717** | **3,663** | **2,101** |

*សម្គាល់ MG = គ្រួសារមានសមាជិកធ្វើចំណាកស្រុកក្នុងរយៈពេល ៥ឆ្នាំចុងក្រោយ*

*ប្រភព: អង្កេតធ្វើឡើងដោយ CDRI នាខែកញ្ញា និងតុលា ២០០៧*

ការប្រៀបធៀបការចំណាយក្នុងគ្រួសារជាបន្ថែមលើការប្រៀបធៀបប្រាក់ចំណូល ក៏សំខាន់ណាស់ដែរ ។ តារាង ៣.១៩ និង ៣.២០ បង្ហាញពីភាពខុសគ្នារវាងចំណាយរបស់គ្រួសារដែលមាន និងគ្មានសមាជិកធ្វើចំណាកស្រុក ។ ស្របគ្នានឹងលំនាំប្រាក់ចំណូលដូចពិពណ៌នាខាងលើ គ្រួសារគ្មានសមាជិកធ្វើចំណាកស្រុកនៅភូមិក្រសាំង គោកធ្លង់ រំដួល និងសៀមពាយ មានការចំណាយច្រើនជាងគ្រួសារដែលមានសមាជិកធ្វើចំណាកស្រុក ។ ការចំណាយមិនខុសគ្នាច្រើនទេ

សំរាប់សំលៀកបំពាក់ និងការជួសជុលផ្ទះ ប៉ុន្តែវាខុសគ្នាច្រើនលើការរៀបចំអាពាហ៍ពិពាហ៍ និងពិធីផ្សេងៗរវាងភូមិទីមួយៗ និងរវាងគ្រួសារដែលមាន និងគ្មានសមាជិកធ្វើចំណាកស្រុក ។ គួរកត់សម្គាល់ដែរថា នៅភូមិចាមមិនសូវមានការចំណាយច្រើនៗសំរាប់ពិធីដូចខាងលើទេ ដោយសារគេមានប្រពៃណី និងទំនៀមទំលាប់រស់នៅខុសគ្នា ។

**តារាង ៣.១៩: ចំណាយគ្រួសារក្នុងអំឡុងពេល ១ឆ្នាំមុន ទៅលើទំនិញមិនមែនអាហារ (ដុល្លារ)**

| ភូមិ | ប្រភេទគ្រួសារ | សំលៀកបំពាក់ | ព្យាបាលជម្ងឺ | មង្គលការ និងបុណ្យផ្សេងៗ | ជួលជុលផ្ទះ និងរបស់ប្រើប្រាស់ | ផ្សេងៗក្រៅពីម្ហូបអាហារ | សរុប |
|---|---|---|---|---|---|---|---|
| ស្រម៉មាស | MG | 58 | 90 | 45 | 73 | 43 | 366 |
| | No MG | 45 | 93 | 33 | 64 | 25 | 316 |
| ក្រសាំង | MG | 66 | 121 | 123 | 15 | 26 | 357 |
| | No MG | 54 | 78 | 159 | 218 | 34 | 754 |
| គោកធ្នង់ | MG | 63 | 137 | 171 | 104 | 49 | 607 |
| | No MG | 65 | 137 | 346 | 60 | 86 | 728 |
| រំដួល | MG | 56 | 127 | 105 | 96 | 27 | 504 |
| | No MG | 44 | 196 | 105 | 92 | 43 | 565 |
| សៀមពាយ | MG | 42 | 76 | 76 | 80 | 33 | 382 |
| | No MG | 38 | 126 | 176 | 50 | 71 | 486 |
| ខ្នាយ | MG | 54 | 126 | 98 | 134 | 98 | 608 |
| | No MG | 47 | 82 | 92 | 133 | 89 | 545 |

*សម្គាល់ MG = គ្រួសារមានសមាជិកធ្វើចំណាកស្រុកក្នុងរយៈពេល ៥ឆ្នាំចុងក្រោយ*

*ប្រភព: អង្កេតធ្វើឡើងដោយ CDRI នាខែកញ្ញា និងតុលា ២០០៧*

**តារាង ៣.២០: ចំណាយជាមធ្យមរបស់គ្រួសារក្នុងរយៈពេល ១ខែ ទៅលើទំនិញមិនមែនអាហារ (ដុល្លារ)**

| ភូមិ | ប្រភេទគ្រួសារ | សាប៊ូ និងផលិតផលថែទាំខ្លួន | ការអប់រំ | ការហូបអាហារនៅក្រៅផ្ទះ | ទឹកភ្លើង | សរុប |
|---|---|---|---|---|---|---|
| ស្រម៉មាស | MG | 2 | 6 | 3 | 1 | 12 |
| | No MG | 2 | 4 | 3 | 3 | 11 |
| ក្រសាំង | MG | 3 | 4 | 8 | 2 | 17 |
| | No MG | 2 | 6 | 5 | 3 | 16 |
| គោកធ្នង់ | MG | 5 | 7 | 5 | 4 | 21 |
| | No MG | 7 | 8 | 8 | 6 | 29 |
| រំដួល | MG | 2 | 6 | 2 | 2 | 12 |
| | No MG | 2 | 4 | 3 | 3 | 13 |
| សៀមពាយ | MG | 2 | 2 | 1 | 2 | 6 |
| | No MG | 2 | 5 | 3 | 4 | 14 |
| ខ្នាយ | MG | 2 | 4 | 2 | 1 | 10 |
| | No MG | 2 | 4 | 2 | 1 | 9 |

*សម្គាល់ MG = គ្រួសារមានសមាជិកធ្វើចំណាកស្រុកក្នុងរយៈពេល ៥ឆ្នាំចុងក្រោយ*

*ប្រភព: អង្កេតធ្វើឡើងដោយ CDRI នាខែកញ្ញា និងតុលា ២០០៧*

ចំណាយលើម្ហូបអាហាររបស់គ្រួសារដែលមាន និងគ្មានសមាជិកធ្វើចំណាកស្រុក មិនសូវខុសគ្នាខ្លាំងទេ ។ ជាមធ្យម គ្រួសារមួយ ចំណាយ ១២ដុល្លារក្នុងមួយសប្ដាហ៍លើម្ហូបអាហារ ឬតិចជាង ២ដុល្លារក្នុងមួយថ្ងៃ ។ ប៉ុន្តែកំរិតចំណាយលើម្ហូបអាហារ មិនឆ្លុះបញ្ចាំងពីស្ថានភាពសេដ្ឋកិច្ចរបស់ភូមិទេ ដោយសារតម្លៃម្ហូបអាហារ ប្រែប្រួលខុសគ្នាពីភូមិមួយទៅភូមិមួយ តែវាបង្ហាញអំពីភាពខុសគ្នារវាងគ្រួសារដែលមាន និងគ្មានសមាជិកធ្វើចំណាកស្រុក ដែលការសិក្សាផ្ដោតការចាប់អារម្មណ៍ ។ យោងតាមតារាងទាំង ៣ (៣.១៩ ៣.២០ និង៣.២១) យើងអាចសន្និដ្ឋានបានថា គ្រួសារដែលមាន និងគ្មានសមាជិកធ្វើចំណាកស្រុក មិនមានភាពខុសគ្នាច្រើនទេពាក់ព័ន្ធនឹងចំណាយលើម្ហូបអាហារ ដែលជាមូលដ្ឋាននៃសុខុមាលភាព ។

**តារាង ៣.២១: ចំណាយរបស់គ្រួសារលើម្ហូបអាហារក្នុងអំឡុង ១សប្ដាហ៍មុន (ដុល្លារ)**

| ភូមិ | ប្រភេទគ្រួសារ | អង្ករ | សាច់ | ត្រី | ស៊ុត | បន្លែ | អាហារផ្សេងៗ | សរុប |
|---|---|---|---|---|---|---|---|---|
| ស្រម៉មាស | MG | 7.08 | 1.88 | 3.17 | 0.41 | 1.14 | 0.34 | 14.03 |
| | No MG | 5.07 | 1.10 | 2.98 | 0.89 | 1.70 | 0.35 | 12.10 |
| ក្រសាំង | MG | 5.29 | 1.87 | 4.08 | 0.29 | 0.88 | 0.86 | 13.28 |
| | No MG | 4.16 | 2.45 | 3.17 | 0.26 | 1.01 | 1.29 | 12.34 |
| គោកធ្លង់ | MG | 3.64 | 3.17 | 3.20 | 0.19 | 1.31 | 1.17 | 12.68 |
| | No MG | 3.57 | 3.38 | 3.24 | 0.18 | 1.33 | 1.82 | 13.53 |
| រំដួល | MG | 5.61 | 2.28 | 2.67 | 0.12 | 1.18 | 0.80 | 12.66 |
| | No MG | 5.02 | 2.57 | 2.31 | 0.16 | 1.15 | 0.51 | 11.72 |
| សៀមពាយ | MG | 4.00 | 0.77 | 3.21 | 0.07 | 0.93 | 0.49 | 9.46 |
| | No MG | 3.50 | 1.70 | 3.01 | 0.26 | 0.95 | 0.81 | 10.22 |
| ខ្នាយ | MG | 3.50 | 1.17 | 2.73 | 0.12 | 0.98 | 0.78 | 9.29 |
| | No MG | 3.41 | 1.17 | 2.53 | 0.19 | 0.86 | 0.59 | 8.75 |

*សម្គាល់ MG = គ្រួសារមានសមាជិកធ្វើចំណាកស្រុកក្នុងរយៈពេល ៥ឆ្នាំចុងក្រោយ*

*ប្រភពៈ អង្កេតធ្វើឡើងដោយ CDRI នាខែកញ្ញា និងតុលា ២០០៧*

### ៣.២.១០. ការប្រៀបធៀបគ្រួសារដែលមាន និងគ្មានសមាជិកធ្វើចំណាកស្រុកក្នុងចន្លោះឆ្នាំ២០០២-២០០៧

ការសិក្សាព្យាយាមវាយតម្លៃពីផលប៉ះពាល់នៃចំណាកស្រុករបស់ពលករទៅលើសុខុមាលភាពគ្រួសារ ។ វិធីល្អបំផុត គឺការដឹងច្បាស់ពីអ្វីដែលត្រូវកើតឡើង ប្រសិនបើគ្រួសារមិនមានសមាជិកធ្វើចំណាកស្រុក ។ ប៉ុន្តែ រឿងនេះមិនអាចធ្វើទៅបានទេ ។ អ្វីដែលយើងអាចសន្និដ្ឋានបាន គឺដោយសារប្រជាជនមួយចំនួនបានធ្វើចំណាកស្រុក ដូចនេះមានការប្រកួតប្រជែង ឬមានពលករតិចជាងមុន ស្វែងរកការងារនៅក្នុងសហគមន៍ ឬនៅក្នុងប្រទេសកម្ពុជា ។ និន្នាការនេះ អាចជួយជំរុញកំណើនប្រាក់កម្រៃរបស់ពលករដែលមិនធ្វើចំណាកស្រុក ។ សំនួរជាទូទៅមួយដែលការសិក្សានេះព្យាយាមផ្ដល់ចម្លើយ គឺ "តើគ្រួសារណាមានជីវភាពប្រសើរឡើងៈ គ្រួសារមានសមាជិកធ្វើចំណាកស្រុក ឬក៏គ្រួសារគ្មានសមាជិកធ្វើចំណាកស្រុក?"

ការសិក្សាខិតខំពិនិត្យក្នុងអំឡុងពេល ៥ឆ្នាំមុន ដូច្នេះ នៅក្នុងអង្កេត យើងបានសុំឱ្យអ្នកឆ្លើយសម្ភាសន៍ខំរកនឹកនូវសូចនាករគន្លឹះមួយចំនួនពាក់ព័ន្ធនឹងគ្រួសាររបស់ពួកគេក្នុងអំឡុងពេល ៥ឆ្នាំមុននេះ ហើយយកមកប្រៀបធៀបនឹងស្ថានភាពបច្ចុប្បន្ន ។ យើងបានដឹងច្បាស់ពីបញ្ហាភ្លេចភ្លាំង ដូច្នេះ ក៏បានសាកសួរតែពីទ្រព្យចំបងៗ ដែលពួកគេច្រើនតែអាចចងចាំបានច្បាស់ ។

គិតជារួម ការប្រែប្រួលពាក់ព័ន្ធនឹងប្រភេទផ្ទះក្នុងភូមិទាំង ៦ មានលក្ខណៈដូចគ្នាសំរាប់គ្រួសារទាំងពីរក្រុម (មាន និងគ្មានសមាជិកធ្វើចំណាកស្រុក) ។ គួរកត់សម្គាល់ថា ភាគរយនៃផ្ទះប្រក់ក្បឿងដែលជាប្រភេទផ្ទះល្អបំផុតនៅតាមភូមិភាគច្រើនក្នុងប្រទេសកម្ពុជា នៅថេរដដែលពីឆ្នាំ២០០២-២០០៧ ទាំងសំរាប់គ្រួសារមានសមាជិកធ្វើចំណាកស្រុក (៣៣%) និងគ្រួសារគ្មានសមាជិកចំណាកស្រុក (២៧%) ។ គ្រួសារទាំងពីរក្រុម បានឈានឡើងដោយបានប្តូរពីផ្ទះស្លឹក ទៅជាផ្ទះឈើប្រក់ស័ង្កសី ដែលជាផ្ទះប្រភេទមធ្យមនៅក្នុងភូមិ ។ ផ្ទះប្រភេទនេះ កើនឡើង ៥០% ក្នុងអំឡុងពេល ៥ឆ្នាំ ចុងក្រោយ (តារាង ៣.២២) ។

**តារាង ៣.២២: ប្រភេទផ្ទះនៅឆ្នាំ២០០២ និង ២០០៧**

| ភូមិ | ប្រភេទគ្រួសារ | ផ្ទះស្លឹក | | ផ្ទះឈើប្រក់ស័ង្កសី | | ផ្ទះឈើប្រក់ក្បឿង | | ផ្ទះប្រភេទផ្សេងទៀត | |
|---|---|---|---|---|---|---|---|---|---|
| | | 2002 | 2007 | 2002 | 2007 | 2002 | 2007 | 2002 | 2007 |
| ស្រម៉មាស | MG | 52 | 15 | 29 | 52 | 17 | 29 | 2 | 4 |
| | No MG | 50 | 18 | 35 | 56 | 15 | 26 | - | - |
| ក្រសាំង | MG | 34 | 10 | 66 | 90 | | | - | - |
| | No MG | 37 | 10 | 61 | 85 | | | 3 | 5 |
| គោកធ្លង់ | MG | 19 | - | 67 | 86 | 11 | 11 | 3 | 3 |
| | No MG | - | - | 57 | 59 | 37 | 34 | 7 | 6 |
| រំដួល | MG | 49 | 18 | 39 | 70 | 10 | 9 | 2 | 2 |
| | No MG | 54 | 28 | 46 | 72 | | | - | - |
| សៀមពាយ | MG | 21 | 14 | 18 | 28 | 59 | 56 | 2 | 2 |
| | No MG | - | 4 | 41 | 52 | 59 | 43 | - | - |
| ខ្នាយ | MG | 4 | 2 | 10 | 16 | 82 | 76 | 4 | 5 |
| | No MG | 4 | | 7 | 11 | 85 | 89 | 4 | - |
| ភូមិទាំងអស់ | MG | 29 | 10 | 36 | 54 | 33 | 33 | 2 | 3 |
| | No MG | 28 | 12 | 43 | 60 | 27 | 27 | 2 | 2 |

*ប្រភព: អង្កេតធ្វើឡើងដោយ CDRI នាខែកញ្ញា និងតុលា ២០០៧*

ពីភូមិមួយទៅភូមិមួយ ការប្រែប្រួលមានកំរិតខុសៗគ្នា ។ ចំនួនផ្ទះប្រភេទល្អបំផុតរបស់គ្រួសារទាំងពីរក្រុម បានកើនឡើងជិតមួយជាពីរនៅភូមិស្រម៉មាសដែលជាភូមិចាម និងមានពលករយ៉ាងច្រើនធ្វើចំណាកស្រុកទៅធ្វើការនៅម៉ាឡេស៊ី ហើយមានការចំណាយតិចលើមង្គលការ ពិធីផ្សេងៗ និងការជប់លៀងជាដើម ។ នៅឆ្នាំ២០០២ មានផ្ទះ ៥១% ជាផ្ទះស្លឹក ប៉ុន្តែនៅឆ្នាំ២០០៧ ផ្ទះប្រភេទនេះ បានថយចុះមកត្រឹម ១៦% ។ នៅ ៥ភូមិផ្សេងទៀត ដែលមានផ្ទះប្រក់ក្បឿងច្រើនជាងស្រាប់ហើយតាំងពីឆ្នាំ២០០២ គេមិនឃើញមានកំណើនថែមអ្វីទេនៅឆ្នាំ២០០៧ ហើយការប្រែប្រួលសំខាន់ គឺពីផ្ទះស្លឹកទៅជាផ្ទះប្រក់ស័ង្កសី ។

នៅភូមិគោកធ្លង់ កាលពីឆ្នាំ២០០២ គ្រួសារគ្មានសមាជិកធ្វើចំណាកស្រុក មិនមែនជាគ្រួសារមានផ្ទះស្លឹកនោះទេ ប៉ុន្តែគឺគ្រួសារមានសមាជិកធ្វើចំណាកស្រុក ១៩% ដែលរស់នៅក្នុងផ្ទះស្លឹក ។ នៅឆ្នាំ២០០៧ គ្រួសារទាំងអស់ មានផ្ទះល្អៗជាងមុន ។ នៅក្នុងភូមិសៀមពាយ ក៏មានការប្រែប្រួលដូចគ្នានេះដែរ ។ នៅឆ្នាំ២០០២ គ្រួសារគ្មានសមាជិកធ្វើចំណាកស្រុក មានផ្ទះគ្រាន់បើជាងប្រភេទផ្ទះស្លឹកបន្តិច ប៉ុន្តែ ២១%នៃគ្រួសារមានសមាជិកធ្វើចំណាកស្រុក

មានតែផ្ទះស្លឹកប៉ុណ្ណោះ ។ នៅឆ្នាំ២០០៧ មានគ្រួសារ ១៤% ប៉ុណ្ណោះ ដែលមានផ្ទះស្លឹក ។ ទោះជាយ៉ាងនេះក្តី ភាគរយគ្រួសារគ្មានសមាជិកធ្វើចំណាកស្រុកដែលមានផ្ទះក្បឿង បានធ្លាក់ចុះពី ៥៩% មកត្រឹម ៤៣% ។

តារាង ៣.២៣ ផ្តល់នូវតម្លៃផ្ទះ ។ ជាទូទៅ មានកំណើនយ៉ាងច្រើននៃតម្លៃផ្ទះរបស់គ្រួសារទាំងពីរក្រុម ។ កំណើនមានធំជាងសំរាប់គ្រួសារមានសមាជិកធ្វើចំណាកស្រុកនៅភូមិស្រម៉មាស ក្រសាំង គោកធ្នង់ និងសៀមពាយ ប៉ុន្តែវាមានការវិវត្តផ្ទុយ នៅភូមិរំដួល និងភូមិខ្ទុយ ។ ជាទូទៅ តម្លៃផ្ទះរបស់គ្រួសារមានសមាជិកធ្វើចំណាកស្រុកតែងខ្ពស់ជាងតម្លៃផ្ទះរបស់គ្រួសារគ្មានសមាជិកធ្វើចំណាកស្រុក ។ ដូច្នេះ បើគិតតាមផ្ទះសំបែង គេអាចនិយាយថា គ្រួសារមានសមាជិកធ្វើចំណាកស្រុក ទំនងជាមានជីវភាពធូរធារជាង ។ នេះបង្ហាញឱ្យឃើញថា ប្រជាជនកម្ពុជាតែងឱ្យតម្លៃខ្ពស់ទៅលើផ្ទះសំបែង ។ របស់ទី១ ដែលគ្រួសារហ៊ានយកប្រាក់សន្សំយ៉ាងច្រើនទៅចំណាយលើ គឺផ្ទះសំបែង បើយោងតាមសំដីរបស់អ្នកចូលរួមនៅក្នុងការពិភាក្សាតាមក្រុមស្នូល ។

**តារាង ៣.២៣: តម្លៃផ្ទះនៅឆ្នាំ២០០២ និង ២០០៧** (ដុល្លារ)

| ភូមិ | ប្រភេទគ្រួសារ | តម្លៃផ្ទះនៅឆ្នាំ២០០២ | | តម្លៃផ្ទះនៅឆ្នាំ២០០៧ | | អត្រាប្រែប្រួល | |
|---|---|---|---|---|---|---|---|
| | | មធ្យម | គំលាតស្តង់ដារ | មធ្យម | គំលាតស្តង់ដារ | មធ្យម | % |
| ស្រម៉មាស | MG | 498 | 697 | 1,249 | 1,626 | 751 | 151 |
| | No MG | 418 | 434 | 793 | 621 | 375 | 90 |
| ក្រសាំង | MG | 298 | 410 | 1,398 | 3,457 | 1,100 | 370 |
| | No MG | 389 | 604 | 1,139 | 1,670 | 751 | 193 |
| គោកធ្នង់ | MG | 1,565 | 1,785 | 2,709 | 2,542 | 1,144 | 73 |
| | No MG | 3,020 | 3,279 | 3,434 | 2,414 | 414 | 14 |
| រំដួល | MG | 809 | 1,225 | 1,347 | 1,473 | 539 | 67 |
| | No MG | 695 | 871 | 1,271 | 1,437 | 576 | 83 |
| សៀមពាយ | MG | 672 | 565 | 1,290 | 1,014 | 618 | 92 |
| | No MG | 591 | 374 | 914 | 738 | 322 | 54 |
| ខ្ទុយ | MG | 1,469 | 967 | 1,936 | 1,104 | 467 | 32 |
| | No MG | 1,216 | 554 | 1,822 | 943 | 607 | 50 |

*ប្រភពៈ អង្កេតធ្វើឡើងដោយ CDRI នាខែកញ្ញា និងតុលា ២០០៧*

គ្រួសារគ្មានសមាជិកធ្វើចំណាកស្រុក តែងមាន និងបង្កើនទ្រព្យមិនមែនហិរញ្ញវត្ថុជាជាងទ្រព្យមិនមែនជាដីធ្លី ។ រឿងនេះបង្ហាញពីភាពចាំបាច់ដែលពួកគេត្រូវមានមធ្យោបាយផ្សេងទៀតសំរាប់រកប្រាក់ចំណូល ។ ចំណុចដែលខុសពីការគិតឃើញតាមធម្មតា គឺគ្រួសារមានសមាជិកធ្វើចំណាកស្រុក ច្រើនតែមានសត្វចិញ្ចឹមច្រើនជាងគ្រួសារគ្មានសមាជិកធ្វើចំណាកស្រុក (តារាង ៣.២៤) ។ ពួកគេមួយចំនួន បានចំណាយប្រាក់ដែលសមាជិកផ្ញើមកផ្ទះទៅលើការចិញ្ចឹមសត្វដែលជាវិធីពេញនិយមសំរាប់ប្រើប្រាស់ប្រាក់សន្សំឱ្យមានផលិតភាព និងជាយុទ្ធសាស្ត្រមូលដ្ឋានក្នុងការបង្កើនទ្រព្យគ្រួសារ និងប្រាក់ចំណូល ។

**តារាង ៣.២៤: តម្លៃទ្រព្យសម្បត្តិរបស់គ្រួសារនៅឆ្នាំ២០០២ និង ២០០៧ (ដុល្លារ)**

| ភូមិ | ប្រភេទគ្រួសារ | ទ្រព្យសម្បត្តិក្រៅពីប្រាក់សន្សំ ដី និងផ្ទះ | | | | សត្វចិញ្ចឹម | | | |
|---|---|---|---|---|---|---|---|---|---|
| | | 2002 | 2007 | ការប្រែប្រួល | % | 2002 | 2007 | ការប្រែប្រួល | % |
| ស្រម៉មាស | MG | 95 | 259 | 164 | 172 | 724 | 992 | 268 | 37 |
| | No MG | 90 | 293 | 203 | 226 | 758 | 1,111 | 352 | 46 |
| ក្រសាំង | MG | 129 | 250 | 121 | 94 | 135 | 106 | (29) | -21 |
| | No MG | 246 | 952 | 706 | 287 | 115 | 96 | (19) | -17 |
| គោកធ្លង់ | MG | 318 | 971 | 653 | 205 | 76 | 114 | 39 | 52 |
| | No MG | 880 | 3,186 | 2,306 | 262 | 139 | 274 | 135 | 97 |
| រំដួល | MG | 283 | 541 | 258 | 91 | 434 | 508 | 74 | 17 |
| | No MG | 291 | 602 | 312 | 107 | 335 | 454 | 119 | 35 |
| សៀមពាយ | MG | 98 | 304 | 206 | 209 | 208 | 224 | 16 | 8 |
| | No MG | 111 | 426 | 314 | 283 | 136 | 206 | 71 | 52 |
| ខ្នាយ | MG | 538 | 1,165 | 627 | 117 | 604 | 546 | (59) | -10 |
| | No MG | 259 | 550 | 291 | 113 | 631 | 482 | (150) | -24 |

*ប្រភព: អង្កេតធ្វើឡើងដោយ CDRI នាខែកញ្ញា និងតុលា ២០០៧*

## ៣.២.១១. ចំណាយ និងផលចំណេញខាងហិរញ្ញវត្ថុរបស់បុគ្គលពលករចំណាកស្រុកទៅថៃ

តារាង ៣.២៥ ប្រៀបធៀបចំណាយ និងផលចំណេញខាងហិរញ្ញវត្ថុរបស់បុគ្គលពលករចំណាកស្រុកទៅថៃ ទាំងតាមវិធីស្របច្បាប់ និងខុសច្បាប់ ។ សំរាប់វិធីខុសច្បាប់ ចំណាកស្រុកអាចធ្វើឡើងជាប្រចាំថ្ងៃ ប្រចាំខែ និងប្រចាំឆ្នាំ ។ សំរាប់វិធីស្របច្បាប់ វាងាយស្រួលក្នុងការព្យាករណ៍ជាង ហេតុនេះ ចំណាយ និងផលចំណេញ ក៏អាចត្រូវបានប៉ាន់ស្មានសំរាប់អំឡុងពេល ២ឆ្នាំ និង ៤ឆ្នាំ ។ ពលករត្រូវបានបញ្ជូនទៅថៃផ្អែកលើអនុស្សរណៈនៃការយោគយល់គ្នា (MoU) សំរាប់រយៈពេល ២ឆ្នាំ និងអនុញ្ញាតឱ្យបន្តស្នាក់នៅធ្វើការបាន ២ឆ្នាំទៀត ។ ប្រាក់ចំណូលសុទ្ធសរុបក្នុងមួយឆ្នាំរបស់ពលករចំណាកស្រុកខុសច្បាប់ មានត្រឹមតែ ៣០០ដុល្លារប៉ុណ្ណោះ ខណៈដែលប្រាក់ចំណូលរបស់ពលករចំណាកស្រុកស្របច្បាប់ មានរហូតដល់ ១១៩០ដុល្លារ ។ រឿងនេះ គឺដោយសារអត្ថប្រយោជន៍សរុបបានមកពីការធ្វើការងារនៅក្រៅក្របខ័ណ្ឌ MoU មានត្រឹមតែ ១០០០ដុល្លារប៉ុណ្ណោះជាមធ្យម ធៀបនឹង ២៥៣០ដុល្លារ ដែលទទួលបានដោយពលករចំណាកស្រុកស្របច្បាប់ ។ គេឃើញច្បាស់ថា ចំណាកស្រុកតាមមធ្យោបាយស្របច្បាប់ វាប្រសើរជាងច្រើន បើគិតពីប្រាក់ចំណូល និងសុវត្ថិភាព ។

**តារាង ៣.២៥: ចំណាយ និងផលចំណេញខាងហិរញ្ញវត្ថុរបស់បុគ្គលពលករចំណាកស្រុកទៅថៃ (ដុល្លារ)**

| | ខុសច្បាប់ | | | ស្របច្បាប់ (MoU) | | | | |
|---|---|---|---|---|---|---|---|---|
| | ប្រចាំថ្ងៃ | ប្រចាំខែ | ប្រចាំឆ្នាំ | ប្រចាំថ្ងៃ | ប្រចាំខែ | ប្រចាំឆ្នាំ | ២ឆ្នាំ | ៤ឆ្នាំ |
| អត្ថប្រយោជន៍សរុប | **5** | **100** | **1,000** | **10** | **230** | **2,530** | **5,060** | **10,120** |
| ដោយផ្ទាល់ (ចំណូលសុទ្ធ) | 5 | 100 | 1,000 | 6 | 150 | 1,650 | 3,300 | 6,600 |
| បន្ថិចម្តងៗតាមពេលវេលា | | | | 4 | 80 | 880 | 1,760 | 3,520 |
| ចំណាយសរុប | **2** | **70** | **700** | **4** | **120** | **1,340** | **2,680** | **4,660** |
| ចំណាយថេរ | 0 | 10 | 100 | 1 | 30 | 350 | 700 | 700 |
| ចំណាយអថេរ | 2 | 60 | 600 | 3 | 90 | 990 | 1,980 | 3,960 |
| ចំណូលសុទ្ធសរុប | **3** | **30** | **300** | **6** | **110** | **1,190** | **2,380** | **5,460** |

*ប្រភព: អង្កេតធ្វើឡើងដោយ CDRI នាខែកញ្ញា និងតុលា ២០០៧*

### ៣.២.១២. អត្ថប្រយោជន៍ និងចំណាយផ្សេងទៀត

ការពិភាក្សាតាមក្រុមស្នូល ជាមួយគ្រួសារមានសមាជិកធ្វើចំណាកស្រុក បង្ហាញថា អត្ថប្រយោជន៍ផ្សេងទៀត ក្រៅពីប្រាក់ មានជាអាទិ៍ ការចេះភាសាថៃ ចំណេះធ្វើ (ដូចជា ការបើកឡានដឹកទំនិញ និងត្រាក់ទ័រ) ជំនាញជួសជុល ជំនាញសំណង់ និងជំនាញផ្សេងៗទៀតក្នុងរោងចក្រ ។

អត្ថប្រយោជន៍មានច្រើនក៏ពិតមែន ប៉ុន្តែពលករបានត្អូញត្អែរពីការលំបាក ដូចជា កង្វះកំលាំងពលកម្មក្នុងគ្រួសារ សំរាប់ជួយធ្វើការងារផ្ទះ កង្វះសមាជិកគ្រួសារសំរាប់មើលថែចាស់ៗនិងកូនក្មេង ចិញ្ចឹមសត្វ ដងទឹក រកអុស និងធ្វើស្រែចំការ ។ ឪពុកម្តាយ និងបងប្អូននៅផ្ទះ ក៏មានការបារម្ភខ្លាំងដែរអំពីសុវត្ថិភាព និងសុខុមាលភាពរបស់សមាជិកធ្វើចំណាកស្រុកទៅធ្វើការនៅស្រុកគេ ។ ពួកគាត់គិតដល់ការហូបចុក គ្រោះថ្នាក់ដែលអាចកើតមាននៅកន្លែងធ្វើការ ការប្រមាថមើលងាយពីអ្នកដទៃ ការផឹកស៊ីច្រើនពេក ទំនាស់ ការពាក់ព័ន្ធនឹងថ្នាំញៀន ហើយក៏ព្រួយបារម្ភផងដែរពីសុវត្ថិភាពរបស់កូនតូចៗដែលពលករយកទៅកន្លែងធ្វើការ ។

អ្នកចូលរួមក្នុងការសិក្សា បានអំពាវនាវដល់រដ្ឋាភិបាលឱ្យជួយសម្របសម្រួលបញ្ចុះតម្លៃចំណាកស្រុកតាមផ្លូវច្បាប់ឱ្យនៅទាបជាង ១០០ដុល្លារក្នុងម្នាក់សំរាប់រយៈពេល ១ឆ្នាំ ។ ពួកគេក៏បានបញ្ជាក់ពីការស្នើសុំលិខិតឆ្លងដែន និងលិខិតអនុញ្ញាតការងារ ដែលត្រូវចំណាយពេលយូរពេក ។

### ៣.២.១៣. ការយល់ឃើញផ្ទាល់ខ្លួននៃក្រុមគ្រួសារដែលមានសមាជិកធ្វើចំណាកស្រុក

ក្រុមសិក្សា បានស្នើសុំគ្រួសារមានសមាជិកធ្វើចំណាកស្រុក ឱ្យប្រៀបធៀបស្ថានភាពសេដ្ឋកិច្ច-សង្គមកិច្ចរបស់ខ្លួននាបច្ចុប្បន្នទៅនឹងគ្រួសារឯទៀតក្នុងភូមិ ។ គ្រួសារជាងពាក់កណ្តាល (៥៤%) យល់ថា ពួកគេមានស្ថានភាពមធ្យម និង ៣0% យល់ថា ពួកគេនៅក្រីក្រ ហើយ ៣% យល់ថា ខ្លួនឯងក្រីក្រខ្លាំង (ក្រាហ្វិក ៣.៣) ។ គួរកត់សម្គាល់ថា គ្រួសារ ១២% បានរាយការណ៍ថា ខ្លួនមានជីវភាពធូរធារ និង ១% ប្រាប់ថា ខ្លួនជាអ្នកមាន ។ ព័ត៌មាននេះបង្ហាញថា មិនមែនតែអ្នកក្រទេ ដែលបញ្ជូនសមាជិកគ្រួសារទៅធ្វើការនៅប្រទេសក្រៅ ។

**ក្រាហ្វិក ៣.៣: ការយល់ឃើញផ្ទាល់ខ្លួននៃក្រុមគ្រួសារដែលមានសមាជិកធ្វើចំណាកស្រុក**




*ប្រភព: អង្កេតធ្វើឡើងដោយ CDRI នាខែកញ្ញា និងតុលា ២០០៧*

ក្រុមសិក្សា បានស្នើក្រុមគ្រួសារពលករចំណាកស្រុក ឱ្យធ្វើការប្រៀបធៀបស្ថានភាពសេដ្ឋកិច្ច-សង្គមកិច្ច របស់ខ្លួន នៅឆ្នាំ២០០៧ នេះ ទៅនឹងស្ថានភាពកាលពីឆ្នាំ២០០២ ។ ចម្លើយតបមានលក្ខណៈវិជ្ជមានគួរសម ។ អ្នកឆ្លើយសម្ភាសន៍ជាងពាក់កណ្តាល (៦០%) រាយការណ៍ថា ពួកគេមានស្ថានភាពធូរធារជាងមុន គឺមាន ៥៣% ប្រាប់ថា ពួកគេមានស្ថានភាពគ្រាន់បើជាងមុនបង្គួរ និង ៧% ប្រាប់ថា ធូរធារជាងមុនច្រើន ។ ប៉ុន្តែមានអ្នកផ្តល់សម្ភាសន៍ ១៣% ឆ្លើយថា ពួកគេមានស្ថានភាពលំបាកជាងមុន ហើយ ២៧% ទៀតប្រាប់ថា ស្ថានភាពគ្រួសារនៅដដែល (ក្រាហ្វិក ៣.៤) ។ ការរៀបរាប់នៅខាងលើ គ្រាន់តែជាការយល់ឃើញរបស់ក្រុមគ្រួសារនីមួយៗប៉ុណ្ណោះ ហើយវាមានកត្តាជាច្រើនទៀតក្រៅពីប្រាក់ផ្ញើទៅផ្ទះ ដែលជួយលើកស្ទួយស្ថានភាពគ្រួសារឱ្យប្រសើរឡើង ។ ទោះយ៉ាងនេះក្តី គេអាចសន្និដ្ឋានបានថា ជាទូទៅ ចំណាកស្រុកផ្តល់ផលល្អច្រើនជាងផលអាក្រក់ដល់គ្រួសារនានា ។ ដើម្បីវិភាគឱ្យបានម៉ត់ចត់ពីផលប៉ះពាល់នៃចំណាកស្រុក ត្រូវមានការវិភាគពីករណីផ្ទុយ (counter-factual analysis) ដែលមិនអាចធ្វើទៅបានទេក្នុងការសិក្សា នៅពេលនេះ ។ ដូច្នេះ យើងក៏មិនអាចអះអាងឱ្យជាក់លាក់ដែរថា ចំណាកស្រុកផ្តល់នូវផលប៉ះពាល់វិជ្ជមានសុទ្ធពិតមែននោះទេ ។

**ក្រាហ្វិក ៣.៤: ការយល់ឃើញពីស្ថានភាពរបស់ខ្លួនផ្ទាល់នៃក្រុមគ្រួសារមានសមាជិកធ្វើចំណាកស្រុក នៅចន្លោះឆ្នាំ២០០៧ និង ២០០២**




*ប្រភព: អង្កេតធ្វើឡើងដោយ CDRI នាខែកញ្ញា និងតុលា ២០០៧*

ចំពោះគ្រួសារដែលរាយការណ៍ថា មានស្ថានភាពប្រសើរឡើងនៅឆ្នាំ២០០៧ បើធៀបនឹងឆ្នាំ២០០២ ក្រុមសិក្សាបានស្នើឱ្យផ្តល់នូវមូលហេតុសំខាន់ៗបំផុតពីរ (តាមលំដាប់សារសំខាន់) ដែលនាំឱ្យមានការឈានឡើងនេះ ។ តាមនេះ មូលហេតុសំខាន់ៗបំផុត គឺមានឱកាសការងារច្រើនជាងមុននៅឯនាយព្រំដែន និងកំណើនចំនួនសមាជិកគ្រួសារដែលអាចជួយរកប្រាក់ចំណូល ហើយនិងកំណើនទិន្នផលផលិតកម្មកសិកម្ម (តារាង ៣.២៦) ។ រឿងដែលនៅពេលបច្ចុប្បន្ន គ្រួសារនានាមានសមាជិកច្រើននាក់ស្ថិតក្នុងវ័យអាចរកចំណូល វាឆ្លុះបញ្ចាំងពីទំរង់ពីរ៉ាមីតនៃរបាយប្រជាជននៅក្នុងប្រទេស ។ នៅកម្ពុជា មានកំណើតកូនយ៉ាងច្រើន (baby boom) នៅទសវត្សរ៍ ១៩៨០ ហើយក្មេងទាំងនោះ សព្វថ្ងៃអាចផ្តល់ពលកម្មជួយរកចំណូលសំរាប់គ្រួសារ ឬសំរាប់ចិញ្ចឹមខ្លួនឯងបាន ។ កំណើនសមាជិកគ្រួសារក្នុងវ័យរកចំណូល បានបង្កើនចំនួនកំលាំងពលករធ្វើចំណាកស្រុកផង និងសកម្មភាពកសិកម្ម ឬសេដ្ឋកិច្ចផ្សេងៗផង ។

**តារាង ៣.២៦: មូលហេតុនាំឱ្យក្រុមគ្រួសារយល់ឃើញថា ស្ថានភាពគ្រួសារបានប្រសើរជាងមុន**

| មូលហេតុនាំឱ្យស្ថានភាពគ្រួសារប្រសើរឡើងនៅឆ្នាំ២០០៧ ធៀបនឹងឆ្នាំ២០០២ | មូលហេតុទី ១ | មូលហេតុទី ២ |
|---|---|---|
| ឱកាសការងារច្រើននៅឯនាយព្រំដែន | 39 | 23 |
| កំណើនសមាជិកគ្រួសារអាចជួយរកប្រាក់ចំណូល | 31 | 38 |
| ទិន្នផលខ្ពស់នៃផលិតកម្មកសិកម្ម | 21 | 23 |
| មានដីកសិកម្មច្រើនជាងមុន | 3 | 7 |
| ឱកាសការងារច្រើននៅតាមព្រំដែន | 3 | 1 |
| ផ្សេងៗ (បញ្ជាក់) | 3 | 7 |
| សរុប | 100 | 100 |

*ប្រភព: អង្កេតធ្វើឡើងដោយ CDRI នាខែកញ្ញា និងតុលា ២០០៧*

ជាការគួរឱ្យពេញចិត្តដែរ ដែលឃើញមានក្រុមគ្រួសារមួយចំនួនលើកឡើងពីទិន្នផលខ្ពស់នៃផលិតកម្មកសិកម្ម ថាជាកត្តាចំបងជួយលើកកម្ពស់សុខុមាលភាពគ្រួសាររបស់ពួកគេ ។ ការវិនិយោគលើប្រព័ន្ធធារាសាស្ត្រ ការកែលំអគ្រាប់ពូជ ព្រមទាំងសកម្មភាពគាំទ្ររបស់រដ្ឋាភិបាល ពួកដៃគូអភិវឌ្ឍន៍ និងកម្មវិធីនានារបស់អង្គការក្រៅរដ្ឋាភិបាល ក៏ដូចជាការប្រឹងប្រែងរបស់ក្រុមគ្រួសារផ្ទាល់ បានផ្តល់ជាផ្លែផ្កាល្អ ។ អ្នកចូលរួមក្នុងការពិភាក្សាជាក្រុម បានលើកថា គ្រាប់ពូជស្រូវល្អ និងទឹកភ្លៀង គឺជាកត្តាសំខាន់នៃកំណើនក្នុងប៉ុន្មានឆ្នាំកន្លងទៅនេះ ។

## ជំពូក ៤ បញ្ហាសំខាន់ៗពាក់ព័ន្ធនឹងការធ្វើចំណាកស្រុកឆ្លងកាត់ព្រំដែន

គេចាំបាច់ត្រូវស្វែងយល់ពីវិធីសាស្ត្ររៀបចំទេសន្តរប្រវេសន៍កំលាំងពលកម្មឆ្លងកាត់ព្រំដែនជាលក្ខណៈអន្តរជាតិក្នុងស្ថាប័ននីមួយៗ ។ ក្រសួងចំនួន ៤ ដែលពាក់ព័ន្ធក្នុងនីតិវិធីរដ្ឋបាលនៃទេសន្តរប្រវេសន៍កំលាំងពលកម្មអន្តរជាតិ គឺក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (MLVT) ក្រសួងមហាផ្ទៃ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងទីស្តីការគណៈរដ្ឋមន្ត្រី (ក្រាហ្វិក ៤.១) ។ ជាមួយគ្នានោះ ក៏មានស្ថាប័នអន្តរក្រសួងចំនួនពីរទៀត ដែលមានសមាជិកមកពីបណ្តាក្រសួង ដើម្បីបម្រើដល់គោលបំណងផ្សេងៗ ។ ក្រុមការងារអន្តរក្រសួងសំរាប់ការអនុវត្តអនុស្សរណៈនៃការយោគយល់គ្នាជាមួយប្រទេសថៃ (Inter-Ministerial Working Group for Implementation of MoU with Thailand) មានតួនាទីចំបងបំពេញនូវអនុស្សរណៈនោះ ចំណែកឯក្រុមការងារអន្តរក្រសួងសំរាប់កិច្ចការទេសន្តរប្រវេសន៍ (Inter-Ministerial Taskforce for Migration—IMTM) ដើរតួសំខាន់ក្នុងការពិភាក្សាពីបញ្ហាចំណាកស្រុក និងផ្តល់ជាអនុសាសន៍ផ្សេងៗដល់រាជរដ្ឋាភិបាលកម្ពុជា ។

**ក្រាហ្វិក ៤.១: ស្ថាប័នពាក់ព័ន្ធនឹងចំណាកពលកម្មអន្តរជាតិ**




*ប្រភព: ការសង្ខេបរបស់អ្នកនិពន្ធដោយផ្អែកលើឯកសារនានា និងការសម្ភាស*

## ៤.១. ការវាយតម្លៃលើអនុស្សរណៈនៃការយោគយល់គ្នារវាងរដ្ឋាភិបាលកម្ពុជា និងថៃ

ពលករបរទេសទៅធ្វើការនៅក្នុងប្រទេសថៃ មានច្រើនប្រភេទខុសៗគ្នា: ពលករមានលិខិតអនុញ្ញាតរយៈពេលវែង លិខិតអនុញ្ញាតបណ្ដោះអាសន្ន លិខិតអនុញ្ញាតជំរុញការវិនិយោគ លិខិតអនុញ្ញាតប្រភេទ ១២ ពលករខុសច្បាប់មិនចុះបញ្ជី និងពលករខុសច្បាប់ចុះបញ្ជី (Paitoonpong and Chalamwong, 2007) ។ កាលពីទសវត្សរ៍កន្លងទៅ ពលករចំណាកស្រុកខុសច្បាប់ពីប្រទេសជាប់ព្រំប្រទល់ មានការកើនឡើង ដោយសារមានតម្រូវការពលករគ្មានជំនាញច្រើន ។ ការហូរចូលពលករខុសច្បាប់ដ៏ច្រើនសន្ធឹកសន្ធាប់ទៅក្នុងប្រទេស បានផ្ដល់ផលចំណេញផ្នែកសេដ្ឋកិច្ច ប៉ុន្តែកើតមានបញ្ហាសង្គមផ្សេងៗនៅក្នុងប្រទេស ។ ហេតុដូចនេះហើយ ទើបរដ្ឋាភិបាលថៃ បានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាជាមួយប្រទេសមីយ៉ាន់ម៉ា ឡាវ និងកម្ពុជា នៅក្នុងឆ្នាំ២០០៣ ដើម្បីរិះរកវិធានការសមស្របមួយ ដើម្បីគ្រប់គ្រងការធ្វើអន្តោប្រវេសន៍ខុសច្បាប់ឱ្យកាន់តែល្អប្រសើរឡើង ។ អនុស្សរណៈនៃការយោគយល់គ្នារវាងកម្ពុជា-ថៃ រៀបរាប់លំអិតអំពីនីតិវិធី ដើម្បីរៀបចំពលករដែលកំពុងធ្វើការនៅក្នុងប្រទេសថៃដែលមិនបានធ្វើសំណុំបែបបទឱ្យមានលក្ខណៈស្របច្បាប់ និងនីតិវិធីក្នុងការបញ្ជូនពលករថ្មីៗដោយស្របច្បាប់ (សូមមើលឧបសម្ព័ន្ធ C) ។

ជាផ្នែកមួយនៃការអនុវត្តអនុស្សរណៈនៃការយោគយល់គ្នា រដ្ឋាភិបាលកម្ពុជា បានចេញសេចក្ដីសម្រេចមួយនៅថ្ងៃទី ១០ មករា ២០០៥ បង្កើតគណៈកម្មាធិការអន្តរក្រសួង ដើម្បីកំណត់អត្តសញ្ញាណពលករកម្ពុជាដែលកំពុងធ្វើការនៅក្នុងប្រទេសថៃ ពីព្រោះពលករមកពីប្រ៊ុយណេ វៀតណាម និងកម្ពុជា ដែលទៅធ្វើការនៅប្រទេសថៃ មានភិនភាគពណ៌សម្បុរស្រដៀងគ្នា ហេតុដូចនេះ ចាំបាច់ត្រូវតែកំណត់អត្តសញ្ញាណឱ្យបានច្បាស់ពីចំនួនពលករចំណាកស្រុកកម្ពុជា ។ គណៈកម្មាធិការនេះ មានសមាសភាពសមាជិកមកពីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ក្រសួងមហាផ្ទៃ ទីស្ដីការគណៈរដ្ឋមន្ត្រី និងក្រសួងការបរទេស ។ ក្រោមការដឹកនាំរបស់អគ្គនាយកមកពីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ គណៈកម្មាធិការនេះ បានធ្វើដំណើរទៅប្រទេសថៃ ដើម្បីផ្ដល់វិញ្ញាបនប័ត្របញ្ជាក់អត្តសញ្ញាណដល់ពលករកម្ពុជាដែលកំពុងធ្វើការនៅប្រទេសថៃ ។ គណៈកម្មាធិការ បានធ្វើការរួមគ្នាជាមួយក្រុមការងារអន្តរក្រសួងថៃ (ដែលមានសមាសភាពបុគ្គលិកមកពីក្រសួងការងារ ក្រសួងមហាផ្ទៃ និងក្រសួងសុខាភិបាល នៃប្រទេសថៃ) ពីកន្លែងមួយទៅកន្លែងមួយ ។ គណៈកម្មាធិការកម្ពុជា បានធ្វើសម្ភាសន៍ជាមួយពលករកម្ពុជា និងបានចេញវិញ្ញាបនប័ត្របញ្ជាក់អត្តសញ្ញាណដល់ពួកគេក្នុងតម្លៃ ១៥០០បាត ចំណែកឯគណៈកម្មាធិការថៃ បានផ្ដល់លិខិតអនុញ្ញាតការងារដល់ពលករកម្ពុជាក្នុងតម្លៃ ៤០០០បាត ដែលតម្លៃនេះ មានរាប់បញ្ចូលទាំងការចំណាយពិនិត្យសុខភាព ដើម្បីដាក់បញ្ចូលទៅក្នុងគ្រោងការណ៍ធានារ៉ាប់រងសុខភាព ។ ដូច្នេះ ដើម្បីទទួលបានវិញ្ញាបនប័ត្របញ្ជាក់អត្តសញ្ញាណ និងលិខិតអនុញ្ញាតការងារ ដែលមានសុពលភាពរយៈពេល ២ឆ្នាំនោះ គេត្រូវចំណាយសរុបប្រហែល ៥៥០០បាត ជាមធ្យម ។

យោងតាមការសម្ភាសជាមួយពលករនៅប្រទេសកម្ពុជា និងនៅប្រទេសថៃ បានឱ្យដឹងថា ពលករចំណាកស្រុកត្រូវចំណាយសរុបចាប់ពី ៦០០០ ទៅ ៨០០០បាត គិតបញ្ចូលទាំងថ្លៃធ្វើដំណើរ និងចំណាយផ្សេងៗ[១] ។ ជាទូទៅនិយោជកតែងតែចេញថ្លៃចំណាយនេះមុនសំរាប់ពលករ បន្ទាប់មកទើបកាត់យកពីប្រាក់ឈ្នួលរបស់ពលករខ្លះៗ ដើម្បីទូទាត់វិញក្នុងរយៈពេល ៦ខែ ឬលើសពីនេះ ។ និយោជកទំនងជាគិតការប្រាក់លើប្រាក់ដែលគេផ្ដល់ឱ្យពលករមុន ។ម្យ៉ាងវិញទៀត ចំណាយសរុបមានចំនួនច្រើន ធៀបទៅនឹងប្រាក់សន្សំប្រមាណ ១៥០០បាត/ខែ របស់ពលករចំណាកស្រុក ។ បញ្ហានេះ ធ្វើឱ្យពលករជាច្រើនរារែកចិត្តក្នុងការធ្វើសំណុំបែបបទ ហើយពួកគេបានសម្រេចចិត្តបន្តធ្វើជាពលករចំណាកស្រុកមិនមានសំណុំបែបបទ ។ ពលករចំណាកស្រុកកម្ពុជាជាង ១១០.០០០នាក់ ដែលធ្វើ

---

១ ការសិក្សាដល់កន្លែង ត្រូវបានធ្វើឡើងដោយ CDRI ដែលជាផ្នែកមួយនៃគម្រោងស្រាវជ្រាវមួយផ្សេងទៀតស្ដីពីផលប្រយោជន៍ និងចំណាយសេដ្ឋកិច្ច នៃការធ្វើចំណាកស្រុក ។

ការនៅប្រទេសថៃ បានចូលរួមក្នុងការពិនិត្យសុខភាពក្នុងឆ្នាំ២០០៤ ដើម្បីធ្វើសំណុំបែបបទស្នើសុំលិខិតអនុញ្ញាត ។ ទោះយ៉ាងនេះក្តី មានពលករប្រមាណ ៧០.០០០នាក់ប៉ុណ្ណោះ ដែលត្រូវបានចុះបញ្ជី និងផ្តល់ជូនលិខិតអនុញ្ញាតការងារនៅក្នុងឆ្នាំ២០០៤ ។

ពលករភាគច្រើនដែលបានសម្ភាស និយាយថា តាមដែលគេដឹង ពលករកម្ពុជាដែលធ្វើការនៅកន្លែងជាមួយគ្នា (កន្លែងនីមួយៗ មានពលករកម្ពុជាប្រហែលពី ៣០-៥០នាក់) មានពលករតិចជាង ៣០% ប៉ុណ្ណោះ ដែលទទួលបានលិខិតអនុញ្ញាតការងារ និងវិញ្ញាបនប័ត្របញ្ជាក់អត្តសញ្ញាណ ។ តួលេខនេះ ស្របគ្នាទៅនឹងរបាយការណ៍របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលថាក្នុងឆ្នាំ២០០៥ ក្នុងចំណោមពលករប្រហែល ១៨០.០០០នាក់ មានពលករប្រហែល ៥០.០០០នាក់ប៉ុណ្ណោះ ដែលបានមករកធ្វើវិញ្ញាបនប័ត្របញ្ជាក់អត្តសញ្ញាណ ។ មកដល់ឆ្នាំ២០០៧ មានពលករប្រហែល ៦០០០នាក់ប៉ុណ្ណោះ បានមកធ្វើវិញ្ញាបនប័ត្របញ្ជាក់ ដូច្នេះហើយ រដ្ឋាភិបាលថៃ (នៅក្នុងជំនួបប្រជុំប្រចាំឆ្នាំក្នុងខែវិច្ឆិកា ២០០៨) បានពន្យារពេលចុះបញ្ជីរហូតដល់ឆ្នាំ២០០៨ ។ រដ្ឋាភិបាលកម្ពុជា បានប៉ាន់ស្មានថា មូលហេតុចំបងនៃបញ្ហានេះ គឺដោយសារនិយោជកនៅក្នុងប្រទេសថៃ មិនបាននាំពលករទៅចុះបញ្ជីជាមួយគណៈកម្មាធិការកម្ពុជា-ថៃឡើយ ។

ដើម្បីអោយពលករកម្ពុជា មកចុះបញ្ជីជាមួយគណៈកម្មាធិការអន្តរក្រសួងកម្ពុជា ដែលកំពុងធ្វើការក្នុងប្រទេសថៃ គឺចាំបាច់ត្រូវផ្តល់ព័ត៌មានដល់កម្មករទាំងនោះ ។ ការផ្សព្វផ្សាយព័ត៌មានជាភាសាថៃ និងតាមរយៈប្រព័ន្ធផ្សព្វផ្សាយសាធារណៈផ្សេងៗ អាចនឹងមិនមានប្រសិទ្ធភាពទេ ព្រោះពលករកម្ពុជាភាគច្រើន មិនមានលទ្ធភាពទទួលបាន ឬយល់ព័ត៌មានទាំងនោះឡើយ ។ ក្រសួងការងារប្រទេសថៃ បានស្នើដល់និយោជកឱ្យផ្សព្វផ្សាយដំណឹងដល់ពលករ ដើម្បីឱ្យពួកគេមកចុះបញ្ជី ។ នេះអាចជាមធ្យោបាយតែមួយគត់ ដើម្បីផ្សព្វផ្សាយព័ត៌មានទៅដល់ពលករកម្ពុជា ។ ប៉ុន្តែមធ្យោបាយនេះ ត្រូវទាមទារឱ្យមានកិច្ចសហការពីនិយោជកនៅក្នុងប្រទេសថៃ ។ គណៈកម្មាធិការប្រទេសកម្ពុជាគិតថា និយោជកថៃមួយចំនួន មិនបានប្រាប់ ឬបញ្ជូនពលកររបស់ខ្លួនឱ្យទៅចុះបញ្ជីទេ ។ ជាទូទៅ ចាំបាច់ត្រូវធ្វើការលើកទឹកចិត្តដល់និយោជក ដើម្បីចូលរួមសហការ ឬធ្វើការផាកពិន័យធ្ងន់ធ្ងរ ប្រសិនបើពួកគេបដិសេធមិនសហការ ។ មានការអះអាងថា និយោជកមួយចំនួន ចូលចិត្តជួលពលករដែលមិនមានចុះបញ្ជីត្រឹមត្រូវ ដោយសារពួកគេអាចទទួលបានអត្ថប្រយោជន៍ជាច្រើនពីពលករទាំងនោះ ប្រសិនបើពួកគេចង់[២] ។

លិខិតអនុញ្ញាតការងារ អាចផ្តល់ឱ្យពលករដែលធ្វើការនៅក្នុងប្រទេសថៃតាំងពីមុនឆ្នាំ២០០៤ ឬមុនដំណើរការនិយតកម្ម ។ ក្នុងអំឡុងពេលចុះស៊ើបអង្កេតដល់កន្លែងនៅក្នុងប្រទេសថៃ ដោយអ្នកនិពន្ធផ្ទាល់សហការជាមួយវិទ្យាស្ថានស្រាវជ្រាវដើម្បីអភិវឌ្ឍន៍ប្រទេសថៃ កាលពីខែវិច្ឆិកា ២០០៧ ពលករកម្ពុជាបានបង្ហាញពីចំណាប់អារម្មណ៍ចំពោះការទទួលបានលិខិតអនុញ្ញាតការងារក្នុងតម្លៃកំណត់មួយ ប៉ុន្តែមិនបានទទួលសេវាកម្មនេះឡើយ ក្នុងគោលបំណងមិនជំរុញឱ្យពលករថ្មីៗចូលមកធ្វើការក្នុងប្រទេសថៃដោយខុសច្បាប់ និងបន្ថយឥទ្ធិពលនៃមធ្យោបាយស្របច្បាប់នៃទីភ្នាក់ងារជ្រើសរើសពលករនៅកម្ពុជា ។ ប្រសិនបើពលករថ្មីៗបន្តចូលប្រទេសថៃដោយខុសច្បាប់ ហើយបន្ទាប់មក ត្រូវបានទទួលស្គាល់ជាផ្លូវការនោះ ពួកគេទំនងជានឹងជ្រើសរើសយកមធ្យោបាយនេះ ព្រោះពួកគេចំណាយត្រឹមតែ ១០០ដុល្លារ និងប្រើរយៈពេលតែប៉ុន្មានថ្ងៃប៉ុណ្ណោះ ។ ដូច្នេះ ប្រសិនបើចង់ឱ្យមធ្យោបាយ

---

២ បញ្ហាមួយផ្សេងទៀត គឺលិខិតអនុញ្ញាតការងារ និងវិញ្ញាបនប័ត្របញ្ជាក់អត្តសញ្ញាណ មិនមានបើកទទួលសំណុំបែបបទគ្រប់ពេលវេលាឡើយ ។ ដំណើរការធ្វើសំណុំបែបបទនេះ មានពេលកំណត់ជាក់លាក់ ហើយធ្វើឡើងរៀងរាល់ពីរឆ្នាំម្តង ។ និយាយជាលក្ខណៈបច្ចេកទេស ពលករដែលចូលទៅប្រទេសថៃក្រោយឆ្នាំ២០០៤ ហើយចង់ទទួលវិញ្ញាបនប័ត្របញ្ជាក់អត្តសញ្ញាណ និងលិខិតអនុញ្ញាតការងារនោះ មិនអាចធ្វើសំណុំបែបបទនោះឡើយ ។

ស្របច្បាប់ មានប្រសិទ្ធភាពនោះ គេចាំបាច់ត្រូវបំបាត់ចោលបណ្តាញខុសច្បាប់សិន ។ ជាមួយគ្នានេះដែរ បណ្តាញស្របច្បាប់ ត្រូវធ្វើយ៉ាងណាឱ្យមានតម្លៃសមរម្យ និងលឿនជាងមុន ។

ជាផ្នែកមួយនៃកិច្ចព្រមព្រៀងសមភាគីកម្ពុជា-ថៃ ប្រព័ន្ធចេញលិខិតអនុញ្ញាតឆ្លងដែនដែលមានសុពលភាពរយៈពេល ២ឆ្នាំ ត្រូវបានដាក់អនុវត្តសាកល្បង ។ អ្នកកាន់លិខិតអនុញ្ញាតឆ្លងដែន ត្រូវត្រលប់ទៅកាន់ច្រកព្រំដែនវិញ ដើម្បីប្រថាប់ត្រាសាជាថ្មីរៀងរាល់សប្តាហ៍ ដោយចំណាយប្រាក់ ២០បាតក្នុងមួយលើក១ ។ ដូច្នេះ គេត្រូវចំណាយ ១០៤០បាត/ឆ្នាំ ប៉ុន្តែចំណាយលើការធ្វើដំណើរ និងពេលវេលា មានចំនួនច្រើនជាងនេះទៅទៀត ។ លិខិតអនុញ្ញាតឆ្លងដែន អាចទទួលបាននៅច្រកព្រំដែនប៉ោយប៉ែតហើយត្រូវបានផ្តល់ឱ្យចំពោះតែប្រជាពលរដ្ឋរស់នៅអចិន្ត្រៃយ៍ក្នុងស្រុកជាក់លាក់តាមព្រំដែនប៉ុណ្ណោះ ។ លិខិតនេះ ផ្តល់អាទិភាពសំរាប់ប្រជាពលរដ្ឋប្រកបរបរកសិកម្មនៅក្បែរព្រំដែន ។

## ៤.២. ទីភ្នាក់ងារជ្រើសរើសពលករ

អនុស្សរណៈនៃការយោគយល់គ្នា មានចែងអំពីដំណើរការនៃការបញ្ជូនពលករចំណាកស្រុកដោយស្របច្បាប់ទៅប្រទេសថៃ ។ ដំណើរការនេះ មានសង្ខេបនៅក្នុងក្រាហ្វិក ៤.២ ។ ក្នុងដំណើរការនេះ មានបញ្ហាប្រឈមជាច្រើន ជាពិសេសការជ្រើសរើសពលករ ។

ទីភ្នាក់ងារជ្រើសរើសពលករ ផ្សព្វផ្សាយជ្រើសរើសតាមរយៈវិទ្យុ និងសារព័ត៌មានក្នុងស្រុក ដើម្បីទាក់ទាញចំណាប់អារម្មណ៍ និងទទួលពាក្យពីពលករដែលមានបំណងរកការងារធ្វើ ។ ពេលពលករមកទាក់ទងដាក់ពាក្យទៅធ្វើការនៅក្រៅប្រទេស ពួកគេត្រូវផ្តល់ឯកសារពេញលក្ខណៈសំខាន់ៗ ដូចជា អត្តសញ្ញាណប័ណ្ណ ឬសៀវភៅគ្រួសារជាដើម ។ មិនមែនអ្នកដាក់ពាក្យគ្រប់រូប មានឯកសារសំខាន់ៗគ្រប់គ្រាន់ ដើម្បីភ្ជាប់ជាមួយពាក្យស្នើសុំរបស់ពួកគេឡើយ ហើយបញ្ហានេះ ក៏ជាកត្តានាំឱ្យមានការពន្យារពេលដំណើរការដាក់ពាក្យស្នើសុំ ។ ក្រៅពីនេះ ក៏មានឈ្មួញកណ្តាលនៅតាមខេត្តខ្លះៗ ជួយជ្រើសរើសពលករនៅតាមភូមិ ឬឃុំ ហើយក្រុមហ៊ុនជ្រើសរើសផ្តល់កម្រៃជើងសាររហូតដល់ ៤០ដុល្លារ បើគេអាចរកបានអ្នកដាក់ពាក្យម្នាក់ ។ វិធីសាស្ត្រនេះ ត្រូវបានអនុវត្តយ៉ាងទូលំទូលាយ ហើយបានធ្វើឱ្យចំណាយក្នុងការបញ្ជូនពលករទៅធ្វើការក្រៅប្រទេសកើនឡើង ។ ក្នុងករណីមួយចំនួន គ្រូបង្រៀន ឬមន្ត្រីក្រុមប្រឹក្សាឃុំ បានជួយបំពេញពាក្យស្នើសុំឱ្យអ្នកដាក់ពាក្យ ហើយពួកគេទទួលបានប្រាក់ពី ៥-២០ដុល្លារ ពីឈ្មួញកណ្តាលសំរាប់ការបំពេញបែបបទឱ្យអ្នកដាក់ពាក្យម្នាក់ (តាមការសម្ភាសជាមួយឈ្មួញកណ្តាលចំនួន ៣នាក់ក្នុងខេត្តព្រៃវែង កាលពីខែកញ្ញា ២០០៧) ។

អ្នកដាក់ពាក្យ ត្រូវតែតម្រូវឱ្យទៅពិនិត្យសុខភាពនៅមន្ទីរពេទ្យសាធារណៈក្នុងរាជធានីភ្នំពេញ ។ អ្នកដាក់ពាក្យត្រូវចេញថ្លៃពិនិត្យសុខភាពដោយខ្លួនឯង ដែលមានតម្លៃប្រហែល ១០ដុល្លារ ។ គេជឿជាក់ថា ការពិនិត្យសុខភាពនេះ គ្រាន់តែធ្វើឱ្យត្រឹមត្រូវតាមច្បាប់ប៉ុណ្ណោះ ។ បន្ទាប់មក ត្រូវរង់ចាំសេចក្តីសម្រេចពីនាយកដ្ឋានការងារ និងហត្ថពលករ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលតម្រូវឱ្យមានការចំណាយប្រាក់ខ្លះៗផងដែរ ។ បន្ទាប់ពីបញ្ចប់បញ្ជីឈ្មោះពលករដែលត្រូវបានជ្រើសរើសរួចមក រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ផ្ញើលិខិតមួយទៅក្រសួងមហាផ្ទៃ ដើម្បីស្នើសុំចេញលិខិតឆ្លងដែនដល់ពលករក្នុងបញ្ជីក្នុងតម្លៃបញ្ចុះមួយគឺ ២០ដុល្លារ រហូតដល់ខែមីនា ២០០៧ និងបន្ទាប់ពីនោះ ឡើងថ្លៃដល់ ៤០ដុល្លារ (ប៉ុន្តែជាទូទៅ ត្រូវបន្ថែម ១៥ដុល្លារទៀតដែលជាកម្រៃក្រៅផ្លូវការ) ។ គេប្រហែលត្រូវចំណាយពេល ៣សប្តាហ៍រង់ចាំការសម្រេចពីនាយកដ្ឋានស្ថិតិ និងលិខិតឆ្លងដែន នៃក្រសួងមហាផ្ទៃក្នុងការចេញលិខិតឆ្លងដែនក្នុងតម្លៃបញ្ចុះនោះ ។ ដើម្បីទទួលបានលិខិតឆ្លងដែនក្នុងតម្លៃបញ្ចុះខាងលើ ត្រូវការពេលពី ២ទៅ ៣ខែ ។ ក្នុងភាពជាក់ស្តែង ដំណើរការនេះតែងត្រូវបានគេ

## ក្រាហ្វិក ៤.២: តារាងដំណើរការជ្រើសរើសពលករ




*ប្រភព: ការសង្ខេបរបស់អ្នកនិពន្ធដោយផ្អែកលើឯកសារនានា និងការសម្ភាស*

វិលងចោល ហើយទីភ្នាក់ងារជ្រើសរើសពលករ តែងងាកទៅរកផ្លូវកាត់មួយនៃការចេញលិខិតឆ្លងដែនដែលប្រើពេលមួយសប្ដាហ៍ ប៉ុន្តែត្រូវចំណាយប្រហែល ១៥០ដុល្លារ ។

ពលករត្រូវបានបញ្ជូនតាមរថយន្តក្រុងទៅកាន់កន្លែងធ្វើការនៅប្រទេសថៃ តាមច្រកព្រំដែនប៉ោយប៉ែត ។ ឈ្មួញកណ្ដាលនៅប្រទេសថៃ បញ្ជូនភ្នាក់ងាររបស់ខ្លួនទៅទទួលពលករនៅច្រកព្រំដែនប៉ោយប៉ែតដោយប្រើរថយន្តក្រុង ។ ជាមធ្យម ការដឹកជញ្ជូនពលករពីច្រកប៉ោយប៉ែតទៅកន្លែងធ្វើការនៅក្នុងប្រទេសថៃ ត្រូវចំណាយប្រាក់ប្រហែល ១០ដុល្លារ ។ ពលករភាគច្រើនទទួលបានការណែនាំដោយសង្ខេបអំពីតំបន់រស់នៅថ្មី និងលក្ខខណ្ឌការងាររបស់ពួកគេ ។ ទីភ្នាក់ងារជ្រើសរើសពលករ លើកឡើងថា ពលករមួយចំនួនមិនបានយកចិត្តទុកដាក់ចំពោះព័ត៌មានដែលផ្ដល់ឱ្យក្នុងអំឡុងពេលណែនាំ ឬបណ្ដុះបណ្ដាលនោះឡើយ ។ ការផ្ដល់ការបណ្ដុះបណ្ដាលដល់ពលកររាប់ពាន់នាក់មុនពេលចាកចេញទៅប្រទេសថៃ គឺជាតម្រូវការហួសហេតុមួយ ។

គេគួរផ្ដោតការយកចិត្តទុកដាក់លើ "ច្រកចេញចូលតែមួយ" ដើម្បីត្រួតពិនិត្យលើដំណើរការបញ្ជូនពលករ ។ គំនិតផ្ដួចផ្ដើមនេះ អាចអនុវត្តបាននៅតាមតំបន់មួយចំនួន ដូចជា ខេត្តបន្ទាយមានជ័យ និងបាត់ដំបង ដែលជាតំបន់ដែលមានពលករជាច្រើនធ្វើចំណាកស្រុក ។ អ្នកតំណាងឱ្យទីភ្នាក់ងារជ្រើសរើសពលករ ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ការិយាល័យលិខិតឆ្លងដែន និងស្ថានទូតថៃ គួរមានវត្តមានជាប្រចាំនៅការិយាល័យច្រកចេញចូលតែមួយ ដើម្បីទទួលយកពាក្យស្នើសុំ និងផ្ដល់ចម្លើយដល់ពលករ ។ សកម្មភាពនេះ នឹងជួយពលករបានយ៉ាងច្រើនទាំងពេលវេលា និងការចំណាយលើការធ្វើដំណើរក្នុងចម្ងាយផ្លូវឆ្ងាយទៅកាន់រាជធានីភ្នំពេញ ។ ដំណើរការបញ្ជូនពលករតាមវិធីនេះ មិនគួរចំណាយពេលលើសពីពីរខែឡើយ ហើយនេះទាមទារឱ្យមានការពិភាក្សាម៉ត់ចត់រវាងក្រសួងការងារប្រទេសថៃ និងក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈរបស់កម្ពុជា ។

## ៤.៣. ចំណាយនៃការបញ្ជូនពលករចំណាកស្រុក

ចំណាយនៃការបញ្ជូនពលករចំណាកស្រុកទៅធ្វើការនៅប្រទេសកូរ៉េខាងត្បូង បានធ្លាក់ចុះយ៉ាងច្រើន ពី ៣០០០ដុល្លារនៅពេលដែលក្រុមហ៊ុនឯកជនជាអ្នកទទួលធ្វើប្រតិបត្តិការនេះ មកត្រឹម ៨៩២ដុល្លារ នៅពេលដែលរដ្ឋាភិបាលសហការជាមួយក្រុមប្រឹក្សាបណ្ដុះបណ្ដាលហត្ថពលករ និងការបញ្ជូនពលករទៅក្រៅប្រទេស (MTOSB) បានចូលខ្លួនទទួលខុសត្រូវចំពោះដំណើរការបញ្ជូនពលករ ចាប់តាំងពីខែមករា ២០០៧ មក ។ នេះគឺជាជោគជ័យដ៏ធំមួយដែលផ្ដល់ប្រយោជន៍ដល់ពលករផ្ទាល់ ។ ភាពខុសគ្នាធំនៃការចំណាយក្នុងដំណើរការទាំងពីរនេះ គឺស្ថិតត្រង់ក្រុមហ៊ុនឯកជនទូទាត់ "ថ្លៃឈ្នួលបញ្ជូន និងចំណាយ" ខ្ពស់ ធៀបនឹងរដ្ឋាភិបាល (តារាង ៤.១) ។ MTOSB មិនគិតថ្លៃឈ្នួលបញ្ជូន ឬចំណាយ ក៏ដូចជាថ្លៃអប់រំ ឬណែនាំ រួមទាំងថ្លៃពន្ធរដ្ឋាភិបាលទៀតផង ។ MTOSB បានបញ្ជូនពលករប្រហែល ៨០០នាក់ ចាប់ពីពេលទទួលរ៉ាប់រងមុខងារនេះមក ។ នេះជាឧទាហរណ៍ជាក់ស្ដែងដែលបង្ហាញថា ការកាត់បន្ថយចំណាយក្នុងការបញ្ជូនពលករទៅក្រៅប្រទេស ពិតជាអាចធ្វើទៅបាន ។

ការបញ្ជូនពលករទៅធ្វើការនៅថៃ ត្រូវការចំណាយ ៧០០ដុល្លារ ដែលមានរាប់បញ្ចូលចំណាយដោយពលករ ១០០ដុល្លារ និងចំណាយរបស់ទីភ្នាក់ងារជ្រើសរើស/និយោជកថៃ ៦០០ដុល្លារ (២០.០០០បាត) ហើយនិយោជិកនឹងកាត់ប្រាក់ខែពលករ ២០០០បាត/ខែក្នុងរយៈពេល ១០ខែ ជាការសងត្រលប់វិញ ។ នេះជាតម្លៃដ៏ខ្ពស់មួយ បើធៀបនឹងបៀវត្សរបស់ពលករ ដែលជាមធ្យមប្រហែល ៦០០០បាតក្នុងមួយខែ ។ ពលករនឹងត្រូវទទួលយកការងារថែមម៉ោងជាច្រើន ដើម្បីបង្កើនប្រាក់សន្សំ ។

ការត្រួតពិនិត្យឱ្យបានតឹងរ៉ឹងលើមធ្យោបាយធ្វើចំណាកស្រុកខុសច្បាប់ មិនមែនជារឿងងាយស្រួលនោះឡើយ ទាំងចំពោះអាជ្ញាធរថៃ និងកម្ពុជា ដោយជាចំបងមកពីព្រំដែនរវាងប្រទេសទាំងពីរមានប្រវែងវែង ។ ហេតុដូចនេះ

**តារាង ៤.១: បញ្ជីថ្លៃចំណាយក្នុងការបញ្ជូនពលករទៅកូរ៉េខាងត្បូង (ដុល្លារ)**

| # | បរិយាយ | ដោយ MTOSB | ដោយផ្នែកឯកជន (CLS) | បង់ប្រាក់ដល់ |
|---|---|---|---|---|
| ចំណាយសរុប | | 892 ដុល្លារ | 2,955 ដុល្លារ | |
| ១ | ការប្រលងសមត្ថភាពភាសាកូរ៉េ | 30 | - | នាយកដ្ឋានធនធានមនុស្ស - កូរ៉េ (១ខែមុនការប្រលង-ថ្ងៃប្រលង) |
| ២ | ការពិនិត្យសុខភាពលើកទីមួយ | 42 | 180 | នាយកដ្ឋានសុខភាព និងសុវត្ថិភាពការងារ (១សប្តាហ៍ បន្ទាប់ពីការប្រលង-ថ្ងៃប្រកាសលទ្ធផល) |
| ៣ | ការពិនិត្យសុខភាពលើកទីពីរ | 25 | | នាយកដ្ឋានសុខភាព និងសុវត្ថិភាពការងារ (១សប្តាហ៍ មុនពេលចេញដំណើរ) |
| ៤ | លិខិតឆ្លងដែន | 50 | 200 | នាយកដ្ឋានស្ថិតិ និងលិខិតឆ្លងដែន (បន្ទាប់ពីការប្រកាសលទ្ធផលប្រលង) |
| ៥ | ការផ្តល់ទិដ្ឋាការ | 50 | 50 | ស្ថានទូតកូរ៉េ (បន្ទាប់ពីទទួលបានវិញ្ញាបនប័ត្របញ្ជាក់ការចេញទិដ្ឋាការ - CCVI) |
| ៦ | ការបណ្តុះបណ្តាលនៅ NPIC មុនពេលចេញដំណើរ | 120 | - | NPIC (បន្ទាប់ពីចុះកិច្ចសន្យាការងារ) |
| ៧ | លិខិតសាកសួរព័ត៌មាន | 35 | 40 | ក្រសួងយុត្តិធម៌ (បន្ទាប់ពីចុះកិច្ចសន្យាការងារ) |
| ៨ | ថ្លៃយន្តហោះ | 420 | 460 | ភ្នាក់ងារធ្វើដំណើរ (៥ថ្ងៃមុនចេញដំណើរ) |
| ៩ | ពន្ធព្រលានយន្តហោះ | 18 | 18 | អាជ្ញាធរអាកាសយានដ្ឋាន (នៅថ្ងៃចេញដំណើរ) |
| ១០ | ឯកសណ្ឋានបែបខ្មែរ សំលៀកបំពាក់ ការងារ និងផ្លាកឈ្មោះ | 20 | - | ក្រុមហ៊ុនឯកជន (៥ថ្ងៃមុនចេញដំណើរ) |
| ១១ | ការអមដំណើរ និងការណែនាំ | 27 | - | MTOSB (៥ថ្ងៃមុនចេញដំណើរ) |
| ១២ | សំណុំបែបបទ | 5 | - | MTOSB (៥ថ្ងៃមុនចេញដំណើរ) |
| | ថ្លៃអប់រំ និងណែនាំ (១) | - | 180 | ក្រុមហ៊ុនឯកជន (CLS) |
| | ពន្ធរដ្ឋ | - | 150 | អគ្គនាយកដ្ឋានការងារ (មួយផ្នែក) |
| | ធានារ៉ាប់រងលើគ្រោះថ្នាក់ | - | 30 | ក្រុមហ៊ុនធានារ៉ាប់រងកូរ៉េ |
| | ថ្លៃឈ្នួលបញ្ជូន | - | 575 | ក្រុមហ៊ុនឯកជន (CLS) |
| | ចំណាយលើការបញ្ជូន | - | 1,072 | ក្រុមហ៊ុនឯកជន (CLS) |
| ១៣ | ផ្សេងៗ (២) | 50 | - | ភាគីផ្សេងៗ |

*(១) ការអប់រំត្រូវបានផ្តល់ដល់ពលករនៅសាលារៀនដែលដំណើរការដោយក្រុមហ៊ុនឯកជន (CLS)*

*(២) មានដូចជា ចំណាយលើការទាក់ទងតាមទូរស័ព្ទ ការធ្វើដំណើរ និងការស្នាក់នៅអំឡុងពេលបណ្តុះបណ្តាល*

*ប្រភព: ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ*

មធ្យោបាយស្របច្បាប់ ចាំបាច់ត្រូវធ្វើឱ្យមានតម្លៃសមរម្យអាចទទួលយកបាន និងបង្កលក្ខណៈងាយស្រួលដល់ពលករ ។ មានមតិមួយថា តម្លៃបញ្ជូនពលករ ៧០០ដុល្លារ គួរតែបន្ថយមកត្រឹម ៣០០ដុល្លារ ហើយរដ្ឋាភិបាលកម្ពុជា និងថៃ អាចសម្រួលដំណើរការបញ្ជូនពលករលឿនជាងមុន ។ ក្នុងចំណាយសរុប ៧០០ដុល្លារ មាន ៤៨០ដុល្លារបានចំណាយនៅកម្ពុជា ។ ការចំណាយធំៗពីរ គឺ "លិខិតឆ្លងដែន" និង "ចំណាយផ្សេងៗ" ។ តម្លៃលិខិតឆ្លងដែន គួរតែបន្ថយពី ១៥០ដុល្លារមកត្រឹម ៥០ដុល្លារ និងការចំណាយផ្សេងៗពី ២២០ដុល្លារមកត្រឹម ៤០ដុល្លារ (តារាង ៤.២) ។ ចំណូលសំរាប់ទីភ្នាក់ងារជ្រើសរើសពលករ នឹងត្រូវរក្សាទុកនៅដដែល គឺជាមធ្យម ៧០ដុល្លារ ។ ផ្នែកដែលពិបាកនឹងដោះស្រាយគឺផ្នែកចំណាយផ្សេងៗដែលមិនមានព័ត៌មានលំអិតជាក់លាក់ ។ ចំណាយលើផ្នែកនេះគឺ ២២០ដុល្លារ ដែលបានមកពីការទូទាត់រវាងចំណាយសរុប ៧០០ដុល្លារ និងចំណាយដទៃទៀតដែលដឹងច្បាស់លាស់ ។ ចំណាយផ្សេងៗនេះមានរាប់បញ្ចូលទាំងថ្លៃឈ្នួលផ្តល់ឱ្យឈ្មួញកណ្តាលនៅកំរិតផ្សេងៗ ហើយក៏មានមួយផ្នែកសំរាប់ទីភ្នាក់ងារជ្រើសរើសពលករ និងសំរាប់ទីភ្នាក់ងាររដ្ឋាភិបាលនានាផងដែរ ។ គេអាចយល់បានថា ការបំបាត់ចោលនូវចំណាយនេះ ជារឿងដែលមិនអាចធ្វើទៅរួចឡើយ ប៉ុន្តែចំណាយបែបនេះ គួរត្រូវបានកាត់បន្ថយមកត្រឹម ៤០ដុល្លារ ដើម្បីបន្ទាបចំណាយខាងមធ្យោបាយតាមផ្លូវច្បាប់ និងចង់ឱ្យពលករងាកមកប្រើប្រាស់មធ្យោបាយនេះ ។

**តារាង ៤.២: បញ្ជីចំណាយក្នុងការបញ្ជូនពលករទៅថៃ**

| មុខចំណាយ | តម្លៃបច្ចុប្បន្ន | តម្លៃស្នើសុំ | មតិយោបល់ |
|---|---|---|---|
| ចំណាយនៅក្នុងប្រទេសកម្ពុជា | 480 | 200 | |
| លិខិតឆ្លងដែន | 150 | 50 | ព័ត៌មានលំអិត មានផ្តល់ខាងក្រោម |
| ការពិនិត្យសុខភាព | 10 | 10 | |
| ថ្លៃចេញដំណើរ | 5 | 5 | |
| វគ្គបណ្តុះបណ្តាល | 15 | 15 | |
| ការធ្វើដំណើរ | 10 | 10 | |
| ភ្នាក់ងារជ្រើសរើសពលករ | 70 | 70 | |
| ចំណាយផ្សេងៗ | 220 | 40 | មិនមានព័ត៌មានលំអិតប្រាកដ |
| ការចំណាយនៅក្នុងប្រទេសថៃ | 220 | 100 | |
| លិខិតអនុញ្ញាតការងារ | 106 | 30 | នឹងដាក់ស្នើទៅរដ្ឋាភិបាលថៃ |
| សំណុំបែបបទការងារ | 3 | 3 | |
| ការពិនិត្យសុខភាព | 18 | 18 | |
| ថ្លៃទិដ្ឋាការ | 59 | 15 | បានសម្រេចរួចជាស្រេចដោយរដ្ឋាភិបាលថៃ |
| ការធ្វើដំណើរទៅកន្លែងធ្វើការ | 20 | 20 | |
| ចំណាយផ្សេងៗ | 14 | 14 | |
| សរុប | 700 | 300 | |

*ប្រភព: សម្ភាសន៍ជាមួយពលករ និងទីភ្នាក់ងារជ្រើសរើសពលករ ធ្វើឡើងនៅឆ្នាំ២០០៧ និងយោបល់របស់អ្នកនិពន្ធចំពោះតម្លៃដែលស្នើឡើង*

រដ្ឋាភិបាលថៃ គួរបន្ថយថ្លៃលិខិតអនុញ្ញាតការងារពី ១០៦ដុល្លារ មកត្រឹម ៣០ដុល្លារ (១០០០បាត) និងថ្លៃទិដ្ឋាការ ពី ៥៩ដុល្លារមកត្រឹម ១៥ដុល្លារ (៥០០បាត) ដូច្នេះ ចំណាយសរុបនៅក្នុងប្រទេសថៃ នឹងថយចុះពី ២២០ដុល្លារមកត្រឹម ១០០ដុល្លារ ។ យោងតាមក្រសួងការងារប្រទេសថៃ ថ្លៃទិដ្ឋាការគួរតែមកត្រឹម ៥០០បាត (ជំនួប

ប្រជុំជាមួយមន្ត្រីថៃនៅក្រសួងការងារប្រទេសថៃកាលពីថ្ងៃទី ១៥ វិច្ឆិកា ២០០៧) ប៉ុន្តែតម្លៃនេះ មិនទាន់ត្រូវបានដាក់ចេញអនុវត្តនៅឡើយទេក្នុងអំឡុងពេលធ្វើសេចក្តីរាយការណ៍នេះ ។ ដូច្នេះ អ្វីដែលរដ្ឋាភិបាលថៃត្រូវបន្តធ្វើក្នុងការចូលរួមចំណែកកាត់បន្ថយចំណាយដល់ពលករ គឺត្រូវកាត់បន្ថយថ្លៃលិខិតអនុញ្ញាតការងារ ។ កាលណាពលករកាន់តែច្រើន ជ្រើសរើសយកមធ្យោបាយតាមផ្លូវច្បាប់នោះ រដ្ឋាភិបាលថៃនឹងទទួលបានថ្លៃចេញទិដ្ឋាការកាន់តែច្រើនដែរ ហើយថែមទាំងទទួលបានសារប្រយោជន៍យ៉ាងច្រើននៅក្នុងផ្នែកសំខាន់ៗផ្សេងទៀតផងដែរ ។ ថ្លៃចំណាយផ្សេងៗអាចបន្តនៅដូចដើម ព្រោះចំណាយទាំងនោះមិនមានលក្ខណៈធំដុំឡើយ ។

### ៤.៤. លិខិតឆ្លងដែន

នៅកម្ពុជា ក្រសួងការបរទេស ជាអ្នកចេញលិខិតឆ្លងដែនសំរាប់មន្ត្រីរាជការស៊ីវិល ចំណែកឯក្រសួងមហាផ្ទៃជាអ្នកចេញលិខិតឆ្លងដែនសំរាប់ប្រជាជនទូទៅ ។ ដំណើរការនៃការចេញលិខិតឆ្លងដែនធម្មតា ត្រូវធ្វើឡើងដោយការិយាល័យលិខិតឆ្លងដែន នៅក្រោមនាយកដ្ឋានស្ថិតិ និងលិខិតឆ្លងដែន ។ ក្នុងផ្ទៃប្រទេសទាំងមូល មានការិយាល័យលិខិតឆ្លងដែនតែមួយប៉ុណ្ណោះ ជាមួយនឹងបុគ្គលិក ៧៥នាក់ក្នុងការធ្វើដំណើរការសំណុំបែបបទលិខិតឆ្លងដែន ។ អគ្គនាយកនៃអគ្គស្នងការដ្ឋាននគរបាលជាតិ ជាអ្នកចុះហត្ថលេខាលើលិខិតឆ្លងដែន ដើម្បីផ្តល់សុពលភាពដល់លិខិតនោះ ។ តម្លៃដ៏ខ្ពស់ និងរយៈពេលវែងនៃដំណើរការចេញលិខិតឆ្លងដែន គឺជាឧបសគ្គរារាំងដ៏ធំមួយយ៉ាងសំខាន់ដែលត្រូវដោះស្រាយ ។

បច្ចុប្បន្ន តម្លៃផ្លូវការនៃលិខិតឆ្លងដែនធម្មតា គឺ ១២០ដុល្លារ ដែលតម្លៃនេះ មានបូកបញ្ចូលថ្លៃ ២០ដុល្លារនៃប្រព័ន្ធមីក្រូឈីប (microchip) សំរាប់រៀបចំលិខិតឆ្លងដែនអេឡិចត្រូនិក (e-passport) ដែលដំណើរការចាប់ពីថ្ងៃទី ៥ មីនា ២០០៧ មក ។ ប៉ុន្តែដោយមានបូកបញ្ចូលនូវថ្លៃក្រៅផ្លូវការប្រហែលជា ១៩ដុល្លារទៀតនោះ ធ្វើឱ្យថ្លៃធ្វើលិខិតឆ្លងដែនសរុប កើនឡើងដល់ ១៣៩ដុល្លារ ហើយត្រូវចំណាយពេល ២ខែ ដើម្បីទទួលបានលិខិតឆ្លងដែននេះ ។ ពីមុនការចេញលិខិតឆ្លងដែន ត្រូវការពេល ១ខែ ប៉ុន្តែក្រោយពេលអនុវត្តប្រព័ន្ធមីក្រូឈីបមក ដំណើរការចេញលិខិតឆ្លងដែនមានរយៈពេលពី ២ ទៅ ៣ខែ សំរាប់ដំណើរការនេះ ។ ប្រសិនបើប្រជាជន ចង់បានលិខិតឆ្លងដែនឆាប់ ពួកគេត្រូវចំណាយប្រាក់ ២២៤ដុល្លារ ដើម្បីទទួលបានលិខិតឆ្លងដែនក្នុងរយៈពេល ១សប្តាហ៍ ។ នេះបានសេចក្តីថា ការចេញលិខិតឆ្លងដែន គឺអាចធ្វើបានក្នុងរយៈពេលមួយសប្តាហ៍ ។ កាលពីខែកញ្ញា ២០០៧ ប្រជាជននៅក្នុងភូមិស្រម៉ាសដែលធ្វើចំណាកស្រុកទៅប្រទេសម៉ាឡេស៊ីតាមមធ្យោបាយស្របច្បាប់ បានប្រាប់ក្រុមសិក្សារបស់ CDRI យើងថា ពួកគាត់ត្រូវចំណាយប្រាក់ពី ១២០ដុល្លារទៅ ១៥០ដុល្លារ ដើម្បីទទួលបានលិខិតឆ្លងដែនក្នុងរយៈពេល ១ខែកន្លះ ។ នៅចុងឆ្នាំ២០០៨ នាយករដ្ឋមន្ត្រីនៃប្រទេសកម្ពុជា បានដាក់បទបញ្ជាដល់ក្រសួងមហាផ្ទៃឱ្យធ្វើលិខិតឆ្លងដែនដោយឥតគិតថ្លៃ ឬក្នុងតម្លៃទាបបំផុតដែលអាចធ្វើទៅបាន សំរាប់ពលករចំណាកស្រុក ។ ប៉ុន្តែសមាសភាពចំណាយផ្សេងៗ នៅតែធ្វើឱ្យលិខិតឆ្លងដែនមានតម្លៃប្រហែល ៤៥ដុល្លារចំពោះពលករចំណាកស្រុកដែលមានចិត្តអត់ធ្មត់ក្នុងការអនុវត្តតាមដំណើរការស្របច្បាប់ ។ ករណីដែលពលករចំណាកស្រុក ឬទីភ្នាក់ងារជ្រើសរើសបុគ្គលិកទាមទារលិខិតឆ្លងដែនឆាប់រហ័សនោះ ពួកគេត្រូវចំណាយប្រាក់យ៉ាងច្រើន ។

ចំពោះប្រទេសវៀតណាម ការធ្វើលិខិតឆ្លងដែន ចំណាយត្រឹមតែ ១២ដុល្លារ (២០០.០០០ដុង) និងរយៈពេល ៥ថ្ងៃ (ថ្ងៃធ្វើការ) ប៉ុណ្ណោះ ។ រីឯនៅប្រទេសថៃ ដំណើរការចេញលិខិតឆ្លងដែន មានតម្លៃ ៣០ដុល្លារ (១០០០បាត) និងត្រូវការរយៈពេលពី ៣-៥ថ្ងៃ ជាមួយគ្នានេះដែរ ថ្លៃលិខិតឆ្លងដែននៅប្រទេសឡាវ គឺ ៣៥ដុល្លារ ។ លើសពីនេះទៀត ប្រទេសទាំងបីនេះ មានការិយាល័យជាច្រើនទាំងក្នុងទីក្រុង និងតាមខេត្ត ។ ចំណែកឯប្រទេសកម្ពុជាវិញ មានការិយាល័យធ្វើលិខិតឆ្លងដែនតែមួយប៉ុណ្ណោះ នៅក្នុងរាជធានីភ្នំពេញ ដែលនេះជាឧបសគ្គជាក់ស្តែងមួយចំពោះដំណើរការធ្វើសំណុំបែបបទក្នុងរយៈពេលខ្លី ។ យើងមិនច្បាស់ថា ការចេញលិខិតឆ្លងដែនក្នុងរយៈពេល ២ខែនេះ

ជាចេតនាមួយដើម្បីឱ្យប្រជាជនដែលចង់បានលិខិតឆ្លងដែនបន្ទាន់ ជ្រើសរើសយកវិធីសាស្ត្រឆាប់រហ័ស ដោយត្រូវចំណាយប្រាក់ ២២៤ដុល្លារ ហើយយើងក៏មិនដឹងច្បាស់ដែរថា ប្រាក់បន្ថែម ៨០ដុល្លារនោះ ធ្លាក់ទៅប្រភពណាឡើយ ។

ពលករភាគច្រើន មិនអាចចំណាយពេលពី ៥-៦ខែ នៅរង់ចាំទទួលលិខិតឆ្លងដែនដែលតម្រូវសំរាប់ការងារនៅក្រៅប្រទេសនោះឡើយ ដូច្នេះ ពួកគេត្រូវបង្ខំចិត្តទិញលិខិតឆ្លងដែនក្នុងរយៈពេល ១សប្តាហ៍ ។ ពួកគេត្រូវចំណាយប្រាក់ប្រហែលពី ១៥០-២០០ដុល្លារ ដោយខ្លួនឯងផ្ទាល់ និងសងទៅនិយោជករបស់គេវិញដោយកាត់កម្រៃរបស់ពួកគេតាមក្រោយ ។ ពលករត្រូវទទួលបន្ទុកចំណាយយ៉ាងច្រើន ។

ការិយាល័យលិខិតឆ្លងដែន មានទំហំតូចប៉ុនផ្ទះមួយប៉ុណ្ណោះ ហើយតែងតែមានមនុស្សកកកុញ ដោយតែងតែទទួលអ្នកដាក់ពាក្យដល់ទៅ ៥០០នាក់/ថ្ងៃ (តាមការទាក់ទងផ្ទាល់ជាមួយមន្ត្រីប្រចាំការិយាល័យ កាលពីចុងខែវិច្ឆិកា ២០០៧) ។ នៅក្នុងសិក្ខាសាលាថ្នាក់ជាតិស្តីពីការគ្រប់គ្រងការងារក្រៅប្រទេសក្នុងប្រទេសកម្ពុជា កាលពីថ្ងៃទី២៦-២៧ កក្កដា ២០០៧ អ្នកតំណាងមកពីក្រសួងមហាផ្ទៃ បានឆ្លើយតបទៅនឹងសំណើសុំឱ្យដំណើរការចេញលិខិតឆ្លងដែនលឿនជាងមុន ដោយបានលើកឡើងអំពីកង្វះធនធានមនុស្ស និងធនធានសម្ភារៈជាជំនួយដល់ការចេញលិខិតឆ្លងដែន ។ ទាក់ទិននឹងបញ្ហាតម្លៃលិខិតឆ្លងដែន អ្នកតំណាងរបស់ក្រសួងមហាផ្ទៃ បានប្រាប់ថា តម្លៃនេះត្រូវបានកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ៤.៥. របៀបសម្រួលការចេញលិខិតឆ្លងដែនក្នុងរយៈពេលលឿន

បញ្ហាកង្វះសម្ភារៈ ឬឧបករណ៍សំរាប់ដំណើរការចេញលិខិតឆ្លងដែន មិនគួរអាចកើតមានឡើយ ប្រសិនបើពិនិត្យមើលលើការចំណាយច្រើនលើតម្លៃលិខិតឆ្លងដែន ។ ចំណូលបានពីការធ្វើលិខិតឆ្លងដែន មានចំនួនច្រើន បើធៀបនឹងចំណាយក្នុងការទិញសម្ភារៈចាំបាច់ និងការជួលបុគ្គលិក ។ មធ្យោបាយដ៏មានប្រសិទ្ធភាពបំផុត គឺការកំណត់ចំនួនថ្ងៃធ្វើការសំរាប់ការចេញលិខិតឆ្លងដែន ។ ប្រសិនបើរយៈពេល ៥ថ្ងៃ មិនអាចទៅរួចនោះ ១០ថ្ងៃគួរតែជាពេលវេលាគ្រប់គ្រាន់សមរម្យ ។ ចំណាយសរុបក្នុងការធ្វើលិខិតឆ្លងដែន គួរបន្ថយមកត្រឹម ៥០ដុល្លារ (ចំណាយផ្លូវការ ៤០ដុល្លារ និងចំណាយក្រៅផ្លូវការ ១០ដុល្លារ ដោយសន្មតថា ការបំបាត់លុយក្រៅផ្លូវការ មិនអាចធ្វើទៅរួច) ។

នៅឆ្នាំ២០០៧ រដ្ឋាភិបាលបានចេញលិខិតឆ្លងដែនចំនួនប្រហែល ៨០.០០០ ហើយប្រមូលបានចំណូលសរុប ១៣លានដុល្លារ ត្រឹមក៏រិតថ្លៃលិខិតឆ្លងដែនប្រភេទផ្សេងៗទាំងនោះ ។ គេប៉ាន់ស្មានថា រដ្ឋគួរទទួលបានចំណូលសុទ្ធ ៨.៦លានដុល្លារ បន្ទាប់ពីបានកាត់ចំណាយលិខិតឆ្លងដែន និងប្រាក់បៀវត្សបុគ្គលិក ។ បច្ចុប្បន្ន មានមន្ត្រីចំនួនប្រហែល ៧៥នាក់ កំពុងបម្រើការនៅក្នុងការិយាល័យធ្វើលិខិតឆ្លងដែន ។ ជាទូទៅ ប្រាក់បៀវត្សរបស់ពួកគាត់ ជាមធ្យមគឺ ១០០ដុល្លារ/ខែ ដូច្នេះ ចំណាយលើប្រាក់បៀវត្សសរុបក្នុងមួយឆ្នាំសំរាប់បុគ្គលិកទាំងអស់ គឺ ៩០.០០០ដុល្លារ ។ ចំណាយសរុបលើការបោះពុម្ព និងឧបករណ៍មីក្រូឈីប អាចមានតម្លៃប្រហែល ២លានដុល្លារ (២៥ដុល្លារចំពោះលិខិតឆ្លងដែនមួយច្បាប់) ។ ដូច្នេះ បញ្ហាកង្វះថវិកាសំរាប់ជួលបុគ្គលិកបន្ថែម មិនគួរអាចកើតមានឡើយ ។ ទោះជាចំនួនបុគ្គលិកកើនច្រើនជាងមុនបីដង ហើយប្រាក់បៀវត្សរបស់ពួកគាត់កើនឡើងបីដងដែរ គឺដល់ ៣០០ដុល្លារ/ខែក៏ដោយ ក៏ចំណាយសរុបសំរាប់បុគ្គលិក គឺប្រហែល ៨១០.០០០ដុល្លារប៉ុណ្ណោះ ។

ជាមួយគោលនយោបាយថ្មីនេះ នឹងមានប្រជាជន ២០០.០០០នាក់ ទៅធ្វើបែបបទសុំលិខិតឆ្លងដែន ដែលនឹងនាំមកនូវចំណូល ៣លានដុល្លារជូនដល់រដ្ឋ និង ២លានដុល្លារទៀតក្នុងលក្ខណៈជាលុយក្រោមទុក ។ រដ្ឋនឹងអាចបង្កើនបុគ្គលិកដល់ទៅ ២២៥នាក់ ដើម្បីសម្រួលដល់ដំណើរការចេញលិខិតឆ្លងដែន ជាមួយនឹងទឹកប្រាក់ត្រូវចំណាយ ៨១.០០០ដុល្លារលើប្រាក់បៀវត្សបុគ្គលិកម្នាក់ៗ មានជាមធ្យម ៣០០ដុល្លារ សំរាប់ការិយាល័យចំនួន ៦ នៅទូទាំងប្រទេស ។ ប្រាក់ចំណូលរដ្ឋ នឹងធ្លាក់ចុះ ៥.៦លានដុល្លារ ហើយប្រាក់បាត់បង់ទាំងនេះ នឹងបានទៅដល់អ្នកធ្វើលិខិតឆ្លងដែន ។

ជាមួយគ្នានេះដែរ ពលករចំណាកស្រុកចំនួន ១០០.០០០នាក់ (ក្នុងចំណោមពលករ ១៨០.០០០នាក់) ដែលទៅធ្វើការនៅក្នុងប្រទេសថៃប៉ុណ្ណោះ នឹងក្លាយជាពលករស្របច្បាប់ ហើយអាចរកចំណូលសុទ្ធបាន ៥០លានដុល្លារ/ឆ្នាំ ឬ ២០០លានដុល្លារក្នុងរយៈពេល ៤ឆ្នាំ (ចំនួនឆ្នាំការងារអតិបរិមាដែលគេអនុញ្ញាត) ។ ក្នុងមួយខែ ពលករចំណាកស្រុកស្របច្បាប់ម្នាក់ អាចរកចំណូលបានច្រើនជាងពលករខុសច្បាប់ម្នាក់ ចំនួន ៤៥ដុល្លារ ហើយពលករស្របច្បាប់ថែមទាំងទទួលបានសារប្រយោជន៍កាន់តែច្រើនទៀតបើពិនិត្យទៅលើផ្នែកច្បាប់ សន្តិសុខ និងផ្នែកផ្សេងៗនៃសង្គម ។ ដូច្នេះ នេះជាគោលនយោបាយទ្រទ្រង់ដល់ជនក្រីក្រ ដែលគួរលើកយកមកពិចារណា ។

ប្រសិនបើពលករប្រហែលជា ២០០.០០០នាក់ អាចទទួលបានលិខិតឆ្លងដែនគ្រប់ៗគ្នា ការិយាល័យតូចមួយនៅក្នុងរាជធានីភ្នំពេញ នឹងមិនអាចបំពេញតាមតម្រូវការនេះឡើយ ដូចនេះ ក្រសួងមហាផ្ទៃ នឹងត្រូវបើកដំណើរការការិយាល័យបន្ថែមនៅក្នុងរាជធានីភ្នំពេញ ។ លើសពីនេះទៅទៀត ក្រសួងមហាផ្ទៃគួរតែបើកការិយាល័យនៅតាមបណ្តាខេត្តមួយចំនួនដែលមានពលករមួយចំនួនធំចង់ទៅធ្វើការនៅក្រៅប្រទេស ។ ការិយាល័យទាំងនេះមិនត្រឹមតែអាចឆ្លើយតបនឹងតម្រូវការលិខិតឆ្លងដែនដ៏សន្ធឹកសន្ធាប់នោះទេ ហើយថែមទាំងជួយកាត់បន្ថយចំណាយលើការធ្វើដំណើរសំរាប់ប្រជាជននៅតាមខេត្តទៀតផង ។ អគ្គនាយកនៃអគ្គស្នងការដ្ឋាននគរបាលជាតិប្រចាំរាជធានីភ្នំពេញ អាចចុះហត្ថលេខាទទួលស្គាល់លិខិតឆ្លងដែនទាំងឡាយតាមរយៈប្រព័ន្ធអេឡិចត្រូនិក ប៉ុន្តែការិយាល័យនៅតាមខេត្តជាអ្នករៀបចំបែបបទ និងផ្តល់លិខិតឆ្លងដែនទៅអ្នកដាក់ពាក្យ ហើយត្រូវទទួលខុសត្រូវ ប្រសិនបើមានកំហុសណាមួយកើតឡើង ។

## ៤.៦. ដំណើរជ្រើសរើសបុគ្គលិក

ដោយសារកង្វះមធ្យោបាយផ្សព្វផ្សាយ បណ្តាញ និងការលើកកម្ពស់ការយល់ដឹងជាសាធារណៈ ធ្វើឱ្យទីភ្នាក់ងារជ្រើសរើសបុគ្គលិក ឬឈ្មួញកណ្តាល មិនសូវទទួលបានអ្នកមករកដាក់ពាក្យឡើយ ។ បញ្ហានេះជំរុញឱ្យទីភ្នាក់ងារជ្រើសរើសបុគ្គលិក តែងសំលឹងមើលលើបរិមាណជាជាងគុណភាព ។ ដំណើរការជ្រើសរើសជម្រុះបេក្ខជនដាក់ពាក្យមិនសូវមានលក្ខណៈតឹងតែង ឬម៉ត់ចត់ឡើយ ដែលបណ្តាលឱ្យកើតមានបញ្ហារត់ចោលកន្លែងធ្វើការ អំឡុងពេលពលករទៅធ្វើការនៅក្នុងប្រទេសថៃ ។ ពលករចំណាកស្រុក មួយភាគធំបានត្រលប់មកផ្ទះវិញ ឬធ្វើជាពលករខុសច្បាប់នៅក្នុងប្រទេសថៃ ព្រោះពួកគេយល់ថា ការងាររបស់ខ្លួនលំបាកពេក ឬពួកគេមិនមានចិត្តអំណត់ស៊ូទ្រាំធ្វើការដើម្បីទូទាត់ថ្លៃចំណាយរបស់ខ្លួន ។ មិនមានស្ថិតិណាមួយ ដែលអាចបញ្ជាក់ច្បាស់ពីចំនួនពលករដែលរត់ចោលការងារនោះទេ ប៉ុន្តែមានប្រភពព័ត៌មានមួយនៅក្នុងប្រទេសថៃ បានរាយការណ៍ថា មានទីភ្នាក់ងារជ្រើសរើសបុគ្គលិកមួយកន្លែងនៅកម្ពុជា ដែលបានបញ្ជូនពលករទៅឱ្យនិយោជកមួយចំនួននៅប្រទេសថៃ បានប្រឈមមុខនឹងបញ្ហាពលកររត់ចោលការងារអស់ដល់ទៅ ៤០% ។ នេះជាហានិភ័យធំមួយដែលនាំឱ្យទីភ្នាក់ងារជ្រើសរើសបុគ្គលិកប្រឈមមុខនឹងការបាត់បង់ចំណូល ព្រោះពួកគេត្រូវទទួលខុសត្រូវទូទាត់សងថ្លៃចំណាយដ៏ច្រើនដែលនិយោជកថៃបានចំណាយមុន ហើយពួកគេពឹងផ្អែកលើការកាត់សងវិញពីពលករចំណាកក្នុងរយៈពេល ១០ខែ ។

## ៤.៧. សំណុំបែបបទទិដ្ឋាការ

កាលណាពលករទទួលបានលិខិតឆ្លងដែនហើយ ក្រុមហ៊ុនជ្រើសរើសបុគ្គលិកត្រូវរង់ចាំទទួលលិខិតសន្យាការងារ ឬលិខិតកោះហៅពីនិយោជកនៅក្នុងប្រទេសដែលទទួលយកពលករ ។ ដំណើរការនេះ ត្រូវធ្វើឡើងដោយក្រសួងការងារប្រចាំប្រទេសនោះ ។ បន្ទាប់មកទៀត ត្រូវរៀបចំសំណុំបែបបទសុំទិដ្ឋាការការងារសំរាប់ពលករ នៅស្ថានទូតរបស់ប្រទេសនោះ ដែលប្រចាំនៅរាជធានីភ្នំពេញ ។ ទីភ្នាក់ងារជ្រើសរើសបុគ្គលិកនៅកម្ពុជា បានត្អូញត្អែរថា

ពួកគេត្រូវចំណាយពេលដល់ទៅមួយខែ ទើបអាចទទួលបានទិដ្ឋាការពីស្ថានទូតថៃនៅរាជធានីភ្នំពេញ ។ ស្ថានទូតថៃបើកទទួលសំណុំបែបបទទិដ្ឋាការតែពីរថ្ងៃប៉ុណ្ណោះក្នុងមួយសប្តាហ៍ ។ តម្លៃទិដ្ឋាការសំរាប់អ្នកដែលមិនមែនជាជនអន្តោប្រវេសន៍ គឺ ២០០០បាត (៥៩ដុល្លារ) ដែលនេះជាតម្លៃខ្ពស់សំរាប់ពលករក្រីក្រ និងជាតម្លៃបន្ថែមធំមួយទៅលើចំណាយសរុបចំនួន ៧០០ដុល្លារ ។ យោងតាមក្រសួងការងារថៃ គេគ្រោងនឹងបន្ថយថ្លៃទិដ្ឋាការមកត្រឹម ៥០០បាត ក្នុងបំណងព្យាយាមកាត់បន្ថយការចំណាយក្នុងការបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេសដោយស្របច្បាប់ (ជំនួបប្រជុំជាមួយក្រសួងការងារថៃ កាលពី ថ្ងៃទី ១៥ វិច្ឆិកា ២០០៧) ។ ដូច្នេះ គេបានធ្វើសំណើមួយជូនចំពោះរដ្ឋាភិបាលថៃ សុំឱ្យកាត់បន្ថយថ្លៃទិដ្ឋាការ និងសុំឱ្យការចេញទិដ្ឋាការមានរយៈពេលឆាប់ជាងមុន ។

## ៤.៤. កង្វះកិច្ចសន្យាដែលមានលក្ខណៈស្តង់ដារ

បញ្ហាធំមួយដែលអ្នកផ្តល់សម្ភាសន៍លើកឡើង គឺកង្វះ "កិច្ចសន្យាដែលមានលក្ខណៈស្តង់ដារ" រវាងពលករ និងនិយោជកនៅក្នុងប្រទេសទទួលពលករ លើផ្នែកបំប៉នចំណេះដឹងដល់ពលករមុនពេលចាកចេញទៅធ្វើការនោះ ។ ទោះបីកម្ពុជាបានបញ្ជូនពលករទៅប្រទេសម៉ាឡេស៊ីតាំងពីយូរយារមកហើយក្តី ក៏ដំណើរការបំប៉នចំណេះដឹងដល់ពលករនៅមិនទាន់បានអនុវត្តឡើយ ។ គោលគំនិតនៃការធ្វើស្តង់ដារូបនីយកម្មកិច្ចសន្យា គឺដើម្បីធ្វើឱ្យប្រសើរឡើងនូវភាពអាចទស្សន៍ទាយបាននៃកិច្ចព្រមព្រៀងការងារ និងដើម្បីជួយបំប៉នចំណេះដឹងពលករដែលពួកគាត់ភាគច្រើនទំនងជាមានចំណេះវិជ្ជាមិនទាន់គ្រប់គ្រាន់ឡើយ ។ មានសេចក្តីរាយការណ៍ថា UNIFEM មានបំណងនឹងជួយដល់ការបង្កើតកិច្ចសន្យាប្រកបដោយលក្ខណៈស្តង់ដារនេះ (កិច្ចប្រជុំជាមួយឯកឧត្តម សេង សក្កា និងបុគ្គលិកក្រោមឱវាទរបស់ឯកឧត្តម កាលពីថ្ងៃទី ១៦ សីហា ២០០៧) ។

ពលករគួរមានចុះហត្ថលេខាលើកិច្ចសន្យាចំនួន ៣ច្បាប់: ទីមួយ គឺកិច្ចសន្យាផ្តល់សេវារវាងពលករចំណាកស្រុក និងទីភ្នាក់ងារជ្រើសរើសពលករ ។ ទីពីរ គឺកិច្ចសន្យាខ្ចីប្រាក់ និងទីបី គឺកិច្ចសន្យាការងាររវាងពលករ និងនិយោជកនៅក្នុងប្រទេសទទួលយកពលករ ។ នៅមិនទាន់មានការអនុវត្តជាស្តង់ដារណាមួយស្តីពីកិច្ចសន្យារវាងទីភ្នាក់ងារជ្រើសរើសពលករផ្សេងៗ ។ រដ្ឋាភិបាលកម្ពុជាមិនមានចេញគោលការណ៍ណែនាំអ្វីឡើយទាក់ទងនឹងកិច្ចសន្យាផ្សេងៗ ។ ប៉ុន្តែដូចបានបង្ហាញនៅក្នុងប្រអប់ ៤.១ អនុក្រឹត្យលេខ ៥៧ បានចែងពីលក្ខខណ្ឌកិច្ចសន្យាការងារ ។

ទោះយ៉ាងណាក្តី កិច្ចសន្យាការងារមិនអាចបង្កើតឡើងដោយភាគីកម្ពុជាតែម្ខាងនោះទេ ។ កិច្ចសន្យានេះអាចត្រូវបានចេញ ចុះហត្ថលេខា និងដាក់ឱ្យប្រតិបត្តិនៅប្រទេសដើមរបស់ពលករ ប៉ុន្តែវាអាចនឹងមិនមានតម្លៃប្រតិបត្តិនៅក្នុងប្រទេសទទួលពលករទេ ។ ដូច្នេះ បញ្ហានេះចាំបាច់ត្រូវទទួលយល់ព្រម និងឆ្លងកាត់ការពិភាក្សាជាលក្ខណៈកិច្ចប្រជុំទ្វេ ឬពហុភាគី ។ កិច្ចសន្យាការងារមួយ ចាំបាច់ត្រូវមានតម្លៃប្រតិបត្តិទាំងនៅក្នុងស្រុក និងអន្តរជាតិ ។ បញ្ហាកែប្រែកិច្ចសន្យាការងាររបស់ពលករ ដោយប្រទេសទទួលពលករ ជាករណីដែលធ្លាប់កើតមានឡើងជាច្រើនលើករួចមកហើយ ។

អនុក្រឹត្យលេខ ៥៧ រៀបរាប់លំអិតពីតម្រូវការសំរាប់កិច្ចសន្យាការងារ និងទម្រង់របស់កិច្ចសន្យានេះ (សូមមើលប្រអប់ ៤.១ និងឧបសម្ព័ន្ធ B) ។ មានព័ត៌មានលំអិតជាច្រើន ត្រូវបានស្នើឡើងឱ្យដាក់បញ្ចូលទៅក្នុងកិច្ចសន្យា ។ ទោះយ៉ាងនេះក្តី អនុក្រឹត្យនេះចងភ្ជាប់តែនឹងលក្ខខណ្ឌប្រទេសកម្ពុជាប៉ុណ្ណោះ និងមិនអាចយកទៅអនុវត្តជាលក្ខណៈអន្តរជាតិឡើយ ដោយសារកង្វះព័ត៌មានលំអិតផ្សេងៗពីសំណាក់និយោជក ឬប្រទេសទទួលពលករ ។

**ប្រអប់ ៤.១: មាត្រាដកស្រង់ពីអនុក្រឹត្យលេខ ៥៧**

មាត្រា ៨: ភាគីទទួលពលករត្រូវបង់សោហ៊ុយសេវា និងការរៀបចំឯកសារផ្សេងៗជូនភាគីផ្តល់ពលករតាមការឯកភាពគ្នា ដែលមានកំណត់ក្នុងកិច្ចសន្យា ។

មាត្រា ៩: កិច្ចសន្យាការងារ ត្រូវបញ្ជាក់ឱ្យច្បាស់ជាអាទិ៍ :

- ឈ្មោះ និងអាស័យដ្ឋានរបស់ភាគីនីមួយៗ
- កាលបរិច្ឆេទនៃការចាប់ផ្តើម និងបញ្ចប់កិច្ចសន្យា
- ទីកន្លែង និងប្រភេទការងារជាក់ស្តែង
- មុខជំនាញពលករ
- ប្រាក់បៀវត្ស និងប្រាក់បំណាច់ផ្សេងៗ
- ភាគបៀវត្ស និងប្រាក់បំណាច់ផ្សេងៗដែលត្រូវបញ្ជូនមកគ្រួសារ
- ពេលម៉ោងធ្វើការ និងថ្ងៃឈប់សំរាកប្រចាំសប្តាហ៍ ប្រចាំឆ្នាំ
- ការស្នាក់នៅ ហូបចុក ស្លៀកពាក់ ព្យាបាល
- ការបង់ប្រាក់ធានារ៉ាប់រងចំពោះពលករម្នាក់ៗ
- ការប្រគល់ និងទទួលពលករពេលទៅ និងពេលត្រឡប់មកវិញ
- សោហ៊ុយដឹកជញ្ជូនពលករទៅ និងមក
- ករណីដែលត្រូវបញ្ជូនពលករមកមាតុប្រទេសវិញមុនកាលកំណត់ក្នុងកិច្ចសន្យាការងារ ។

## ៤.៩. កង្វះកញ្ចប់បណ្តុះបណ្តាលពលករមុនពេលចាកចេញតាមលក្ខណៈស្តង់ដារ

ការរៀបចំពលករឱ្យសម្របខ្លួនទៅនឹងភាពខុសប្លែកគ្នានៃវប្បធម៌ និងឱ្យពួកគេដឹងខ្លះៗពីច្បាប់ ឬបទបញ្ញត្តិផ្សេងៗនៅក្នុងប្រទេសដែលពួកគេទៅធ្វើការនោះ គឺជារឿងសំខាន់មួយ ។ បច្ចុប្បន្ន អង្គការក្រៅរដ្ឋាភិបាលមួយចំនួនជាពិសេសគឺ CARAM កំពុងចូលរួមយ៉ាងសកម្មក្នុងការផ្តល់ការបណ្តុះបណ្តាលច្បាស់លាស់ស្តីពីបញ្ហាសុខភាព ជម្ងឺអេដស៍ និងសិទ្ធិមនុស្ស ទៅដល់ពលករមុនពេលចេញទៅធ្វើការនៅក្រៅប្រទេស ។ ទីភ្នាក់ងារជ្រើសរើសពលករ ក៏ត្រូវផ្តល់វគ្គបណ្តុះបណ្តាលមុនពេលចាកចេញផងដែរ ដែលជាទូទៅវគ្គនីមួយខុសៗគ្នា ដោយផ្អែកលើប្រទេសគោលដៅរបស់ពលករ ។ ទោះជាយ៉ាងណាក្តី ក៏នៅតែមានការស្នើសុំការផ្តល់កញ្ចប់បណ្តុះបណ្តាលមួយតាមលក្ខណៈស្តង់ដារផងដែរ ។

គម្រោងមួយរបស់អង្គការ ILO នៅរាជធានីភ្នំពេញ កំពុងដំណើរការផ្តល់ជំនួយបណ្តុះបណ្តាលទាក់ទងនឹងបញ្ហាខាងលើ ប៉ុន្តែគេបានជួបប្រទះនឹងបញ្ហាលំបាកមួយក្នុងការស្វែងរកទីប្រឹក្សាសមស្របមួយរូបនៅក្នុងប្រទេស ដែលមានបទពិសោធន៍ក្នុងការបង្កើតកញ្ចប់បណ្តុះបណ្តាលលក្ខណៈស្តង់ដារ និងបើកវគ្គបណ្តុះបណ្តាល (តាមទំនាក់ទំនងជាលក្ខណៈបុគ្គលជាមួយលោក ក្លុង រិម មន្ត្រីម្នាក់នៅក្នុងគម្រោងរបស់ ILO កាលពីថ្ងៃទី២៦ កក្កដា ២០០៧) ។ ដូច្នេះ គេនៅមិនទាន់បង្កើតបាននូវវគ្គបណ្តុះបណ្តាលមុនពេលចាកចេញ ដែលមានលក្ខណៈជាប្រព័ន្ធណាមួយសំរាប់ពលករនៅឡើយទេ ។ វគ្គបណ្តុះបណ្តាលនេះ គួរត្រូវបង្កើតឡើងជាចាំបាច់ ហើយនេះក៏ប្រហែលជាមធ្យោបាយមួយដើម្បីគ្រប់គ្រងបញ្ហាចំណាកស្រុកឱ្យមានរបៀបរៀបរយផងដែរ ។ MLVT គួរបង្កើតជាគោលនយោបាយមួយស្តីពីតម្រូវការនៃវគ្គបណ្តុះបណ្តាលមុនពេលពលករចាកចេញ ។

បញ្ហាមួយទៀតដែលបានលើកឡើងដោយអ្នកផ្តល់បទសម្ភាសន៍ គឺពលករមួយចំនួនមិនយកចិត្តទុកដាក់ទៅលើការបណ្តុះបណ្តាល ឬការណែនាំឡើយ ហើយពួកគេទំនងជាសន្និដ្ឋានថា ការងារនឹងដំណើរការបានល្អ ។ នេះអាចបណ្តាល

មកពីពលករទាំងនោះធ្លាប់ទទួលបានការអប់រំតិចតួច ឬមានការឆ្វេសប្រហែស ។ ទីភ្នាក់ងារជ្រើសរើសពលករ គួរធ្វើការជ្រើសរើសប្រកបដោយការប្រុងប្រយ័ត្នជាងមុន និងផ្តល់ការយកចិត្តទុកដាក់បន្ថែមទៅលើសារសំខាន់នៃការណែនាំ ឬការបណ្តុះបណ្តាលមុនពេលចាកចេញ ។ ការបញ្ជូនពលករមិនត្រឹមត្រូវចេញទៅ មិនត្រឹមតែអាចធ្វើឱ្យក្រុមហ៊ុនជាអ្នកបញ្ជូននោះ ខាតបង់ប្រាក់ប៉ុណ្ណោះទេ ថែមទាំងប៉ះពាល់ជាអវិជ្ជមានដល់កិត្តិស័ព្ទរបស់ពលករកម្ពុជាទាំងពួងទៀតផង ។

### ៤.១០. កង្វះធនធានក្នុងការគ្រប់គ្រងទេសន្តរប្រវេសន៍កំលាំងពលកម្ម និងត្រួតពិនិត្យទីភ្នាក់ងារជ្រើសរើសពលករ

អគ្គនាយក អគ្គនាយករង និងនាយកនៃនាយកដ្ឋានកំលាំងពលកម្ម និងការងារ តំណាងឱ្យក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានសម្គាល់ឃើញនូវកង្វះធនធានមនុស្ស និងសមត្ថភាពខាងស្ថាប័នក្នុងការគ្រប់គ្រងចរន្តទេសន្តរប្រវេសន៍កំលាំងពលកម្ម ។ ភាពខ្វះខាតនេះ រួមមានសមត្ថភាពក្នុងការលើកកម្ពស់ការយល់ដឹងរបស់ពលករនៅតាមខេត្ត និងក្នុងការត្រួតពិនិត្យ និងគ្រប់គ្រងទីភ្នាក់ងារជ្រើសរើសពលករ ។ បញ្ហាការរត់ចោលការងារ គឺជាផ្នែកមួយនៃកង្វះការប្រុងប្រយ័ត្នក្នុងការជ្រើសរើសពលករពីសំណាក់ក្រុមហ៊ុន ឬកង្វះការណែនាំដល់ពលករ ។ ពលករខ្មែរមួយចំនួនដែលបានផ្តល់សម្ភាសន៍នៅក្នុងខេត្តសាមុតសាខន ប្រទេសថៃ បានប្រាប់ថា ពួកគាត់ទទួលបានដំណឹងមិនពិតទាក់ទងនឹងបៀវត្សរបស់ពួកគាត់ ។ គេបានប្រាប់ពួកគាត់ថា អាចរកចំណូលបានពី ១០.០០០-១២.០០០បាត/ខែ ប៉ុន្តែជាក់ស្តែង ពួកគាត់រកបានតែ ៥៥០០បាតប៉ុណ្ណោះ ។ មានពលករម្នាក់បានបោះបង់ចោលការងារសមរម្យមួយនៅក្នុងស្ប៉ាមួយកន្លែងក្នុងខេត្តសៀមរាប ព្រោះនាងរំពឹងថា នាងនឹងអាចរកចំណូលបានច្រើន ពីការងារនៅពេលធ្វើចំណាកស្រុក ប្រសិនបើនាងធ្វើការថែមម៉ោងច្រើន ។

មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនៅតាមខេត្ត និងសាលាក្រុង មិនសូវចូលរួមសកម្មឡើយ ដោយសារតែកង្វះធនធានមនុស្ស និងហិរញ្ញវត្ថុ ។ មន្ទីរខ្លះ មិនទាន់មានរចនាសម្ព័ន្ធបុគ្គលិកនៅឡើយទេ ដោយសារតែក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនេះ ជាក្រសួងទើបបង្កើតថ្មី ។ ដើម្បីរៀបចំទេសន្តរប្រវេសន៍កំលាំងពលកម្មឱ្យមានលក្ខណៈផ្លូវការនោះ ក្រសួងចាំបាច់ត្រូវការឱ្យមន្ទីរក្រោមឱវាទនៅតាមខេត្ត ជួយដើរតួយ៉ាងសំខាន់ក្នុងការលើកស្ទួយចំណេះដឹង ផ្សព្វផ្សាយព័ត៌មានទាក់ទងនឹងគោលនយោបាយ និងបទបញ្ញត្តិ ក៏ដូចជាដំណើរការសំណុំបែបបទផ្សេងៗ ដែលស្មើដោយទីភ្នាក់ងារជ្រើសរើសពលករដែលនឹងបង្កើតការិយាល័យតំណាងនៅតាមខេត្ត ហើយក្នុងពេលបច្ចុប្បន្ននេះ នៅពុំទាន់មានគណៈកម្មការខេត្ត ដើម្បីសម្របសម្រួលសកម្មភាពទេសន្តរប្រវេសន៍កំលាំងពលកម្មទេ ។ សកម្មភាពផ្សេងៗមានលក្ខណៈប្រមូលផ្តុំនៅទីក្រុងនៅឡើយ ។

### ៤.១១. បញ្ហានៃការបោះបង់ និងរត់ចោលការងារ: បញ្ហាពាក់ព័ន្ធនឹងការចំណាយចុះរបស់អ្នកជ្រើសរើសពលករ

ការតម្រូវឱ្យទីភ្នាក់ងារជ្រើសរើសពលករ ឬនិយោជក ទទួលបន្ទុកលើការចំណាយក្នុងការបញ្ជូនពលករនោះ គឺជាបញ្ហាលំបាកស្មុគស្មាញមួយ ។ ទីភ្នាក់ងារជ្រើសរើសពលករ ត្រូវប្រឈមមុខនឹងការខាតបង់ ប្រសិនបើពលករបោះបង់ ឬរត់ចោលការងារ ។ ព័ត៌មានពីទីភ្នាក់ងារជ្រើសរើសបុគ្គលិក បានឱ្យដឹងថា រហូតមកទល់ពេលនេះ ការរត់ចោលការងារមានអត្រាខ្ពស់ ជាពិសេសគឺនៅក្នុងប្រទេសថៃ ។ គេអាចយល់ពីបញ្ហានេះបានយ៉ាងងាយ ព្រោះពលករដែលបញ្ជូនទៅធ្វើការស្របច្បាប់ មានត្រឹមតែ ៦១១៥នាក់ប៉ុណ្ណោះ ចំណែកឯពលករដែលចូលទៅធ្វើការនៅប្រទេសថៃដោយខុសច្បាប់ មានចំនួន ១៨០.០០០នាក់ ពលករស្របច្បាប់ទំនងជាចង់រត់គេចពីបំណុល ដើម្បីទៅធ្វើការក្នុងក្រុមពលករខុសច្បាប់វិញ ។ ទោះយ៉ាងណាក្តី នេះមិនមែនជាបញ្ហាដែលកើតមានតែនៅប្រទេសថៃនោះទេ ។ Dang (2007) បានរាយការណ៍ថា អត្រារត់ចោលការងាររបស់កម្មករវៀតណាមនៅក្នុងប្រទេសជប៉ុន គឺ ២៧-៣០% កូរ៉េខាងត្បូង ២០-២៥% និងតៃវ៉ាន់ ៩-១២% ។

និយោជកនៅក្នុងប្រទេសថៃ បានបង់ថ្លៃចំណាយមុនសំរាប់ពលករ ដោយត្រូវបង់សរុប (២០.០០០បាត) តែមួយលើកសំរាប់ពលករខ្លះ ហើយខ្លះទៀតទូទាត់ជាពីរដំណាក់កាល ។ បន្ទាប់មក និយោជកទាំងនេះ នឹងកាត់យកពីប្រាក់ខែរបស់ពលករចំនួន ២០០០បាតជាប្រចាំក្នុងរយៈពេល ១០ខែ ។ ទីភ្នាក់ងារជ្រើសរើសពលករមួយចំនួន បានបញ្ជូនបុគ្គលិករបស់ខ្លួនម្នាក់ឱ្យទៅស្នាក់នៅជាមួយពលករ ដើម្បីផ្តល់ជាជំនួយខ្លះៗ និងកាន់កាប់លិខិតឆ្លងដែនរបស់ពលករទាំងនោះ ដោយធ្វើយ៉ាងណាធានាថា ពលករដែលបញ្ជូនទៅទាំងនោះ នឹងបន្តនៅធ្វើការ ហើយប្រាក់ដែលក្រុមហ៊ុនចំណាយមុននោះ នឹងអាចទទួលបានមកវិញ ។ ការដកហូតលិខិតឆ្លងដែនទុកជារបស់បញ្ចាំនេះ មិនមានប្រសិទ្ធភាពណាស់ណាទេ ព្រោះការឆ្លងកាត់ព្រំប្រទល់កម្ពុជា-ថៃ មិនមែនជាបញ្ហាលំបាកឡើយ ។ និយោជកនៅប្រទេសថៃ នឹងទាមទារឱ្យទីភ្នាក់ងារជ្រើសរើសពលករស្វែងរកពលករដែលរត់ចោលការងារនោះ និងជំនួសពលករផ្សេង ដោយមិនមានផ្តល់កម្រៃសំរាប់ទីភ្នាក់ងារនោះឡើយ ។ ជាលទ្ធផល ទីភ្នាក់ងារជ្រើសរើសពលករ ចាំបាច់ត្រូវតំឡើងថ្លៃសេវារបស់ខ្លួន ។

បញ្ហាមួយទៀត គឺពលករយល់ឃើញថា ការងារនោះលំបាកពេក ហើយគិតចង់ត្រលប់ទៅផ្ទះវិញ ។ នេះប្រហែលមកពីពួកគេមិនបានទទួលការណែនាំគ្រប់គ្រាន់ ឬត្រឹមត្រូវ នៅមុនពេលទទួលធ្វើការងារ ឬការងារនោះ ជាក់ស្តែងមានភាពខុសប្លែកពីអ្វីដែលពួកគេបានសន្យា ។ ទីភ្នាក់ងារជ្រើសរើសពលករ ត្រូវទទួលខុសត្រូវមួយចំណែកលើបញ្ហារត់ចោលការងារនេះ ព្រោះពួកគេជ្រើសរើសពលករមិនបានត្រឹមត្រូវល្អដូចដែលក្រុមហ៊ុនធនធានមនុស្សជំនាញភាគច្រើនធ្វើឡើយ ។ ពួកគេមិនបានជ្រើសរើសជម្រុះឱ្យម៉ត់ចត់ឡើយ ។ គោលបំណងរបស់ពួកគេ គឺធ្វើយ៉ាងណាអាចទទួលបានកម្រៃពីការជ្រើសរើសពលករឆាប់រហ័ស ។ ប្រសិនបើពលករដែលបញ្ជូនទៅ មិនបានឆ្លងកាត់ការជ្រើសរើសម៉ត់ចត់ឡើយ ហើយក្រុមហ៊ុនជាអ្នកចេញថ្លៃចំណាយឱ្យពួកគេមុនទៀត ដូចមានបញ្ជាក់ក្នុងកិច្ចព្រមព្រៀងនាពេលបច្ចុប្បន្ននោះ ពលករទាំងនោះ ទំនងជានឹងរត់ចោលការងារ ឬប្រឈមមុខនឹងបញ្ហាដទៃទៀត ។ បញ្ហានេះនឹងបង្កើតជារូបភាពអាក្រក់មួយសំរាប់ពលករកម្ពុជា ហើយទៅថ្ងៃខាងមុខ តម្រូវការពលករនឹងធ្លាក់ចុះ ។

ការដោះស្រាយបញ្ហារត់ចោលការងារនេះ មិនមែនជារឿងងាយស្រួលឡើយសំរាប់ទីភ្នាក់ងារជ្រើសរើសពលករ ។ មានករណីខ្លះ ក្រុមហ៊ុនត្រូវស្នើឱ្យស្ថានទូតថៃបង្អាក់ការចេញទិដ្ឋាការថ្មីទៀតដល់ពលករទាំងនោះ ។ នៅប្រទេសកូរ៉េខាងត្បូង និងម៉ាឡេស៊ី ពលករចំណាកស្រុកស្ទើរតែទាំងអស់ជាពលករស្របច្បាប់ ហើយមិនងាយនឹងត្រលប់មកស្រុកវិញឡើយ ប្រសិនបើមិនមានលិខិតឆ្លងដែន ។ ប៉ុន្តែប្រទេសថៃជាករណីពិសេស ។ ដោយសារទីតាំងភូមិសាស្ត្រ និងភាពធូររលុងក្នុងការត្រួតពិនិត្យតាមព្រំដែន វាបានផ្តល់នូវភាពងាយស្រួលឱ្យពលកររត់ចោលការងារ ។ ក្នុងមួយថ្ងៃៗ មានប្រជាជនកម្ពុជារាប់ម៉ឺននាក់ អាចចេញចូលច្រកព្រំដែន ដោយមិនមានលិខិតឆ្លងដែន ។

ដំណោះស្រាយចំពោះបញ្ហារត់ចោលការងារនេះ គឺជាការបន្ទាបថ្លៃចំណាយដល់ពលករក្នុងការទទួលបានការងារធ្វើដោយស្របច្បាប់នៅក្នុងប្រទេសថៃ ។ គេអាចយល់បានយ៉ាងងាយថា ពលករពិបាកនឹងរកប្រាក់បានដល់ទៅ ៦០០ដុល្លារ ក្នុងរយៈពេល ១០ខែ ដើម្បីសងក្រុមហ៊ុនវិញណាស់ ហើយពួកគាត់ថែមទាំងត្រូវចំណាយ ១០០ដុល្លារ តាំងពីដំបូងទៀតផង ។ ដូច្នេះ ការកាត់បន្ថយចំណាយមកត្រឹម ៣០០ដុល្លារ ដូចមានពិភាក្សាខាងលើ គួរតែជាមធ្យោបាយដ៏ល្អមួយ ។ ប្រសិនបើពលករអាចទូទាត់សងថ្លៃចំណាយនោះ បញ្ហារត់ចោលការងារ ក៏ប្រហែលនឹងស្រាកស្រាន្តដែរ ហើយវាក៏នឹងជួយបន្ធូរបន្ថយបន្ទុកហិរញ្ញវត្ថុរបស់ទីភ្នាក់ងារជ្រើសរើសពលករក្នុងការសងប្រាក់ក្នុងករណីមានការរត់ចោលការងារផងដែរ ។

### ៩.១២. ជម្រើសផ្សេងៗក្រៅពីការចំណាយប្រាក់ជាមុនដោយទីភ្នាក់ងារជ្រើសរើសពលករ

ប្រសិនបើរដ្ឋាភិបាលកម្ពុជា និងថៃ មានបំណងឱ្យសកម្មភាពទេសន្តរប្រវេសន៍កំលាំងពលកម្ម ត្រូវធ្វើឡើងដោយឆ្លងកាត់ទីភ្នាក់ងារជ្រើសរើសពលករនោះ ចំនួនទីភ្នាក់ងារបែបនេះ គួរកើនឡើងច្រើនជាងមុនខ្លាំង ។ ប្រសិនបើពលករភាគច្រើន ត្រូវតែបញ្ជូនមកប្រទេសដើមវិញ បន្ទាប់ពីរយៈពេល ២ ឬ ៤ឆ្នាំ ដូចមានចែងក្នុងអនុស្សរណៈនៃការយោគយល់គ្នានោះ នឹងមានតម្រូវការដើម្បីបំពេញកន្លែងពលករ ដែលតាមការប៉ាន់ស្មាននាពេលបច្ចុប្បន្ន មានប្រមាណ ១៨០.០០០កន្លែងនៅក្នុងប្រទេស ។ ទោះជាយ៉ាងណាក្តី គេសន្និដ្ឋានថា មិនមានប្រព័ន្ធណាមួយល្អឥតខ្ចោះ ដើម្បីការពារកុំឱ្យប្រជាជនឆ្លងកាត់ព្រំដែន ដោយខុសច្បាប់ទៅរកការងារធ្វើក្នុងប្រទេសថៃនោះទេ ។ យោងតាមស្ថានភាពពេលនេះ ប្រសិនបើមានប្រព័ន្ធណាមួយអាចជំរុញឱ្យពលករ ៥០% ឆ្លងកាត់តាមច្រកផ្លូវការនោះ គេអាចចាត់ទុកថាប្រព័ន្ធនោះសម្រេចបានជោគជ័យដ៏ធំមួយ ។ ពលករចំណាកស្រុកទាំងអស់ សុទ្ធតែរំពឹងថា អាចនឹងត្រូវបញ្ជូនត្រលប់ទៅធ្វើការនៅក្នុងប្រទេសថៃវិញក្នុងលក្ខខណ្ឌស្របច្បាប់ ។ បច្ចុប្បន្ន មានតម្រូវការពលករយ៉ាងច្រើនពី ២០.០០០-៣០.០០០នាក់ បន្ថែមពីលើចំនួន ១៨០.០០០នាក់ដែលបានប៉ាន់ស្មាន ។ ដូច្នេះ គេត្រូវការកិច្ចប្រឹងប្រែងយ៉ាងច្រើនថែមទៀត ដើម្បីបំពេញតម្រូវការនេះ ។

យើងអាចដោះស្រាយបញ្ហារត់ចោលការងារនេះ ដោយការស្វែងរកមធ្យោបាយជួយដល់ពលករដែលខិតខំធ្វើការក្នុងការទទួលបានកម្ចីដោយមាន ឬមិនមានការប្រាក់ ។ កម្ចីនេះ អាចផ្តល់តាមរយៈធនាគារ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ (MFIs) កម្មវិធីផ្តល់ឥណទានរបស់អង្គការមិនមែនរដ្ឋាភិបាល គម្រោងប្រាក់សន្សំក្នុងសហគមន៍ ឬបានពីសាច់ញាតិរបស់ពួកគេ ។ ពលករដែលមានសមត្ថភាពរកចំណូលតាមរយៈការងារក្រៅប្រទេស នឹងប្រើប្រាស់ប្រាក់កម្ចី ដើម្បីបង់ទៅឱ្យទីភ្នាក់ងារជ្រើសរើសពលករ ។ កម្ចីបែបនេះ គួរមានការទទួលស្គាល់ពីអាជ្ញាធរមូលដ្ឋាន ឬអ្នករៀបចំចាត់ចែងណាដែលស្គាល់អ្នកស្នើសុំច្បាស់លាស់ ។

បុគ្គលិកជំនាញរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ គួរត្រួតពិនិត្យឱ្យបានម៉ត់ចត់ទៅលើទីភ្នាក់ងារជ្រើសរើសពលករ ដើម្បីជៀសវាងបញ្ហាការចំណាយទៅក្នុងផ្លូវខុសនូវប្រាក់ដែលពលករបានបង់ បើទោះជាការទូទាត់ប្រាក់ អាចនឹងធ្វើឡើង នៅពេលដែលពលករប្រាកដថា នឹងទទួលបានការងារ ហើយត្រៀមរួចរាល់សំរាប់ការចេញដំណើរក៏ដោយ ។ នៅក្នុងសេណារីយ៉ូនេះ វាហាក់ដូចជាមានភាពលំអៀងចំពោះពលករក្រីក្រ និងងាយរងគ្រោះ ដោយពួកគាត់មិនមានប្រាក់ ឬមិនអាចទទួលបានកម្ចីអ្វីឡើយ ។ ជាទូទៅ មានតែពលករមានសមត្ថភាពបង់កម្រៃប៉ុណ្ណោះដែលអាចធ្វើចំណាកស្រុកទៅធ្វើការនៅបរទេស ។

នេះអាចជាមធ្យោបាយល្អមួយ ព្រោះពលករចំណាកស្រុកកម្ពុជា ដែលស្ថិតក្នុងក្រុមនេះ ទំនងជាធ្វើការងារបានល្អ និងពោរពេញដោយលទ្ធភាពប្រកួតប្រជែងនៅក្រៅប្រទេស ។ នេះជារឿងល្អចំពោះពលករក្រីក្រ និងងាយរងគ្រោះ ព្រោះពួកគេអាចស្វែងរកការងារនៅក្នុងប្រទេសបាន ដោយសារពួកគេទំនងជាមិនសូវមានលទ្ធភាពប្រកួតប្រជែងនៅក្រៅប្រទេសឡើយ ហើយក៏ប្រហែលជារឿងល្អផងដែរនៅក្នុងគោលគំនិតរបស់និយោជកបរទេស ។ និយោជកបរទេសនឹងឃើញថា ពលករកម្ពុជាប្រភេទនេះ ធ្វើការងារបានល្អ ហើយតម្រូវការនូវពលករកម្ពុជា ក៏ទំនងជានឹងកើនឡើងច្រើនជាងមុន បើធៀបនឹងពលករនៃប្រទេសដទៃទៀត ។

### ៩.១៣. សុខុមាលភាព និងលក្ខខណ្ឌការងារ នៅក្នុងប្រទេសទទួលពលករ

ក្នុងអំឡុងពេលធ្វើការក្នុងប្រទេសថៃ ពលករចំណាកស្រុកត្រូវចូលរួមវិភាគទានក្នុងធានារ៉ាប់រងសុខភាព ។ នេះជាប្រយោជន៍មួយចំពោះពលករ ព្រោះបុព្វលាភធានារ៉ាប់រងនេះ គឺត្រឹមតែ ៣០បាត (០.៩០ដុល្លារ) ប៉ុណ្ណោះដែលទឹកប្រាក់នេះមិនជាថ្លៃឡើយ បើធៀបនឹងចំណូលរបស់ពលករ (ការងារភាគច្រើននៅក្នុងប្រទេសថៃ ផ្តល់កម្រៃ

១៨៥បាតក្នុងមួយថ្ងៃ) ។ ចំពោះសុខុមាលភាពសង្គម មានតម្លៃស្មើនឹង ១៥% នៃប្រៀវត្សរបស់ពលករដែលក្នុងនោះ ៥% ត្រូវចេញដោយក្រុមហ៊ុនដែលពលករកំពុងបម្រើការ និង ៥% ទៀតចេញដោយរដ្ឋាភិបាលថៃ និង ៥% ដែលនៅសល់ត្រូវចេញដោយពលករផ្ទាល់ ។ នេះជាតម្លៃសមរម្យមួយសំរាប់ពលករនៅក្នុងប្រទេសថៃ ដែលបានចុះឈ្មោះក្នុងបញ្ជីការងារ ។ ទោះយ៉ាងណាក្តី ពលករចំណាកស្រុក តែងស្ថិតនៅក្រោមសំពាធធ្ងន់ធ្ងរក្នុងអំឡុងពេលបីខែដំបូង ព្រោះពេលនោះ ពួកគេត្រូវទូទាត់ចំណាយទាំងនេះ ប៉ុន្តែពួកគេមិនទាន់រកចំណូលបានច្រើនពីការងារថែមម៉ោងនៅឡើយ ។ ករណីរត់ចោលការងារយ៉ាងច្រើន កើតមានក្នុងអំឡុងពេលបីខែដំបូងនេះ ។

ក្នុងករណីមានជម្លោះកើតឡើង អ្នកដែលត្រូវចូលរួមសម្រុះសម្រួលភ្លាមៗ គឺបុគ្គលិកក្រុមហ៊ុនដែលត្រូវបានតែងតាំង ដើម្បីធានាថា ពលករគោរពតាមកិច្ចសន្យា និងសងប្រាក់ដែលក្រុមហ៊ុនចំណាយឱ្យពួកមុន ។ គេបានធ្វើសំណើមួយទៅរដ្ឋាភិបាល សុំឱ្យបង្កើតមុខតំណែងមួយ គឺភ្នាក់ងារស្ថានទូតកម្ពុជាទទួលខុសត្រូវលើពលករនៅតាមបណ្តាប្រទេសដែលចាត់ទុកពលករចំណាកស្រុកពីកម្ពុជា ជាកំលាំងពលកម្មសំខាន់មួយផ្នែក ។ ការស្នើសុំនេះ ទំនងជាអាចបានសម្រេច ប៉ុន្តែគេនៅតែមានមន្ទិលសង្ស័យថា តើមនុស្សម្នាក់ពិតជាអាចដោះស្រាយបញ្ហាយ៉ាងច្រើនដែលអាចកើតចេញពីពលកររាប់ម៉ឺននាក់នោះបានដែរឬទេ ។

រហូតមកទល់ពេលនេះ នៅមិនទាន់មានការណែនាំអំពីវិធានការណាមួយក្នុងការផ្តល់ការការពារពលករចំណាកស្រុក ដូចជា អង្កេតកន្លែងធ្វើការ ការគ្រប់គ្រង/ជន្លៀសពីវិបត្តិ ឬពេលដោះស្រាយវិវាទ នៅឡើយទេ ។ ជាទូទៅ ការត្រួតពិនិត្យ និងសវនកម្មលើលក្ខខណ្ឌការងាររបស់ពលករចំណាកស្រុកនៅក្រៅប្រទេស មានធ្វើឡើងតិចតួចបំផុត ។ រដ្ឋាភិបាលមិនមានថវិកាបំរុងសំរាប់ធ្វើដំណើរទៅក្រៅប្រទេស ដើម្បីពិនិត្យលើបញ្ហានេះឡើយ ។ ក្នុងការអនុវត្តជាក់ស្តែងសព្វថ្ងៃ ក្រុមហ៊ុនជ្រើសរើសពលករ ជាអ្នកចេញថ្លៃចំណាយដល់មន្ត្រីរដ្ឋាភិបាល ដើម្បីធ្វើដំណើរទៅពិនិត្យរៀងរាល់ពីរឆ្នាំម្តង ។ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មិនមានរបាយការណ៍ជាផ្លូវការណាស្តីពីលក្ខខណ្ឌការងាររបស់ពលករចំណាកស្រុកឡើយ ។

# ជំពូក ៥ សន្និដ្ឋាន និងអនុសាសន៍

ករណីសិក្សានានារបស់សហគមន៍ដែលយើងចុះធ្វើអង្កេត បង្ហាញថា ទេសន្តរប្រវេសន៍កំលាំងពលកម្ម នាំមកនូវប្រយោជន៍ខាងសេដ្ឋកិច្ចច្រើនជាងចំណាយ ។ ពលករចំណាកស្រុកភាគច្រើន អាចរកចំណូលបាន និងផ្ញើប្រាក់ត្រលប់មកផ្ទះវិញ បើទោះជាពលករមួយចំនួនតូច ទទួលបរាជ័យ ហើយផុងខ្លួនជាប់បំណុលក៏ដោយ ។ បញ្ហានេះដោយសារពួកគេជ្រើសរើសយកមធ្យោបាយខុសច្បាប់ក្នុងការឆ្លងព្រំដែនទៅរកការងារនៅប្រទេសថៃ ។ ការវាយតម្លៃឱ្យប្រាកដជាក់លាក់ពីផលប៉ះពាល់នៃការធ្វើចំណាកស្រុក គឺជារឿងដែលមិនអាចទៅរួចឡើយ ប៉ុន្តែយើងអាចឃើញថាក្រុមគ្រួសារដែលមានសមាជិកធ្វើចំណាកស្រុកយ៉ាងហោចណាស់ ក៏មានស្ថានភាពមិនយ៉ាប់យ៉ឺនជាងគ្រួសារ ដែលមិនមានសមាជិកធ្វើចំណាកស្រុកដែរ ។ បញ្ហាដ៏ធ្ងន់ធ្ងរមួយចំនួន គឺជាឧបសគ្គរារាំងពលករកម្ពុជាក្នុងការជ្រើសរើសយកមធ្យោបាយស្របច្បាប់ ដើម្បីចូលទៅធ្វើការនៅប្រទេសថៃ ។ ដូច្នេះ ដំណោះស្រាយគន្លឹះ គឺត្រូវកាត់បន្ថយចំណាយនៃការធ្វើចំណាកស្រុកស្របច្បាប់ ។ រដ្ឋាភិបាលកម្ពុជា និងថៃ គួររួមគ្នាបន្ថយថ្លៃចំណាយសំរាប់ពលករចំណាកស្រុកក្នុងការចូលទៅធ្វើការក្នុងប្រទេសថៃពី ៧០០ដុល្លារមកត្រឹម ៣០០ដុល្លារ ។

ទេសន្តរប្រវេសន៍កំលាំងពលកម្ម គួរត្រូវបានគ្រប់គ្រងឱ្យបានប្រសើរជាងមុន ព្រោះវាផ្តល់ឱកាសការងារដល់ពលករកម្ពុជា ខណៈដែលកម្ពុជាទំនងជាមិនអាចផ្តល់ការងារគ្រប់គ្រាន់ដល់ពលករនៅក្នុងស្រុកឡើយ ក្នុងរយៈពេលខ្លីនិងមធ្យម ។ ចំណាយសំរាប់ពលករចំណាកស្រុកទៅធ្វើការនៅក្នុងប្រទេសថៃដោយស្របច្បាប់ គួរត្រូវបញ្ចុះឱ្យទាបបំផុត ហើយដើម្បីធ្វើដូចនេះបាន គេចាំបាច់ត្រូវកែលំអការរៀបចំបែបស្ថាប័នឱ្យមានភាពប្រសើរឡើង ហើយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ គួរបង្កើតនាយកដ្ឋានមួយ ដើម្បីទទួលខុសត្រូវដោយផ្ទាល់ចំពោះទេសន្តរប្រវេសន៍កំលាំងពលកម្ម និងគួរជ្រើសរើសបុគ្គលិកដែលមានសមត្ថភាពក្នុងការដោះស្រាយបញ្ហាចំណាកស្រុកបន្ថែម ។ គួរពិចារណារៀបចំបង្កើតគោលនយោបាយស្តីពីការធ្វើចំណាកស្រុក និងក្របខ័ណ្ឌច្បាប់សមស្របបន្ថែមទៀត ។ ម្យ៉ាងទៀត គេគួរបញ្ចុះថ្លៃធ្វើលិខិតឆ្លងដែន និងបង្កើនចំនួនការិយាល័យធ្វើលិខិតឆ្លងដែនបន្ថែមទៀត ទាំងនៅរាជធានីភ្នំពេញ និងខេត្តសំខាន់ៗ ដូចជា ខេត្តបាត់ដំបង សៀមរាប និងព្រៃវែង ជាដើម ។

ក្រុមហ៊ុន និងទីភ្នាក់ងារជ្រើសរើសពលករ គួរត្រូវបានបង្កើតឱ្យបានច្រើនជាងមុននៅតាមបណ្តាខេត្តដែលមានតួលេខពលករធ្វើចំណាកស្រុកទៅប្រទេសថៃខ្ពស់ ។ អនុក្រឹត្យលេខ ៥៧ គួរតែត្រូវកែសម្រួលឡើងវិញ ដើម្បីបញ្ចូលនូវការវិវត្តថ្មីៗ ។ ប្រាក់បញ្ញើ (១០០.០០០ដុល្លារនាពេលបច្ចុប្បន្ន) ដែលតម្រូវនៅមុនពេលបង្កើតជាទីភ្នាក់ងារជ្រើសរើសពលករនោះ គួរមានការបន្ធូរបន្ថយខ្លះ ដើម្បីបង្កើនចំនួនសេវាកម្មនៅក្នុងវិស័យនេះ ។ ទីភ្នាក់ងារជ្រើសរើសពលករ គួរធ្វើការជ្រើសរើសពលករប្រកបដោយការប្រុងប្រយ័ត្នជាងមុន ដើម្បីជៀសវាងបញ្ហារត់ចោលការងារ ហើយអង្គការក្រៅរដ្ឋាភិបាលមួយចំនួន ប្រហែលអាចជួយសម្រួលបញ្ហានេះបានខ្លះ ។ ទីភ្នាក់ងារជ្រើសរើសពលករ គួរអនុញ្ញាតឱ្យគិតថ្លៃពីពលករក្នុងការទៅធ្វើការនៅប្រទេសថៃ ដើម្បីជៀសវាងបញ្ហារត់ចោលកន្លែងធ្វើការ ។

ប្រទេសថៃ ក៏មានទទួលផលចំណេញពីពលករចំណាកស្រុកដែរ ។ ហេតុនេះ ប្រទេសថៃ គួរជួយសម្រួលដល់ដំណើរការធ្វើឱ្យពលករនៅទីនោះមានលក្ខណៈផ្លូវការ ។ រដ្ឋាភិបាល គួរបន្ទាបថ្លៃប្រតិបត្តិការនានា (សំរាប់លិខិតអនុញ្ញាតការងារ និងទិដ្ឋាការ) ។ ការទទួលយកពលករចំណាកស្រុកខុសច្បាប់ឱ្យធ្វើការ គួរត្រូវបញ្ឈប់ ហើយគួរលើកទឹកចិត្តដល់ពលករស្របច្បាប់ ។ គេគួររកមធ្យោបាយមួយក្នុងការផ្តល់ភាពពេញច្បាប់ទៅដល់ពលករដែលបាន និងកំពុងធ្វើការក្នុង

ប្រទេសថៃពីមុនៗមក ដោយមិនចាំបាច់ឱ្យពួកគេមកទទួលលិខិតឆ្លងដែន និងទិដ្ឋាការនៅរាជធានីភ្នំពេញវិញឡើយ ។ រាល់ចំណាយទាក់ទងនឹងការបញ្ជូលពលករចំណាកស្រុកឱ្យទទួលបានភាពពេញច្បាប់នោះ គួរត្រូវបន្ទាបថ្លៃតាមដែលអាចធ្វើទៅបាន ។

គេគួរពិចារណាពីគំនិត "ការិយាល័យច្រកចេញចូលតែមួយ" ដើម្បីគ្រប់គ្រងរាល់ដំណើរការនានា ។ ការិយាល័យនេះ គួរមានបង្កើតក្នុងតំបន់ ដែលជាប្រភពនៃការធ្វើចំណាកស្រុកយ៉ាងច្រើន ទៅកាន់ប្រទេសថៃ ។ ទីភ្នាក់ងារជ្រើសរើសពលករ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងការិយាល័យធ្វើលិខិតឆ្លងដែន ក៏ដូចជាអ្នកតំណាងរបស់ស្ថានទូតថៃ គួរចូលរួមក្នុងការិយាល័យច្រកចេញចូលតែមួយនេះ ដើម្បីទទួលសំណុំបែបបទ និងផ្តល់លទ្ធផលដល់ពលករ ។ ការធ្វើបែបនេះ នឹងជួយដល់ពលករបានយ៉ាងច្រើនទាំងក្នុងការសន្សំពេលវេលា និងចំណាយលើការធ្វើដំណើររបស់ពលករមកកាន់រាជធានីភ្នំពេញ ។ ដំណើរការមួយចប់សព្វគ្រប់ គួរចំណាយពេលមិនលើសពី ២ខែឡើយ ។ ទោះជាយ៉ាងណាក្តី ដំណើរការនេះ តម្រូវឱ្យមានការពិភាក្សាដោយម៉ត់ចត់រវាងក្រសួងការងារថៃ និងក្រសួងការងារកម្ពុជា ។

# ឯកសារយោង


Acharya, S. (2003), *Labour Migration in the Transitional Economies of South-East Asia*, Working Paper on Migration and Urbanization, Economic and Social Commission for Asia and the Pacific, http://www.unescap.org/esid/psis/population/workingpapers/LabourMigration/index.asp (accessed on 26 November 2007)

Asian Migrant Centre (2005), *Resource Book: Migration in the Greater Mekong Subregion*, (Khon Khaeng: Asian Migrant Centre & Mekong Migration Network)

Asian Migrant Centre (2004), *Asian Migrant Yearbook 2002-2003: Migration Facts, Analysis and Issues in 2001-2002*, (Khon Khaeng: Asian Migrant Centre & Migrant Forum in Asia)

Asian Migrant Centre (2002a), *Migration in the Greater Mekong Subregion: An Annotated Bibliography*, (Khon Khaeng: Asian Migrant Centre & Mekong Migration Network)

Asian Migrant Centre (2002b), *Migration Needs, Issues and Responses in the Greater Mekong Subregion: A Resource Book*, (Khon Khaeng: Asian Migrant Centre Ltd. & Mekong Migration Network)

Brett M. Ballard, Christian Sloth, David Wharton, Ingrid FitzGerald, K.A.S. Murshid, Kasper K. Hansen, Phim Runsinarith and Lim Sovannara (2007) '*We are living with worry all the time*', A Participatory Poverty Assessment of the Tonle Sap (Phnom Penh: CDRI)

CDRI (2007a), *Annual Development Review 2006-07*, (Phnom Penh: CDRI)

CDRI (2007b), Participatory Poverty Assessment: *We are living with worry all the time*, Cambodia Development Resource Institute, Phnom Penh.

Chan Sophal. & So Sovannarith. (1999), *Cambodian Labour Migration to Thailand: A Preliminary Assessment*, Working Paper 11, (Phnom Penh: CDRI)

Commission of Social Affairs (2002), *Policy and Strategy on Social Affairs in Cambodia, Revised Edition* (Phnom Penh: MOSALVY)

Dang Nguyen Anh (2007), "Labour Export from Vietnam: Issues of Policy and Practice", paper presented to the Eighth International Conference on Asia Pacific Migration Research Network, Fuzhou, China, 25-29 May

Godfrey, Martin, So Sovannarith, Tep Saravy, Pon Dorina, Claude Katz, Sarthi Acharya, Sisowath D. Chanto and Hing Thoraxy (2001), *A Study of the Cambodian Labour Market: Reference to Poverty Reduction, Growth and Adjustment to Crisis*, Working Paper 18 (Phnom Penh: CDRI)

IFAD (2007), *Sending Money Home: Worldwide Remittance Flows to Developing Countries*, http://www.ifad.org/events/remittances/maps/ (accessed on 12 December 2008)

IMF (2008), "Cambodia: Macroeconomic Developments", presentation to the Cambodia Outlook Conference 2008, Phnom Penh

IOM (2006), *Review of Labour Migration Dynamics in Cambodia*, (Phnom Penh: IOM)

Maltoni, B. (2006), *Impact of Remittances on Local Communities in Cambodia: The Case of Prey Veng Province*, (Phnom Penh: IOM)

MLVT (2007), Ministry of Labour and Vocational Training Strategic Plan 2006-2010 (Phnom Penh)

MLVT (2008), "Report on Achievements in 2007 and Directions in 2008, Ministry of Labour and Vocational Training" (Phnom Penh)

Morris, Elizabeth (2007), "Promoting Employment in Cambodia: Analysis and Options", draft working paper for the Ministry of Labour and Vocational Training (Phnom Penh)

Nou K., Phim R. & Tuot S. (forthcoming), *Regional Economic Integration and Trade Impact Assessment*, (Phnom Penh: CDRI)

Srawooth Paitoonpong and Yongyuth Chalamwong (2007), "Cross-border Labor Migration in the GMS: A Study on Remittances, Thailand Country Report 1- Preliminary Review", paper for Development Analysis Network First Research Team Workshop, 26-27 March, Phnom Penh

Srawooth Paitoonpong (2007), "Thailand's demand for labour in the next 50 years", slides presented to the Development Analysis Network First Research Team Workshop, 26-27 March, Phnom Penh

Todaro, Michael P. and Stephen C. Smith (2006), *Economic Development*, Ninth Edition, (London, New York: Pearson Education Limited)

Tuot Sokphally (2007), "Cross-Border Labour Migration in and out of Cambodia", *Cambodian Economic Review*, Issue 3, June, pp. 21-39

UNIFEM (2006), "Cambodian Women Migrant Workers: Findings from a Migration Mapping Study", (Phnom Penh)

World Bank (2006), *Cambodia: Halving Poverty by 2015? Poverty Assessment 2006* (Phnom Penh: World Bank)

World Bank (2007), *World Development Indicators 2007*, CD ROM

# ឧបសម្ព័ន្ធ

**ឧបសម្ព័ន្ធ A:** (តារាងព័ត៌មានបន្ថែម)

**តារាង A១. បំណែងចែកតាមភេទក្នុងតំបន់គោលដៅទូទៅនៃការធ្វើចំណាកស្រុកក្នុងរយៈពេល ៥ឆ្នាំកន្លងទៅ**

| ភូមិ | | ចំនួន | | | | ភាគរយ | | | |
|---|---|---|---|---|---|---|---|---|---|
| | | ក្នុងប្រទេសថៃ | តាមព្រំដែនថៃ | ម៉ាឡេស៊ី | សរុប | ក្នុងប្រទេសថៃ | តាមព្រំដែនថៃ | ម៉ាឡេស៊ី | សរុប |
| ស្រម៉មាស | ប្រុស | 1 | 0 | 31 | 32 | 3 | 0 | 97 | 100 |
| | ស្រី | 2 | 0 | 26 | 28 | 7 | 0 | 93 | 100 |
| | ទាំងពីរ | 3 | 0 | 57 | 60 | 5 | 0 | 95 | 100 |
| ក្រសាំង | ប្រុស | 18 | 44 | 0 | 62 | 29 | 71 | 0 | 100 |
| | ស្រី | 6 | 31 | 3 | 40 | 15 | 78 | 8 | 100 |
| | ទាំងពីរ | 24 | 75 | 3 | 102 | 24 | 74 | 3 | 100 |
| គោកធ្លង់ | ប្រុស | 30 | 0 | 0 | 0 | 100 | 0 | 0 | 100 |
| | ស្រី | 36 | 1 | 0 | 37 | 97 | 3 | 0 | 100 |
| | ទាំងពីរ | 66 | 1 | 0 | 37 | 178 | 3 | 0 | 100 |
| រំដួល | ប្រុស | 48 | 2 | 0 | 50 | 96 | 4 | 0 | 100 |
| | ស្រី | 23 | 0 | 0 | 0 | 100 | 0 | 0 | 100 |
| | ទាំងពីរ | 71 | 2 | 0 | 50 | 142 | 4 | 0 | 100 |
| សៀមពាយ | ប្រុស | 15 | 71 | 0 | 86 | 17 | 83 | 0 | 100 |
| | ស្រី | 3 | 37 | 0 | 40 | 8 | 93 | 0 | 100 |
| | ទាំងពីរ | 18 | 108 | 0 | 126 | 14 | 86 | 0 | 100 |
| ខ្ចយ | ប្រុស | 73 | 3 | 0 | 76 | 96 | 4 | 0 | 100 |
| | ស្រី | 8 | 1 | 0 | 9 | 89 | 11 | 0 | 100 |
| | ទាំងពីរ | 81 | 4 | 0 | 85 | 95 | 5 | 0 | 100 |
| ភូមិទាំងអស់ | ប្រុស | 185 | 120 | 31 | 306 | 60 | 39 | 10 | 100 |
| | ស្រី | 78 | 70 | 29 | 154 | 51 | 45 | 19 | 100 |
| | ទាំងពីរ | 263 | 190 | 60 | 460 | 57 | 41 | 13 | 100 |

## តារាង A២. តំបន់គោលដៅនៃការធ្វើដំណើរថ្មីៗបំផុតក្នុងរយៈពេល ៥ឆ្នាំកន្លងទៅ

| ភូមិ | | ចំនួន | | | | ភាគរយ | | | |
|---|---|---|---|---|---|---|---|---|---|
| | | ក្នុងប្រទេសថៃ | តាមព្រំដែនថៃ | ម៉ាឡេស៊ី | សរុប | ក្នុងប្រទេសថៃ | តាមព្រំដែនថៃ | ម៉ាឡេស៊ី | សរុប |
| ស្រម៉មាស | ប្រុស | 1 | 0 | 31 | 32 | 3 | 0 | 97 | 100 |
| | ស្រី | 2 | 0 | 26 | 28 | 7 | 0 | 93 | 100 |
| | ទាំងពីរ | 3 | 0 | 57 | 60 | 5 | 0 | 95 | 100 |
| ក្រសាំង | ប្រុស | 16 | 46 | 0 | 62 | 26 | 74 | 0 | 100 |
| | ស្រី | 5 | 32 | 3 | 40 | 13 | 80 | 8 | 100 |
| | ទាំងពីរ | 21 | 78 | 3 | 102 | 21 | 76 | 3 | 100 |
| គោកធ្នង់ | ប្រុស | 30 | 0 | 0 | 0 | 100 | 0 | 0 | 100 |
| | ស្រី | 36 | 1 | 0 | 37 | 97 | 3 | 0 | 100 |
| | ទាំងពីរ | 66 | 1 | 0 | 37 | 178 | 3 | 0 | 100 |
| រំដួល | ប្រុស | 47 | 3 | 0 | 50 | 94 | 6 | 0 | 100 |
| | ស្រី | 23 | 0 | 0 | 0 | 100 | 0 | 0 | 100 |
| | ទាំងពីរ | 70 | 3 | 0 | 50 | 140 | 6 | 0 | 100 |
| សៀមពាយ | ប្រុស | 15 | 71 | 0 | 86 | 17 | 83 | 0 | 100 |
| | ស្រី | 3 | 37 | 0 | 40 | 8 | 93 | 0 | 100 |
| | ទាំងពីរ | 18 | 108 | 0 | 126 | 14 | 86 | 0 | 100 |
| ខ្ពយ | ប្រុស | 73 | 3 | 0 | 76 | 96 | 4 | 0 | 100 |
| | ស្រី | 8 | 1 | 0 | 9 | 89 | 11 | 0 | 100 |
| | ទាំងពីរ | 81 | 4 | 0 | 85 | 95 | 5 | 0 | 100 |
| ភូមិទាំងអស់ | ប្រុស | 182 | 123 | 31 | 306 | 59 | 40 | 10 | 100 |
| | ស្រី | 77 | 71 | 29 | 154 | 50 | 46 | 19 | 100 |
| | ទាំងពីរ | 259 | 194 | 60 | 460 | 56 | 42 | 13 | 100 |

**ព្រះរាជាណាចក្រ កម្ពុជា**

Kingdom of Cambodia

**រាជរដ្ឋាភិបាល កម្ពុជា** | **ជាតិ សាសនា ព្រះមហាក្សត្រ**

Royal Government of Cambodia | Nation Religion King

លេខ: ៥៧ អនុក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេស

## រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញច្បាប់ការងារដែលប្រកាសអោយប្រើដោយក្រឹត្យលេខ ៩៩ក្រ ចុះថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ១៩៩២
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តមសីហនុវរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តមសីហនុវរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- តាមសំណើរបស់រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន ។

សំ រេ ច :

<u>មាត្រា ១</u> : ដើម្បីដោះស្រាយជីវភាព និងបង្កើនមុខជំនាញវិជ្ជាជីវៈ រាជរដ្ឋាភិបាលអនុញ្ញាតអោយបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេស នៅពេលដែលទីផ្សារការងារក្នុងប្រទេស មិនទាន់មានលទ្ធភាពទទួលយកអ្នកគ្មានការងារធ្វើ និងអ្នកដែលមានការងារមិនពេញលេញ បានអស់ និងរកប្រាក់ចំណូលចូលថវិកាជាតិ ។

<u>មាត្រា ២</u> : ការបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេស និងការគ្រប់គ្រងពលករទាំងនេះ ជាសមត្ថកិច្ចរបស់ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន ។

ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន អាចអនុញ្ញាតតាមប្រកាសរបស់ក្រសួងឱ្យក្រុមហ៊ុនណាមួយបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេសបាន ។

ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន ត្រូវចេញសារាចរណែនាំអនុវត្តបន្ថែមទៀតក្នុងករណីចាំបាច់ ។

ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន ត្រូវសហការជាមួយក្រសួងមហាផ្ទៃ ក្នុងការធ្វើទំរង់បែបបទដូចជា លិខិតឆ្លងដែនជាដើម ដើម្បីបញ្ជូនពលករទៅបរទេស ហើយត្រូវសហការជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិក្នុងការគ្រប់គ្រងពលករខ្មែរដែលធ្វើការនៅបរទេស ។

មាត្រា ៣ : ត្រូវបានចាត់ទុកជាបេក្ខជនសំរាប់ជ្រើសរើសបញ្ជូនឱ្យទៅធ្វើការនៅបរទេស ពលករខ្មែរទាំងពីរភេទមានអាយុចាប់ពី ១៨ឆ្នាំឡើងទៅ ដែលបានដាក់ពាក្យសុំការងារធ្វើនៅក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន ។

មាត្រា ៤ : ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន ហៅថាភាគីផ្តល់ពលករ ។ ក្រុមហ៊ុនដែលស្នើសុំជ្រើសរើសពលករ ហៅថាភាគីទទួលពលករ ។

មាត្រា ៥ : រាល់សំណើពីភាគីទទួលពលករ ត្រូវបញ្ជាក់ឱ្យច្បាស់លាស់អំពីល័ក្ខខ័ណ្ឌសំខាន់ៗជាអាទិ៍:

- កាលបរិច្ឆេទចាប់ផ្តើមអនុវត្ត និងបញ្ចប់ការងារ
- ប្រភេទការងារ
- ទីកន្លែងទៅធ្វើការងារ
- ចំនួន និងមុខជំនាញរបស់ពលករ
- ប្រាក់បៀវត្ស ប្រាក់បំណាច់ផ្សេងៗ ដោយគិតទាំងការស្នាក់នៅ ហូបចុក ស្លៀកពាក់ ព្យាបាល ព្រមទាំងបញ្ហាផ្សេងៗទៀតក្នុងជីវភាពប្រចាំថ្ងៃ
- ការដឹកជញ្ជូនពលករទៅ និងមក ។

ក្រោយពីបានទទួលសំណើ ភាគីផ្តល់ពលករត្រូវឆ្លើយទៅភាគីទទួលពលករវិញយ៉ាងយូរបំផុត ៤៥ថ្ងៃ ដោយត្រូវបញ្ជាក់ថា តើអាចផ្តល់ពលករបានកំរិតណា ឬមិនបាន ឬត្រូវពិភាក្សាគ្នាបន្ថែមទៀត ។

ភាគីទទួលពលករ ត្រូវឆ្លើយមកភាគីផ្តល់ពលករវិញយ៉ាងយូរ ៣០ថ្ងៃ ថាតើត្រូវការពលករទាំងអស់នោះ ឬទេ ឬត្រូវការតែកំរិតណាមួយនោះ ដោយត្រូវចូលមកពិភាក្សានៅពេលជាមួយគ្នានេះដែរ ។ ហួសរយៈពេល ៣០ថ្ងៃ ហើយបើគ្មានចម្លើយ និងមិនឃើញចូលមកពិភាក្សាទេ ភាគីផ្តល់ពលករកំណត់ថា ភាគីទទួលពលករ មិនត្រូវការពលករទាំងនោះទេ ។

មាត្រា ៦ : ការបញ្ជូនពលករទៅបរទេស អាចអនុវត្តបាន លុះត្រាតែមានការអនុញ្ញាតពីភាគីផ្តល់ពលករ និងត្រូវមានកិច្ចសន្យាការងាររវាងពលករជាមួយភាគីទទួលពលករ ។

មាត្រា ៧ : ក្រោយពេលទទួលការអនុញ្ញាតជាផ្លូវការរយៈពេល ៧ថ្ងៃយ៉ាងយូរ ភាគីទទួលពលករ ត្រូវតំកល់ប្រាក់ធានាចំនួនមួយរយពាន់ដុល្លារអាមេរិកនៅក្នុងគណនីរបស់ភាគីផ្តល់ពលករ ។ បើភាគីទទួលពលករ មិនបានបង់ប្រាក់ធានានេះទេ ការអនុញ្ញាតនេះនឹងត្រូវចាត់ទុកជាមោឃៈ ។

ប្រាក់តំកល់នេះ សំរាប់ឱ្យភាគីផ្តល់ពលករបើកឱ្យពលករជំនួសភាគីទទួលពលករ ក្នុងករណីដែលភាគីនេះមិនបានគោរពល័ក្ខខ័ណ្ឌណាមួយដែលមានចែងក្នុងកិច្ចសន្យាការងារ ។

ក្នុងពេលអនុវត្តកិច្ចសន្យាការងារ បើប្រាក់តំកល់នេះ ត្រូវបានដកខ្លះ ដើម្បីឱ្យពលករ ភាគីទទួលពលករត្រូវបង់បំពេញឱ្យបានគ្រប់ចំនួនឡើងវិញ ។

ភាគីទទួលពលករ អាចដកប្រាក់តំកល់នេះទៅវិញបាន នៅពេលចប់កិច្ចសន្យាការងារជាស្ថាពរជាមួយពលករទាំងអស់ ។

ប្រាក់តំកល់ក្នុងមាត្រានេះ អាចបន្ធូរបន្ថយបាន ចំពោះនិយោជកដែលត្រូវការជ្រើសរើសពលករខ្មែរតែបន្តិចបន្តួចដោយផ្ទាល់ ដើម្បីយកទៅធ្វើការក្នុងរោងជាង ឬរោងសិប្បកម្មរបស់ខ្លួន ។ ប៉ុន្តែនិយោជិកនោះ ចាំបាច់ត្រូវពិភាក្សាជាមួយក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន ដើម្បីធ្វើកិច្ចសន្យាឯកត្តភូតជាមួយពលករទាំងនោះ ។

មាត្រា ៨ : ភាគីទទួលពលករ ត្រូវបង់សោហ៊ុយសេវា និងការរៀបចំឯកសារផ្សេងៗជូនភាគីផ្តល់ពលករតាមការឯកភាពគ្នាដែលមានកំណត់ក្នុងកិច្ចសន្យា ។

មាត្រា ៩ : កិច្ចសន្យាការងារ ត្រូវបញ្ជាក់ឱ្យច្បាស់ ជាអាទិ៍:

- ឈ្មោះ និងអាស័យដ្ឋានរបស់ភាគីនីមួយៗ
- កាលបរិច្ឆេទនៃការចាប់ផ្តើម និងបញ្ចប់កិច្ចសន្យា
- ទីកន្លែង និងប្រភេទការងារជាក់ស្តែង
- មុខជំនាញពលករ
- ប្រាក់បៀវត្ស និងប្រាក់បំណាច់ផ្សេងៗ
- ប្រាក់បៀវត្ស និងប្រាក់បំណាច់ផ្សេងៗដែលត្រូវបញ្ជូនមកគ្រួសារ
- ពេលម៉ោងធ្វើការ និងថ្ងៃឈប់សំរាកប្រចាំសប្តាហ៍ ប្រចាំឆ្នាំ
- ការស្នាក់នៅ ហូបចុក ស្លៀកពាក់ ព្យាបាល
- ការបង់ប្រាក់ធានារ៉ាប់រងចំពោះពលករម្នាក់ៗ
- ការប្រគល់ និងទទួលពលករពេលទៅ និងពេលត្រឡប់មកវិញ
- សោហ៊ុយដឹកជញ្ជូនពលករទៅ និងមក
- ករណីដែលត្រូវបញ្ជូនពលករមកមាតុប្រទេសវិញមុនកាលកំណត់ក្នុងកិច្ចសន្យាការងារ ។

មាត្រា ១០ : ពលករទាំងអស់ត្រូវមានសិទ្ធិឈប់សំរាកប្រចាំឆ្នាំ ដោយមានប្រាក់ឈ្នួលដែលភាគីទទួលពលករត្រូវចេញឱ្យ ។ ឯចំនួនថ្ងៃឈប់សំរាកនេះ ត្រូវគិតជាថ្ងៃធ្វើការធម្មតាមួយថ្ងៃកន្លះយ៉ាងតិចក្នុងរយៈពេលធ្វើការមួយខែជាប់ ។

មាត្រា ១១ : កិច្ចសន្យាការងារ ត្រូវធ្វើជាពីរភាសាដែលមានតម្លៃស្មើគ្នា គឺភាសាខ្មែរ និងភាសាបារាំង ឬ អង់គ្លេស ។ រយៈពេលនៃកិច្ចសន្យាការងារ មិនត្រូវឱ្យលើសពីពីរឆ្នាំឡើយ ។

នៅពេលចប់អាណត្តិនៃកិច្ចសន្យាការងារ ភាគីទាំងពីរអាចពិភាក្សាគ្នាបន្តអនុវត្តកិច្ចសន្យាទៅទៀតបាន ឬមួយធ្វើកិច្ចសន្យាសាថ្មី ។ កិច្ចសន្យាបន្តការងារតទៅទៀត ឬធ្វើសាជាថ្មី ក៏ត្រូវមានការចុះទិដ្ឋាការសាថ្មីពីក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជនដែរ ។

មាត្រា ១២ : ភាគីផ្តល់ពលករ ជាអ្នកជ្រើសរើសពលករតាមមុខជំនាញនីមួយៗឱ្យបានគ្រប់ចំនួនដែលបានកំណត់ក្នុងកិច្ចសន្យាការងារ ។

កិច្ចសន្យាការងារដែលពលករចុះហត្ថលេខាជាមួយភាគីទទួលពលករ ត្រូវមានចុះទិដ្ឋាការរបស់អធិការការងារមានសមត្ថកិច្ច ។

មាត្រា ១៣ : នៅពេលចុះកិច្ចសន្យាការងារ ពលករម្នាក់ៗ ត្រូវផ្តល់:

- ជីវប្រវត្តិសង្ខេបរបស់សាមីជនមានបិទរូបថត ៤ x ៦ ស.ម ២ សន្លឹក
- សំបុត្រថ្កោលទោស ២ ច្បាប់
- លិខិតបញ្ជាក់សុខភាព ដែលចេញឱ្យដោយនាយកដ្ឋានពេទ្យការងារ ២ ច្បាប់
- សេចក្តីចម្លងសញ្ញាប័ត្រ ឬលិខិតបញ្ជាក់មុខជំនាញ "បើសិនជាមាន" ២ ច្បាប់
- សេចក្តីចម្លងលិខិតឆ្លងដែនរបស់សាមីជន ២ ច្បាប់
- ប័ណ្ណសុំការងារ ១ ច្បាប់

មាត្រា ១៤ : មុនពេលចេញដំណើរទៅបរទេស ភាគីផ្តល់ពលករនិងទទួលពលករ ត្រូវទទួលបន្ទុករៀបចំធ្វើកម្មសិក្សាអំពីរបៀបរបបធ្វើការងារ របៀបរបបរស់នៅ ទំនៀមទំលាប់ប្រពៃណី និងច្បាប់ទំលាប់ជាចាំបាច់របស់ប្រទេសទទួលពលករ ។

មាត្រា ១៥ : ប្រាក់បៀវត្សរបស់ពលករម្នាក់ៗត្រូវជាប់ពន្ធតាមច្បាប់ជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ១៦ : ភាគីទទួលពលករ ត្រូវរ៉ាប់រងចេញសោហ៊ុយចំណាយឱ្យមន្ត្រីរបស់ប្រទេសផ្តល់ពលករទៅបំពេញបេសកកម្មដើម្បីជូនពលករទៅដល់ប្រទេសទទួលពលករ ត្រួតពិនិត្យល័ក្ខខ័ណ្ឌការងារ ទីកន្លែងធ្វើការងារ និងទីស្នាក់នៅអាស្រ័យរបស់ពលករដែលបានកំណត់ក្នុងកិច្ចសន្យា ។

ភាគីផ្តល់ពលករ ត្រូវបញ្ជូនមន្ត្រីទៅពិនិត្យការអនុវត្តន៍កិច្ចសន្យាការងារដល់ទីកន្លែងក្នុងរយៈពេលដែលចាំបាច់ ។

មាត្រា ១៧ : បើមានវិវាទការងារកើតឡើង ភាគីទទួលពលករត្រូវពិភាក្សា និងដោះស្រាយជាមួយពលករភ្លាម ដោយផ្អែកទៅលើកិច្ចសន្យាការងារ ។ បើការពិភាក្សាគ្នានេះ មិនអាចសំរុះសំរួលគ្នាបានទេនោះ គេត្រូវផ្តល់ព័ត៌មានភ្លាមទៅស្ថានឯកអគ្គរាជទូត ឬបេសកកម្មទូតរបស់ព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសនោះ ដើម្បីចូលរួមដោះស្រាយ ។

មាត្រា ១៨ : ភាគីទទួលពលករ ត្រូវផ្តល់ព័ត៌មានដល់ភាគីផ្តល់ពលករឱ្យបាន ៤៥ថ្ងៃ មុនកាលបរិច្ឆេទនៃការវិលត្រឡប់មកមាតុប្រទេសវិញពិតប្រាកដរបស់ពលករ ។

ភាគីទទួលពលករ និងភាគីផ្តល់ពលករ ត្រូវរៀបចំរួមគ្នាអំពីប្រតិទិននៃការធ្វើមាតុភូមិនិវត្តន៍របស់ពលករ ។

មាត្រា ១៩ : ការបាត់ខ្លួនរបស់ពលករនៅក្នុងរយៈពេលអនុវត្តកិច្ចសន្យាការងារ ភាគីទទួលពលករត្រូវផ្តល់ព័ត៌មានជាបន្ទាន់ដល់ស្ថានឯកអគ្គរាជទូត ឬបេសកកម្មទូតរបស់ព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសនោះ និងមកក្រសួងសង្គមកិច្ច ការងារ និង អតីតយុទ្ធជន នៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ២០ : ជនណាដែលបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេស ដោយល្មើសនឹងបទបញ្ញត្តិទាំងឡាយក្នុងអនុក្រឹត្យនេះត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន ។

<u>មាត្រា ២១</u> : បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

<u>មាត្រា ២២</u> : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និងចុះហត្ថលេខាតទៅ ។

ភ្នំពេញ, ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៥

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ត្រា និងហត្ថលេខា

នរោត្តម រណឫទ្ធិ ហ៊ុន សែន

<u>កន្លែងទទួល</u> :

- ខុទ្ទកាល័យព្រះមហាក្សត្រ
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេច នាយករដ្ឋមន្ត្រីទី ១
- ខុទ្ទកាល័យសម្តេច នាយករដ្ឋមន្ត្រីទី ២
- ដូចមាត្រា ២២ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

**ឧបសម្ព័ន្ធ C:** **(ការបកប្រែរបស់ CDRI)**

## អនុស្សរណៈនៃការយោគយល់គ្នា
## រវាង
## រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
## និង
## រដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃ
## ស្តីអំពី
## កិច្ចសហប្រតិបត្តិការទ្វេភាគីក្នុងការបញ្ជូលពលករទៅធ្វើការនៅប្រទេសថៃ

------------

រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និង រដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃ ដែលតទៅនេះ ហៅកាត់ថា "រដ្ឋជាភាគី"

**ដោយទទួលស្គាល់** នូវគោលការណ៍ដែលមានចែងក្នុង សេចក្តីប្រកាសនៅទីក្រុងបាងកកស្តីពីការធ្វើចំណាកស្រុកមិនប្រក្រតី ឆ្នាំ១៩៩៩

**ដោយមានការព្រួយបារម្ភ** ពីផលប៉ះពាល់អវិជ្ជមានទៅលើសង្គម និងសេដ្ឋកិច្ច ដែលបណ្តាលមកពីការងារមិនស្របច្បាប់

**ដោយមានគោលបំណង** លើកកម្ពស់កិច្ចសហប្រតិបត្តិការទ្វេភាគីរវាងប្រទេសទាំងពីរ

បានព្រមព្រៀងគ្នា ដូចតទៅ:

<u>ទិសដៅ និងវិសាលភាព</u>

មាត្រា ១

រដ្ឋជាភាគី ត្រូវអនុវត្តរាល់វិធានការចាំបាច់នានា ដើម្បីធានាឱ្យបាននូវ:

១- នីតិវិធីសមស្របក្នុងការជួលពលករ

២- ការធ្វើមាតុភូមិនិវត្តន៍នៃពលករដែលបានបញ្ចប់អាណត្តិ និងលក្ខខណ្ឌការងារ ឬការបញ្ជូនដោយអាជ្ញាធរពាក់ព័ន្ធនៃរដ្ឋជាភាគីនីមួយៗនូវពលករដែលមិនទាន់បានបញ្ចប់អាណត្តិ និងលក្ខខណ្ឌការងារ ទៅកាន់អាសយដ្ឋានអចិន្ត្រៃយ៍របស់ពួកគេវិញ ប្រកបដោយប្រសិទ្ធភាព ។

៣- ការការពារពលករដោយសមស្រប ដើម្បីធានាថា មិនមានការបាត់បង់នូវសិទ្ធិ និងការការពារពលករ និងធានាឱ្យពួកគេទទួលបានសិទ្ធិដែលពួកគេត្រូវទទួលបាន ។

៤- ការទប់ស្កាត់ និងការចាត់វិធានការដ៏មានប្រសិទ្ធភាពប្រឆាំងនឹងការឆ្លងដែនខុសច្បាប់ ការធ្វើចរាចរណ៍ពលករខុសច្បាប់ និងការជួលពលករដោយខុសច្បាប់ ។

អនុស្សរណៈនៃការយោគយល់គ្នានេះ មិនមានអានុភាពអនុវត្តលើនីតិវិធីផ្សេងទៀតដែលមានស្រាប់ ស្តីពីការជួលពលករ និងដែលមានលក្ខណៈស្របតាមច្បាប់នៃរដ្ឋជាភាគីឡើយ ។

<u>ស្ថាប័នអនុវត្ត</u>

មាត្រា ២

សំរាប់គោលដៅនៃអនុស្សរណៈនៃការយោគយល់គ្នានេះ ក្រសួងសង្គមកិច្ច ការងារ វិជ្ជាជីវៈ និងយុវនីតិសម្បទានៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងការងារនៃព្រះរាជាណាចក្រថៃ គឺជាស្ថាប័នអនុវត្ត នៃរដ្ឋជាភាគីរៀងៗខ្លួន ។

មាត្រា ៣

រដ្ឋជាភាគីនីមួយៗ ដែលមានស្ថាប័នអនុវត្តជាតំណាង ត្រូវពិគ្រោះយោបល់ជាទៀងទាត់នៅថ្នាក់ក្រសួង និង/ឬ ថ្នាក់មន្ត្រីជាន់ខ្ពស់ ទាក់ទងនឹងការអនុវត្តអនុស្សរណៈនេះ យ៉ាងហោចណាស់រៀងរាល់មួយឆ្នាំម្តង ។

ស្ថាប័នអនុវត្តនៃរដ្ឋជាភាគីទាំងពីរ ត្រូវធ្វើការរួមគ្នាបង្កើតនូវនីតិវិធី ដើម្បីធ្វើសមាហរណកម្មឱ្យចូលទៅក្នុងដែនអនុវត្តនៃអនុស្សរណៈនេះ នូវពលករខុសច្បាប់ដែលបានមករស់នៅក្នុងប្រទេសនីមួយៗ នៅមុនពេលដែលអនុស្សរណៈនេះចូលជាធរមាន ។

## <u>សិទ្ធិអំណាច និងនីតិវិធី</u>

មាត្រា ៤

រដ្ឋជាភាគី ត្រូវចាត់រាល់វិធានការចាំបាច់ ដើម្បីធានាឱ្យមាននីតិវិធីសមស្របលើការជួលពលករ ។

ការជួលពលករ តម្រូវឱ្យមានការអនុញ្ញាតជាមុនពីស្ថាប័នអនុវត្តក្នុងប្រទេសរៀងៗខ្លួន ។ ការអនុញ្ញាតនេះអាចផ្តល់ឱ្យ ក្រោយពីមានការបំពេញស្រេចបាច់ទៅតាមនីតិវិធីដែលច្បាប់ និងបទបញ្ញត្តិនៃប្រទេសរៀងៗខ្លួនបានតម្រូវឡើង ។

ស្ថាប័នអនុវត្ត អាចធ្វើមោឃភាព ឬ លុបចោលការអនុញ្ញាតរបស់ខ្លួន នៅពេលណាមួយស្របទៅតាមច្បាប់ និងបទបញ្ញត្តិពាក់ព័ន្ធ ដែលមានជាធរមាន ។

ការធ្វើមោឃភាព ឬ ការលុបចោលនេះ មិនមានអានុភាពទៅលើផ្នែកដែលបានអនុវត្តរួចហើយ នៅមុនពេលមានការធ្វើមោឃភាព ឬ ការលុបចោលនេះ ។

មាត្រា ៥

តាមរយៈការប្រកាសផ្តល់ការងារ ស្ថាប័នអនុវត្តគួរជូនដំណឹងដល់សមភាគីរបស់ខ្លួនអំពីឱកាសការងារ ចំនួនរយៈពេល កំរិតជំនាញតម្រូវឡើង លក្ខខណ្ឌការងារ និងលាភការដែលនិយោជកផ្តល់ជូន ។

មាត្រា ៦

ស្ថាប័នអនុវត្ត ត្រូវផ្តល់ឱ្យសមភាគីរបស់ខ្លួននូវបញ្ជីរាយនាមបេក្ខជនដែលត្រូវបានជ្រើសរើស សំរាប់ការងារព្រមទាំងព័ត៌មានស្តីពីអាយុ អាសយដ្ឋានអចិន្ត្រៃយ៍ អ្នកធានា កំរិតអប់រំ បទពិសោធន៍ និងព័ត៌មានផ្សេងទៀត ដែលយល់ថាចាំបាច់សំរាប់និយោជកធ្វើការពិចារណា ។

មាត្រា ៧

ស្ថាប័នអនុវត្ត ត្រូវធ្វើការសម្របសម្រួលជាមួយអាជ្ញាធរអន្តោប្រវេសន៍ និងអាជ្ញាធរពាក់ព័ន្ធផ្សេងទៀត ដើម្បីធានាថា បេក្ខជនដែលនិយោជកបានជ្រើសរើស និងមានការអនុញ្ញាតស្របតាមមាត្រា ៦ បានបំពេញនូវលក្ខខណ្ឌនានាមានជាអាទិ៍ៈ

១- ទិដ្ឋាការ ឬទំរង់បែបបទផ្សេងទៀតសំរាប់ការអនុញ្ញាតឱ្យចូល

២- លិខិតអនុញ្ញាតការងារ

៣- ធានារ៉ាប់រងសុខភាព ឬសេវាថែទាំសុខភាព

៤- វិភាគទានបង់ចូលមូលនិធិសន្សំ ដែលស្ថាប័នអនុវត្តនៃរដ្ឋជាភាគីនីមួយៗអាចតម្រូវឡើង

៥- ពន្ធ ឬកាតព្វកិច្ចផ្សេងទៀត ដែលតម្រូវឡើងដោយរដ្ឋជាភាគី

៦- កិច្ចសន្យាការងាររវាងនិយោជក និងពលករ

កិច្ចសន្យាការងារ ត្រូវមានចុះហត្ថលេខារបស់ពលករ និងនិយោជក ហើយត្រូវមានការផ្ញើសេចក្តីចម្លងមួយច្បាប់នៃកិច្ចសន្យានីមួយៗ ទៅឱ្យស្ថាប័នអនុវត្ត ។

មាត្រា ៨

ស្ថាប័នអនុវត្តមានភារកិច្ចគ្រប់គ្រងបញ្ជីពលករដែលទទួលបានការអនុញ្ញាតឱ្យធ្វើការ ស្របតាមអនុស្សរណៈ នេះ ។ ដើម្បីជាឯកសារយោង និងងាយស្រួលធ្វើការពិនិត្យឡើងវិញ ស្ថាប័នអនុវត្តត្រូវរក្សាទុកចំនួនបួនឆ្នាំ គិតតាំងពីកាលបរិច្ឆេទដែលពលករមកបង្ហាញខ្លួន ឬយកឯកសារមកសុំសេចក្តីបញ្ជាក់ នូវបញ្ជីពលករដែលបានមកបង្ហាញខ្លួន ឬយកឯកសារមកសុំសេចក្តីបញ្ជាក់ថា សាមីពលករបានវិលត្រឡប់ទៅកាន់អាសយដ្ឋានអចិន្ត្រៃយ៍របស់ខ្លួនក្រោយបានបំពេញចប់អាណត្តិ និងលក្ខខណ្ឌការងារហើយ ។

## ការវិលត្រឡប់ និងមាតុភូមិនិវត្តន៍

មាត្រា ៩

អាណត្តិ និងលក្ខខណ្ឌការងារ មិនអាចមានរយៈពេលលើសពីពីរឆ្នាំឡើយ លើកលែងតែមានសេចក្តីចែងផ្សេងពីនេះ ។ ក្នុងករណីចាំបាច់ អាណត្តិ និងលក្ខខណ្ឌការងារ អាចបន្តបានចំនួនពីរឆ្នាំទៀត ។ ទោះក្នុងករណីណាក៏ដោយ អាណត្តិ និងលក្ខខណ្ឌការងារ មិនអាចមានរយៈពេលលើសពីបួនឆ្នាំឡើយ ។ នៅក្រោយរយៈពេលនេះ កិច្ចសន្យាការងារត្រូវបានចាត់ទុកថា បានចប់សព្វគ្រប់ហើយ ។

សំរាប់ពលករដែលបានបញ្ចប់តាមអាណត្តិ និងលក្ខខណ្ឌការងាររួចហើយ ត្រូវមានការផ្អាកចំនួនបីឆ្នាំសិន ទើបអាចដាក់ពាក្យសុំការងារសាជាថ្មីបាន ។

មាត្រា ១០

រដ្ឋជាភាគី ត្រូវពង្រីកកិច្ចសហប្រតិបត្តិយ៉ាងពេញលេញរវាងគ្នា និងគ្នា ដើម្បីធានានូវការវិលត្រឡប់ទៅកាន់អាសយដ្ឋានអចិន្ត្រៃយ៍របស់ខ្លួនវិញនូវពលករមានជំហរស្មោះត្រង់ដែលបានបញ្ចប់អាណត្តិ និងលក្ខខណ្ឌការងាររបស់ខ្លួន ។

មាត្រា ១១

ស្ថាប័នអនុវត្តនៃប្រទេសអ្នកជួលពលករ ត្រូវបង្កើត និងគ្រប់គ្រងនូវមូលនិធិសន្សំមួយ ដែលពលករត្រូវបង់វិភាគទានចូលជារៀងរាល់ខែ ក្នុងបរិមាណ ១៥% នៃប្រាក់បៀវត្សប្រចាំខែរបស់ខ្លួន ។

មាត្រា ១២

ពលករដែលបានបញ្ចប់អាណត្តិ និងលក្ខខណ្ឌការងាររបស់ខ្លួន ហើយវិលត្រឡប់ទៅកាន់អាសយដ្ឋានអចិន្ត្រៃយ៍របស់ខ្លួនវិញ គឺមានសិទ្ធិទទួលបានការបង្វិលសងវិញនូវប្រាក់វិភាគទានដែលបានសន្សំទុកក្នុងមូលនិធិសន្សំ ព្រមទាំងការប្រាក់ផង ដោយដាក់ពាក្យសុំទៅស្ថាប័នអនុវត្តចំនួនបីខែមុនកាលបរិច្ឆេទគ្រោងចេញដំណើរ បន្ទាប់ពីបានបញ្ចប់កិច្ចសន្យាការងារ ។ ការបើកផ្តល់ប្រាក់ ត្រូវធ្វើឡើងក្នុងរយៈពេល ៤៥ថ្ងៃ ក្រោយការបញ្ចប់កិច្ចសន្យាការងារ ។

ក្នុងករណីពលករបានបញ្ចប់ការងារមុនកាលកំណត់ និងត្រូវវិលត្រឡប់ទៅកាន់អាសយដ្ឋានអចិន្ត្រៃយ៍វិញ ការបង្វិលសងវិញនូវប្រាក់វិភាគទានបានសន្សំទុក និងការប្រាក់ ត្រូវធ្វើឡើងក្នុងរយៈពេល ៤៥ថ្ងៃក្រោយការបញ្ចប់កិច្ចសន្យាការងារ ។

មាត្រា ១៣

សំរាប់ពលករដែលមានអាណត្តិ និងលក្ខខណ្ឌការងារនៅមានសុពលភាព ហើយអនុវត្តស្របតាមបទបញ្ញត្តិរបស់ស្ថាប័នអនុវត្ត ការវិលត្រឡប់ជាបណ្តោះអាសន្នទៅប្រទេសដើមរបស់ពលករ មិនធ្វើឱ្យចប់ដល់លិខិតអនុញ្ញាតការងារដូចមានចែងក្នុងមាត្រា ៤ ឡើយ ។

មាត្រា ១៤

ស្ថាប័នអនុវត្ត ត្រូវកំណត់នូវនីតិវិធី និងឯកសារដែលត្រូវមានក្នុងការដាក់ពាក្យសុំការបង្វិលសងប្រាក់ ដូចមានចែងក្នុងមាត្រា ១២ ។

មាត្រា ១៥

ពលករដែលមិនបានវិលត្រឡប់ទៅកាន់អាសយដ្ឋានអចិន្ត្រៃយ៍វិញ ក្រោយពីបានបញ្ចប់អាណត្តិ និងលក្ខខណ្ឌការងារ ត្រូវបាត់បង់សិទ្ធិទទួលបានការបង្វិលសងប្រាក់វិភាគទានដែលបានបង់ចូលមូលនិធិសន្សំ ។

មាត្រា ១៦

ស្ថាប័នអនុវត្តនៃប្រទេសអ្នកជួលពលករ អាចដកប្រាក់ពីមូលនិធិសន្សំ ដើម្បីទូទាត់ចំណាយរដ្ឋបាលទៅលើធនាគារ និងការបញ្ជូនពលករត្រឡប់ទៅប្រទេសដើមវិញ ។

## ការការពារ

មាត្រា ១៧

រាល់ភាគីនៅក្នុងប្រទេសអ្នកជួលពលករ ត្រូវធានាថា ពលករទទួលបាននូវការការពារស្របទៅតាមបទបញ្ញត្តិនៃច្បាប់ក្នុងស្រុករបស់ប្រទេសរៀងៗខ្លួន ។

មាត្រា ១៨

ពលករនៃរដ្ឋជាភាគីទាំងពីរ មានសិទ្ធិទទួលបានប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗ ដូចគ្នានឹងពលករក្នុងស្រុកដែរ ដោយផ្អែកលើគោលការណ៍ស្មើភាព និងគ្មានការរើសអើងលើភេទ ជាតិសាសន៍ និងសាសនា ។

មាត្រា ១៩

ស្ថាប័នអនុវត្ត ត្រូវធ្វើការដោះស្រាយវិវាទការងារដែលកើតមានរវាងពលករ និងនិយោជក ដោយផ្អែកតាមច្បាប់ និងបទបញ្ញត្តិដែលមាននៅក្នុងប្រទេសអ្នកជួលពលករ ។

## វិធានការទប់ស្កាត់ការជួលពលករដោយខុសច្បាប់

មាត្រា ២០

រដ្ឋជាភាគី ត្រូវចាត់វាល់វិធានការចាំបាច់នានាក្នុងដែនដីរបស់ខ្លួន ដើម្បីបង្ការ និងទប់ស្កាត់ការឆ្លងដែនខុសច្បាប់ ការធ្វើចរាចរណ៍ពលករខុសច្បាប់ និងការជួលពលករដោយខុសច្បាប់ ។

មាត្រា ២១

រដ្ឋជាភាគី ត្រូវជូនព័ត៌មានឱ្យគ្នាទៅវិញទៅមក ពាក់ព័ន្ធនឹងការជួញដូរមនុស្ស អន្តោប្រវេសន៍ខុសច្បាប់ ការធ្វើចរាចរណ៍ពលករខុសច្បាប់ និងការជួលពលករដោយខុសច្បាប់ ។

## ការធ្វើវិសោធនកម្ម

មាត្រា ២២

អនុស្សរណៈនេះ អាចធ្វើវិសោធនកម្ម ឬបន្ថែម ដោយឈរលើមូលដ្ឋាននៃការព្រមព្រៀងរវាងរដ្ឋជាភាគីតាមនីតិវិធីការទូត ។

## ការដោះស្រាយវិវាទ

មាត្រា ២៣

រាល់ភាពផ្ទុយគ្នា ឬវិវាទ ដែលកើតចេញពីអនុស្សរណៈនេះ ត្រូវដោះស្រាយប្រកបដោយអធ្យាស្រ័យល្អ ដោយការពិភាក្សារវាងរដ្ឋជាភាគី ។

## សុពលភាព និងការបញ្ចប់នៃអនុស្សរណៈ

មាត្រា ២៤

អនុស្សរណៈនេះ ត្រូវចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខា ។ រដ្ឋជាភាគីអាចធ្វើការបញ្ចប់សុពលភាពនៃអនុស្សរណៈនេះ តាមរយៈការជូនដំណឹងជាលាយលក្ខណ៍អក្សរដល់ភាគីម្ខាងទៀត ។ ការជូនដំណឹងអំពីការបញ្ចប់សុពលភាពនៃអនុស្សរណៈ នឹងចាប់មានសុពលភាពនៅពេល ៩០ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទជូនដំណឹង ។ ក្នុងករណីនៃការបញ្ចប់សុពលភាពនៃអនុស្សរណៈនេះជាឯកតោភាគី រដ្ឋជាភាគីត្រូវពិភាក្សាគ្នាពីដំណោះស្រាយលើកិច្ចសន្យាការងារដែលនៅមានសុពល ដើម្បីការពារផលប្រយោជន៍របស់ពលករ ។

ដើម្បីជាសក្ខីភាព អ្នកតំណាងដែលបានទទួលសិទ្ធិពេញលេញពីរដ្ឋសាមីរៀងៗខ្លួន បានចុះហត្ថលេខាលើសន្ធិសញ្ញានេះ ។

អនុស្សរណៈនេះ ធ្វើនៅ Ubon Ratchathani ថ្ងៃទី៣១ ឧសភា ២០០៣ ជាភាសាអង់គ្លេស ចំនួនពីរច្បាប់ដើម ដែលមានតម្លៃស្មើគ្នាខាងផ្លូវច្បាប់ ។

តាងនាមរាជរដ្ឋាភិបាលកម្ពុជា
អ៊ិត សំហេង
រដ្ឋមន្ត្រី ក្រសួងការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ
និងយុវនីតិសម្បទា

តាងនាមរាជរដ្ឋាភិបាលថៃឡង់ដ៍
Suwat Liptapanlop
រដ្ឋមន្ត្រី ក្រសួងការងារ

# បញ្ជីឯកសារពិភាក្សារបស់ វបសអ

១. Kannan, K. P. (វិច្ឆិកា ១៩៩៥) ការកសាងសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់សំរាប់ប្រទេសកម្ពុជា: ការពិនិត្យឡើងវិញលើការអនុវត្តន៍នាពេលបច្ចុប្បន្ន និងការលើកមតិកែលំអ (ឯកសារពិភាក្សាលេខ ១) ។

២. McAndrew, John P. (មករា ១៩៩៦) ជំនួយហូរចូលជំនួយស្រពិចស្រពិល: ជំនួយសង្គ្រោះ និងអភិវឌ្ឍន៍ទ្វេ និងពហុភាគី ១៩៩២-៩៥ (ឯកសារពិភាក្សាលេខ ២) ។

៣. Kannan, K. P. (មករា ១៩៩៧) កំណែទំរង់សេដ្ឋកិច្ច កំណែតម្រូវរចនាសម្ព័ន្ធ និងការអភិវឌ្ឍកម្ពុជា (ឯកសារពិភាក្សាលេខ ៣) ។

៤. ជីម-ចរិយា ស្រ៊ុន-ពិច្ចូ សូ-សុវណ្ណារិទ្ធ ចន-ម៉ាកឃិនត្រូ ងួន-សុគន្ធា ប៊ុន-ដូវីណា និងរ៉ូប៊ីន-ប៊ិជីលវី (មិថុនា ១៩៩៨) ការរៀនសូត្រពីកម្មវិធីអភិវឌ្ឍន៍ជនបទក្នុងប្រទេសកម្ពុជា (ឯកសារពិភាក្សាលេខ ៤) ជាភាសាខ្មែរ តម្លៃ ៩.000រៀល ។

៥. Toshiyasu-Kato ច័ន្ទ-សុផល និងឡុង-វូ-ពិសិដ្ឋ (កញ្ញា ១៩៩៨) សមាហរណកម្មសេដ្ឋកិច្ចតំបន់សំរាប់ការអភិវឌ្ឍន៍ជានិរន្តរ៍ក្នុងប្រទេសកម្ពុជា (ឯកសារពិភាក្សាលេខ ៥) ជាភាសាខ្មែរ តម្លៃ ៩.000រៀល ។

៦. Murshid, K. A. S. (ធ្នូ ១៩៩៨) សន្តិសុខស្បៀងនៅក្នុងសេដ្ឋកិច្ចអន្តរៈអាស៊ី: បទពិសោធន៍កម្ពុជា (ឯកសារពិភាក្សា លេខ ៦) ជាភាសាខ្មែរ តម្លៃ ៧.៥00រៀល ។

៧. McAndrew, John P. (ធ្នូ ១៩៩៨) ការពឹងពាក់គ្នាទៅវិញទៅមកក្នុងយុទ្ធសាស្រ្តចិញ្ចឹមជីវិតគ្រួសារនៅក្នុងភូមិខ្មែរពីរ (ឯកសារពិភាក្សាលេខ ៧) ជាភាសាខ្មែរ តម្លៃ ៧.៥00រៀល ។

៨. ច័ន្ទ-សុផល Martin-Godfrey, Toshiyasu-Kato ឡុង-វូ-ពិសិដ្ឋ Nina-Orlova, Per-Ronnås ទា-សាវ៉ា (មករា ១៩៩៩) ប្រទេសកម្ពុជា: បញ្ហាប្រឈមមុខនៃការបង្កើតការងារដែលមានផលិតភាព (ឯកសារពិភាក្សាលេខ ៨) ជាភាសាខ្មែរ តម្លៃ ៦.000រៀល ។

៩. តេង-យូគីប៊ុន-ដូវីណាសូ-សុវណ្ណារិទ្ធនិងចន-ម៉ាកឃិនត្រូ(មេសា១៩៩៩) បទពិសោធន៍របស់សកម្មភាពសហគមន៍ដើម្បីអភិវឌ្ឍន៍សង្គមនៃអង្គការយូនីសេហ្វ (ឯកសារពិភាក្សាលេខ ៩) ជាភាសាខ្មែរ តម្លៃ ៤.៥00រៀល ។

១០. Gorman, Siobhan, ជាមួយ ប៊ុន-ដូវីណា និង សុខ-ខេង (មិថុនា ១៩៩៩) បញ្ហាតួនាទីបុរស-ស្ត្រី និងការអភិវឌ្ឍន៍នៅក្នុងប្រទេសកម្ពុជា: ការពិនិត្យមើលជាទូទៅ (ឯកសារពិភាក្សាលេខ ១០) ជាភាសាខ្មែរ តម្លៃ ៤.៥00រៀល ។

១១. ច័ន្ទ-សុផល និង សូ-សុវណ្ណារិទ្ធ (មិថុនា ១៩៩៩) ចំណាកពលកម្មកម្ពុជាទៅប្រទេសថៃ: ការប៉ាន់ស្មានជំហានដំបូង (ឯកសារពិគ្រោះលេខ ១១) ជាភាសាខ្មែរ តម្លៃ ៣.000រៀល ។

១២. ច័ន្ទ-សុផល Toshiyasu Kato ឡុង-វូពិសិដ្ឋ ទា-សាវ៉ា សូ-សុវណ្ណារិទ្ធ ហង់-ជួនណារ៉ុន កៅ-គីមហួន និងជា-វុធណា (តុលា ១៩៩៩) ផលប៉ះពាល់នៃវិបត្តិហិរញ្ញវត្ថុអាស៊ីលើសេដ្ឋកិច្ចអន្តរកាលនៅបណ្តាប្រទេសអាស៊ីអគ្នេយ៍: ទស្សនៈកម្ពុជា (ឯកសារពិគ្រោះលេខ ១២) ជាភាសាខ្មែរ តម្លៃ ៤.៥00រៀល ។

១៣. អ៊ុង-ប៊ុនឡេង (សីហា ២000) ការប្រែប្រួលតាមរដូវកាលនៃសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅក្នុងប្រទេសកម្ពុជា (ឯកសារពិភាក្សាលេខ ១៣) ជាភាសាខ្មែរ តម្លៃ ៣.000រៀល ។

១៤. Toshiyasu-Kato Jeffrey A. Kaplan, ច័ន្ទ-សុផល និង រៀល-សុភាព (សីហា ២000) ប្រទេសកម្ពុជា: លើកកំពស់ អភិបាលកិច្ចសំរាប់ការអភិវឌ្ឍន៍មាននិរន្តរភាព (ឯកសារពិភាក្សាលេខ ១៤) ជាភាសាខ្មែរ តម្លៃ ៣.000រៀល ។

១៥. Toshiyasu Kato, ច័ន្ទ-សុផល Jeffrey A. Kaplan, (សីហា ២០០០) ជំនួយបច្ចេកទេស និងការអភិវឌ្ឍន៍សមត្ថភាព នៅក្នុងសេដ្ឋកិច្ចមួយដែលពឹងផ្អែកលើជំនួយៈ បទពិសោធន៍កម្ពុជា (ឯកសារពិភាក្សាលេខ ១៥) ជាភាសាខ្មែរ តម្លៃ ១០.០០០រៀល ។

១៦. ស៊ិក បូរ័ក្ស (ធ្នូ ២០០០) កម្មសិទ្ធិការលក់ដូរ និងការប្រមូលផ្តុំដីធ្លីនៅកម្ពុជាៈ ការពិនិត្យវិភាគដោយត្រួសៗនូវទិន្នន័យទីពីរ និងទិន្នន័យដើម ដែលបានមកពីអង្កេតថ្មីៗចំនួនបួន (ឯកសារពិភាក្សាលេខ ១៦) ជាភាសាខ្មែរ តម្លៃ ៨.០០០រៀល ។

១៧. ច័ន្ទ-សុផល សូ-សុវណ្ណារិទ្ធ និងប៊ុន-ដូរីណា (មិថុនា ២០០១) ជំនួយបច្ចេកទេស និងការអភិវឌ្ឍន៍សមត្ថភាពនៅសាលាកសិកម្មព្រែកលៀប (ឯកសារពិភាក្សាលេខ ១៧) ជាភាសាខ្មែរ តម្លៃ ៧.០០០រៀល ។

១៨. Martin Godfrey, សូ-សុវណ្ណារិទ្ធ ទេព-សារ៉ាវី ប៉ុន-ដូរីណា Claude-Katz Sarthi-Acharya ស៊ីសុវត្ថិ-ឌួង-ចាន់តូ និងហ៊ីង ថូរ៉ាក់ស៊ី (តុលា ២០០១) ការសិក្សាអំពីទីផ្សារពលកម្មនៅកម្ពុជាៈ ការកាត់បន្ថយភាពក្រីក្រ ការលូតលាស់ និងការកែ តំរូវចំពោះវិបត្តិ (ឯកសារពិភាក្សាលេខ ១៨) ជាភាសាខ្មែរ តម្លៃ ៨.០០០រៀល ។

១៩. ច័ន្ទ-សុផល ទេព-សារ៉ាវី និង Sarthi Acharya (ធ្នូ ២០០១) ការកាន់កាប់ដីនៅកម្ពុជាៈ ការវិភាគលើទិន្នន័យចុងក្រោយ (ឯកសារពិភាក្សាលេខ ១៩) ជាភាសាខ្មែរ តម្លៃ ៨.០០០រៀល ។

២០. សូ-សុវណ្ណារិទ្ធ រៀល-សុភាព អ៊ុច-ឧទេយ្យ ស៊ី-រត្ន័មុនី, Brett Ballard និង Sarthi Acharya (មីនា ២០០២) ការវាយតំលៃសង្គមពាក់ព័ន្ធនឹងដីធ្លីនៅកម្ពុជា (ឯកសារពិភាក្សាលេខ ២០) ជាភាសាខ្មែរ តម្លៃ ៨.០០០រៀល ។

២១. Bhargavi Ramamurthy ស៊ិក-បូរ័ក្ស, Per Ronnås និង សុក-ហាច (មីនា ២០០២) ប្រទេសកម្ពុជាឆ្នាំ១៩៩៩-២០០០ៈ ការផ្តោតលើបញ្ហាដីធ្លី កំលាំងពលកម្ម និងការចិញ្ចឹមជីវិតនៅជនបទ (ឯកសារពិភាក្សាលេខ ២១) ជាភាសាខ្មែរ តម្លៃ ៨.០០០រៀល ។

២២. ច័ន្ទ-សុផល និង Sarthi Acharya (កក្កដា ២០០២) ការលក់ដូរដីធ្លីនៅកម្ពុជាៈ ការវិភាគទិន្នន័យនៃការផ្ទេរ និងការលក់ដូរដីធ្លី (ឯកសារពិភាក្សាលេខ ២២) ជាភាសាខ្មែរ តម្លៃ ៨.០០០រៀល ។

២៣. Bruce McKenney និង ព្រុំ-តុលា (កញ្ញា ២០០២) ធនធានធម្មជាតិ និងជីវភាពនៅតាមជនបទក្នុងប្រទេសកម្ពុជាៈ ការវាយតំលៃជាមូលដ្ឋាន (ឯកសារពិភាក្សាលេខ ២៣) ជាភាសាខ្មែរ តម្លៃ ១០.០០០រៀល ជាភាសាអង់គ្លេស តម្លៃ ១០ដុល្លារ ។

២៤. ច័ន្ទ-សុផល គីម-សេតារា និង Sarthi Acharya (ធ្នូ ២០០២) ដីធ្លី ជីវភាពជនបទ និងសន្តិសុខស្បៀងនៅកម្ពុជាៈ ទស្សនៈបានពីអង្កេតតាមមូលដ្ឋាន (ឯកសារពិភាក្សាលេខ ២៤) ជាភាសាខ្មែរ តម្លៃ ៦.០០០រៀល ជាភាសាអង់គ្លេស តម្លៃ ៧ដុល្លារ ។

២៥. ច័ន្ទ-សុផលនិងSarthi Acharya (ធ្នូ២០០២) បញ្ហាប្រឈមចំពោះការចិញ្ចឹមជីវិតនៅជនបទៈ ការសិក្សាលើភូមិចំនួន ៩ នៅកម្ពុជា (ឯកសារពិភាក្សាលេខ ២៥) ជាភាសាខ្មែរ តម្លៃ ៨.០០០រៀល ជាភាសាអង់គ្លេស តម្លៃ ១០ដុល្លារ ។

២៦. Sarthi Acharya គីម-សេតារា ចាប-សុថារិទ្ធ និង មាច-យ៉ាឌី (កញ្ញា ២០០៣) ការងារក្រៅកសិដ្ឋាន និង ការងារមិនមែនកសិកម្មៈ ទស្សនៈស្តីពីការបង្កើតការងារនៅកម្ពុជា (ឯកសារពិភាក្សាលេខ ២៦) ជាខ្មែរ ៧.០០០រៀល ជាភាសាអង់គ្លេស តម្លៃ ៥ដុល្លារ ។

២៧. យឹម-ជា និង Bruce McKenney (ធ្នូ ២០០៣) ការនាំចេញត្រីពីបឹងទន្លេសាបទៅប្រទេសថៃៈ ការវិភាគលើការរាំងស្ទះពាណិជ្ជកម្ម អភិបាលកិច្ច និងបរិយាកាសសំរាប់ការលូតលាស់ (ឯកសារពិភាក្សាលេខ ២៧) ជាខ្មែរ តម្លៃ ៧.០០០រៀល ជាភាសាអង់គ្លេស តម្លៃ ១០ដុល្លារ ។

២៨. ព្រុំ-តុលា និង Bruce McKenney (ធ្នូ ២០០៣) ការធ្វើពាណិជ្ជកម្មផលព្រៃឈើនៅកម្ពុជា: ការប្រឈម ការគំរាមកំហែង និងឱកាសសំរាប់ពាណិជ្ជកម្មជ័រទឹក (ឯកសារពិភាក្សាលេខ ២៨) ជាភាសាខ្មែរ តម្លៃ ៧.០០០រៀល ជាភាសាអង់គ្លេស តម្លៃ ១០ដុល្លារ ។

២៩. យឹម-ជា និង Bruce McKenney (វិច្ឆិកា ២០០៣) ពាណិជ្ជកម្មត្រីក្នុងស្រុក: ករណីសិក្សានៃម៉ាឃីទីងត្រីពីបឹងទន្លេសាបទៅក្រុងភ្នំពេញ (ឯកសារពិភាក្សាលេខ ២៩) ជាភាសាខ្មែរ តម្លៃ ៥.០០០រៀល ជាភាសាអង់គ្លេស តម្លៃ ៥ដុល្លារ ។

៣០. Caroline Hughes និង គីម សេតារា (មិថុនា ២០០៤) ការវិវត្តន៍នៃដំណើរការប្រជាធិបតេយ្យ និងការគ្រប់គ្រង ទំនាស់នៅកម្ពុជា: ការសិក្សាប្រៀបធៀបការបោះឆ្នោតបីលើកនៅកម្ពុជា (ឯកសារពិភាក្សាលេខ ៣០) ជាភាសាខ្មែរ តម្លៃ ១០.០០០រៀល ជាភាសាអង់គ្លេស តម្លៃ ១៣,៥០ដុល្លារ ។

៣១. Robert Oberndorf (កក្កដា ២០០៤) សុខដុមនីយកម្មច្បាប់ទាក់ទងនឹងដំណើរការវិមជ្ឈការនៅកម្ពុជា (ឯកសារពិភាក្សាលេខ ៣១) ជាភាសាខ្មែរ តម្លៃ ៥.០០០រៀល ជាភាសាអង់គ្លេស តម្លៃ ៦,៥០ដុល្លារ ។

៣២. K.A.S. Murshid និងទួត សុខផល្លី (ឧសភា ២០០៥) សេដ្ឋកិច្ចឆ្លងកាត់ព្រំដែនរបស់ប្រទេសកម្ពុជា: ការសិក្សាជំហានដំបូង (ឯកសារពិភាក្សាលេខ ៣២) ជាភាសាខ្មែរ តម្លៃ ៨.០០០រៀល ជាភាសាអង់គ្លេស តម្លៃ ៥ដុល្លារ ។

៣៣. Hansen, Kasper K. & Neth Top (December 2006), Natural Forest Benefits and Economic Analysis of Natural Forest Conversion in Cambodia.

៣៤. Pak Kimchoeun, Horng Vuthy, Eng Netra, Ann Sovatha, Kim Sedara, Jenny Knowles & David Craig (March 2007), Accountability and Neo-patrimonialism in Cambodia: A Critical Literature Review.

៣៥. Kim Sedara & Joakim Öjendal with the assistance of Ann Sovatha (May 2007), Where Decentralisation Meets Democracy: Civil Society, Local Government, and Accountability in Cambodia.

៣៦. Lim Sovannara (November 2007), Youth Migration and Urbanisation in Cambodia.

៣៧. Chem Phalla et al. (May 2008), Framing Research on Water Resources Management and Governance in Cambodia: A Literature Review.

៣៨. Pak Kimchoeun and David Craig (July 2008), Accountability and Public Expenditure Management in Decentralised Cambodia.

៣៩. Horng Vuthy and David Craig (July 2008), Accountability and Planning in Decentralised Cambodia.

៤០. Eng Netra and David Craig (March 2009), Accountability and Human Resource Management in Decentralised Cambodia.

៤១. ហ៊ីង វុត្ថា និង Hossein Jalilian (មេសា ២០០៩) ផលប៉ះពាល់នៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ចិន ចំពោះបរិស្ថាន នៅតាមបណ្តាប្រទេសក្នុងមហាអនុតំបន់មេគង្គ (ឯកសារពិភាក្សាលេខ ៤១) ជាភាសាខ្មែរ តម្លៃ ៨.០០០រៀល ជាភាសាអង់គ្លេស តម្លៃ ៣,០០ដុល្លារ ។

៤២. Thon Vimealea, Ou Sivhuoch, Eng Netra and Ly Tem (October 2009), *Leadership in Local Politics of Cambodia: A Study of Leaders in Three Communes of Three Provinces*.

៤៣. ហ៊ីង វុត្ថា និង បណ្ឌិត ធន់ វឌ្ឍនា (ធ្នូ ២០០៩) ពាណិជ្ជកម្មកសិកម្មក្នុងមហាអនុតំបន់មេគង្គៈ ករណីដំឡូងឈើ និងកៅស៊ូ នៅកម្ពុជា (ឯកសារពិភាក្សាលេខ ៤៣) ជាភាសាខ្មែរ តម្លៃ ៦.០០០រៀល ជាភាសាអង់គ្លេស តម្លៃ ៣,០០ដុល្លារ ។

GREATER MEKONG SUB-REGION DEVELOPMENT ANALYSIS NETWORK

GMS-DAN

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

☞ អគារលេខ ៥៦ ផ្លូវលេខ ៣១៥ ទួលគោក ភ្នំពេញ កម្ពុជា

✉ ប្រអប់សំបុត្រ ៦២២ ភ្នំពេញ កម្ពុជា

☎ (៨៥៥-២៣) ៨៨១-៣៨៤/៨៨១-៧០១/៨៨១-៩១៦/៨៨៣-៦០៣

🖷 (៨៥៥-២៣) ៨៨០-៧៣៤

អ៊ីមែល: cdri@wicam.com.kh

គេហទំព័រ: http://www.cdri.org.kh

តម្លៃ ៨.០០០រៀល

9789995052317